ឥន្ទបញ្ញោភិក្ខុ ហ. មណីចិន្តា

# ព្រះបាទធម្មិក




ការផ្សាយរបស់
ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ជាមួយការឧបត្ថម្ភដោយ
មូលនិធិ ខុនរ៉ាដ អាដិនណៅអ៊ែរ, ប្រទេសអាល្លឺម៉ង់
A publication of *Buddhism for Development*
with the support of the Konrad-Adenauer-Foundation, Germany

www.budinst.gov.kh www.elibraryofcambodia.org

**ស្កាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្កាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ** និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្កាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh www.elibraryofcambodia.org**

www.budinst.gov.kh www.elibraryofcambodia.org

២៦០

ឥន្ទបញ្ញោភិក្ខុ ហេង មណីចិន្តា

# ព្រះឃនជម្ពិក

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

បោះពុម្ពផ្សាយលើកទី២

ការផ្សាយរបស់

*ពុទ្ធសាសនា ដើម្បីអភិវឌ្ឍន៍*

ឧបត្ថម្ភដោយ

មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ, អាល្លឺម៉ង់

អន្លង់វិល / ភ្នំពេញ

១៩៩៥

www.budinst.gov.kh www.elibraryofcambodia.org

Indabanno Bhikkhu **Heng Monychenda**

# PREAHBAT DHAMMIK

SECOND REVISED EDITION

A publication of
*Buddhism for Development*
with the support of the
Konrad-Adenauer-Foundation, Germany

Anlongvil / Phnom Penh

1995

www.budinst.gov.kh www.elibraryofcambodia.org

# មាតិកា

អត្ថបទ ទំព័រ


- អារម្ភកថា របស់លោក ភីធ័រ សៀវ (ភាសាខ្មែរ) ១០
- អារម្ភកថា របស់លោក ភីធ័រ សៀវ (ភាសាអង់គ្លេស) ២០
- កថាមុខរបស់អ្នករៀបរៀង ២៨
- លិខិតគាំទ្ររបស់ព្រឹទ្ធាចារ្យ ឆេង ផុន ៣១

១. សារសំខាន់របស់អ្នកដឹកនាំ ៣៤

២. ព្រះបាទធម្មិក ៣៩

៣. រហស្សគុណរបស់អ្នកដឹកនាំ ៤៣

- អ្នកដឹកនាំ ៤៥
- ប្រធាន ៤៨
- ប្រមុខ ៥០
- រាជា ៥២
- មេ ៥៤

៤. គុណសម្បត្តិរបស់អ្នកដឹកនាំ ៥៨

- គុណសម្បត្តិទី ១ : សុខភាព ៥៩
- គុណសម្បត្តិទី ២ : សមត្ថភាព ៦៣
- ត្រីសមត្ថភាព ៦៥
- អ្នកជឿមានហេតុផល ៦៨
- អ្នកមានញាណ ៧០
- បដិសម្ភិទាជន ៧២


www.budinst.gov.kh www.elibraryofcambodia.org

| អត្ថបទ | ទំព័រ |
|---|---|


- អនុត្តរជន ៧៤
- អ្នកមានទសពលញាណ ៨០
- អ្នកមានទេពកោសល្យ ៨៣
- អ្នកមានយុត្តិធម៌ ៨៥
- អ្នកមានសេចក្តីព្យាយាម ៨៩
- គុណសម្បត្តិទី ៣ ៖ គុណធម៌ ៩១

ក). ទសពិធរាជធម៌ ៩៤

- ទាន ៩៦
- សីល ១០១
- បរិច្ចាគ ១១០
- អាជ្ជវៈ ១១៧
- មទ្ទវៈ ១២៥
- តបៈ ១៣២
- អក្កោធៈ ១៣៨
- ខន្តី ១៤៨
- អវិហឹង្សា ១៦០
- អវិរោធនៈ ១៦៨
- សរុបសេចក្តីទសពិធរាជធម៌ ១៧៥
- បារមីអ្នកដឹកនាំ ១៧៨

ខ). ព្រហ្មវិហារធម៌ ១៨២

- មេត្តា ១៨៤


www.budinst.gov.kh www.elibraryofcambodia.org

| អត្ថបទ | ទំព័រ |
|---|---|


- . ករុណា ១៨៨
- . មុទិតា ១៩០
- . ឧបេក្ខា ១៩៤
- ៥. ដើម្បីសេចក្ដីសុខរបស់មហាជន ១៩៨
- ៦. ព្រោះត្រូវធ្វើជាប្រធាន ២០៧
- ៧. គោលធម៌បន្ថែម ២០៩
- ៨. ឧបសម្ព័ន្ធ ៖ ពុទ្ធទស្សនគតិក្នុងការកសាងសង្គម ២១៥
- ៨. ឯកសារពិគ្រោះ ២២៨


www.budinst.gov.kh www.elibraryofcambodia.org

# អារម្ភកថា

## របស់លោក **ភីធ័រ សៀរ**

អ្នកតំណាងអចិន្ត្រៃយ៍នៃមូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ

ប្រចាំព្រះរាជាណាចក្រ កម្ពុជា

ចាប់តាំងពីមនុស្សលោកចេះធ្វើការពិចារណាមក គេហាក់ដូចជាមានទស្សនៈពីរផ្សេងគ្នា ដែលស្តីពីអត្ថន័យរបស់ជីវិតមនុស្សយើង គឺ :

១) ក្នុងឋានៈជាមនុស្សម្នាក់ តើយើងគួរតែរស់ធ្វើការសំរាប់តែដើម្បីផលប្រយោជន៍ ដើម្បីសុខុមាលភាព និងព្យាយាមដើម្បីសំរេចនូវមោក្ខធម៌ផ្ទាល់ខ្លួនទេឬ ?

២) ឬក៏ យើងគួររស់ និងធ្វើការដើម្បីជាប្រយោជន៍មនុស្សជាតិដែរ ? និងតើយើងគួរជួយអ្នកទាំងឡាយណាដែលមិនមានភ័ព្វសំណាងដូចពួកយើងឱ្យរួចពីសេចក្តីទុក្ខផងដែរទេ ?

ចំពោះពួកយើង គ្មានអ្វីគួរឱ្យសង្ស័យទេ ដែលថាមានតែទស្សនៈទីពីរទេ ដែលឆ្លុះបញ្ចាំងអំពីពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ និងព្រះយេស៊ូគ្រិស្ត ។ មានតែអ្នកប្រព្រឹត្តស្របទៅនឹងគោលការណ៍របស់ព្រះពុទ្ធអង្គ និងព្រះយេស៊ូគ្រិស្តទេ ដែលនឹងមិនគិតឃើញតែពីប្រយោជន៍ខ្លួន ប៉ុន្តែជួយអ្នកដែលទន់ខ្សោយ និងអ្នកក្រីក្រក្នុងសង្គមនោះផង ។ នេះហើយដែលជាអត្ថន័យដ៏ជាក់ស្តែងនៃពាក្យ មេត្តា

www.budinst.gov.kh www.elibraryofcambodia.org

ករុណា មុទិតា និងឧបេក្ខា ។ គោលការណ៍ជាមូលដ្ឋានរបស់ពុទ្ធសាសនាទាំង ៤ នេះ មិនមែនសំរាប់តែប្រជារាស្ត្រធម្មតាទេ គឺជាពិសេស សំរាប់អ្នកដឹកនាំគ្រប់ស្រទាប់ក្នុងសង្គម ដែលមានការទទួលខុសត្រូវសំខាន់ក្នុងប្រយោជន៍របស់ប្រទេសជាតិ ។

ការដើរតាមព្រហ្មវិហារធម៌ទាំង ៤ នេះ គឺមានសារសំខាន់ខ្លាំងណាស់សំរាប់វាសនាប្រជារាស្ត្រ និងប្រទេសជាតិ ។ បើសិនជាគោលការណ៍ទាំង ៤ នេះត្រូវបានអនុវត្តដោយប្រជារាស្ត្រទូទៅ ព្រមទាំងអ្នកដឹកនាំនោះ ប្រទេសជាតិទាំងមូល ប្រាកដជានឹងមានសុខដុមរមនា មានសន្តិភាព វឌ្ឍនភាព និងសេចក្ដីសុខជាមិនខាន ។ ហើយបើសិនជាប្រជារាស្ត្រ និងអ្នកដឹកនាំសង្គមណាមួយ ពុំបានដើរតាមព្រហ្មវិហារធម៌ទាំង ៤ នេះទេ ជំងឺចងអាឃាតព្យាបាទគ្នាពុំមានទីបញ្ចប់ សង្គ្រាមទុរគតភាព និងអពមង្គល នឹងរាតត្បាតសង្គមនោះជាពុំខាន ។

ការជួយអ្នកដទៃឱ្យគេជួយខ្លួនឯងស្វែងរកការត្រាស់ដឹង និងរំដោះផុតពីសេចក្ដីទុក្ខដោយខ្លួនគេផ្ទាល់នេះ គឺមានន័យថា ដើរតាមមាគ៌ារបស់ព្រះពោធិ-សត្វហើយ ។ ព្រះពោធិសត្វ គឺជាអ្នកបានត្រាស់ដឹងនូវសម្ពោធិញាណ ព្រមទាំងមានលទ្ធភាពដើម្បីនឹងចូលនិព្វានបានគ្រប់ពេលវេលា តែសុខចិត្តរស់នៅជាមួយមនុស្សលោក ដើម្បីជួយមនុស្សជាតិស្វែងរកការត្រាស់ដឹង និងរំលត់ទុក្ខ ។

ក្នុងប្រវត្តិសាស្ត្រខ្មែរយើង បានដឹងអំពីព្រះរាជាមួយអង្គដែលជាតួព្រះពោធិសត្វដ៏ល្បីល្បាញ គឺព្រះបាទជ័យវរ្ម័នទី ៧ ( សោយរាជ្យពីឆ្នាំ ១១៨១ ដល់ឆ្នាំ ១២១៩ ) ។ ព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់បានកំណត់ខ្លួនព្រះអង្គថាជាតួអង្គពោធិសត្វអវលោកិតេស្វរៈ ដែលជាព្រះពោធិសត្វមានករុណាធម៌ដ៏ធំធេងគ្មានទីកំណត់ ។

www.budinst.gov.kh www.elibraryofcambodia.org

ដើម្បីជួយប្រជារាស្ត្រ ព្រះអង្គទ្រង់បានបញ្ជាឱ្យគេកសាងនូវប្រព័ន្ធធារាសាស្ត្រធំៗ កសាងផ្លូវថ្នល់ និងមន្ទីរពេទ្យដែលមានចំនួនច្រើន និងមានគុណភាពល្អជាងកិច្ចការរបស់ទាយាទព្រះអង្គក្នុងសម័យបន្ទាប់ឆ្ងាយណាស់ ។ តាមពិត ប្រព័ន្ធធារាសាស្ត្រដែលកសាងក្នុងសម័យព្រះបាទជ័យវរ្ម័នទី ៧ ដូចជាមានគុណភាពល្អជាងប្រព័ន្ធធារា-សាស្ត្រក្នុងប្រទេសកម្ពុជា បច្ចុប្បន្ននេះទៀតផង ។

បន្ទាប់ពីព្រះបាទជ័យវរ្ម័នទី ៧ គេឃើញមានព្រះរាជាខ្មែរមួយអង្គទៀតតែប៉ុណ្ណោះ ដែលព្យាយាមដើរតាមគន្លងរបស់ព្រះពោធិសត្វ ។ ពោលគឺ ព្រះបាទនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រ កម្ពុជា ។

នៅក្នុងសម័យសង្គមរាស្ត្រនិយម សម្តេចព្រះនរោត្តម សីហនុ បានបំពេញនូវព្រះរាជកិច្ចជាច្រើនដើម្បីជាប្រយោជន៍សាធារណៈ មានការកសាងសាលារៀន ប្រព័ន្ធធារាសាស្ត្រ ផ្លូវថ្នល់ មន្ទីរពេទ្យជាដើម ។ ចាប់តាំងពីទសវត្ស ១៩៨០ មក ព្រះអង្គបានព្យាយាមដោយមិនខ្លាចនឿយហត់ដើម្បីជួយអ្នកក្រីក្រ និងអ្នកទន់ខ្សោយក្នុងសង្គម ដើម្បីរួមចំណែកស្តារឡើងវិញនូវកិច្ចអភិវឌ្ឍន៍ ដែលតម្រង់ទិសដៅដោយពុទ្ធសាសនា ដែលជាមូលដ្ឋាននៃប្រព័ន្ធសីលធម៌ និងចរិយាធម៌ក្នុងប្រទេសខ្មែរ និងដើម្បីទ្រទ្រង់ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងសេរីភាព តាមរដ្ឋ-ធម្មនុញ្ញរបស់ប្រជារាស្ត្រខ្មែរ ដែលទាំងអស់នេះបានបង្កើតជាបុរេលក្ខខ័ណ្ឌមូលដ្ឋានសម្រាប់ការកសាងឡើងវិញដ៏ជោគជ័យនៃប្រទេសកម្ពុជា និងសុខុមាលភាព ដ៏ប្រសើរនៃប្រជារាស្ត្រកម្ពុជា ។ យើងមិនមានការសង្ស័យទេថា បើសិនជាភាគច្រើននៃអ្នកដឹកនាំខ្មែរគ្រប់និន្នាការទាំងអស់ព្យាយាម និងដើរតាមផ្លូវរបស់ព្រះពោធិសត្វ

www.budinst.gov.kh www.elibraryofcambodia.org

នោះ ជាតិខ្មែរប្រហែលជាមានអនាគតមួយដ៏ធំធេង ហើយប្រជារាស្ត្រខ្មែរ ក៏នឹងរស់ក្នុងភាពសុខដុមរមនា សន្តិភាព វិបុលភាព និងសេចក្តីរីករាយជាពិតប្រាកដ ។

អាស្រ័យដោយទស្សនៈដែលបានពោលមកខាងលើនេះឯង ដែលមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលទេ ដែលសៀវភៅរបស់ព្រះតេជព្រះគុណ **ហេង មណីចិន្តា** ស្តីអំពីរបៀបដឹកនាំតាមគោលការណ៍ព្រះពុទ្ធសាសនា បានទទួលការយកចិត្តទុកដាក់យ៉ាងខ្លាំងពីសាធារណជន នៅពេលដែលបោះពុម្ពលើកទី ១ នៅឆ្នាំ ១៩៩២ ដោយការឧបត្ថម្ភរបស់មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ ។ សៀវភៅនេះត្រូវចែកផ្សាយអស់ក្នុងរយៈពេលត្រឹមតែ ២-៣ ខែប៉ុណ្ណោះ បន្ទាប់ពីបោះពុម្ព ។ សៀវភៅនេះ បានអធិប្បាយយ៉ាងល្អិតល្អន់នូវគុណតម្លៃរបស់ពុទ្ធសាសនា ដែលអ្នកដឹកនាំខាងផ្នែកនយោបាយ និងយោធា គួរតែដើរតាម ។ ប្រធានបទនេះ ទាក់ទងធំណាស់ទៅនឹងស្ថានការណ៍បច្ចុប្បន្ន នៅក្នុងពេលដែលសីលធម៌ ប្រពៃណី និងប្រព័ន្ធគុណតម្លៃខាងចរិយាធម៌នៃប្រទេសកម្ពុជា សឹងតែបានបំផ្លាញខ្ទេចខ្ទី ក្នុងកំឡុងពេលជាង ២០ ឆ្នាំមកហើយ ។ ការចុះអន់ថយនៃសីលធម៌ និងគុណធម៌ បានប៉ះពាល់ដល់សង្គមខ្មែរគ្រប់ស្រទាប់ទាំងអស់ ជាពិសេស ស្រទាប់ខ្លះនៃអ្នកដឹកនាំ ។ ក្នុងអតីតកាលថ្មីៗនេះ ប្រព័ន្ធគុណតម្លៃសាសនាបានត្រូវគេផ្លាស់ចេញយ៉ាងព្រៃផ្សៃដោយមនោគមវិជ្ជាកុំមុយនីស្ត ដែលបានបន្ថោកសាសនាទាំងអស់ថាជា "*គ្រឿងញៀនសំរាប់មនុស្ស*" ។ សព្វថ្ងៃនេះទៀតសោត គុណតម្លៃខាងការសម្បូរប្រាក់និងសម្ភារៈ បានកំពុងជំនួសអ្វីទាំងឡាយដែលសល់អំពីសីលធម៌ និងចរិយាធម៌របស់ប្រពៃណីពុទ្ធសាសនាហើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ការបោះបង់ចោលនូវគុណតម្លៃពុទ្ធសាសនានៅក្នុងអតីតកាល និងបច្ចុប្បន្ន បានជះឥទ្ធិពលជាអវិជ្ជមានយ៉ាងខ្លាំងដល់សង្គមខ្មែរគ្រប់ថ្នាក់ទាំងអស់ ។ ជាពិសេស ក្នុងចំណោមរង្វង់អ្នកដឹកនាំនយោបាយ និងយោធា ។

អាស្រ័យហេតុដូច្នេះហើយបានជា ព្រះតេជព្រះគុណ ហេង មណីចិន្ដា និងមូលនិធិ-ខុរ៉ាដ-អាដិនណៅអ៊ែរ សំរេចចិត្តបោះពុម្ពជាលើកទី ២ នូវសៀវភៅព្រះបាទធម្មិកនេះ ដោយបរិមាណខ្ពស់ ។ មូលនិធិ-ខុរ៉ាដ-អាដិនណៅអ៊ែរ និងរូបខ្ញុំផ្ទាល់ មានសេចក្ដីរីករាយ និងកិត្តិយសដែលបានជួយឧបត្ថម្ភក្នុងការបោះពុម្ពលើកទី ២ នេះ ។ មូលនិធិយើងសង្ឃឹមថា ដោយការឧបត្ថម្ភលើការបោះពុម្ពនេះ យើងអាចនឹងចូលរួមចំណែកក្នុងការស្ដារឡើងវិញយ៉ាងខ្លាំងក្លានូវប្រព័ន្ធសីលធម៌ ចរិយា-ធម៌ តាមបែបពុទ្ធសាសនាក្នុងស្រទាប់សង្គមខ្មែរ ជាមិនខាន ។

ជាបញ្ចប់នេះ ខ្ញុំសូមផ្ដល់ជូនដល់អ្នកអានជាទីគោរពនូវពត៌មានខ្លះៗ អំពីមូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ ដើម្បីឱ្យបានយល់ថា ហេតុអ្វីបានជាមូលនិធិប្រជា-ធិបតេយ្យគ្រិស្ដអាល្លឺម៉ង់នេះ ឧបត្ថម្ភបុព្វហេតុនៃការអភិវឌ្ឍន៍តាមបែបពុទ្ធ-សាសនា ក្នុងព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

លោក ខុនរ៉ាដ អាដិនណៅអ៊ែរ គឺជាប្រធានទី ១ នៃគណបក្សសហភាពប្រជាធិបតេយ្យគ្រិស្ដសាសនិក និងជា " អធិការបតី " ទីមួយ, នាយករដ្ឋមន្ត្រី នៃប្រទេសអាល្លឺម៉ង់ប្រជាធិបតេយ្យដ៏ពិតប្រាកដ ។ ដោយហេតុនេះ លោកអាចត្រូវបានគេចាត់ទុកជាបិតាម្នាក់នៃប្រទេសអាល្លឺម៉ង់បច្ចុប្បន្ន ។ គោលបំណងរបស់មូល-និធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ គឺបន្តអនុវត្តការងាររបស់លោក ខុនរ៉ាដ អាដិនណៅ

www.budinst.gov.kh www.elibraryofcambodia.org

អ៊ែរ ទៅតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យគ្រិស្តសាសននិក ។

មូលនិធិកំពុងបំពេញកិច្ចការជាដំបូង ក្នុងវិស័យអប់រំនយោបាយ និងពលរដ្ឋ ហើយនិងការស្រាវជ្រាវ និងការពិគ្រោះខាងនយោបាយ ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយ, មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ បានចូលរួមក្នុងការកំចាត់មូលហេតុទាំងឡាយដែលនាំឱ្យមានភាពក្រីក្រ ដោយមធ្យោបាយសន្តិភាពផងដែរ ។

គោលបំណងជាគ្រឹះរបស់មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ គឺ :

- លើកស្ទួយឱ្យមាន សន្តិភាព និងការផ្សះផ្សា,
- លើកស្ទួយឱ្យមាន លទ្ធិប្រជាធិបតេយ្យ និងច្បាប់,
- លើកស្ទួយឱ្យមាន សិទ្ធិមនុស្ស និងសិទ្ធិស៊ីវិល,
- លើកស្ទួយឱ្យមាន សេដ្ឋកិច្ចទីផ្សារ ដែលតម្រង់ទិសតាមសង្គម និងតាមបរិដ្ឋានសាស្ត្រ ,
- លើកស្ទួយឱ្យមាន ការកំចាត់ចោលមូលហេតុនៃភាពក្រីក្រ ដោយមធ្យោបាយសន្តិភាព ឱ្យស្របទៅតាមគោលការណ៍ជួយមនុស្ស ឱ្យចេះជួយខ្លួនឯង មួយដំណាក់ម្តងៗ ។

ព្រោះហេតុអ្វីបានជា មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ លើកស្ទួយឱ្យមានសន្តិភាព និងការផ្សះផ្សា ?

ដើម្បីរកឃើញចម្លើយ, យើងត្រូវក្រឡេកមើលប្រវត្តិសាស្ត្រប្រទេសអាល្លឺម៉ង់ អោយបានជិតដល់នៅក្នុងអំឡុងពេលពាក់កណ្តាលខាងដើមនៃសតវត្សទី ២០ : សង្គ្រាមលោកពីរដង ត្រូវបានចេញដំណើរពីទឹកដីប្រទេសអាល្លឺម៉ង់ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រឹត្តិការណ៍នេះ បាននាំមកនូវទុរគតភាពជាអនេកប្បការ មិនមែនគ្រាន់តែដល់ប្រទេសជិតខាងខ្ញុំ ប៉ុណ្ណោះទេ, ប៉ុន្តែដល់ប្រជាជន និងប្រទេសអាល្លឺម៉ង់ផងដែរ ។ ក្រោយឆ្នាំ ១៩៤៥, ខ្ញុំត្រូវរៀនមេរៀនដែលប្រវត្តិសាស្ត្រទើបតែបានបង្រៀនរួចហើយនោះ, ហើយខ្ញុំបានរៀនដោយបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនយោបាយសន្តិភាព និងការផ្សះផ្សាជាមួយប្រទេសជិតខាង ទន្ទឹមនឹងប្រមូលកំឡាំងខិតខំផ្ទៃក្នុងរបស់ខ្ញុំ ទៅលើការកសាងឡើងវិញ និងការធ្វើឱ្យមាននិតិសម្បទាខាងសេដ្ឋកិច្ច ហើយនិងការអភិវឌ្ឍន៍ប្រទេសរបស់ខ្ញុំ ។ គឺដោយមានការអនុវត្តន៍យ៉ាងម៉ឺតចត់នូវនយោបាយសន្តិភាព និងការផ្សះផ្សា ដែលត្រូវបានលោកខុនរ៉ាដ-អាដិនណៅអ៊ែរ រៀបចំដោយផ្ទាល់ហើយនោះ, ទើបអាចស្ដាបនាជាថ្មី និងអភិវឌ្ឍន៍ប្រទេសរបស់ខ្ញុំ ហើយនៅទីបំផុត សម្រេចបាននូវការបង្រួបបង្រួមប្រទេសអាល្លឺម៉ង់ ទៀតផង ។

ព្រោះហេតុអ្វីបានជា មូលនិធិ-ខុនរ៉ាដ-អាដិណៅអ៊ែរ លើកស្ទួយឱ្យមានលទ្ធិប្រជាធិបតេយ្យ និងច្បាប់ ព្រមទាំងសិទ្ធិមនុស្ស និងសិទ្ធិស៊ីវិល ?

ជាថ្មីម្ដងទៀត យើងត្រូវក្រឡេកមើលប្រវត្តិសាស្ត្រសម័យថ្មី នៃប្រទេសអាល្លឺម៉ង់ ៖ របបណាហ្ស៊ីរបស់អាដុលហ្វ៍ ហ៊ីត្លែរ បានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏គួរឱ្យស្អប់, ដោយសម្លាប់ជនរួមជាតិកំណើតជ្វីហ្វ៍របស់ខ្ញុំអស់រាប់លាននាក់, នេះមិននិយាយដល់ប្រជាជនរាប់សិបលាននាក់ទៀត ត្រូវសម្លាប់ក្នុងអំឡុងសង្គ្រាមលោកលើកទីពីរផងទេ ដែលត្រូវបានចាប់ផ្ដើមដោយរបបហ៊ីត្លែរ ។ ក្នុងបណ្ដាឆ្នាំចន្លោះ ឆ្នាំ ១៩៣៣ និងឆ្នាំ ១៩៤៥ គឺជាសម័យកាលដ៏អព្ភូតបំផុត នៅក្នុងប្រវត្តិ-

www.budinst.gov.kh www.elibraryofcambodia.org

សាស្ត្រប្រទេសអាល្លឺម៉ង់ ។ ម្ល៉ោះហើយ យើងត្រូវតែរៀនមេរៀនប្រវត្តិសាស្ត្រដ៏សំខាន់មួយទៀត ៖ ដើម្បីលុបបំបាត់លទ្ធភាពនៃការកើតឡើងជាថ្មី នៃលទ្ធិផ្តាច់ការប្រល័យពូជសាសន៍, យើងបានលើកស្ទួយ ហើយយើងត្រូវតែបន្តលើកស្ទួយឱ្យមានលទ្ធិប្រជាធិបតេយ្យ, គោលការណ៍នៃច្បាប់ ក៏ដូចជាសិទ្ធិមនុស្ស និងសិទ្ធិស៊ីវិល ។

ព្រោះហេតុអ្វីបានជា មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ លើកស្ទួយឱ្យមានសេដ្ឋកិច្ចទីផ្សារស្របតាមសង្គម និងបរិស្ថានវិទ្យា ?

ពីព្រោះ គ្រាន់តែតាមការលើកកំរិតជីវភាពរស់នៅរបស់ប្រជាជន និងតាមការអនុវត្តនយោបាយទទួលខុសត្រូវចំពោះបរិស្ថានវិទ្យា, យើងក៏អាចធ្វើឱ្យសង្គមមានស្ថិរភាព និងធ្វើឱ្យប្រព័ន្ធនយោបាយនៃលទ្ធិប្រជាធិបតេយ្យ មានស្ថិរភាពបានដែរ ។ ដូច្នេះ វាធានាបានអត្ថប្រយោជន៍រយៈពេលវែង សំរាប់ប្រជាជននៃប្រទេសរបស់យើងទាំងឡាយបាន ។

បច្ចុប្បន្ននេះ មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ កំពុងបំពេញសកម្មភាពនៅក្នុងជាង ១៣០ ប្រទេស ហើយចំណាយប្រាក់ប្រហែល ៧៥ លានដុល្លារសហរដ្ឋអាមេរិក សំរាប់ការងារអន្តរជាតិរបស់ខ្ញុំ ជារៀងរាល់ឆ្នាំ ។

នៅក្នុងឆាកអន្តរជាតិ, មូលនិធិ-ខុនរ៉ាដ-អាដិណៅអ៊ែរ កំពុងសហប្រតិ-បត្តិការជាមួយទាំងរដ្ឋាភិបាល ទាំងអង្គការក្រៅរដ្ឋាភិបាល ។ ខ្ញុំផ្តល់យោបល់ដល់ភ្នាក់ងាររដ្ឋាភិបាល ហើយហ្វឹកហ្វឺនមន្ត្រីដ៏ចំណាន១ ក្នុងការធ្វើយ៉ាងណាកសាងឱ្យបាន ប្រព័ន្ធប្រជាធិបតេយ្យដ៏ត្រឹមត្រូវ ។ ខ្ញុំផ្តល់ការហ្វឹកហ្វឺនខាងច្បាប់ផងដែរ និង

www.budinst.gov.kh www.elibraryofcambodia.org

និងធ្វើយ៉ាងណាឱ្យអភិវឌ្ឍន៍សេដ្ឋកិច្ចទីផ្សារតម្រង់ទិសតាមសង្គម និងតាមបរិស្ថាន វិទ្យា ។ ជាមួយគ្នានេះ ខ្ញុំឧបត្ថម្ភអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ពីព្រោះខ្ញុំចាត់ទុកអង្គការក្រៅរដ្ឋាភិបាលនៅមូលដ្ឋាន ជាកំឡាំងដ៏សំខាន់ក្រៃលែង សំរាប់ធ្វើចលនាឱ្យប្រជាជនចេះជួយខ្លួនឯង ដើម្បីបង្កើនកំរិតរស់នៅរបស់គេ, ដើម្បីចេះទទួលភារកិច្ចខុសត្រូវជាពលរដ្ឋ និងដើម្បីរក្សាការពារសិទ្ធិប្រជាធិបតេយ្យរបស់ខ្លួន ។ បទពិសោធន៍ផ្ទាល់របស់ខ្ញុំបានប្រាប់ឱ្យដឹងថា បើគ្មានអង្គការក្រៅ រដ្ឋាភិបាលយ៉ាងច្រើន និងគ្មានការចូលរួមរបស់ប្រជាជន ជាពិសេស នៅថ្នាក់មូលដ្ឋានទេ ប្រទេសអាល្លឺម៉ង់ មុខជាមិនត្រូវបានកសាងឡើងវិញយ៉ាងឆាប់ ហើយប្រកបដោយជោគជ័យកើតទេ ក្រោយសង្គ្រាមលោកលើកទីពីរចប់ទៅនោះ ។

មូលនិធិ-ខុនរ៉ាដ-អាដឺនណោអ៊ែរ តែងគោរពផលប្រយោជន៍សេដ្ឋកិច្ច និងនយោបាយរបស់ប្រទេសម្ចាស់ផ្ទះ ដោយមិនធ្វើឱ្យខូចកិត្តិយស ឬស្ទើរបោះបង់ចោលបណ្ដាគោលការណ៍ផ្ទាល់របស់ខ្លួនដែលមានមកយូរយារហើយ ដែលត្រូវបានប្រវត្តិសាស្ត្របញ្ជាក់ថាត្រឹមត្រូវហើយនោះទេ ។ យើងតែងគោរពអត្តសញ្ញាណវប្បធម៌របស់ប្រទេសជាម្ចាស់ផ្ទះ ។ នេះមិនមែនជាការនិយាយទទេទេ ។ ខ្ញុំក្នុងឋានៈជាមូលនិធិប្រជាធិបតេយ្យគ្រិស្តសាសនិក បានផ្ដល់ប្រាក់យ៉ាងច្រើនដល់អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ នៅអន្លង់វិល ខេត្តបាត់ដំបង ហើយយើងខ្ញុំកំពុងឧបត្ថម្ភសិក្ខាសាលាជាតិនេះ ស្ដីពីពុទ្ធសាសនា និងការអភិវឌ្ឍន៍សង្គមខ្មែរ ។ នេះគឺជាអ្វីដែលខ្ញុំយោងដល់ នៅពេលដែលខ្ញុំនិយាយអំពីការយោគយល់ និងការអត់ឱន អធ្យាស្រ័យជាអន្តរវប្បធម៌ និងជាអន្តរសាសនា ដ៏ជាគោលការណ៍សំខាន់មួយខាងគំនិតរបស់អង្គការប្រជាធិបតេយ្យគ្រិស្តសាសនិករបស់ខ្ញុំ ។

www.budinst.gov.kh www.elibraryofcambodia.org

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះព្រះតេជព្រះគុណ ហេង មុណីចិន្តា នាយកពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ដែលបានជួយបកប្រែអារម្ភកថារបស់ខ្ញុំក្នុងសៀវភៅនេះជាភាសាខ្មែរ ។ អរគុណផងដែរចំពោះលោក ឱម ខែម នាយកពុទ្ធសាសនបណ្ឌិត្យ (ភ្នំពេញ) ដែលទទួលខុសត្រូវក្នុងការចម្លងឯកសារនេះឡើងវិញ និងត្រួតពិនិត្យឯកសារសៀវភៅនេះ យ៉ាងម៉ត់ចត់ ។ ហើយនៅទីបំផុត ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះអ្នកជំនួយការខ្ញុំ គឺលោក វស់ ថាន់ សន ដែលបានយកចិត្តទុកដាក់មិនត្រឹមតែជួយផ្ទៀងផ្ទាត់ឯកសារសំណៅដើមប៉ុណ្ណោះទេ ថែមទាំងបានជួយរៀបចំរចនាលំអក្របសៀវភៅនេះទៀតផង ។

ភិបាល សៀវ

www.budinst.gov.kh www.elibraryofcambodia.org

# Preface of Peter Schier,
## Permanent Representative of the Konrad-Adenauer-Foundation to the Kingdom of Cambodia

From time immemorial, there seem to have been two different ways of thinking about the meaning of life of mankind:

1) Should we, as individual human beings, live and work only for our own sake and for our own well-being? Should we strive to attain the salvation only of ourselves?

2) Or, should we live and work for the sake and well-being of our fellow creatures, too, and should we help those others who are not as fortunate as ourselves to free themselves from their sufferings?

There can be no doubt that only the second way of thinking reflects the teachings of Buddha and also of Jesus Christ. Only those who do not only care for themselves but who help the weak and poor in society, too, act according to the principles of Buddha and Jesus Christ. This is exactly the meaning of loving kindness (metta), compassion (karuna), sympathetic joy (mudita) and equity and justice (upekha). These four fundamental Buddhist principles do not only apply to ordinary people but also, and especially, to the leaders in all sectors of society who have a special responsibility for the sake of people and the nation.

www.budinst.gov.kh www.elibraryofcambodia.org

To follow these four basic principles is of utmost importance for the fate of people and their countries: If these precepts are adhered to both by the people and, especially, the leaders, all nations would live in harmony, peace, prosperity and happiness. However, if people and their leaders do not follow the four fundamental Buddhist principles, any society will be plagued by endless feuds, war, poverty and unhappiness.

To help others to help themselves to find enlightenment and free themselves from suffering means to walk the Boddhisatthva way. Boddhisatthvas are enligthened people who, through their good deeds, have qualified to enter nirvana but who have decided to be reincarnated in order to help others to find enlightenment and free themselves from suffering.

In Khmer history, we know about the existence of one outstanding Boddhisatthva king: Jayavarman VII (1181-1219). Jayavarman VII regarded himself as the reincarnation of the Boddhisatthva Avalokiteshvara who is the Buddhist saint of boundless compassion. This is why Jayavarman VII, in order to help his people, gave orders to build a great number of irrigation systems, roads and hospitals which were much more numerous and much better than the respective public works of his successors. Indeed, it seems that the irrigation system built during the reign of Jayavarman VII was far better than the existing irrigation system in present-day Cambodia.

www.budinst.gov.kh www.elibraryofcambodia.org

It seems that, apart from Jayavarman VII, there has been only one other outstanding Khmer king who has honestly tried to walk the Boddhisatthva way: King Norodom Sihanouk.

During the Sangkum Reastr Niyum period, King Sihanouk undertook numerous works for public benefit including the building of schools, irrigation systems, roads, hospitals etc. Since the 1980s, King Sihanouk has made untiring efforts to achieve national reconciliation and peace in Cambodia, to help the poor and weak in society, to contribute to a revival of a development-oriented Buddhism as the basic moral and ethical value system in Cambodia and to safeguard democracy, human rights and the constitutional freedoms of the Cambodian people, which all constitute the basic preconditions for a successful reconstruction of Cambodia and the well-being of the Cambodian people.

There can be no doubt that if the majority of the Khmer leaders of all factions would be ready to walk the Boddhisatthva way, the Khmer nation would have a great future and the Khmer people would live in harmony, peace, prosperity and happiness.

In view of the above-mentioned, it is not surprising that the present book of Venerable Heng Monychenda about *Leadership through Buddhist Principles* met with great public interest when it was first published in 1992 with the support of the Konrad-Adenauer-Foundation. Indeed, the first edition of this book went out of print within a few months.

www.budinst.gov.kh www.elibraryofcambodia.org

This book describes in a splendid way the Buddhist virtues which should be followed by the political and military leaders of Cambodia. This subject is of great relevance to the present situation as the traditional moral and ethical value system of Cambodia has been nearly completely destroyed during the past 20 years or more. The decline of morals and virtues has affected all strata of Khmer society, especially parts of the ruling classes. In the recent past, the Buddhist value system was brutally replaced by Communist ideology which despised every religion as 'opium of the people'. Today, the value of money and material wealth is day by day replacing what is left of the traditional Buddhist morals and ethics.

The abandoning of Buddhist values in the past and present has had extremely negative effects on Khmer society at all levels, especially amongst the leading political and military circles. Therefore, Venerable Heng Monychenda and the Konrad-Adenauer-Foundation decided to publish this second, revised edition of *Leadership through Buddhist Principles* with a large circulation. The Konrad-Adenauer-Foundation and myself are very happy and honoured to support this second, revised edition, too. The Konrad-Adenauer-Foundation hopes that, by supporting this publication, we will be able to contribute to a powerfull revival of a development-oriented Buddhist value system of morals and ethics in all strata of Khmer society.

Finally, I would like to give the respected readers of this book some information about the Konrad-Adenauer-Foundation so that they will understand

www.budinst.gov.kh www.elibraryofcambodia.org

why this German Christian-democratic foundation is supporting the cause of a development-oriented Buddhism in Cambodia to a considerable extent.

Konrad Adenauer (1876-1967) was the first chairman of the Christian Democratic Union Party (1950-1967) and the first 'Chancellor' (Prime Minister) of the truly democratic Germany (1949-1963). He can therefore be regarded as one of the fathers of modern Germany. The aim of the Konrad-Adenauer-Foundation is to carry forward the commitment of Konrad Adenauer to the principles of Christian democracy.

The Foundation is working primarily in the fields of political and civic education and political research and consulting. In developing countries the Konrad-Adenauer-Foundation is also engaged in eliminating the causes of poverty by peaceful means.

The basic aims of the Konrad-Adenauer-Foundation are:

- to promote peace and reconciliation,
- to promote democracy and law,
- to promote human and civil rights,
- to promote a socially and ecologically oriented market economy,
- to promote the elimination of the causes of poverty by peaceful means, according to the principle of helping people to help themselves, step by step.

www.budinst.gov.kh www.elibraryofcambodia.org

Why does the Konrad-Adenauer-Foundation promote peace and reconciliation?

To find the answer we have to take a close look at German history in the first half of the 20th century: two world wars were started from German soil. This brought untold misery not only to our neighbors but also to the German people and nation. After 1945, we had to learn the lesson history had just taught us, and we did it by steadfastly pursuing a policy of peace and reconciliation with our neighbors while concentrating our internal efforts on the reconstruction and economic rehabilitation and development of our country. Only by strictly following the policy of peace and reconciliation which had been originally designed by Konrad Adenauer were we able to rebuild and develop our country and finally even achieve the reunification of Germany.

Why does the Konrad-Adenauer-Foundation promote democracy and law as well as human and civil rights?

Again, we have to look at modern German history: the Nazi regime of Adolf Hitler committed abominable crimes, killing millions of our Jewish compatriots, not to mention the tens of millions of people killed during the Second World War started by the Hitler regime. The years between 1933 and 1945 constitute the darkest period in German history. And we had to learn another important historical lesson: in order to eliminate the possibility of a rebirth of a genocidal dictatorship we had to, and we still have to, promote democracy and the rule of law, as well as human and civil rights.

www.budinst.gov.kh www.elibraryofcambodia.org

Why does the Konrad-Adenauer-Foundation promote a social and ecological market economy and the elimination of the causes of poverty?

Only by raising the standard of living of the people and by implementing a responsible ecological policy can we stabilize society and stabilize the political system of democracy, thus ensuring a long term-benefit for the people of our countries.

At present, the Konrad-Adenauer-Foundation is active in more than 130 countries and we spend about US$ 75 million for our international work annually.

In the international field, the Konrad-Adenauer-Foundation is cooperating both with government and non-governmental organizations. We advise government agencies and we train talented officials in how to set up sound democratic systems. We also provide training in law and how to develop a socially and ecologically oriented market economy. At the same time, we support indigenous non-governmental organizations because we regard local NGOs as a very important force for mobilizing the people to help themselves in order to increase their standard of living, to assume civic responsability and to look after their democratic rights. Our own experiences tell us that without the many NGOs and people's associations, especially at the local level, Germany would not have been rebuilt as quickly and as successfully as it was after the Second World War.

www.budinst.gov.kh www.elibraryofcambodia.org

The Konrad-Adenauer-Foundation respects the economic and political interests of the host country without compromising on or even giving up its own long-time established principles which have been proved correct by history. We respect the cultural identity of the host country. This is not empty talk. We, as a *Christian* democratic foundation, give considerable funds to the *Buddhism for Development* association in Anlongvil, Battambang province, and we have supported the first national seminar on *Buddhism* and the development of Khmer society in November 1994. This is what we mean when we talk about inter-cultural and inter-religious understanding and tolerance as being one important principle of our *Christian Democratic* body of thought.

Finally, I would like to thank Venerable Heng Monychenda, director of the *Buddhism for Development* association, for skillfully translating my preface for this book. My thanks go, too, to Mr. Om Khem, director of the Buddhist Institute (Phnom Penh), who was responsible for the type-setting and proof-reading of this book. Last but not least, I would like to thank my assistant Mr. Ros Than San who did not only carefully proof-read but also untertook the artwork of the present book.

Peter Schier

www.budinst.gov.kh www.elibraryofcambodia.org

# កថាមុខ

បើអ្នកដឹកនាំប្រកបដោយធម៌ រាស្ត្រទាំងឡាយរមែងដេកជាសុខ

តែ

បើអ្នកដឹកនាំមិនប្រកបដោយធម៌ រាស្ត្រទាំងឡាយរមែងដេកជាទុក្ខ

ពុទ្ធភាសិតពីរឃ្លាខាងលើនេះ គ្របដណ្តប់លើប្រវត្តិសាស្ត្រដែលរុងរឿង និងឱនថយរបស់រាស្ត្រខ្មែរ ដោយឥតប្រកែកបាន ។ ខ្មែរធ្លាប់រុងរឿង មាននិសាលៈភាពទឹកដីទូលំទូលាយ ជាមហានគរមួយ នាភូមិភាគអាស៊ីអាគ្នេយ៍ ក៏ព្រោះអ្នកដឹកនាំ ហើយខ្មែរធ្លាប់បាត់បង់ទឹកដីរះស្លាប់ផុតពូជ ក៏ព្រោះអ្នកដឹកនាំ ។

វដ្តចក្រ *«ឃ្លោកលិច អម្បែងអណ្តែត ឃ្លោកត្រសែត អម្បែងលង់ ត្អូងកង់ត្រាច ត្អូងកង់ធ្នង់ វិលវង់ដូចកង់ សង់ជាប្រវត្តិសាស្ត្រ»* នឹងនៅតែវិល ទៅមុខជាបន្តទៀត បើខ្មែរយើងនៅតែមិនអើពើក្នុងការជួយកសាង សង់ កែឆ្នៃធម្មិករាជា ដើម្បីមកគ្រប់គ្រងដឹកនាំខ្លួនទេនោះ ។

ពុទ្ធសាសនា ជាកម្មនិយម ។ គ្រប់ៗគ្នាទទួលខុសត្រូវចំពោះព្រឹត្តិការណ៍ទាំងឡាយដែលកើតមាន ( កម្មស្សកោម្ហិ ), ជាអ្នកសាងបង្កបង្កើតនូវអ្វីៗទាំងឡាយ ( កម្មយោនិ ), ជាអ្នកតាក់តែងនូវទាយាទ គឺអ្នកបន្តពូជពង្សរបស់ខ្លួន ( កម្មទាយាទោ ) ។ ដូច្នេះ រាស្ត្រខ្មែរយើងអាចអាស្រ័យកម្មនិយម ដើម្បីទទួលខុសត្រូវក្នុងការបង្កបង្កើតអ្នកដឹកនាំល្អ សំរាប់ធ្វើជាទាយាទបន្តពូជពង្សវង្សត្រកូល និងកេរ្តិ៍មរតករបស់ជាតិខ្លួនបាន ។

បើយើងសាងអ្នកដឹកនាំបានល្អ យើងក៏រមែងដេកលក់ដោយសុខ បើយើងបណ្តោយឱ្យជនអាក្រក់មកដឹកនាំ យើងប្រាកដជាដេកកើតទុក្ខមិនខាន ។

www.budinst.gov.kh www.elibraryofcambodia.org

សៀវភៅព្រះបាទធម្មិកនេះ ជាពុទ្ធធម្មូបករណ៍ ដែលរៀបរៀងឡើង ប្រយោជន៍ដើម្បី ៖

- ឱ្យអ្នកដឹកនាំទាំងឡាយ បានធ្វើស្វ័យពិចារណាលើឥរិយាបថ ក្នុងការដឹកនាំរបស់ខ្លួន ប្រៀបធៀបទៅនឹងបែបបទរបស់ព្រះសម្មាសម្ពុទ្ធ ដែលជាធម្មិករាជា,

- ឱ្យពលរដ្ឋខ្មែរទាំងពួងបានសិក្សា និងយល់អំពីអ្នកដឹកនាំកាន់តែច្រើនឡើង ទាំងអំពីសារសំខាន់របស់អ្នកដឹកនាំ និងគុណសម្បត្តិរបស់បុគ្គល ដែលនឹងត្រូវជ្រើសរើស ឬសាងឡើងសំរាប់ធ្វើជាទាយាទ ដើម្បីតបស្នងនូវចេតនារម្មណ៍របស់ខ្លួនគឺ « *បជាសុខំ មហុត្តមំ* = សេចក្តីសុខរបស់រាស្ត្រប្រជា គឺជាគោលដៅដ៏ឧត្តមបំផុត » ។

- បង្ហាញឱ្យឃើញថា ក្នុងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ មានអ្វីច្រើនណាស់ ដែលជាប្រយោជន៍សំរាប់សេចក្តីសុខ និងសេចក្តីចំរើនរបស់មនុស្សជាតិ ដែលយើងជាខ្មែរគួរសិក្សាស្រាវជ្រាវ និងអនុវត្តឱ្យបានត្រឹមត្រូវ និងត្រូវត្រង់។

រចនាករ បានទទួលនូវការណែនាំពីព្រះតេជព្រះគុណអធិបតីសង្ឃ ស៊ីរិ-សុវណ្ណោ **ពិន សែម** ដែលត្រូវជាគ្រូ ឱ្យរៀបរៀងជាសៀវភៅប្រភេទនេះឡើងតាំងពីនៅជំរំភៀសខ្លួនម្ល៉េះ ។ សៀវភៅនេះសរសេរដោយប្រើពេលយូរបន្តិច ដោយហេតុមានកិច្ចធុរៈ ១៩៩១ ក្នុងព្រះវស្សាច្រើនពេក លុះត្រាតែដល់ថ្ងៃទី ២៣ តុលា ដែលជាថ្ងៃចេញព្រះវស្សា និងជាថ្ងៃដែលគូភាគីខ្មែរទាំងអស់ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពខ្មែរ នាក្រុងប៉ារីស ប្រទេសបារាំង ទើបចប់សព្វគ្រប់ ។ រចនាករមានសេចក្តីរំភើបជាខ្លាំង និងសង្ឃឹមថា សៀវភៅនេះនឹងមានគុណ-ប្រយោជន៍ សំរាប់ខ្មែរ ។

ក្នុងការបោះពុម្ពលើកទី ២ នេះ មូលនិធិ-ខុនរ៉ាដ-អាដិនណៅអ៊ែរ នៃប្រទេសអាឡឺម៉ង់ បានយកជាធុរៈក្នុងការចេញថវិកាដើម្បីបោះពុម្ពដូចលើកទី១ ដែរ

www.budinst.gov.kh www.elibraryofcambodia.org

ដែលជាការមួយបង្ហាញឱ្យឃើញនូវការយកចិត្តទុកដាក់ជាបន្ត ពុំមានដាច់របស់មូលនិធិ តាំងពីឆ្នាំ ១៩៨៥ ដល់ការរស់ឡើងវិញនៃវប្បធម៌ខ្មែរ ។ សូមមូលនិធិទទួលនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅអំពីរចនាករ និងអ្នកដែលបានទទួលប្រយោជន៍អំពីសៀវភៅនេះ ។

ចំពោះការបោះពុម្ពលើកនេះ រចនាករពុំបានកែខៃន័យសេចក្តីអ្វីទេ គ្រាន់តែកែអក្ខរាវិរុទ្ធខ្លះៗតែប៉ុណ្ណោះ ហើយពុំបានអស់ទៀត ព្រោះមានការរវល់ជាមមាញឹកពេក ។ សង្ឃឹមថា មិត្តអ្នកអានប្រាកដជាយោគយល់ពុំខាន ។

ចំពោះអានិសង្សដែលកើតចេញអំពីការបោះពុម្ពលើកទី ២ នេះ ទាំងប៉ុន្មាន រចនាករសូមឧទ្ទិសចំពោះអ្នកដឹកនាំខ្មែរ ដែលមានគុណចំពោះប្រទេសជាតិទាំងអស់ ទាំងគ្រហស្ថ ទាំងបព្វជិត ទាំងបាត់បង់ជីវិតទៅហើយក្តី ទាំងកំពុងដឹកនាំប្រទេសជាតិក្តី ដែលនៅក្នុងនោះ មានញោមបិតារបស់រចនាករផងដែរ គឺ លោក **ហេង ដានី** ជាមេឃុំ ឃុំអន្លង់វិល ដែលលោកខំធ្វើការបំរើប្រជារាស្ត្រដោយការស្មោះត្រង់ និងយកជីវិតជាថ្នូរ រហូតទាល់តែធ្លាក់ខ្លួនឈឺជាទម្ងន់ និងដែលពុំមានសង្ឃឹមថា នឹងអាចជាសះស្បើយឡើយ ។ សូមលោកទាំងអស់គ្នា បានទទួលនូវបុណ្យកុសលនេះ ដោយសេចក្តីគោរពអំពីរចនាករ ។

០៨

វត្តអន្លង់វិល, ស្រុកសង្កែ បាត់ដំបង ១ ។ ១ ព.ស ២៥៣៨, ១១ ធ្នូ ១៩៩៤

វស្សា ១៥

ឥន្ទបញ្ញោភិក្ខុ

**ហេង មណីចិន្តា**

www.budinst.gov.kh www.elibraryofcambodia.org

# មជ្ឈមណ្ឌលវប្បធម៌ និង វិបស្សនា
## ព្រែកហូរ ខេត្តកណ្ដាល

ប្រគេនព្រះតេជព្រះគុណ ហេង មុណីចិន្ដា,

ខ្ញុំព្រះករុណា បានសិក្សាស្រាវជ្រាវ រៀនសូត្រពីសៀវភៅព្រះបាទធម្មិកនេះ ហើយព្រមទាំងបានដកពិសោធន៍ជាមេរៀនមួយចំនួនធំ សំរាប់ចែកចាយជូនដល់មិត្តភ័ក្តិ និងសិស្សករុណាទាំងឡាយ រមែងមកសិក្សាអំពីសីលធម៌ គុណធម៌ ដឹកនាំ និងវិធីសាស្ត្រគ្រប់គ្រងមនុស្ស និងសង្គម ។

ខ្ញុំព្រះករុណាយល់ឃើញថា សៀវភៅនេះ មានសារសំខាន់សំរាប់ជីវិត ៖

១) ចំពោះគុណធម៌ សីលធម៌ និងវិធីសាស្ត្រគ្រប់គ្រងខ្លួនឯង គ្រប់គ្រងសង្គម ដឹកនាំខ្លួនឯង និងដឹកនាំសង្គម ដោយប្រសិទ្ធិភាព ។

២) សៀវភៅនេះ បានធ្វើឱ្យផ្លូវទាំងពីរ គឺផ្លូវលោកិយៈ និងផ្លូវលោកុត្តរៈ មិនឃ្លាតឆ្ងាយពីគ្នាពេក ហើយជួយបំពេញគ្នាទៅវិញទៅមក ។

៣) សៀវភៅនេះ បានធ្វើឱ្យលក្ខណៈប្រាកដនិយម ជីវិតនិយម បរានុមត្តិនិយម របស់ពុទ្ធសាសនា ក្នុងការយល់សភាវធម៌ពិត សភាវធម៌ពិតមែននៃជីវិត ។

៤) សៀវភៅនេះ បានធ្វើឱ្យពុទ្ធសាសនា មានសារសំខាន់នៅក្នុងជីវិត និងក្លាយទៅជាការចាំបាច់ជាបណ្ដើរៗ ។

៥) សៀវភៅនេះ មានលក្ខណៈវិទ្យាសាស្ត្រ លក្ខណៈប្រមូលផ្ដុំបំផុត ក្នុងការធ្វើឱ្យឋានៈក្រោម និងឋានៈលើ ធ្វើឱ្យឋានៈកណ្ដាលមានប្រយោជន៍ ។

www.budinst.gov.kh www.elibraryofcambodia.org

- អតីត និងអនាគត ធ្វើឱ្យបច្ចុប្បន្នមានប្រយោជន៍
- ម្សិលមិញ និងថ្ងៃស្អែក ធ្វើឱ្យថ្ងៃនេះមានប្រយោជន៍ ។ ល ។

ខ្ញុំព្រះករុណា សូមជួយគ្រាំទ្រក្នុងការរៀបចំបោះពុម្ពផ្សាយឱ្យបានច្រើនទូលំទូលាយ ដើម្បីជាកុសលធម៌ដល់មនុស្សគ្រប់ៗរូប ។

នាយកមជ្ឈមណ្ឌលវប្បធម៌ និង វិបស្សនា

ព្រឹទ្ធាចារ្យ **សេង ផុន**

www.budinst.gov.kh www.elibraryofcambodia.org

# ព្រះបាទធម្មិក

www.budinst.gov.kh www.elibraryofcambodia.org

# ១. សារសំខាន់របស់អ្នកដឹកនាំ

អ្នកដឹកនាំ នាយក ប្រធាន ប្រធានាធិបតី រាជា ប្រមុខ ប្រមុខរដ្ឋ មានសារសំខាន់យ៉ាងណាខ្លះ ចំពោះប្រជារាស្ត្រ និងសង្គម ដែលខ្លួនគ្រប់គ្រង និងមើលការខុសត្រូវនោះ? ខ្ញុំគិតថា អ្នកអានគង់នឹងយល់ជាមិនខាន ។ ក្នុងទីនេះ ខ្ញុំសូមលើកយកទស្សនៈរបស់ព្រះសម្មាសម្ពុទ្ធ មេដឹកនាំមួយយ៉ាងធំ ដែលពិភពលោកទទួលស្គាល់ និងជឿពុទ្ធដីការបស់លោកថាមានសច្ចភាព យកមកជូនមិត្តអ្នកអានដោយផ្ទាល់តែម្តង ។ ទស្សនៈរបស់ព្រះអង្គនេះ ទ្រង់សម្តែងនៅក្នុងគម្ពីរព្រះសុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ។ ក្នុងព្រះសូត្រនេះ ព្រះអង្គប្រើពាក្យព្រះរាជា សំរាប់សំគាល់អ្នកដឹកនាំប្រទេសទូទៅ ដូច្នេះ សូមអ្នកអានសំគាល់ពាក្យរាជានេះ ជាវេវចនៈនឹងពាក្យអ្នកដឹកនាំ នាយក ប្រធាន ប្រធានាធិបតី រាជា ប្រមុខ ប្រមុខរដ្ឋ ឬនាយករដ្ឋមន្ត្រីផងចុះ ។

ព្រះសូត្រនេះ មានសេចក្តីដូចតទៅ ៖

- « ម្នាលភិក្ខុទាំងឡាយ សម័យណា ពួកព្រះរាជាមិនប្រកបដោយធម៌ សម័យនោះ ពួកខ្ញុំរាជការក៏មិនប្រកបដោយធម៌ដែរ ។

ម្នាលភិក្ខុទាំងឡាយ កាលពួកអ្នករាជការមិនប្រកបដោយធម៌ សម័យនោះ ពួកព្រាហ្មណ៍ និងគហបតី ក៏មិនប្រកបដោយធម៌ដែរ ។ កាលពួកព្រាហ្មណ៍ និងគហបតី មិនប្រកបដោយធម៌ហើយ សម័យនោះ ពួកអ្នកនិគម និងអ្នកជនបទ មិនប្រកបដោយធម៌ដែរ ។ កាលអ្នកនិគម និងអ្នកជនបទ មិនប្រកបដោយធម៌ហើយ ព្រះច័ន្ទនិងព្រះអាទិត្យ ក៏គោចរទៅមិនស្មើដែរ ។ កាលព្រះច័ន្ទនិងព្រះអាទិត្យគោចរទៅមិនស្មើ ពួកផ្កាយនក្ខត្តឫក្ស ក៏គោចរមិនស្មើដែរ ។ កាលពួកផ្កាយនក្ខត្តឫក្ស

www.budinst.gov.kh www.elibraryofcambodia.org

គោចរទៅមិនស្មើ យប់និងថ្ងៃ ក៏ប្រព្រឹត្តទៅមិនស្មើដែរ ។ កាលយប់និងថ្ងៃ ប្រព្រឹត្តទៅមិនស្មើ ខែនិងកន្លះខែ ក៏ប្រព្រឹត្តទៅមិនស្មើដែរ ។ កាលខែនិងកន្លះខែ ប្រព្រឹត្តទៅមិនស្មើ រដូវនិងឆ្នាំ ក៏ប្រព្រឹត្តទៅមិនស្មើដែរ ។ កាលរដូវនិងឆ្នាំប្រព្រឹត្តទៅមិនស្មើ ខ្យល់ក៏បក់មិនស្មើដែរ ។ កាលខ្យល់បក់មិនស្មើ ខ្យល់បក់ខុសផ្លូវទាំងឡាយក៏ប្រព្រឹត្តទៅមិនស្មើដែរ ។ កាលខ្យល់បក់ខុសផ្លូវទាំងឡាយប្រព្រឹត្តទៅមិនស្មើ ទេវតាទាំងឡាយក៏ខឹងសម្បារ ។ កាលទេវតាទាំងឡាយខឹងសម្បារ ភ្លៀងក៏មិនបង្អុរទឹកភ្លៀងមកដោយប្រពៃ ។ កាលភ្លៀងមិនបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ ស្រូវទាំងឡាយក៏ឱ្យផលមិនស្មើល្អ ។

• ម្នាលភិក្ខុទាំងឡាយ ពួកមនុស្ស កាលបរិភោគស្រូវដែលឱ្យផលមិនស្មើល្អ រមែងមានអាយុខ្លី មានសម្បុរអាក្រក់ មានកម្លាំងតិច មានអាពាធច្រើន ។

ម្នាលភិក្ខុទាំងឡាយ សម័យណា ពួកព្រះរាជាប្រកបដោយធម៌ សម័យនោះ ពួកខ្ញុំរាជការក៏ប្រកបដោយធម៌ដែរ ។ កាលបើពួកខ្ញុំរាជការប្រកបដោយធម៌ ។ ល។ កាលបើផ្លូវខ្យល់ទាំងឡាយស្មើ ពួកទេវតាមិនខឹងសម្បារ កាលពួកទេវតាមិនខឹងសម្បារ ភ្លៀងក៏បង្អុរទឹកភ្លៀងចុះមកដោយប្រពៃ ។ កាលភ្លៀងបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ ស្រូវក៏ឱ្យផលស្មើល្អ ។

ម្នាលភិក្ខុទាំងឡាយ មនុស្សទាំងឡាយ កាលបរិភោគស្រូវដែលមានផលស្មើល្អ រមែងមានអាយុវែង មានសម្បុរល្អ មានកម្លាំង ព្រមទាំងមានអាពាធតិច » ។

យកព្រះសូត្រនេះមកវិភាគ យើងនឹងឃើញថាភាពមិនល្អ ឬអធម៌របស់អ្នកដឹកនាំ ពោលគឺអ្នកដឹកនាំដែលគ្មានគុណភាព គ្មានគុណធម៌ នឹងនាំឱ្យសង្គមនោះជាសង្គមមិនល្អ គ្មានគុណភាព-គុណធម៌ដែរ ។ សង្គមដែលគ្មានគុណភាព-គុណធម៌រមែងនាំឱ្យធម្មជាតិមិនល្អ ហិនហោច ប្រែប្រួល មិនប្រក្រតី ហើយកាលណា ធម្ម-

www.budinst.gov.kh www.elibraryofcambodia.org

ជាតិមិនប្រក្រតីហើយ ភាពទុរភិក្ស ព្រោះធ្វើកសិកម្មមិនល្អកើតឡើង ។ ទាំងអស់គ្នាធ្មេចភ្នែក ហើយស្រមៃថា កាលមនុស្សកើតទុរភិក្ស ពោលគឺ ឥតមានអ្វីបរិភោគ ឬបរិភោគមិនគ្រប់គ្រាន់ តើអ្វីនឹងកើតឡើង ? ការដណ្តើម ? ការកាប់សម្លាប់ ? សង្គ្រាម ? ផលនៃសង្គ្រាម យើងដឹងហើយថា គឺមនុស្សខ្លួនឯងនេះឯង ដែលនឹងត្រូវរងទុក្ខវេទនា ។

យើងអាចគូររូបដែលបង្ហាញពីទោស និងគុណនៃការដែលមានអ្នកដឹកនាំមិនល្អ និងល្អ ដូចខាងក្រោមនេះ ៖




www.budinst.gov.kh www.elibraryofcambodia.org




នៅចុងបញ្ចប់នៃព្រះសូត្រ ព្រះសម្មាសម្ពុទ្ធបានប្រៀបអ្នកដឹកនាំទៅនឹងគោមេហ្វូង ដែលមានសេចក្តីដូចតទៅ ៖

• « ម្នាលភិក្ខុទាំងឡាយ បើគោទាំងឡាយកំពុងឆ្លងទៅ កាលបើគោមេហ្វូងនាំទៅកាន់ផ្លូវខុសកំពង់ ពួកគោទាំងអស់នោះ ក៏នាំគ្នាទៅកាន់ផ្លូវខុសកំពង់ដែរ ។ មានឧបមាយ៉ាងណា ក្នុងពួកមនុស្សក៏ដូច្នោះដែរ ។ អ្នកណាដែលគេសន្មតថាប្រសើរជាងគេ (ជាប្រមុខគេ) បើអ្នកនោះប្រព្រឹត្តមិនត្រូវតាមធម៌ និងមិនបាច់និយាយទៅថ្វីដល់ប្រជាជនដទៃឡើយ » ។

បើព្រះរាជាមិនប្រកបដោយធម៌ រាស្ត្រទាំងអស់រមែងដេកកើតទុក្ខ ។

• ម្នាលភិក្ខុទាំងឡាយ បើគោទាំងឡាយកំពុងឆ្លងទៅ កាលបើគោមេហ្វូងនាំទៅកាន់ផ្លូវត្រង់ គោទាំងអស់នោះរមែងទៅកាន់ផ្លូវត្រង់ដែរ ។ មានឧបមា

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងណា ក្នុងពួកមនុស្សក៏ដូច្នោះដែរ ។ អ្នកណាដែលគេសន្មតថាប្រសើរជាងគេ ( ជាប្រមុខគេ ) បើអ្នកនោះប្រព្រឹត្តតាមធម៌ នឹងមិនបាច់និយាយទៅថ្វីដល់ប្រជាជនដទៃ។

• បើព្រះរាជាប្រកបដោយធម៌ រាស្ត្រទាំងអស់រមែងដេកនៅជាសុខ ។

នៅក្នុងព្រះសូត្រនេះ យើងឃើញថា ទំនាក់ទំនងរវាងរាស្ត្រនិងអ្នកដឹកនាំ ជាកត្តាកំណត់នូវជោគវាសនារបស់សង្គម ឬប្រទេស ។ បើរាស្ត្រជ្រើសរើសប្រមុខដែលល្អ ប្រមុខនោះក៏នឹងនាំទៅរកសេចក្តីសុខ ដែលជាគោលបំណងធំបំផុតរបស់រាស្ត្របាន តាមពុទ្ធវចនៈដែលថា « *បជាសុខំ មហុត្តមំ* = សេចក្តីសុខរបស់រាស្ត្រគឺជារបស់ដ៏មហាឧត្តម » តែបើប្រជារាស្ត្រជ្រើសរើសប្រមុខមិនល្អ ឬមានអ្នកដឹកនាំអធម៌ ( ឡើងកាន់អំណាចដោយកម្លាំងអាវុធជាដើម ) នោះ សេចក្តីទុក្ខក៏នឹងកើតឡើងដល់ប្រជារាស្ត្រខ្លួនឯងវិញ ជាមិនខាន ។




ដូច្នេះ ជាការសំខាន់ណាស់ ចំពោះប្រជារាស្ត្រដែលជាអ្នកដើរតាម ត្រូវសម្លឹងមើល ពិនិត្យពិច័យ ជ្រើសរើសយកតែអ្នកដឹកនាំដែលល្អ ដែលកាន់សីលធម៌ និងនាំទៅរកសេចក្តីសុខ ដែលជាគោលបំណងរបស់រាស្ត្រខ្លួនឯង ។

www.budinst.gov.kh www.elibraryofcambodia.org

# ២. ព្រះបាទធម្មិក

នៅពេលដែលគេកំពុងតែជួបនឹងសេចក្ដីទុក្ខ មនុស្សភាគច្រើនតែងតែនឹកសង្ឃឹមថា នឹងមានអ្នកណាមួយដែលពូកែមកជួយខ្លួនជាមិនខាន ជាឧទាហរណ៍ ក្នុងសាសនាព្រាហ្មណ៍ ពេលដែលពួកអសុរកម្រើកបះបោរ ពួកបរិស័ទព្រាហ្មណ៍តែងតែសង្ឃឹមថាព្រះពិស្ណុ និងអវតារចុះមកជួយជាមិនខាន ។

ពួកសាសនាយូដាយ តែងសង្ឃឹមថា នឹងមានម៉េសស៊ីអារ ដែលជាតំណាងព្រះយ៉េហូវ៉ា ចុះមកជួយខ្លួនជាមិនខាន ។ មុនពុទ្ធកាល ពេលដែលប្រជារាស្ត្រឥណ្ឌា កំពុងតែច្របល់ដោយជំនឿ និងទស្សនវិជ្ជា ដែលមិនអាចរកការពិត និងការរួចផុតពីទុក្ខបាននោះ គេក៏សង្ឃឹមថា នឹងមាន « *ពុទ្ធៈ* » គឺអ្នកត្រាស់ដឹងពិតមកបង្ហាញការពិត និងផ្លូវដែលនាំជីវិតឱ្យរួចពីសេចក្ដីទុក្ខ ។

ក្នុងប្រទេសខ្មែរយើង ការរងគ្រោះដោយសង្គ្រាមក្នុងស្រុក និងសង្គ្រាមលុកលុយជាញឹកញយ ចាប់តាំងពីអាណាចក្រអង្គរធ្លាក់រាប់ឱនមក បានធ្វើឱ្យខ្មែរយើងបង្កើតនូវសេចក្ដីសង្ឃឹមក្នុងចិត្ត និងប្រាប់ត១ដល់កូនចៅ ឱ្យបណ្ដុះនូវសេចក្ដីសង្ឃឹមនោះ កុំឱ្យដាច់ ។

សេចក្ដីសង្ឃឹមរបស់ខ្មែរ តាមការនិយាយត១គ្នា និងការមាននៅលើសាស្ត្រាស្លឹករឹត ដែលមានឈ្មោះថា « *ពុទ្ធទំនាយ* » នោះ គឺថា នឹងមាន «*ធម្មិក-រាជ*» ឬព្រះបាទធម្មិកមកកំចាត់ពួកអសុរនៅទន្លេបួនមុខ ហើយពេលនោះឯងដែលប្រទេសខ្មែរ នឹងមានសេចក្ដីសុខចំរើនជាងពេលណា១ ទាំងអស់ ។

បញ្ហាដែលចោទឡើង គឺថា នរណាជាធម្មិករាជ ឬព្រះបាទធម្មិក ធ្វើម្ដេចនឹងបានស្គាល់ព្រះបាទធម្មិក ព្រះបាទធម្មិកលោកមកជួយដូចម្ដេចខ្លះ និងពេលណាបានលោកមកដល់ ? ។ ជាពិសេស « ពេលណា » នេះឯង ដែលសំខាន់ ព្រោះខ្មែររង

www.budinst.gov.kh www.elibraryofcambodia.org

ទុក្ខវេទនាសឹងតែដល់ថ្នាក់ « ទ្រាំមិនបានទៀតទេ » ទៅហើយ ។

ព្រះបាទធម្មិកក្នុងទស្សនៈខ្មែរ ហាក់ដូចជាព្រះរាជាមួយអង្គ ដែលមានឫទ្ធានុភាព មន្តអាគមពូកែ ហោះហើរបាន ជាអ្នកពូកែចបាំង គ្រាន់តែមកដល់ ពួកបច្ចាមិត្តក៏ខ្លាចទៅហើយ ។ ក្នុងទីនេះ ខ្ញុំនឹងវិភាគពាក្យថា « *ធម្មិករាជ* » ក្នុងបរិបទព្រះពុទ្ធសាសនាតែប៉ុណ្ណោះ ព្រោះពាក្យនេះមានប្រើនៅក្នុងគម្ពីរព្រះពុទ្ធ-សាសនា ជាពិសេសនៅក្នុងព្រះសូត្រដែលនិយាយពីសារសំខាន់របស់អ្នកដឹកនាំ ដែលបានបង្ហាញរួចមកហើយ ។

**ធម្មិក** គឺអ្នកកាន់ធម៌ អ្នកមានធម៌ អ្នកប្រកបដោយធម៌ ។ ក្នុងចក្កវត្តិ-សូត្រ *ធម្មិក* ឬអ្នកកាន់ធម៌ មានលក្ខណៈ ២ យ៉ាងគឺ ៖

*១. ធម្មាធិបតេយ្យ ៖* គោរពរាប់អាន បូជា កោតក្រែងធម៌ យកធម៌ជាគោល យកធម៌ជាទង់ជ័យ ជាធម្មាធិបតេយ្យ ។

ក្នុងសៀវភៅឈ្មោះ ប្រជាធិបតេយ្យចាស់ទុំ របស់ព្រះភិក្ខុធម្មបាល ខៀវ ជុំ អ្នកប្រាជ្ញពុទ្ធសាសនាបែបនិយមការរីកចំរើន (Progressive) ក្នុងកំឡុងសម័យសាធារណរដ្ឋខ្មែរ បានពន្យល់ពាក្យធម្មាធិបតេយ្យថា « ដូចនេះ លទ្ធិធម្មា-ធិបតេយ្យ ដែលគេរកឃើញដោយព្រះសម្មាសម្ពុទ្ធ ហើយអនុវត្ត ឬប្រតិបត្តដោយប្រជាសត្វលោកនោះ » ។ ពាក្យនេះ បើនិយាយពីធម៌ ឬច្បាប់ ត្រូវឱ្យឈ្មោះថា " ធម្មាធិបតេយ្យ " បើនិយាយដល់អ្នករកឃើញ ឬអ្នកបង្កើតនូវធាតុនេះ ត្រូវឱ្យឈ្មោះថា " ប្រជាធិបតេយ្យ " ។

បើតាមការពន្យល់របស់ព្រះអង្គនេះ បរិបទនៃពាក្យធម្មាធិបតេយ្យ ក្នុងចក្កវត្តិសូត្រនេះ នឹងមានន័យថា " គោរពច្បាប់ មតិ សំឡេង ដែលប្រជារាស្ត្របាន

www.budinst.gov.kh www.elibraryofcambodia.org

សំរេចឱ្យអ្នកដឹកនាំធ្វើតាម គោរពរាប់អាន ឬជាលទ្ធិប្រជាធិបតេយ្យ ដែលមានរដ្ឋ-ធម្មនុញ្ញ តាក់តែងដោយប្រជារាស្ត្រ ៖ យកសំឡេង មតិ សេចក្តីសំរេចរបស់រាស្ត្រជាធំ " ។

*២. ធម្មិការក្ខាវរណគុបតិ* ៖ ចាត់ការរក្សាការពារ គ្រប់គ្រងប្រកបដោយធម៌ដល់មន្ត្រីរដ្ឋការ ទាហាន អាជីវករ ប្រជារាស្ត្រ ព្រះសង្ឃ សត្វព្រៃ ទាំងឡាយ និងការពារកំចាត់មិនឱ្យអធម៌ អំពើអមនុស្សធម៌កើតឡើងបាន ។

យោងតាមព្រះសូត្រនេះ ក្នុងទស្សនៈខ្ញុំ ពាក្យថា ធម្មិក ឬអ្នកមានធម៌ អ្នកកាន់ធម៌ គួរមានករណីយកិច្ច ៣ ប្រការ ៖

• *យកធម៌ ឬ ច្បាប់ជាធំ* ៖ គឺជាអ្នកដែលរស់នៅក្នុងច្បាប់ អនុវត្តច្បាប់ គោរពច្បាប់ មិនបំពាន ល្មើសច្បាប់ យកច្បាប់ជាជីវិតរបស់ខ្លួន ។ ក្នុងទីនេះ ច្បាប់បានដល់ច្បាប់រដ្ឋធម្មនុញ្ញ ដែលជាមេបទនៃច្បាប់ទាំងឡាយក្នុងប្រទេសនីមួយៗ ។

• *គោរពធម៌ ឬនាទីរបស់ខ្លួន* ក្នុងឋានៈជាអ្នកដឹកនាំ ជាប្រមុខរបស់ពួកជន ពោលគឺ ការគោរពភារកិច្ចដែលរាស្ត្រប្រគល់ឱ្យ បានដល់ការស្វែងរកសេចក្តីសុខឱ្យរាស្ត្រ និងសេចក្តីចំរើនដល់ប្រទេសជាតិ ។

• *តម្កល់ធម៌ជាគោលមាត្រដ្ឋាន* ៖ សំរាប់វាស់ច្បាប់ វាស់នាទី វាស់មធ្យោបាយ និងវាស់សេចក្តីសុខរបស់រាស្ត្រ ថាតើច្បាប់ នាទី មធ្យោបាយ និងសេចក្តីសុខទាំងនោះប្រកបដោយធម៌ តាមគន្លងធម៌ មានសីលធម៌ ជាកុសល ជាសេចក្តីល្អ ត្រឹមត្រូវតាមមនុស្សធម៌ តាមគោលសិទ្ធិមនុស្សឬទេ ។

ការគោរពទាំង ៣ យ៉ាងរបស់ធម្មិក មិនអាចញែកឱ្យដាច់ចេញពីគ្នាបានទេ លក្ខណៈនីមួយៗ ត្រូវពឹងលើលក្ខណៈមួយទៀត ដោយខានមិនបាន ។

www.budinst.gov.kh www.elibraryofcambodia.org




## ធម្មិកមកដល់ពេលណា ?

បញ្ហាដែលចោទចំពោះមុខសំរាប់ស្ថានការណ៍ខ្មែរ គឺធម្មិកមិនទាន់មកដល់ ។ តែបើតាមសេចក្ដីអត្ថាធិប្បាយនៃពាក្យធម្មិកនេះ យើងឃើញថា ការបង្កើតធម្មិក ជារឿងមួយអាចប្រព្រឹត្តទៅបាន បើធ្វើឥឡូវ ក៏នឹងកើតឥឡូវ ហើយមានចំនួនច្រើនទៀតផង ។ តែបញ្ហានៅត្រង់ថា សព្វថ្ងៃនេះ មិនមានអ្នកណាចង់ធ្វើធម្មិកសោះ មិនមាននរណាចង់បង្កើតធម្មិកឡើយ ដូច្នេះទើបបានជាធម្មិកមិនព្រមមកដល់ ហើយខ្មែរយើងក៏បានតែត្រឹមសង្ឃឹមបន្តទៅទៀត ។ ខ្មែរនឹងមានធម្មិក ខ្មែរនឹងទៅជាធម្មិក ប្រទេសខ្មែរនឹងបានសន្តិភាព ប្រជារាស្ត្រ នឹងដេកស្រួលជាសុខ បើសិនជាខ្មែរទាំងអស់គ្នាគោរពច្បាប់ ឬគោរពរាស្ត្រ គោរពនាទីខ្លួន និងគោរពធម៌ឥឡូវនេះ !

www.budinst.gov.kh www.elibraryofcambodia.org

# ៣. រហស្សគុណរបស់អ្នកដឹកនាំ

**ភាសា** គឺជាឧបករណ៍ សំរាប់ទាក់ទងគ្នាឱ្យដឹងន័យទៅវិញទៅមក ។ ក្នុងការប្រើភាសា អ្នកប្រើតែងបញ្ចូលន័យនៅក្នុងពាក្យដែលខ្លួនប្រើនោះហើយជាស្រេច យ៉ាងហោចណាស់ ក៏ដើម្បីឱ្យយល់ជាដំបូងភ្លាមដែរ ដើម្បីឱ្យការប្រើភាសានោះអាចបន្តទៅមុខទៀត មុននឹងពន្យល់ពាក្យ ១ ម៉ាត់ៗ នោះឱ្យបានពិស្តារ ។

ក្នុងភាសាខ្មែរយើង ដែលសឹងតែទាំងអស់បានទទួលឥទ្ធិពលពីភាសាបាលី និងសំស្ក្រឹតនោះ ក៏មានលក្ខណៈដូចគ្នានេះដែរ គឺពាក្យ ១ ម៉ាត់ៗដែលប្រើ តែងមានបង្កប់ន័យនៅក្នុងនោះស្រេច ជួនកាលជានាម ជាគុណនាម ជាកិរិយាស័ព្ទ ឬរួមទាំង ៣ នេះក៏មាន ព្រមទាំងពាក្យ១ ម៉ាត់នេះ អាចប្រែបានច្រើនន័យទៅទៀតផង ។ ដូច្នេះ ក្នុងការប្រើភាសា គប្បីរំលឹកដល់ន័យរបស់តួអក្សរសិន ដែលលោកហៅថា " ប្រែដោយព្យញ្ជនៈ " រួចសឹមពន្យល់ន័យរបស់ពាក្យនោះ ដែលលោកហៅថា " ប្រែដោយអត្ថៈ " ។ រឿងនេះក៏ដូចគ្នា សំរាប់អ្នកដែលប្រុង បញ្ញត្តស័ព្ទថ្មី១យកមកប្រើ គប្បីរំលឹកដល់គោលការណ៍នេះផង បើពុំដូច្នោះទេ អ្នកអានប្រាកដជាពុំអាចស្រាវជ្រាវរកការយល់បានឡើយ ។ ដែលលើកយករឿងនេះមកអធិប្បាយ ព្រោះយើងនឹងនាំគ្នាមើលទៅលើរហស្សគុណ ( គឺគុណលក្ខណៈដែលមាន តែគេមិនដឹង ) របស់ពាក្យដែលខ្មែរយើងប្រើ សំរាប់សំគាល់អ្នកដែលជាប្រធាន អ្នកដឹកនាំ នាយក ប្រមុខ រាជា មេ ។ល។ ថាតើមានគុណលក្ខណៈយ៉ាងដូចម្តេចខ្លះក្នុងពាក្យ ១ ម៉ាត់ៗ នោះ ទាំងសេចក្តីប្រែដោយព្យញ្ជនៈ និងប្រែដោយអត្ថន័យ ។

ពាក្យដែលរចនាករ នឹងលើកយកមកពិចារណាវែកញែកក្នុងទីនេះ មាន ៥ ម៉ាត់ គឺ : ១. អ្នកដឹកនាំ ២. ប្រធាន ៣. ប្រមុខ ៤. រាជា ៥. មេ ។

www.budinst.gov.kh www.elibraryofcambodia.org

ដែលលើកយកតែ ៥ នេះ ព្រោះជាពាក្យដែលយើងប្រើរាល់ថ្ងៃ ហើយទាំង ៥ នេះ ជារហស្សគុណដែលអ្នកដឹកនាំនីមួយៗ ត្រូវមានគ្រប់ទាំង ៥ ប្រភេទនៅក្នុងខ្លួន មិនអាចខ្វះណាមួយបានឡើយ ឧបមាដូចជាវិញ្ញាណយើងទាំង ៥ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត និងកាយ ដូច្នោះដែរ ដែលមិនអាចខ្វះណាមួយបាន ឬបើធៀបជារូបមនុស្សវិញ គឺមាន ក្បាល ១ ដៃ ២ និងជើង ២ ។




www.budinst.gov.kh www.elibraryofcambodia.org

# អ្នកដឹកនាំ ( នាយក )

ក្នុងភាសាខ្មែរយើង ពាក្យថាអ្នកដឹកនាំ សំដៅទៅលើអ្នកទទួលខុសត្រូវក្នុងកិច្ចការអ្វីមួយ ដែលមានគេឯងចាំទទួលបញ្ជា ចាំធ្វើតាមដើម្បីឆ្ពោះទៅរកគោលដៅណាមួយ ឬដើម្បីសំរេចកិច្ចការណាមួយឱ្យបានជោគជ័យ ។ ក្នុងទីនេះ ជាដំបូងយើងនឹងញែកពាក្យ " ដឹកនាំ " មកជាពាក្យពីរម៉ាត់ដែលដាច់ចេញពីគ្នា និងព្យាយាមផ្តល់នូវព្យញ្ជនន័យ ព្រមទាំងអត្ថន័យឱ្យដល់ពាក្យ តាមដែលអាចនឹងរកបានតាមសមគួរ ។

**• អ្នកដឹក :** ពាក្យថា *ដឹក* ជាកិរិយាស័ព្ទ ដែលមានន័យសំដៅដល់ការទាញនូវវត្ថុណាមួយ ឱ្យកម្រើកចេញផុតពីទីកន្លែងដើមមកតាមអ្នកដែលដឹក ។ ឧទាហរណ៍ : ដឹកដៃ គឺយកដៃទៅចាប់ដៃមនុស្សម្នាក់ទៀតឱ្យមកតាមខ្លួន, ដឹកគោ គឺយកដៃទៅកាន់ខ្សែគោដែលចងជាប់នឹងគោឱ្យមកតាមខ្លួនអ្នកដឹក, ដឹកឥវ៉ាន់ គឺការទាញរទេះដែលផ្ទុកឥវ៉ាន់ឱ្យមកតាមខ្លួនអ្នកដឹក ។ ល ។

ក្នុងន័យនេះ យើងអាចឃើញរូបភាពនៃការដឹក ដូចតទៅ :

- មានអ្នកដឹកមុខ ឬមានអ្នកនៅពីមុខ,
- មានអ្នកដែលត្រូវគេទាញឱ្យដើរតាម,
- មានឧបករណ៍សំរាប់ដឹក ដូចជា ដៃ ខ្សែ ឬរថយន្ត,
- មានគោលបំណង ឬទីណាមួយដែលត្រូវធ្វើដំណើរទៅ,
- អ្នកដើរមុខដឹងថាត្រូវទៅទីណា,
- អ្នកដើរក្រោយមិនដឹងថាត្រូវទៅទីណាទេ ចាំតែតាម ។

www.budinst.gov.kh www.elibraryofcambodia.org

## ចំពោះអ្នកដើរមុខ គប្បីដឹង

- គោលដៅដែលត្រូវទៅ,
- ផ្លូវដែលត្រូវទៅ,
- មធ្យោបាយដែលប្រើក្នុងការដឹក,
- ដឹករបៀបណា,
- សមត្ថភាពខ្លួនដឹករួចមិនរួច,
- របស់ដែលត្រូវដឹក តើមានលក្ខណៈយ៉ាងណា និងត្រូវទទួលខុសត្រូវ ក្នុងសុវត្ថិភាពរបស់វត្ថុដែលខ្លួនដឹក ។

• **អ្នកនាំ** ៖ ពាក្យថា *នាំ* ជាកិរិយាស័ព្ទ ដែលមានន័យស្រដៀងនឹងដឹកដែរ ខុសត្រង់ថាមិនបាច់ទៅរួស ឬដឹកផ្ទាល់ទេ គឺអាចដើរពីមុខ អាចគ្រាន់តែប្រាប់គេឱ្យធ្វើតាម ដោយមិនចាំបាច់យកដៃទៅចាប់ផ្ទាល់ អាចគ្រាន់តែពន្យល់ រួចហើយឱ្យគេធ្វើ គេដើរខ្លួនឯង ក៏បាន ។

## ក្នុងន័យនេះ អ្នកនាំគប្បីដឹង

- ស្គាល់ពីកិច្ចការដែលខ្លួនប្រុងនាំនោះឱ្យច្បាស់លាស់,
- ចេះពន្យល់ឱ្យគេធ្វើខ្លួនឯងបាន ។

ឯការទទួលខុសត្រូវ ពុំសូវធ្ងន់ដូចអ្នកដឹកទេ ព្រោះថា អ្នកដែលត្រូវគេនាំមានចំណង់ក្នុងការដើរ និងការទទួលខុសត្រូវខ្លួនឯងច្រើនជាង *ឧទាហរណ៍* ៖ នាំផ្លូវ អ្នកនាំដើរមុខ ឬប្រាប់ឱ្យដើរ, ឯអ្នកត្រូវគេនាំ បើដើរទៅធ្លាក់គន្លុក មិនអាចបន្ទោសអ្នកនាំទាំងស្រុងទេ ព្រោះយើងពុំបានប្រយ័ត្នខ្លួនឯងដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះ អ្នកដឹកនាំ តាមបរិបទនៃពាក្យដែលបានរៀបរាប់ហើយនេះ បានដល់អ្នកដែលមានតួនាទីដឹកអ្នកដែលមិនដឹងគោលដៅ និងនាំអ្នកមិនស្គាល់ផ្លូវឱ្យបានទៅដល់គោលដៅមួយដែលគេប្រាថ្នាដោយសុវត្ថិភាព ។

ក្នុងបាលិភាសា ពាក្យថា *នាយក* ប្រែថា *អ្នកនាំ* ឬ *អ្នកដឹក* ស្មើនឹងពាក្យខ្មែរតែម្តង ។

www.budinst.gov.kh www.elibraryofcambodia.org

# ប្រធាន

តាមឫសរបស់ស័ព្ទ *ប្រធាន* ជាភាសាសំស្រ្កឹត ឯភាសាបាលីប្រើជា *បធាន* ។ បធាន ឬប្រធាន ប្រែថា សេចក្ដីព្យាយាម ការខំប្រឹងប្រែង ការឧស្សាហ៍ ការសំភឹ ។ ក្នុងព្រះពុទ្ធសាសនា ប្រធាន ឬសេចក្ដីព្យាយាមនេះ មាន ៤ ប្រការគឺ ៖

១- សំវរបធាន *សេចក្ដីព្យាយាមប្រយ័ត្នការពារ* . មិនឱ្យអំពើបាប អំពើអកុសល អំពើអាក្រក់ បញ្ហានានា ដែលមិនទាន់កើត កុំឱ្យកើតឡើងបាន ។

២- បហានបធាន *សេចក្ដីព្យាយាមលះបង់* ឬកំចាត់បំផ្លាញអំពើបាប អកុសល អំពើអាក្រក់ និងបញ្ហានានាដែលកើតឡើងហើយ ឱ្យអស់ទៅវិញ ។

៣- ភាវនាបធាន *ព្យាយាមចំរើន* បង្កើតបង្កើននូវអំពើល្អ កុសល បុណ្យ សេចក្ដីសុខដែលមិនទាន់កើតមាន ឱ្យកើតមានឡើង ។

៤- អនុរក្ខនាបធាន *ព្យាយាមរក្សា* អភិរក្ស ការពារ គ្រប់គ្រង ថែទាំ កុសលធម៌ សេចក្ដីល្អ សេចក្ដីសុខ ដែលកើតឡើងហើយ ឬដែលកំពុងមាននោះ ឱ្យគង់វង្ស និងរីតតែចំរើនឡើងៗ ថែមទៀត ។

ពិនិត្យមើលទៅលើការប្រើពាក្យ *ប្រធាន* នេះ គឺសំរាប់សំគាល់អ្នកដែលធំលើសគេ ។ ដែលគួរហៅថាជាប្រធាននោះ ព្រោះត្រូវមានសេចក្ដីព្យាយាមទាំង ៤ យ៉ាងនេះ ជាលក្ខណៈសំគាល់ គឺព្យាយាមកុំឱ្យសេចក្ដីទុក្ខ និងបញ្ហាផ្សេងៗ កើតឡើងក្នុងសង្គមខ្លួន, ព្យាយាមកំចាត់នូវសេចក្ដីទុក្ខដែលសង្គមកំពុងជួបប្រទះ ឱ្យអស់ទៅ, ព្យាយាមបង្កើតរកសេចក្ដីសុខស្រួលឱ្យបានច្រើនជាទីបំផុតដល់សង្គម និងព្យាយាមថែរក្សា គ្រប់គ្រងកុំឱ្យសេចក្ដីសុខនោះបាត់បង់ទៅវិញ ។

ក្នុងសម័យបច្ចុប្បន្ននេះ យើងប្រើទាំងពាក្យប្រធាន និងប្រធានាធិបតី

www.budinst.gov.kh www.elibraryofcambodia.org

ដោយពាក្យប្រធានាធិបតី សំរាប់សំគាល់អ្នកដឹកនាំថ្នាក់កំពូលនៃប្រទេសណាមួយ ជាពិសេស ក្នុងរបបប្រជាធិបតេយ្យ ។ បើតាមន័យនេះ ប្រធានាធិបតី ប្រែថា ជាធំលើប្រធាន ឬប្រធានលើប្រធាន ។ បើយកជាន័យវិញ ប្រធានាធិបតី គឺអ្នកដែលមានសេចក្តីព្យាយាមក្នុងព្យាយាមទាំង ៤ ដ៏លើសលប់លើគេឯងទាំងអស់ ។

www.budinst.gov.kh www.elibraryofcambodia.org

# ប្រមុខ

ប្រមុខ ជាភាសាសំស្ក្រឹត បាលីប្រើជា បមុខ ប្រែថា *ដែលជាមុខ* ។ *មុខ* គឺជាប្រធាននៃសរីរប្រទេស គឺប៉ែករូបកាយត្រង់ទីប្រជុំនៃថ្ងាស ចិញ្ចើម ភ្នែក ច្រមុះ មាត់ ចង្កា ។ កន្លែងខ្លះលោកប្រែថា *មាត់* ។ មុខ គឺជាសរីរៈមួយដ៏សំខាន់ណាស់ ព្រោះជាទីប្រជុំនៃវិញ្ញាណដ៏សំខាន់ៗទាំងឡាយ គឺ ភ្នែក ត្រចៀក ច្រមុះ មាត់ និងជាពិសេស ខួរក្បាលដែលយើងតែងឱ្យសារសំខាន់ក្នុងការគិតនោះ ក៏នៅម្តុំមុខនេះដែរ ។ ជាទូទៅ បើមុខស្អាតល្អ យើងក៏ចូលចិត្តចង់នៅជាមួយ បើមិនស្អាតអាក្រក់ យើងក៏មិនចូលចិត្តចង់នៅជាមួយ ។ បើនិយាយឱ្យច្បាស់ថែមទៅទៀត មនុស្សយើងល្អ បានសុខ ឬអាក្រក់ បានទុក្ខ ក៏ព្រោះមុខនេះឯង ព្រោះថា ៖

• បើមាត់និយាយ តែពាក្យកុហក និយាយតែពាក្យអាក្រក់មិនគួរស្តាប់ និយាយតែពាក្យចាក់ដោតឱ្យបែកបាក់ ឈ្លោះប្រកែកគ្នា និងនិយាយពាក្យមិនបានការនោះ សេចក្តីទុក្ខក៏នឹងកើតមានដល់ជីវិតជននោះជាមិនខាន ដូចសុភាសិតពោលថា *« អណ្តាតជាអាទីកន្លង ស្លាប់ផង រស់ផង ក៏ព្រោះអណ្តាត»* ឬ*« ត្រីកំភ្លាញស្លាប់ ព្រោះមាត់ »* ជាដើម ។

• បើភ្នែកខ្វាក់ ភ្នែកអានអក្សរមិនដាច់ ភ្នែកមិនចេះមើល ភ្នែកមើលឃើញតែរឿងថោកទាប រឿងមិនបានការ ក្រឡឹតក្រឡាប់ៗនោះ ជីវិតនោះក៏នឹងកើតទុក្ខ ជួបបញ្ហាជាមិនខាន ។ ខ្មែរយើងតែងនិយាយថា *« អញមើលភ្នែកវាក្រឡឹតក្រឡាប់ៗ ដូចជាមិនទុកចិត្តសោះ ឬ ភ្នែកមើលតែចោរ »* គឺសំគាល់លក្ខណៈមនុស្សបាននៅលើភ្នែក ។

• បើច្រមុះហិតក្លិនអាភៀន ក្លិនស្រា ច្រមុះដកដង្ហើមមិនរួច ក៏នឹងអាច

www.budinst.gov.kh www.elibraryofcambodia.org

អាចធ្វើឱ្យខូចសុខភាព និងប៉ះពាល់ដល់ជីវិតជាមិនខាន ។

• បើត្រចៀកស្ដាប់ដំណឹងមិនពិត ស្ដាប់ពាក្យអាក្រក់ ពាក្យញុះញង់ ពាក្យមិនបានការ ជីវិតនេះក៏នឹងកើតទុក្ខទៀត ។

• បើខួរក្បាលពិការ គ្មានសមត្ថភាព គ្មានគុណភាព ល្ងង់ ល្ងីល្ងើ មិនចេះពិចារណានោះ បានសេចក្ដីថា ជីវិតនោះអស់ខ្លឹមសាររលីង ។

ឃើញសារសំខាន់មុខដូច្នេះឯង ទើបបានជាលោកប្រើពាក្យប្រមុខនេះ សំរាប់សំគាល់ហៅអ្នកដឹកនាំសង្គម ព្រោះថា ប្រជារាស្ត្រទុកចិត្ត ផ្ដល់អំណាចឱ្យអ្នកដឹកនាំនោះគិត និយាយ មើល ស្ដាប់ នូវកិច្ចការទាំងពួងជំនួសប្រជារាស្ត្រ ព្រមទាំងដកដង្ហើម និងបរិភោគនូវប្រយោជន៍ទាំងឡាយឱ្យដល់ប្រជារាស្ត្រ ។

ខ្មែរយើងតែងនិយាយថា « *ខ្ញុំយកលោកជាត្រីមុខ* » ពាក្យនេះ បើតាម ខ្ញុំអាចយល់បាន គង់នឹងមានន័យថា « *ខ្ញុំយកលោកជាតំណាងក្នុងការមើល ស្ដាប់ និងនិយាយជំនួសនេះឯង* » ។

ដូច្នេះ យើងឃើញថា ពាក្យថាប្រមុខនេះ មានសារសំខាន់ណាស់សំរាប់សេចក្ដីសុខ និងសេចក្ដីទុក្ខរបស់សង្គម ។ ប្រមុខរដ្ឋ គឺមុខរបស់រដ្ឋ បានដល់អ្នកដឹកនាំកំពូលរបស់រដ្ឋនីមួយៗ ជាពិសេសក្នុងប្រទេសខ្មែរ ក្នុងសម័យសម្ដេចព្រះនរោត្តម សីហនុ ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

# រាជា

« *ពេញចិត្តហើយ ពេញចិត្តហើយ* » នេះជាសម្រែកជ័យឃោសន៍របស់ប្រជារាស្ត្របន្លឺឡើងចំពោះអ្នកដឹកនាំរបស់ខ្លួន ដែលបានបំពេញប្រយោជន៍ឱ្យដល់អ្នកដើរតាម រហូតដល់អ្នកដើរតាម ឬប្រជារាស្ត្រទទួលស្គាល់ថា កិច្ចការដែលសំរេចនោះពេញចិត្តគេហើយ ។

ក្នុងភាសាបាលី ពាក្យថា « *រាជា* » មានអត្ថន័យពីរយ៉ាង គឺប្រែថា « *ពេញចិត្ត* » បានដល់អាការៈដែលពេញចិត្តចំពោះរឿងអ្វីមួយផង និងបានដល់បុគ្គលដែលគេតាំងទុកឱ្យធ្វើជា « *ប្រមុខ* » សំរាប់ដឹកនាំប្រជារាស្ត្រផង ។

ដូច្នេះ រាជា ឬដែលយើងតែងហៅថា ព្រះរាជា ឬស្តេចនេះ គឺបុគ្គលណានីមួយដែលគ្រប់គ្រង ដឹកនាំប្រជារាស្ត្រដោយត្រឹមត្រូវតាមធម៌ រហូតដល់ប្រជារាស្ត្ររបស់ខ្លួនចេញជាប្រជាមតិថា ការដឹកនាំនេះពេញចិត្តហើយ ត្រឹមត្រូវទៅតាមសេចក្តីប្រាថ្នារបស់ប្រជារាស្ត្រហើយ ។

យើងគប្បីទទួលស្គាល់ថា ការគ្រប់គ្រង ដឹកនាំប្រទេសជាតិ ឬសង្គមណាមួយ រហូតដល់ប្រជារាស្ត្រក្នុងប្រទេស ឬសង្គមនោះស្រែក ឬឆ្លើយថា ពេញចិត្តហើយទាំងអស់គ្នានោះ ពិតជារឿងដែលមិនអាចប្រព្រឹត្តទៅបានឡើយ ។ ក្នុងលក្ខណៈដែលមិនអាចប្រព្រឹត្តទៅបានដូច្នេះ ការយកសំឡេងភាគច្រើនលើសលប់ទើបជាការមួយដែលគេនិយមយកជាមាត្រដ្ឋាន សំរាប់វាស់នូវការពេញចិត្តនោះ ។ ក្នុងព្រះពុទ្ធសាសនា មានវចនៈដែលនិយាយអំពីមាត្រដ្ឋានសំរាប់វាស់នេះបីយ៉ាង គឺ :

- *អត្តាធិបតេយ្យ* គឺការយកការយល់ឃើញរបស់ខ្លួនជារង្វាស់,
- *លោកាធិបតេយ្យ* គឺការយកលោក ឬប្រជាជនជារង្វាស់,
- *ធម្មាធិបតេយ្យ* ការយកធម៌ យកច្បាប់ យកភាពត្រឹមត្រូវជារង្វាស់ ។

www.budinst.gov.kh www.elibraryofcambodia.org

អ្នកអានគង់នឹងយល់ព្រមជាមួយខ្ញុំជាមិនខានថា ការយកបុគ្គលម្នាក់ជារង្វាស់នោះ មិនអាចត្រឹមត្រូវ និងធានាដល់សុវត្ថិភាពរបស់ប្រទេសជាតិបានឡើយ តែការយកសំឡេងប្រជាជន និងសំឡេងច្បាប់ ភាពត្រឹមត្រូវជារង្វាស់នេះ ប្រាកដជាទទួលការយល់ព្រមពីប្រជារាស្ត្រមិនខាន ។

www.budinst.gov.kh www.elibraryofcambodia.org

# មេ

តាមប្រវត្តិសាស្ត្រក្នុងដើមសតវត្សទី១ នៃគ.ស អាណាចក្រកម្ពុជា គ្រប់គ្រងដោយម្ចាស់ក្សត្រិយ៍ ១ ព្រះអង្គ ព្រះនាមថា « *សោមា* » ឬតាមភាសាចិន ហៅថា « *លិវយី* » ។ ដោយសារការមានស្រីជាធំលើគេនៅក្នុងប្រទេសដូច្នេះ ហើយបានជា យើងឃើញថា វប្បធម៌ខ្មែរយើង មានលក្ខណៈពិសេសផ្ទាល់ខ្លួន ខុសពីវប្បធម៌ឥណ្ឌា និងចិន ដែលចូលមកតាមក្រោយ ។ វប្បធម៌ខ្មែរយើង ជាវប្បធម៌មាតាធិបតេយ្យ គឺយកមាតា ឬស្រីជាធំ ឯវប្បធម៌ឥណ្ឌា និងចិន ជាវប្បធម៌បិតា-ធិបតេយ្យ គឺយកប្រុស ឬបិតាជាធំ ។

ភស្តុតាងនៃឥទ្ធិពលមាតាធិបតេយ្យ ដែលឃើញច្បាស់នាបច្ចុប្បន្ន គឺពាក្យថា « មេ » ។ ក្នុងភាសាខ្មែរ មេ សំដៅដល់ភេទញី ភេទស្រី ដូចជា មាន់មេ គោមេ ជាដើម ។ ការឱ្យតម្លៃទៅលើស្រីជាធំ បានធ្វើឱ្យពាក្យ មេ នេះ ត្រូវខ្មែរយើងយកទៅដាក់នាំមុខពាក្យដទៃទៀត កាលណាគេចង់បញ្ជាក់ថារបស់នោះធំ ដើមចម ប្រធាន អ្នកដឹកនាំ ។ ល ។ ដូចជាពាក្យថា ៖ មេដឹកនាំ មេចោរ មេទ័ព មេជើង មេសោរ មេដំបូល មេភ្លើង មេខ្លូច រើសយកអាណាមេ១ ... ជាដើម ។ ថ្វីដ្បិតរបស់នោះគ្មានភេទ ឬជាភេទឈ្មោល ភេទប្រុសក្ដី ក៏គេយកពាក្យ មេ ដាក់ពីមុខដែរ ។

នៅក្នុងស្ថាប័នពុទ្ធសាសនា ភិក្ខុដែលទទួលនាទីជាអ្នកគ្រប់គ្រងវត្ត ក៏ត្រូវខ្មែរយើងហៅថាមេដែរ គឺ លោកគ្រូមេវត្ត ដែលអាចមានន័យថា អ្នកដឹកនាំវត្ត ប្រធានវត្ត នាយកវត្ត មាតាវត្ត ក៏បាន ។ ដែលលើកយកពាក្យមេនេះមកអធិប្បាយ ក៏ព្រោះចង់យកពាក្យលោកគ្រូមេវត្តនេះ មកធ្វើការវែកញែកស្រង់យកជាប្រ-យោជន៍សំរាប់ការដឹកនាំទូទៅ ពីព្រោះ ព្រះសម្មាសម្ពុទ្ធលោកបានសំដែងពីលក្ខណៈ

www.budinst.gov.kh www.elibraryofcambodia.org

របស់មេវត្ត ដែលជាទីកោតសរសើររបស់កូនវត្តទុកឱ្យ ដោយមានខ្លឹមសារជាខ្លាំង ។ ប្រៀបធៀបនឹងផ្លូវលោក ស្ថាប័នវត្តមានលក្ខណៈដូចជាសង្គមមួយដ៏បរិបូណ៌ និងជាសង្គមដែលព្រះសម្មាសម្ពុទ្ធតាំងឡើងជាគម្រូសំរាប់សង្គមទូទៅ ។ ការគ្រប់គ្រងក្នុងវត្ត ជាការគ្រប់គ្រងបែបសង្ឃាធិបតេយ្យ និងធម្មាធិបតេយ្យ ដែលការគ្រប់គ្រងបែបនេះ យើងឃើញមានប្រើនៅក្នុងផ្នែកអាណាចក្រដែរ ដែលយើងស្គាល់នៅក្នុងនាមថា *ប្រជាធិបតេយ្យ* ។

ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រកាសនូវលក្ខណៈ ១០ យ៉ាង របស់ភិក្ខុសង្ឃដែលគួរនឹងធ្វើជាមេវត្ត ឬជាអ្នកគ្រប់គ្រងវត្ត ដែលយើងអាចយកមកប្រើបានក្នុងការរៀបចំខ្លួនយើងឱ្យទៅជាមេដឹកនាំល្អ និងទុកជាគតិសំរាប់ឱ្យប្រជាពលរដ្ឋជ្រើសរើសយកបេក្ខជន ដែលមានលក្ខណៈបែបនេះយកមកធ្វើជាមេដឹកនាំខ្លួន ។

លក្ខណៈរបស់មេ ឬរបស់ព្រះថេរៈរបស់ព្រះសម្មាសម្ពុទ្ធទាំង ១០ យ៉ាងនោះ គឺ :

*១. ថេរោ រតញ្ញូ* : ជាមនុស្សពេញវ័យ បួសបានយូរ ដឹងកិច្ចការចាំរឿងរ៉ាវបានច្រើន ។ អនុវត្តក្នុងការគ្រប់គ្រងផ្នែកឃរាវាស អ្នកដឹកនាំគួរជាមនុស្សដែលមានវ័យច្រើន មានការពិសោធន៍ក្នុងកិច្ចការយូរ ចេះចាំរឿងរ៉ាវផ្សេងៗច្រើន ដឹងការរាក់ជ្រៅ ធ្លាប់ឆ្លងកាត់បទរៀនជីវិត និងការងារយូរមកហើយ ចេះអត់ធ្មត់មិនឈោមរាវដូចកូនក្មេង ។

*២. សីលវា* : មានសីល ប្រព្រឹត្តត្រឹមត្រូវតាមសិក្ខាបទទាំងឡាយ ។ ក្នុងអាណាចក្រ បានដល់ការគោរពតាមច្បាប់ តាមវិន័យ បទបញ្ញត្តិផ្សេងៗ មានច្បាប់រដ្ឋធម្មនុញ្ញជាដើមជម មិនព្រមប្រព្រឹត្តល្មើសច្បាប់ និងមានព្រឹត្តិកម្មខាងកាយវាចាល្អប្រពៃ មិនមានស្លាកស្នាមខាងអំពើទុច្ចរិត ។

*៣. ពហុស្សុតោ* : ជាអ្នកចេះច្រើន មានចំណេះវិជ្ជាខ្ពស់ និងទូលំ-

www.budinst.gov.kh www.elibraryofcambodia.org

ទូលាយ ស្គាល់បញ្ហា ស្គាល់សេចក្ដីត្រូវការរបស់សង្គមដែលខ្លួនគ្រប់គ្រង និងឆ្លៀវឆ្លាតក្នុងការដោះបញ្ហាទាំងនោះ ។ បើជាភិក្ខុសង្ឃ គឺអង្គដែលទ្រទ្រង់នូវព្រះត្រៃបិដក ។

*៤. ស្វាគតបាដិមោក្ខោ* : ទ្រទ្រង់បាដិមោក្ខ ដឹងគោលព្រះវិន័យចំពោះអ្នកគ្រប់គ្រងប្រទេស គឺដឹងពីគោលច្បាប់ គោលវិន័យ ទាំងច្បាប់គ្រប់គ្រងប្រទេស គឺច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ជាតិ អន្តរជាតិទាំងឡាយ រួមទាំងពួកសន្ធិ-សញ្ញា កតិកាផ្សេងៗ ដែលទាក់ទងនឹងរឿងនយោបាយ សង្គ្រាម សេដ្ឋកិច្ច សង្គម-កិច្ច វប្បធម៌ ... ។ ល ។ តាមបច្ចុប្បន្ននេះ គេច្រើនហៅថាជានីតិបណ្ឌិត ។

*៥. អធិករណសមុប្បាទវូបសមកុសលោ* : ជាអ្នកវៃឆ្លាត ពូកែក្នុងការរំងាប់អធិករណ៍ ជម្លោះ ការទាស់ទែងគ្នាក្នុងសង្គម ដូចជាទំនាស់រវាងនាយទុន និងកម្មករ រដ្ឋ និងរាស្ត្រ ទំនាស់រវាងបក្សផ្សេងៗ ទំនាស់ខាងផ្នែកសេដ្ឋកិច្ច ខាងសង្គ្រាម ជាដើម ដែលកើតឡើង ឱ្យរលត់បាត់ទៅវិញបាន និងបានសេចក្ដីសប្បាយរីករាយ ទាំងសងខាង ទាំងប្រកបដោយគតិយុត្តិធម៌ ។

*៦. ធម្មកាមោ* : ជាអ្នកស្រឡាញ់ធម៌ គោរពធម៌ យកធម៌ជាធំ លើកតម្កើងធម៌ ស្រឡាញ់ការចេះដឹង ស្រឡាញ់ការពិត ចេះស្ដាប់ ចេះនិយាយ ចេះពិភាក្សា ធ្វើខ្លួនឱ្យគេសរសើរ ចង់ចូលជិតដើម្បីប្រឹក្សា សន្ទនា និងចូលចិត្តសិក្សារៀនសូត្រនូវគោលការណ៍ច្បាប់ទម្លាប់ដែលជ្រៅៗ ថែមទៀត ។

*៧. សន្តុដ្ឋោ* : ជាអ្នកសន្ដោសដោយបច្ច័យ ៤ តាមមាន តាមបាន មិនលោភលន់ មិនខ្នះខ្នែង មិនចង់បានឱ្យហួសឋានៈខ្លួន រស់នៅតាមបែបធម្មតាៗ មិនហ៊ឺហា ស៊ីវិល័យហួសពីអ្វីដែលខ្លួន ដែលប្រទេសខ្លួនកំពុងមាន ។

*៨. ឈានលាភី* : ស្ទាត់ជំនាញក្នុងឈានទាំង ៤ ដែលជាវិហារធម៌សំរាប់បព្វជិតរស់នៅដោយសុខសប្បាយនាបច្ចុប្បន្ន ។ ចំពោះមេដឹកនាំផ្លូវលោកវិញ

www.budinst.gov.kh www.elibraryofcambodia.org

បានដល់អ្នកដែលមានសុខភាពចិត្តល្អបរិបូណ៌ មិនងាយខឹង ងាយក្រោធ សប្បាយចិត្ត សុខចិត្តជានិច្ច ចិត្តមិនមួហ្មង តក់ស្លុត ទោះជាមានហេតុការណ៍អ្វីៗកើតឡើងក៏ដោយ ចិត្តរឹងប៉ឹង ក្លាហាន នឹងធឹង ប្រកបដោយសតិសម្បជញ្ញៈ ។

៩. *បាសាទិកោ* មានកិរិយាមារយាទគួរឱ្យជ្រះថ្លា ដឹងពិធីការ ដឹងសុជីវៈធម៌ក្នុងសង្គម មិនឆ្គង មិនឈ្លើយ ។

១០. *អនាសវចេតោវិមុត្តិបញ្ញាវិមុត្តិ* ៖ ចំពោះភិក្ខុសង្ឃ បានដល់ភិក្ខុដែលអស់នូវអាសវក្កិលេស សំរេចជាព្រះអរហន្ត ។ ក្នុងន័យដែលអាចអនុវត្តបានចំពោះអ្នកដឹកនាំ គឺការដែលមានបញ្ញា ឃើញនូវសភាពពិតរបស់ធម្មជាតិ និងការគ្រប់គ្រងខ្លួន មិនជាប់ជំពាក់ដោយលោកធម៌ទាំង ៨ គឺ មិនញាប់ញ័រពេលមានគេសរសើរ, និន្ទា, បានលាភ, ខូចខាតលាភ, បានយសសក្តិឋានៈ, បាត់យសសក្តិឋានៈ, បានសុខ, និងបានទុក្ខ តែដាក់ចិត្តជាកណ្តាល ពិចារណាទៅតាមកម្មផល ហេតុផល គិតតែបំពេញនាទីរបស់ខ្លួនយ៉ាងណាកុំឱ្យខុសនឹងធម៌ ។ អ្នកដឹកនាំបែបនេះ មានទឹកមុខញញឹម គេងលក់ជានិច្ច ទោះជាហេតុការណ៍អាក្រក់កើតឡើងក៏ដោយ ។ តែមិនមែនមានន័យថា ញញឹមហើយមិនដោះស្រាយបញ្ហានោះទេ គឺថា មេត្តា ករុណា មុទិតា ឧបេក្ខា នៅមានជាប់ជានិច្ច ។

ទាំង ១០ យ៉ាង ដែលអធិប្បាយដោយសង្ខេបមកនេះ គឺជាលក្ខណៈរបស់ « *មេ* » ដែលយើងជាពុទ្ធបរិស័ទអាចរៀន ធ្វើតាមបាន ព្រោះមិនមែនជារបស់ដែលត្រឹមតែជាទ្រឹស្តី ឥតមាននរណាអនុវត្តនោះឡើយ ព្រះអរហន្ត និងព្រះសង្ឃ ទាំងឡាយ លោកបានធ្វើជាមេដឹកនាំខាងផ្នែកចិត្ត វិញ្ញាណ ជាង ២៥០០ ឆ្នាំ ប្រកបដោយជោគជ័យរួចហើយ ។

សង្ឃឹមថា អ្នកដឹកនាំខ្មែរទាំងឡាយ នឹងធ្វើខ្លួនឱ្យទៅជាមេគេបានដ៏ល្អប្រសើរឡើងជាលំដាប់ តាមការអនុវត្តន៍នូវថេរធម៌ទាំង ១០ ប្រការនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

# ៤. គុណសម្បត្តិរបស់អ្នកដឹកនាំ

ពាក្យខ្មែរយើងតែងនិយាយថា « *ឃ្វាលគោ ១០០ ក្បាល មិនលំបាកស្មើនឹងមើលមនុស្ស ១០ នាក់ទេ* » ។ ពាក្យនេះពិតណាស់ ព្រោះមនុស្សមានព្រឹត្តិកម្មប្លែកៗគ្នា មានធម្មសញ្ញា មិនមែនដូចសត្វដែលមានតែមនោសញ្ចេតនាញាណនោះទេ ។ ដូច្នេះ ទំរាំនឹងគ្រប់គ្រង ដឹកនាំមនុស្សមួយរយ មួយពាន់ មួយលាន ឬ ១០ លាន អ្នកនោះរឹតតែជាការពិបាក និង ស្មុគស្មាញកាន់តែខ្លាំងឡើង ជាមិនខាន ។ ការណ៍នេះ គឺទាមទារតម្រូវអ្នកដឹកនាំណាដែលមានគុណសម្បត្តិគ្រប់គ្រាន់តែប៉ុណ្ណោះ ទើបអាចនាំទៅរកជោគជ័យបាន ។

គុណសម្បត្តិល្អរបស់អ្នកដឹកនាំ តាមទស្សនៈព្រះពុទ្ធសាសនា គឺអ្នកដឹកនាំណាដែលមានសុខភាព សមត្ថភាព និង គុណធម៌គ្រប់គ្រាន់ ដើម្បីនឹងបំពេញនាទីរបស់ខ្លួនក្នុងឋានៈជាធម្មិកឱ្យបានល្អ ។




www.budinst.gov.kh www.elibraryofcambodia.org

# គុណសម្បត្តិទី ១
# សុខភាព

« *អរោគ្យា បរមា លាភា* ការមិនមានរោគ គឺជាលាភដ៏ធំបំផុត » នេះគឺភាសិតរបស់ព្រះពុទ្ធបរមគ្រូ សរសើរពីការមានសុខភាពល្អ ឬការមិនមានរោគ ។

អ្នកដឹកនាំ មិនគប្បីមើលរំលងនូវសុខភាពរបស់ខ្លួនឱ្យសោះ ក៏ដូចជាប្រជារាស្ត្រដែលមិនគួររើសមនុស្សដែលមានរោគ ឬសុខភាពមិនល្អយកមកដឹកនាំខ្លួនឡើយ ។

លក្ខណៈរបស់ការមានសុខភាពល្អ ដូចជា ៖

- ជាបុរស ឬស្ត្រីពេញលក្ខណៈ,
- រាងកាយមិនពិកលពិការ មិនដាច់ដៃដាច់ជើង វិញ្ញាណទាំង ៥ គឺ ៖ ភ្នែក ត្រចៀក ច្រមុះ មាត់ រាងកាយ ប្រើការបានល្អ,
- ជាមនុស្សមិនជរាពេក,
- ជាមនុស្សមិនវិកលចរិត មិនខូចសរសៃប្រសាទ,
- ធន់នឹងជំងឺ គឺមិនងាយឈឺផ្ដេសផ្ដាស,
- មិនមានរោគធ្ងន់ ឬសាហាវណាមួយបៀតបៀន,
- ជាមនុស្សមានអនាម័យ មិនស្មោកគ្រោក ចំរេះ,

បើសិនជាមានជំងឺមកបៀតបៀន ត្រូវប្រញាប់ព្យាបាលឱ្យបានឆាប់រួសរាន់ ព្រោះថា ការបណ្ដែតបណ្ដោយជំងឺតិចតួចថ្ងៃនេះ អាចនឹងឱ្យឈឺធ្ងន់ថ្ងៃស្អែក ដែលរឹតតែឱ្យខូចការកាន់តែច្រើន ។ នៅសហរដ្ឋអាមេរិក កាលពីប្រធានាធិបតីរ៉ូណាល់រេហ្គិន មានជំងឺធ្ងន់ ត្រូវវះកាត់ គេឃើញថា លុយដុល្លារដែលជារូបិយប័ណ្ណ

www.budinst.gov.kh www.elibraryofcambodia.org

គោលនៃសេដ្ឋកិច្ចពិភពលោក ចុះថោកភ្លាមមួយរំពេច ឬដូចក្នុងករណីប្រទេសថៃ កាលណាព្រះមហាក្សត្រិយ៍ទ្រង់ប្រឈួន ប្រជាជនថៃមានការព្រួយបារម្ភជាខ្លាំង ព្រោះខ្លាចកើតមានវឹកវរនៅក្នុងប្រទេសជាដើម ។ ក្នុងករណីប្រទេសខ្មែរ ជំងឺរបស់លោកសេនាប្រមុខ លន់ នល់ ជាបច្ច័យមួយយ៉ាងធំផងដែរ ក្នុងការធ្លាក់ចុះនៃប្រ- ទេសខ្មែរ ព្រោះលោក លន់ នល់ មិនអាចមានសមត្ថភាពបញ្ញា និងដឹកនាំប្រទេសឱ្យបានជិតដល់ ។

សុខភាពរបស់មនុស្សមានពីរយ៉ាង *គឺសុខភាពផ្លូវកាយ និង សុខភាពផ្លូវចិត្ត* ។ សុខភាពផ្លូវចិត្ត នឹងអធិប្បាយនៅឯវគ្គដែលនិយាយពីគុណធម៌ ទីនេះគ្រាន់តែចង់ជម្រាបថា សុខភាពកាយ និងសុខភាពចិត្តនេះ មានទំនាក់ទំនងនឹងគ្នា និងមានផលប៉ះទង្គិចដល់គ្នានឹងគ្នាណាស់ ។ កាលណាកាយមានជំងឺ ក៏នឹងធ្វើឱ្យចិត្តតប់ប្រម៉ល់ឈឺទៅផងដែរ ហើយបើចិត្តតប់ប្រម៉ល់យូរពេកទៅ ក៏នឹងនាំឱ្យរាងកាយឈឺទៅជាមួយផង ។ ដូចជាការដែលគិតច្រើនពេក ពិបាកចិត្តច្រើនពេក នឹងនាំឱ្យចុកដៃចុកជើង ដង្ហើមរកស្ទះៗ គ្មានកម្លាំងកំហែង ខូចក្រពះ ។ល។

អ្នកដឹកនាំត្រូវប្រុងប្រយ័ត្នពីរឿងសុខភាពឱ្យបានល្អជានិច្ច ។ ពាក្យចាស់ពោលថា « *ក្រៗចុះ កុំឱ្យតែឈឺ* » ព្រោះថាបើមិនឈឺ យើងអាចធ្វើការរកលុយបាន ថ្ងៃណាមួយនឹងឈប់ក្រជាមិនខាន តែកាលណាឈឺ យើងនឹងមិនអាចទៅធ្វើការបានឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

# វិធីថែរក្សាសុខភាព : ថ្នាំអាយុវឌ្ឍនៈ ៧ យ៉ាង

អាយុវឌ្ឍនធម៌ គឺវិធីចម្រើនអាយុឱ្យវែង ថែរក្សាសុខភាពឱ្យបានមាំមួន ដែលព្រះសម្មាសម្ពុទ្ធលោកប្រើដើម្បីរក្សាសុខភាពព្រះអង្គ សំរាប់ព្រះភារកិច្ចដ៏ធ្ងន់ធ្ងរជារៀងរាល់ថ្ងៃ អស់រយៈពេល ៤៥ ព្រះវស្សា ។ ដោយសារអាយុវឌ្ឍនធម៌នេះឯង ទើបព្រះអង្គអាចតម្រង់ព្រះជន្មបានរហូតដល់៨០វស្សា ទើបចូលបរិនិព្វាន ។

*១. សប្បាយការី* : ចេះធ្វើសេចក្តីសប្បាយឱ្យដល់ខ្លួនឯង គឺ អនុវត្តទៅតាមក្បួនអនាម័យ និងក្បួនសុខភាព ។ ដូចជាឥរិយាបថទាំង ៤ គឺ ដេក ដើរ ឈរ អង្គុយ ត្រូវផ្លាស់ប្តូរឱ្យបានសមរម្យ មានការហាត់ប្រាណបញ្ចេញកម្លាំង សំអាតខ្លួនប្រាណ ។ ល ។ ជាដើម ។

*២. សប្បាយេ មត្តញ្ញូ* : មានប្រមាណ ស្គាល់ល្មម ស្គាល់ប្រមាណនៅក្នុងរបស់សប្បាយទាំងឡាយ ដូចជាមិនបរិភោគរហូតដល់ទៅហាល់ មើលសម្លឹងទូរទស្សន៍ រហូតដល់ទៅព្រិលភ្នែក ហៀរទឹកភ្នែក ផឹករហូតដល់គ្រើចេញមកវិញ ។ ម្យ៉ាងទៀត គឺចេះជ្រើសរើសរបស់ណាដែលមិនហុចទោស យកមកបំរើសេចក្តីសប្បាយរបស់ខ្លួន ដូចជាស្រា បារី កញ្ឆា ជាដើមនេះ សុទ្ធតែជារបស់ដែលនាំឱ្យទោស អ្នកសប្បាយត្រូវចេះស្គាល់ប្រមាណក្នុងការជ្រើសរើសរបស់ទាំងនេះ មកប្រើផងដែរ ។

*៣. បរិណតភោជី* : បរិភោគតែអាហារណាដែលរលាយ ងាយក្រពះស្រួលកិន មិននាំឱ្យខូចក្រពះ និងទំពារឱ្យបានម៉ដ្ឋល្អ ។

*៤. កាលចារី* : ស្គាល់ពេលវេលាក្នុងការធ្វើការ ធ្វើត្រូវសមពេលធ្វើ មានពេល មានវេលា ស្គាល់ថាគួរធ្វើការប៉ុន្មានម៉ោង សំរាកកាយប៉ុន្មានម៉ោង រៀន

www.budinst.gov.kh www.elibraryofcambodia.org

ស្ងួតប៉ុន្មានម៉ោង ជាដើម ។

*៥. ព្រហ្មចារី* ៖ ប្រព្រឹត្តព្រហ្មចរិយធម៌ អ្នកដែលជាគ្រហស្ថ ត្រូវចេះកំណត់កាមារម្មណ៍របស់ខ្លួន ត្រូវវៀរចាកនូវការសេពសន្ថវៈខ្លះ ព្រោះអ្នកល្មោភក្នុងកាមគុណពេក នឹងនាំឱ្យបាក់កម្លាំង ។

*៦. សីលវា* ៖ មានសីល ប្រព្រឹត្តល្អ មិនធ្វើអ្វីដែលខុស ។

*៧. កល្យាណមិត្ត* ៖ មានកល្យាណមិត្ត មិត្តល្អ មិត្តដែលមិនបបួលទៅរកអបាយមុខទាំង ៤ គឺ ស្រី ស្រា ល្បែង អំពើពាលា ។

ក្រៅពីអាយុវឌ្ឍនធម៌នេះហើយ ខ្មែរយើងក៏តែងទទួលមានថ្នាំប៉ូវ ថ្នាំកម្លាំង ថ្នាំស្រលខ្លួន ថ្នាំដើរខ្យល់ ថ្នាំបាយបានជាដើម ថែមទៀត ។ គោលបំណងនៃការប្រើថ្នាំ ដើម្បីឱ្យមានសុខភាពល្អ តែប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

# គុណសម្បត្តិទី ២

# សមត្ថភាព

**សមត្ថភាព** គឺភាពដែលអាចបំពេញកិច្ចការណាមួយឱ្យសំរេចទៅបាន ដោយការប្រើមធ្យោបាយគ្រប់បែបយ៉ាង ទាំងផ្លូវកាយ ផ្លូវចិត្ត ផ្លូវបញ្ញា ទាំងផ្លូវសម្ភារៈ ដំណើរធ្វើកើត ដំណើរដែលអាចទៅរួច អាចប្រឹងប្រែងបាន ។

សមត្ថភាពរបស់បុគ្គលម្នាក់ ជារបស់បុគ្គលនោះដោយផ្ទាល់ ។ សមត្ថភាព ជារបស់ដែលអាចបណ្តុះបាន បើគេធ្វើការហ្វឹកហាត់អប់រំឱ្យបានត្រឹមត្រូវ ។ ជាទូទៅ សមត្ថភាពអាចកើតមានពី ៖

- អំណាចធម្មជាតិពីកំណើត,
- ការរៀនសូត្រ ត្រិះរិះ សាកសួរ ចងចាំច្រើន,
- ការហ្វឹកហាត់ អប់រំ,
- ការពិសោធន៍ក្នុងកិច្ចការ,
- កម្លាំងចិត្ត,
- កល្យាណមិត្ត,
- នៅក្នុងបរិយាកាសដែលអំណោយផលល្អ ។

ក្នុងចំណោមប្រភេទទាំង ៧ នេះ មានតែសមត្ថភាពដែលកើតពីធម្មជាតិផ្តល់ឱ្យទេ ដែលលំបាកក្នុងការស្វែងរក ក្រៅពីនេះ សុទ្ធតែជារឿងដែលអាចហ្វឹក-ហាត់ និងរកបានទាំងអស់ ។

www.budinst.gov.kh www.elibraryofcambodia.org

# លក្ខណសម្បត្តិរបស់អ្នកមានសមត្ថភាព

ដូចបានពោលរួចមកហើយ សមត្ថភាពជារឿងដែលអាចបណ្ដុះបាន ។ តទៅនេះ ខ្ញុំសូមលើកយកការបណ្ដុះសមត្ថភាព និងលក្ខណៈរបស់អ្នកមានសមត្ថ-ភាព តាមបែបបទរបស់ព្រះពុទ្ធសាសនា ៨ យ៉ាង មកជូនទុកជាគតិ និងការពិចារណា ដូចតទៅ ៖



# គ្រឹះសមត្ថភាព ៖ សប្បុរិសធម៌ ៧

ស្ថាបត្យកម្មទាំងឡាយ ដែលនឹងអាចឈរតាំងនៅមាំបាន ព្រោះអាស្រ័យគ្រឹះជាមូលដ្ឋានទ្រយ៉ាងណា អ្នកដឹកនាំក៏ត្រូវចាក់គ្រឹះសមត្ថភាពជាតួទ្រទ្រង់សំរាប់បំពេញកិច្ចការនាទីខ្លួនយ៉ាងដូច្នោះដែរ ។ ជាពិសេស បើការងាររឹតតែធំ និងលំបាកគ្រឹះសមត្ថភាពក៏រឹតតែត្រូវមាំទាំថែមទៀតដែរ ។ គ្រឹះសមត្ថភាពរបស់អ្នកដឹកនាំហៅថា « *សប្បុរិសធម៌* » មាន ៧ យ៉ាងគឺ ៖

*១. ធម្មញ្ញុតា* ៖ ធម្មញ្ញុតា គឺការស្គាល់ ដឹងហេតុ គោលការណ៍ ស្គាល់វិធីដែលនឹងនាំឱ្យទៅដល់គោលដៅ ថាមានអ្វីខ្លះ មានលក្ខណៈយ៉ាងដូចម្តេច មានរបៀបប្រើយ៉ាងណា ហេតុណា វិធីណានាំទៅរកផល និងគោលដៅបែបណា ។

បើតាមគោលអរិយសច្ចៈ បានដល់ការដឹងហេតុដែលនាំឱ្យកើតទុក្ខ បញ្ហា និងវិបត្តិផ្សេងៗ និងដឹងហេតុវិធី គោលការណ៍ ដែលសំរាប់យកទៅបំបាត់ទុក្ខ កែបញ្ហា និងវិបត្តិនោះ ។

*២. អត្ថញ្ញុតា ៖* អត្ថញ្ញុតា គឺការដឹងផល ដឹងគោលបំណង ស្គាល់ប្រយោជន៍ ដែលខ្លួនចង់បាន ថាមានលក្ខណៈយ៉ាងណា ផលហ្នឹង គោលបំណងហ្នឹងកើតឡើងបានព្រោះអាស្រ័យគោលការណ៍យ៉ាងដូច្នេះ ដូច្នោះជាដើម ។ ការស្គាល់គោលបំណង គោលដៅឱ្យបានច្បាស់លាស់ សំរាប់ធានាដល់ការបញ្ជាក់ ឬការវាស់ប្រមាណផល ថាយើងបានដឹកនាំកិច្ចការនោះមកដល់ទីដែលយើងប្រាថ្នាហើយឬនៅ ។ បើតាមគោលអរិយសច្ចៈ គឺការស្គាល់ថាអ្វីជាទុក្ខ ជាបញ្ហា ជាវិបត្តិ ដែលខ្លួនកំពុងមាន កំពុងជួបប្រទះ និងដឹងថាអ្វីជាគោលបំណងរបស់យើង ដែលជាទូទៅគឺសភាវៈដែលផ្ទុយនឹងសេចក្តីទុក្ខ ឬបញ្ហានោះៗ ដូចជាពាក្យផ្ទុយនឹងបញ្ហាខ្វះទឹក គឺការមានទឹកប្រើ ជាដើម ។

www.budinst.gov.kh www.elibraryofcambodia.org

ចំពោះការដឹងទាំងពីរនេះ ទាមទារឱ្យអ្នកដឹកនាំសិក្សា រៀនសូត្រ ស្រាវជ្រាវ ធ្វើការអង្កេតពិនិត្យឱ្យបានត្រឹមត្រូវ ត្រឹមត្រង់ ច្បាស់លាស់ ។

ពុទ្ធសាសនា និយាយពីរឿងហេតុផល មិនមែនធ្វើអ្វីស្រេចតែនឹងនឹកឃើញ ឬខ្វះគោលការណ៍ច្បាស់លាស់នោះទេ ។

*៣. អត្តញ្ញុតា* ៖ អត្តញ្ញុតា គឺការស្គាល់ពីខ្លួន ដឹងពីខ្លួនថា ឋានៈ ភារៈ ភេទ កម្លាំង ចំណេះដឹង សមត្ថភាព ការស្ទាត់ជំនាញ និងគុណធម៌ជាដើម ឥឡូវនេះ មានប៉ុណ្ណា គ្រប់គ្រាន់ សក្តិសមនឹងធ្វើការដឹកនាំកិច្ចការហ្នឹងបានឬទេ ទទួលខុសត្រូវបានឬទេ មិនមែនស្អីក៏ចេះតែបាន ស្អីក៏ថាចេះ ស្អីក៏គ្មានបញ្ហា ព្រោះដោយសារតែការឃើញតែប្រយោជន៍ខ្លួន ឬខ្លាចគេថាខ្លួនមិនមានសមត្ថភាពនោះទេ ។

*៤. មត្តញ្ញុតា* ៖ មត្តញ្ញុតា គឺការស្គាល់ប្រមាណ ស្គាល់អ្វីដែលល្មម ដែលសមរម្យ ប៉ុណ្ណាគួរធ្វើ ប៉ុណ្ណាគួរគ្រវាត់ចោល ប៉ុណ្ណាគួរយកមកប្រើប្រាស់ ដូចជាស្ថានការណ៍បែបនេះ គួរយកពន្ធអាករប៉ុណ្ណា ប្រៀបធៀបឱ្យសមល្មម ។ មត្តញ្ញុតានេះ មានលក្ខណៈស្រដៀងនឹងការដើរនៅក្នុងផ្លូវដែលជាមជ្ឈិមប្បដិបទា គឺមិនតឹងពេក មិនធូរពេក ជាកណ្តាល ។ បើជាការប្រើប្រាស់វត្ថុវិញ គឺការដឹងថាវត្ថុហ្នឹងអាចប្រើបាននៅក្នុងកិរិតណា រថយន្តហ្នឹងត្រូវបើកត្រឹមល្បឿនប៉ុណ្ណា ទើបមិនមានគ្រោះថ្នាក់ មិនឆាប់ខូច ។

*៥. កាលញ្ញុតា* ៖ កាលញ្ញុតា គឺការស្គាល់កាល ស្គាល់ពេលវេលា ស្គាល់កាលៈទេសៈ ស្គាល់ស្ថានការណ៍ ដែលគួរនឹងធ្វើ នឹងនិយាយ គួរនឹងប្រើប្រាស់ឱ្យបានទាន់ពេលវេលា ត្រូវនឹងឱកាស ឱ្យសមនឹងស្ថានការណ៍ ជាដើម ។

*៦. បរិសញ្ញុតា* ៖ បរិសញ្ញុតា គឺការស្គាល់បរិស័ទ បានដល់ការស្គាល់ទីប្រជុំជន ស្គាល់សហគមន៍ ស្គាល់ប្រទេស ទាំងក្នុងវិស័យការគ្រប់គ្រង ការសិក្សា សេដ្ឋកិច្ច សាសនា ក្រុមគ្រួសារ ការកំសាន្ត តិកណ្ឌូឡូយី ឬដែលយើងតែងនិយាយ

www.budinst.gov.kh www.elibraryofcambodia.org

ថា ស្គាល់ ដឹងពីប្រព័ន្ធសេដ្ឋកិច្ច និងវប្បធម៌របស់កន្លែងនោះៗ ថាមានអ្វីខ្លះ មាន លក្ខណៈយ៉ាងណា ជាដើម រួមទាំងភូមិសាស្ត្រ និងប្រវត្តិសាស្ត្ររបស់ទីកន្លែង បរិស័ទ ប្រជុំជន ដែលយើងនឹងត្រូវដឹកនាំធ្វើ ឬនិយាយជាមួយ ។ តីទីប្រជុំជនបែប នេះ គួរធ្វើយ៉ាងនេះ គួរនិយាយយ៉ាងនេះ គួរសង្គ្រោះ គួរដឹកនាំ គួរអភិវឌ្ឍយ៉ាងនេះ យ៉ាងនោះ ជាដើម ។

*៧. បុគ្គលញ្ញុតា* ៖ គឺការស្គាល់បុគ្គលម្នាក់ៗ ថាតើមានអធ្យាស្រ័យ សមត្ថភាព គុណធម៌ ចំណេះដឹងប៉ុណ្ណា អ្នកនេះមានដូចម្ដេច ម្នាក់ទៀតមានកិរិត ប៉ុណ្ណោះ ចេះវែកញែកមិនឱ្យច្រឡំគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ព្រមទាំង ដឹងថា មនុស្សនេះគួរសេពគប់ឬទេ គួរឱ្យធ្វើការប្រភេទណា សមនឹងស្ថានការណ៍ បែបណា គួរឱ្យនៅត្រឹមតំណែងប៉ុណ្ណា មនុស្សនេះគួរប្រដៅយ៉ាងណា ជាដើម ។

ក្នុងការស្គាល់បុគ្គលនេះ ពុទ្ធសាសនាបានចែកមនុស្សជា ៦ ប្រភេទ ទៅ តាមចរិតរបស់បុគ្គលម្នាក់ៗ គឺ ៖

*១. រាគចរិត* ៖ ចរិតស្រឡាញ់ស្អាតល្អ,
*២. ទោសចរិត* ៖ ចរិតទោសៈ ប្រញាប់ប្រញាល់ ក្ដៅក្រហាយ,
*៣. មោហចរិត* ៖ ចរិតទើកមើក ល្ងង់ ល្ងីល្ងើ,
*៤. សទ្ធាចរិត* ៖ ចរិតដែលចូលចិត្តជឿ រហ័សជឿ,
*៥. វិតក្កចរិត* ៖ ចរិតចូលចិត្តខ្វាយខ្វល់,
*៦. ពុទ្ធិចរិត* ៖ ចរិតចូលចិត្តត្រិះរិះច្រើន ឆ្លាត

ស្ដាបត្យកម្មដែលមានគ្រឹះមាំ មិនងាយរំលំទេ
ប្រមុខដែលមានសប្បុរិសធម៌ ជាប្រមុខរឹងប៉ឹង

www.budinst.gov.kh www.elibraryofcambodia.org

# អ្នកជឿមានហេតុផល

*« ធ្វើមេគេហើយ នៅត្រចៀកស្រាលទៀត »* ។ នេះជាពាក្យដែលខ្មែរយើងចំណាំនិយាយរិះគន់ចំពោះមេដឹកនាំណា ដែលគេនិយាយអ្វីបន្តិចក៏ជឿ អ្វីបន្តិចក៏ខឹង ព្រោះដាក់ចិត្តថា រឿងហ្នឹងជារឿងពិត ។

*« អ្នកណាទៅដល់មុន អ្នកហ្នឹងឈ្នះហើយ »* ។ នេះជាពាក្យដែលនិយាយសំដៅចំពោះអ្នកដឹកនាំដែលមិនបានគិតពិចារណាឱ្យបានដិតដល់ បានអ្នកណាទៅនិយាយរឿងប្រាប់មុន ក៏ជឿថារឿងហ្នឹងពិត ឯអ្នកមកដល់ក្រោយ ទោះខំប្រាប់ការពិតយ៉ាងណា ក៏មិនជឿដែរ ។

*យោ ច សទ្ធបរិត្តាសី វនេ វាតមិគោ យថា*
*លហុចិត្តោតិ តំ អាហុ នាស្ស សម្បជ្ជតេ វតំ ។*

*« អ្នកណាភ្ញាក់ផ្អើលចំពោះសំឡេង ដូចម្រឹគស្មាន់ក្នុងព្រៃ លោកហៅអ្នកនោះថាមានចិត្តស្រាល កិច្ចការរបស់អ្នកនោះរមែងមិនសម្រេច »* ។

នេះគឺជាពុទ្ធភាសិតដែលព្រះសម្មាសម្ពុទ្ធសម្ដែងអំពីការតាំងចិត្តក្នុងការឮសំឡេង ដែលនឹងអាចនាំទៅរកព្រឹត្តិកម្មនៃការសំរេចចិត្តរបស់អ្នកដឹកនាំ ។

ក្នុងកាលាមសូត្រនៃអង្គុត្តរនិកាយ តិកនិបាត ព្រះសម្មាសម្ពុទ្ធបានសម្ដែងអំពីវិធីបដិបត្តិក្នុងរឿងដែលគួរសង្ស័យ ឬគោលការណ៍នៃការជឿចំនួន ១០ យ៉ាង សំរាប់ជាការពិចារណា ពិសោធន៍ មុននឹងជឿរឿងនោះថាពិតមិនពិត ។

១. *មា អនុស្សវេន* កុំដាក់ចិត្តជឿ ព្រោះគ្រាន់តែការបានស្ដាប់តៗគ្នាមក ។

២. *មា បរម្បរាយ* កុំដាក់ចិត្តជឿ ព្រោះដោយការកាន់តៗគ្នាជាប្រពៃណីពីបុរាណ ឬពីដើមមក ។

www.budinst.gov.kh www.elibraryofcambodia.org

៣. *មា ឥតិកិរាយ* កុំជាក់ចិត្តជឿ ព្រោះដោយការនិទានតៗគ្នា ។

៤. *មា បិដកសម្បទានេន* កុំជាក់ចិត្តជឿ ព្រោះដោយការអាងតម្រា ឬគម្ពីរ ។

៥. *មា តក្កហេតុ* កុំជាក់ចិត្តជឿ ព្រោះការគិតបែបតក្កវិទ្យា ។

៦. *មា នយហេតុ* កុំជាក់ចិត្តជឿ ដោយការអនុមាន ។

៧. *មា អាការបរិវិតក្កេន* កុំជាក់ចិត្តជឿ ដោយការគិតពិចារណា តាមបែបហេតុផល ។

៨. *មា ទិដ្ឋិនិជ្ឈានក្ខន្តិយា* កុំជាក់ចិត្តជឿ ព្រោះត្រូវនឹងទ្រឹស្តីដែលពិនិត្យហើយ ។

៩. *មា ភព្វរូបតាយ* កុំជាក់ចិត្តជឿ ព្រោះមើលទៅរូបលក្ខណៈ ហាក់ដូចជាអញ្ចឹងមែន ។

១០. *មា សមណោ* កុំជាក់ចិត្តជឿ ព្រោះលោករូបនេះជាគ្រូរបស់យើង ។

បើដូច្នេះ តើយើងគួរជឿដូចម្តេច ?

ព្រះសម្មាសម្ពុទ្ធបានត្រាស់ថា « លុះត្រាតែកាលណាដឹងច្បាស់ដោយចិត្តរបស់ខ្លួនថា ធម៌ទាំងអស់នោះជាអកុសល ជាកុសល មានទោស មិនមានទោស ជាដើមហើយ ទើបគួរលះបង់ចេញ ឬបដិបត្តិតាមនោះ ។

អ្នកដឹកនាំ ជាអ្នកទទួលខុសត្រូវលើវាសនារបស់អ្នកដទៃទៀតជាច្រើននាក់ ។ ដូច្នេះ មុននឹងជឿត្រូវពិចារណាលើគោលការណ៍ទាំង ១០ នេះជាមុនសិន ដូចសុភាសិតខ្មែរថា : « *ស្តាប់មិនទាន់ជាក់ កុំអាលញាក់ចិញ្ចើម* » ។

www.budinst.gov.kh www.elibraryofcambodia.org

# អ្នកមានញាណ

**ញាណ** ប្រែថា ប្រាជ្ញាចាក់ធ្លុះ ការដឹងជ្រៅជ្រះ ដឹងសព្វគ្រប់ គឺដឹងថា រឿងហ្នឹងគឺរឿងអ្វី (What) កើតនៅទីណា (Where) កើតពេលណា (When) អ្នកណាជាអ្នកបង្កើត (Who) ហេតុអ្វីបានជារឿងហ្នឹងកើត (Why) និងសាច់រឿងហ្នឹងកើតឡើងដោយរបៀបណា ( How ) ។

ទាំង ៦ នេះ ជាលក្ខណៈដឹងរបស់ញាណ ។ អ្នកដឹកនាំ បើនឹងដឹងរឿងអ្វីមួយ ឬចង់ដឹងរឿងអ្វីមួយ ឬនឹងធ្វើកិច្ចការណាមួយ ត្រូវពិចារណាលើកត្តាទាំង ៦ យ៉ាងនេះឱ្យបានសព្វគ្រប់ មុននឹងអនុវត្តការនោះ ។

*ញាណ* ឬ *ការដឹងច្បាស់* មាន ៣ ប្រការគឺ ដឹងអតីត ដឹងអនាគត និងដឹងបច្ចុប្បន្ន មានសេចក្តីអធិប្បាយសង្ខេប ដូចតទៅ ៖

*១. អតីតំសញាណ* គឺញាណដឹងពីអតីត ដឹងពីប្រវត្តិសាស្ត្រ ដឹងពីអតីតកាលរបស់រឿង កិច្ចការ ឬហេតុការណ៍មួយដោយច្បាស់លាស់ និងអាចលំដាប់ហេតុការណ៍នោះបានគ្រប់លក្ខណៈ ។ ប្រវត្តិសាស្ត្រមានប្រយោជន៍ក្នុងការយកមកជាមេរៀន សំរាប់ការងារបច្ចុប្បន្ន និងការពារកុំឱ្យហេតុការណ៍ ដែលមិនពេញចិត្តកើតឡើងម្តងទៀត និងរើសយកការពិសោធន៍ណាដែលល្អមកកែខៃ រៀបចំ សំរាប់អនាគត ។

*២. អនាគតំសញាណ* គឺការដឹងពីអនាគត កាត់ស្មាន ផលហេតុការណ៍ដែលនឹងត្រូវកើតឡើងបានដោយត្រឹមត្រូវ ដោយយោងភ្ជាប់នឹងហេតុការណ៍បច្ចុប្បន្ន ។ ការដឹងរឿងអនាគតបាន គឺអាចឱ្យយើងរៀបចំយុទ្ធវិធី ដើម្បីសំរេចជោគជ័យបានយ៉ាងមានប្រសិទ្ធភាព ព្រមទាំងអាចការពារនូវលក្ខខ័ណ្ឌអាក្រក់ទាំងឡាយ ដែលនឹងកើតឡើងបានដោយងាយស្រួល ។ ក្នុងភាសាសម័យថ្មី គេប្រើ

www.budinst.gov.kh www.elibraryofcambodia.org

ពាក្យថា ការប្រមើលមើលអនាគត (Forecasting) ដែលជាបច្ច័យដ៏សំខាន់មួយក្នុងប្រព័ន្ធការរៀបចំគំរោងការ ឬ ផែនការណាមួយ ដែលជារឿងត្រូវសិក្សាដោយយកចិត្តទុកដាក់ ព្រោះបើកាត់ស្មានខុសហើយ ផែនការនោះនឹងដួលរលំ ជាមិនខាន ។

*៣. បច្ចុប្បន្នំសញ្ញាណ* គឺការដឹងពីបច្ចុប្បន្ន ដំណើរការដែលកំពុងប្រព្រឹត្តទៅ មានលក្ខណៈបែបណា មានហេតុបច្ច័យអ្វីខ្លះ មានលក្ខខ័ណ្ឌយ៉ាងណា ។

ការដឹងទាំង ៣ យ៉ាងនេះ មិនអាចញែកចេញពីគ្នាបានឡើយ គឺអតីត បច្ចុប្បន្ន និងអនាគត មានទំនាក់ទំនងគ្នាជាហេតុនិងផល ជាវដ្តចក្រកាលវេលា ដែលវិលទៅវិលមក ក្នុងឆាកជីវិតមិនងាយដាច់រយៈ ។

យើងអាចគូររូបតំណាងការដឹងទាំង ៣ កាល និង ៦ លក្ខណៈ ព្រមទាំងលក្ខខ័ណ្ឌផ្សេងៗ ដូចខាងក្រោមនេះ :

លក្ខខ័ណ្ឌ




www.budinst.gov.kh www.elibraryofcambodia.org

# បដិសម្ភិទាជន

**បដិសម្ភិទា** ឬការដែលមានប្រាជ្ញាយល់ច្បាស់ ប្រាជ្ញាដែលបែកយល់ធ្លុះធ្លាយឥតទើសទាក់ ប្រាជ្ញាដែលភ្លឺស្វាង អាចពិចារណាយល់ជាក់ប្រាកដភ្លាមៗ នូវហេតុផលនៃកិច្ចការទាំងពួង ។ បដិសម្ភិទា គឺជាប្រាជ្ញាជាន់ខ្ពស់បំផុតរបស់អរិយៈបុគ្គលដែលបានសំរេចនូវអរហត្តផលពិសេស ។ លោកដែលបានសំរេចបដិសម្ភិទាញាណនេះហើយ ទោះនឹងធ្វើកិច្ចការអ្វី ក៏សំរេចជោគជ័យគ្រប់ប្រការ ព្រោះលោកមានបដិសម្ភិទាទាំង ៤ ជួយជាកម្លាំង ។

អ្នកដឹកនាំ ជាអ្នកធ្វើកិច្ចការកម្រ កិច្ចការលំបាក កិច្ចការដែលមនុស្សភាគច្រើនមិនអាចធ្វើបាន ។ ដូច្នេះ ជាការចាំបាច់ណាស់ដែលអ្នកដឹកនាំត្រូវតែជាមនុស្សមានប្រាជ្ញាខ្លាំង ប្រាជ្ញាច្រើន និងប្រាជ្ញាត្រឹមត្រូវ ដើម្បីដឹកនាំរាស្ត្រ ។ ប្រាជ្ញាយល់ច្បាស់ ឬបដិសម្ភិទា ៤ ដែលអាចយកមកអនុវត្តក្នុងឋានៈជាអ្នកដឹកនាំបានគឺ ៖

*១. អត្ថបដិសម្ភិទា* ប្រាជ្ញាចាក់ធ្លុះធ្លាយក្នុងអត្ថៈ ក្នុងអត្ថន័យឃើញបញ្ហា ឬសេចក្តីត្រូវការ ឬរឿងហេតុអ្វីមួយរបស់រាស្ត្រតែបន្តិចបន្តួច ឬខ្លីៗ ក៏អាចវែកញែក អធិប្បាយពង្រីកសេចក្តីឱ្យពិស្តារបាន ។ ឃើញហេតុណាមួយកើតឡើង ក៏អាចវែកញែកពង្រីក ថ្លឹងថ្លែង តភ្ជាប់ទៅរកផល ឬវិបាក ដែលនឹងត្រូវកើតឡើងភ្លាមមួយរំពេច ។ ខ្មែរយើងតែងនិយាយថា ៖ *« និយាយតែ ២-៣ ម៉ាត់របស់យល់ដឹងថាចង់ធ្វើអ្វី ចង់បានអ្វីភ្លាម »* ។

*២. ធម្មបដិសម្ភិទា* បញ្ញាយល់ច្បាស់ក្នុងធម៌ ដឹងច្បាស់នូវគោលទាំងឡាយ ឃើញអត្ថាធិប្បាយពិស្តារនៃបញ្ហា ឬរឿងណាមួយដែលគេពន្យល់ ក៏ចាប់សេចក្តីបានថា រឿងហ្នឹងជារឿងអ្វី មានប្រភពមកពីអ្វីភ្លាម ។ បើនិយាយឱ្យងាយស្តាប់ គឺឃើញអត្ថបទ ១ ដែលពិពណ៌នាពីរឿងមួយដ៏ពិស្តារ ក៏អាចរកចំណងជើង

www.budinst.gov.kh www.elibraryofcambodia.org

មកដាក់ឱ្យចំ និងសមទៅនឹងអត្ថបទនោះភ្លាម ឬឃើញផលវិបាកមួយកើតឡើង ក៏ដឹងថា ផលវិបាកនោះកើតមកពីប្រភពអ្វី ពីហេតុអ្វី ។ ខ្មែរយើងហៅថា "*រហ័សចាប់គោលសេចក្តីបាន* "។

*៣. និរុត្តិបដិសម្ភិទា* : គឺការដែលមានបញ្ញាឆ្លៀវឆ្លាតក្នុងភាសា ស្គាល់ស័ព្ទ ពាក្យបញ្ញត្តិ និងចេះនិយាយភាសាបរទេសផ្សេងៗ ក្រៅពីភាសាខ្លួនបានច្រើន ចេះនិយាយឱ្យគេស្តាប់ពីរោះ ឱ្យគេស្តាប់បាន ឱ្យគេចូលចិត្ត និងឱ្យគេជឿ យល់តាមខ្លួនប្រាថ្នាបាន និយាយដោយសង្ខេប គឺស្ទាត់ជំនាញក្នុងភាសា និងការនិយាយ ។

*៤. បដិភាណបដិសម្ភិទា* : គឺបញ្ញាដែលគិតរហ័ស គិតលឿន (Present d'Esprit) មានបដិភាណយល់ច្បាស់ក្នុងចំណេះដឹងដែលមាន អាចយកទៅប្រើបានយ៉ាងមានប្រសិទ្ធភាព និងប្រសិទ្ធផល សមរម្យទៅតាមករណី និងស្ថានការណ៍ ។

បដិសម្ភិទាទាំង ៤ នេះ ជារបស់ដែលហ្វឹកហាត់បាន រៀនបាន ។ អ្នកដឹកនាំត្រូវខ្នះខ្នែង ហ្វឹកហាត់បដិសម្ភិទានេះឱ្យកើតមានឡើង ដើម្បីជាប្រយោជន៍ក្នុងការដឹកនាំប្រជារាស្ត្រ ទាក់ទងជាមួយបរទេស ដើម្បីកុំឱ្យចាញ់គេ ។

www.budinst.gov.kh www.elibraryofcambodia.org

# អនុត្តរជន

« *បើមិនខ្លាំងជាងគេ ធ្វើមេគេមិនបានទេ* » នេះគឺជាពាក្យទំនៀមខ្មែរ ដែលតែងតែនិយាយលេង សំរាប់អ្នកណាដែលធ្វើជាមេដឹកនាំគេ ។

ពិតមែនតែជាពាក្យនិយាយលេងៗក្តី តែពាក្យនេះក៏បានបង្កប់នូវសក្តានុភាពរបស់ខ្លួន សំរាប់ឱ្យអ្នកដឹកនាំយកជាគតិក្នុងការដឹកនាំមហាជន ។ ពាក្យថា ខ្លាំងជាងគេ ប្រសើរជាងគេ ល្អជាងគេនេះ ក្នុងភាសាបាលីលោកហៅថា *អនុត្តរិយៈ* ។ អនុត្តរិយៈ ប្រែថា ភាវៈដែលឥតមានអ្វីធៀបស្មើបាន ប្រសើរបំផុត ។ ក្នុងគម្ពីរព្រះសុត្តន្តបិដក អង្គុត្តរនិកាយ ឆក្កនិបាត ព្រះសម្មាសម្ពុទ្ធបានត្រាស់សំដែងអំពីអនុត្តរិយៈ គឺគុណជាតិ ឬមធ្យោបាយវិធី ៦ យ៉ាងដ៏ប្រសើរជាទីបំផុត ដើម្បីធ្វើឱ្យជាក់ច្បាស់នូវអភិញ្ញា ។ អភិញ្ញា គឺជាគុណធមិជាន់ខ្ពស់របស់ព្រះពុទ្ធសាសនា ដែលបុគ្គលណាមានហើយ បុគ្គលនោះអាចសំដែងឫទ្ធិបាន មានត្រចៀកទិព្វ ទាយចិត្តអ្នកដទៃបាន រលឹកជាតិរបស់ខ្លួនបាន មានភ្នែកទិព្វ និងអាចធ្វើឱ្យអស់នូវអាសវក្កិលេសបាន ។

អ្នកដឹកនាំគេ ត្រូវខ្លាំងជាងប្រជាជន ទើបប្រជាជនទុកចិត្តឱ្យធ្វើជាប្រមុខគេបាន ។ អ្នកដឹកនាំ នឹងក្លាយទៅជាមនុស្សអច្ឆរិយៈ ទៅជាអនុត្តរជនក្នុងក្រសែភ្នែករបស់ប្រជាពលរដ្ឋបាន កាលណាបានអនុវត្តតាមអនុត្តរិយៈ ទាំង ៦ ដែលមាន ៖

១. *ទស្សនានុត្តរិយៈ* ៖ គឺការឃើញដ៏ប្រសើរ ។ អ្នកដឹកនាំគប្បីជាអ្នកដែលឃើញសេចក្តីទុក្ខរបស់ប្រជាជនរបស់ខ្លួន ឃើញបញ្ហាក្នុងសង្គម ជាអ្នកពេញចិត្តក្នុងការដើរសាកសួរប្រជាជនខ្លួន ។

អ្នកដឹកនាំណាដែលធ្មេចភ្នែក ធ្វើមិនដឹងចំពោះសេចក្តីទុក្ខរបស់ប្រជាជន អ្នកនោះមិនអាចដឹងដោះស្រាយបញ្ហារបស់ប្រជាជនខ្លួនបានឡើយ ។ ខ្មែរយើងហាក់ដូចជាមិនពេញចិត្តចំពោះអ្នកដឹកនាំណា ដែលមិនព្រមចុះអើតសួរសុខទុក្ខរបស់

www.budinst.gov.kh www.elibraryofcambodia.org

ខ្លួនសោះ ។

ការសំរេចជោគជ័យក្នុងការយកឈ្នះចិត្តប្រជារាស្ត្រខ្មែរ របស់សម្តេចព្រះនរោត្តម សីហនុ គឺការដែលទ្រង់ឧស្សាហ៍ចុះយាងមើលសាកសួរសុខទុក្ខរបស់ប្រជារាស្ត្រព្រះអង្គនេះឯង ។

ម្យ៉ាងទៀត ខ្ញុំតែងតែឮប្រជារាស្ត្រខ្មែរ សំដែងការខឹងក្រោធចំពោះអ្នកតំណាងប្រជារាស្ត្រខ្មែរពីជំនាន់មុន ដែលចុះទៅមើលរាស្ត្រខ្លួនតែនៅពេលដែលត្រូវការសន្លឹកឆ្នោតតែប៉ុណ្ណោះ លុះដល់ជាប់ឆ្នោតហើយ ក៏បាត់មុខតែម្តង ។ ពាក្យខ្មែរ ១ ម៉ាត់ដែលយើងគួរយកជាគតិគឺ "*ខ្វាក់អ្វីមិនស្មើនឹងមិនព្រមយកភ្នែកមើល* "។

*២. សវនានុត្តរិយៈ* ៖ គឺការស្តាប់ដ៏ប្រសើរ ។ អ្នកដឹកនាំត្រូវជាអ្នកចេះស្តាប់ ចូលចិត្តស្តាប់ និងពូកែស្តាប់ ។ ការស្តាប់អាចឱ្យគេដឹងបញ្ហា ដឹងរឿង ។ ការស្តាប់អាចឱ្យអ្នកនិយាយប្រាប់សប្បាយចិត្ត ពេញចិត្តនឹងប្រាប់ថែមទៀត ។ ការស្តាប់មិនចាំបាច់ជឿទេ ព្រោះអ្នកស្តាប់អាចពិចារណារកហេតុផលបាន ។ ប្រជារាស្ត្រនឹងសប្បាយចិត្ត បើគេនាំមកនូវបញ្ហារបស់គេ ឬការស្នើរបស់គេមកប្រាប់អ្នកដឹកនាំ ហើយអ្នកដឹកនាំស្តាប់ដោយយកចិត្តទុកដាក់ និងធ្វើការពិចារណា ។ អ្នកដឹកនាំគប្បីដឹងថា ធម្មជាតិបង្កើតភ្នែកពីរ ត្រចៀកពីរ សំរាប់មើល និងស្តាប់ឱ្យបានច្រើនជាងមាត់ ដែលធម្មជាតិដាក់មានឱ្យមកតែមួយ ។

*៣. លាភានុត្តរិយៈ* ៖ គឺការបានលាភដ៏ប្រសើរ ។ បញ្ហា សេចក្តីត្រូវការ និងមធ្យោបាយសំរាប់ដោះស្រាយផ្សេងៗ ដែលអ្នកដឹកនាំបានឃើញ បានដឹង បានស្តាប់ដំណឹងទាំងនេះ ត្រូវយកមកចាត់ចែងជាក្រុម ជាថ្នាក់ ទៅតាមប្រភេទ តាមលំដាប់សំខាន់ ។ កន្លែងណាដែលពតិមានមានមិនគ្រប់គ្រាន់ ក៏រកមកបំពេញបន្ថែម ។ កន្លែងដែលលើសហួសពីការពិត ក៏កាត់ចេញ ចំរាញ់ទុកតែរបស់ណា ដែលមានប្រយោជន៍ពិតៗ ឱ្យសមនឹងពាក្យថា បានទទួលលាភដែលជាការពិត ជាទីបំផុត ។

www.budinst.gov.kh www.elibraryofcambodia.org

*៤. សិក្ខានុត្តរិយៈ* ៖ គឺការសិក្សាដ៏ប្រសើរ ។ ពតិមានដែលបានមកពីការបានឃើញ បានស្ដាប់ និងបានយកមកចាត់លំដាប់ និងចំរាញ់យកការពិតបានហើយនោះ គប្បីយកមកសិក្សា ពិនិត្យ ពិចារណាឱ្យបានច្បាស់លាស់ ។

- អ្វីជាបញ្ហាចំបង១ ដ៏ពិតប្រាកដរបស់រាស្ត្រ,
- អ្វីជាប្រភពនៃបញ្ហាទាំងនោះ,
- អ្វីជាសេចក្ដីត្រូវការដែលរាស្ត្រចង់បានដ៏ពិតប្រាកដ,
- កម្មវិធី និងមធ្យោបាយណាដែលអាចកំចាត់នូវបញ្ហាទាំងឡាយ និងបំពេញនូវសេចក្ដីត្រូវការរបស់រាស្ត្របាន ។

ការសិក្សាទាំងនេះ ត្រូវប្រកបដោយហេតុផល គតិយុត្តិធម៌ ប្រកបដោយធម៌ និងឈរនៅលើសប្បុរិសធម៌ទាំង ៧ ដែលបានអធិប្បាយរួចមកហើយ ។ កម្មវិធីឬគំរោងការណា ដើម្បីដឹកនាំប្រទេសដែលមិនបានសិក្សាឱ្យបានច្បាស់លាស់ ប្រកបដោយគោលការណ៍វិទ្យាសាស្ត្រ គ្មានហេតុផល កម្មវិធី ឬគំរោងការនោះ គឺជារឿងផ្សងព្រេង ដែលផ្ទុយនឹងគោលពុទ្ធសាសនា និងគោលការណ៍វិទ្យាសាស្ត្រ នាបច្ចុប្បន្នដ៏ពិតប្រាកដ ហើយឱកាសដែលនឹងអាចយកទៅអនុវត្តបានជោគជ័យនោះ មានតិចជាទីបំផុត ។ លោកឧបមាដូចជាមនុស្សដែលដើរក្នុងព្រៃ ដែលមិនដឹងគោលដៅគ្មានត្រីវិស័យ គ្មានស្បៀងអាហារ ដែលនឹងត្រូវវង្វេងក្នុងព្រៃស្លាប់ថ្ងៃណាមួយ ជាពុំខាន ។

*៥. បារិចរិយានុត្តរិយៈ* ៖ គឺការបំរើដ៏ប្រសើរ ។ បន្ទាប់ពីបានសិក្សានូវបញ្ហា សេចក្ដីត្រូវការ និងវិធីសំរាប់ដោះស្រាយហើយ គំរោងការនោះត្រូវយកទៅអនុវត្តឱ្យទៅជាប្រយោជន៍របស់រាស្ត្រ ។ ការបំរើដ៏ប្រសើរ គឺការបំរើណាដែលឆ្ពោះទៅដើម្បីជាប្រយោជន៍រាស្ត្រ និងសំរាប់រាស្ត្រ មិនមែនដើម្បីខ្លួនឯងទេ ។ កិច្ចការនោះ ត្រូវបាចផលប្រយោជន៍ឱ្យបានដល់បុគ្គលម្នាក់១ ឱ្យបានដល់សង្គម និងមិន

www.budinst.gov.kh www.elibraryofcambodia.org

ប៉ះពាល់ដល់ធម្មជាតិ បរិយាកាសជុំវិញរបស់វាស្រ្តឡើយ ។ បច្ច័យទាំង ៣ គឺបុគ្គល សង្គម និងធម្មជាតិ ត្រូវមានតុល្យភាព ទើបការបំរើនោះ ជាការបំរើដ៏ប្រសើរ ហុច នូវផលប្រយោជន៍ពិតៗមែន ។




*៦. អនុស្សតានុត្តរិយៈ* ៖ គឺការរលឹកដ៏ប្រសើរ ។ កាលណា កិច្ចការ ចុះអនុវត្តហើយ អ្នកដឹកនាំត្រូវតាមដានមើល ស្តាប់ឱ្យបានជារឿយៗ ថាមានដំណើរ ការដល់ណាហើយ មានបញ្ហាអ្វីមកជាឧបសគ្គថែមទៀតទេ ។ រួចហើយ ក៏យក ពតិមានទាំងនោះមកចាត់លំដាប់សាជាថ្មីទៀត ព្រមទាំងធ្វើការសិក្សាឱ្យបានច្បាស់ លាស់ ។ អនុស្សតានុត្តរិយៈនេះ គឺជាការពិនិត្យការងារ (Controlling) និងជា ការវាស់ប្រមាណផលក្នុងកំឡុងប្រតិបត្តិការ (During Work Evaluation) ដើម្បីជាផលប្រយោជន៍សំរាប់យកទៅកែខៃ និងជំរុញការងារនោះឱ្យបានទៅដល់ ជោគជ័យ សក្តិសមជាបារិចរិយានុត្តរិយៈ គឺការបំរើដ៏ប្រសើរពិតៗ ។

អនុត្តរិយៈទាំង ៦ នេះ ក្នុងទស្សនៈខ្ញុំ គឺជាវិធីកម្ម សំរាប់ដោះស្រាយបញ្ហា

www.budinst.gov.kh www.elibraryofcambodia.org

មួយដ៏មានប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយទាំងអស់ ដែលអ្នកវិទ្យាសាស្ត្រសង្គមបច្ចុប្បន្ន តែងតែអនុវត្តប្រើសំរាប់ដោះស្រាយបញ្ហាផ្សេងៗ ឱ្យបានជោគជ័យ ។ យើងអាចគូរជារង្វង់បង្ហាញនូវវដ្តចក្រនៃវិធីកម្ម (Process) នេះ ដូចខាងក្រោម ៖




បើចែកជាលំដាប់ៗ នៃវិធីកម្មវិញ យើងអាចចែកជា ៦ លំដាប់ ដូចខាងក្រោម ៖

១. ពិនិត្យមើលបញ្ហា និងសេចក្តីត្រូវការ,

២. ស្តាប់ ប្រមូលបញ្ហា និងសេចក្តីត្រូវការ,

www.budinst.gov.kh www.elibraryofcambodia.org

៣. វិភាគបញ្ហា និងសេចក្ដីត្រូវការ,

៤. សិក្សាពីវិធីសំរាប់ដោះស្រាយ,

៥. អនុវត្តគំរោងការ,

៦. ត្រួតពិនិត្យ និងប្រមើលមើលគំរោងការ ។

www.budinst.gov.kh www.elibraryofcambodia.org

# អ្នកមានទសពលញាណ

ទសពលញាណ គឺព្រះញាណដែលជាកម្លាំងរបស់ព្រះសម្មាសម្ពុទ្ធ ១០ ប្រការ ដែលធ្វើឱ្យព្រះអង្គអាចបន្លឺសីហនាទប្រកាសព្រះពុទ្ធសាសនារហូតបានគង់វង្ស ចំរើនរុងរឿង កុះករដោយពុទ្ធបរិស័ទគ្រប់ទិសទី ។

អ្នកដឹកនាំអាចយកនូវកម្លាំងទាំង ១០ ប្រការរបស់ព្រះសម្មាសម្ពុទ្ធ មកអនុវត្តធ្វើជាកម្លាំងរបស់ខ្លួន ដើម្បីដឹកនាំប្រជារាស្ត្រឱ្យឆ្ពោះទៅរកសេចក្ដីសុខប្រកបដោយប្រសិទ្ធិភាពបាន ។ កម្លាំងទាំង ១០ ប្រការដែលអធិប្បាយជាន័យសំរាប់ការអនុវត្តរបស់មេដឹកនាំ គឺ ៖

*១. ឋានាឋានញាណ* ៖ ការដឹង ការយល់ក្នុងន័យសេចក្ដី និងក្របខ័ណ្ឌរបស់ច្បាប់ គោលការណ៍ផ្សេងៗ ដែលទាក់ទងដល់មុខនាទីខ្លួន ឬដែលនឹងនាំយកមកប្រើក្នុងការដឹកនាំបានយ៉ាងច្បាស់លាស់ រហូតដល់ដឹងនូវសមត្ថភាពរបស់បុគ្គល ក្នុងកម្រិតឋានៈផ្សេងៗបានយ៉ាងល្អ ។

*២. កម្មវិបាកញាណ* ៖ មានការយល់ដឹងក្នុងព្រឹត្តិកម្មរបស់មនុស្សបានយ៉ាងល្អ ដឹងថាព្រឹត្តិកម្មបែបនេះ នឹងនាំទៅរកលទ្ធផលបែបណា លទ្ធផលបែបនេះចេញមកពីព្រឹត្តិកម្មបែបណា និងមានបច្ច័យអ្វីដែលគាំទ្រចំពោះព្រឹត្តិកម្មប្រភេទនោះ ។

*៣. សព្វត្ថគាមិនីបដិបទាញាណ* ៖ មានការយល់ដឹងក្នុងមធ្យោបាយយុទ្ធសាស្ត្រផ្សេងៗ សំរាប់នាំទៅរកគោលដៅដែលបានតាំងឡើងគឺ ដឹងថាវិធីនេះនឹងនាំទៅរកគោលដៅបែបនេះ វិធីនេះមានប្រសិទ្ធិភាពអាចនាំទៅរកជោគជ័យបាន ។

*៤. នានាធាតុញាណ* ៖ មានការយល់ដឹងច្បាស់ក្នុងរឿងសង្គមវិទ្យា រដ្ឋ-សាស្ត្រ យ៉ាងហោចណាស់ ក៏ដឹងថាអ្វីជាអង្គប្រកបរបស់សង្គម មុខងារ និងការងារ

www.budinst.gov.kh www.elibraryofcambodia.org

របស់អង្គប្រកបនីមួយៗក្នុងរចនាសម្ព័ន្ធសង្គម ហើយបើឱ្យរឹតតែប្រសើរថែមទៀតនោះ គួរមានចំណេះទូទៅឱ្យបានទូលំទូលាយ ដូចជា ចំណេះខាងវិទ្យាសាស្ត្រ ខាងចិត្តវិទ្យាសង្គម ចិត្តវិទ្យាទូទៅ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រនយោបាយ ជាដើម ។ល។ ដើម្បីញ៉ាំងឱ្យការគ្រប់គ្រង ដឹកនាំនោះ រឹតតែបានផលល្អឡើង ។

៥. *នានាធិមុត្តិកញ្ញាណ* ៖ ចេះដឹង យល់ច្បាស់ពីភាពខុសគ្នារបស់បុគ្គលម្នាក់ៗ ក្រុមនីមួយៗ បក្សនីមួយៗ ទាំងខាងអធ្យាស្រ័យ និន្នាការ ការចូលចិត្តមនោ-គមវិជ្ជា និងការថ្នឹកពីធម្មជាតិ ។

៦. *ឥន្ទ្រិយបរោបរិយត្តញ្ញាណ* ៖ ដឹងយល់ពីភាពផ្សេងៗ រវាងបុគ្គលខាងផ្នែកកម្រិតសតិបញ្ញា សមត្ថភាព វិវឌ្ឍនាការក្នុងផ្នែកផ្សេងៗ និងការត្រៀមខ្លួនដើម្បីធ្វើការអភិវឌ្ឍន៍ ។

៧. *ឈានាទិសង្កិលេសាទិញ្ញាណ* ៖ ដឹងនូវបច្ច័យផ្សេងៗដែលនឹងទៅជាឧបសគ្គ ឬជាជំនួយក្នុងការដឹកនាំ ព្រមទាំងយល់ក្នុងការប្រើបច្ចេកទេសផ្សេងៗ ដើម្បីកែខៃបញ្ហា ឬជួយឧបត្ថមដល់ការដឹកនាំ ការគ្រប់គ្រង ឬការអភិវឌ្ឍន៍ផ្សេងៗ បានយ៉ាងប្រសើរ ។

៨. *បុព្វេនិវាសានុស្សតិញ្ញាណ* ៖ គឺយល់ដឹងពីអតីតកាល ពីប្រវត្តិសាស្ត្រ ប្រវត្តិរូប និងការពិសោធន៍របស់បុគ្គល ក្រុម សហគមន៍នីមួយៗ របស់អ្នកនៅក្រោមការគ្រប់គ្រងបានយ៉ាងច្បាស់លាស់ ។

៩. *ចុតូបបាតញ្ញាណ* ៖ ប្រមើលមើលដឹងដោយមិនខុសផ្លាត នូវផល ឬគោលបំណងអនាគតរបស់បុគ្គល និងសង្គមបានយ៉ាងប្រសើរ ថាបុគ្គលនេះ និងសង្គមនេះ តទៅអនាគតនឹងមានលក្ខណៈយ៉ាងនេះ យ៉ាងនោះ ។ គោលត្រង់នេះភាសាសម័យថ្មី គឺការប្រមើលមើលនូវដំណើរនាអនាគត ។

១០. *អាសវក្ខយញ្ញាណ* ៖ ដឹងច្បាស់ និងប្រាកដក្នុងចិត្តថា ផលសំរេច

www.budinst.gov.kh www.elibraryofcambodia.org

ដែលជាគោលបំណងនោះគឺអ្វី មានលក្ខណៈយ៉ាងណា ហើយប្រាកដក្នុងចិត្តថាខ្លួនអាចធ្វើផលសំរេចនោះឱ្យកើតប្រាកដបានដោយពិត ៗ ។

ខ្ញុំសុំឆ្លៀតឱកាសត្រង់នេះជំរាបអ្នកអានថា ខ្ញុំពុំមានចេតនានឹងបង្វែរពុទ្ធ.វចនៈឱ្យខុសពីការពិតដើមទេ ។ អត្ថាធិប្បាយពិទសពលញាណនេះ គឺខ្ញុំព្យាយាមដើម្បីទាញយកអត្ថន័យ ដែលអាចអនុវត្តបានជាភាសាផ្លូវលោក សំរាប់អ្នកដឹកនាំដោយមានចេតនា និងការពិតតែមួយគត់គឺ ធម្មៈ ព្រះសម្មាសម្ពុទ្ធប្រើបានទាំងសំរាប់ការត្រាស់ដឹង និង ទាំងសំរាប់រស់នៅក្នុងសង្គមនេះបានទាំងអស់ ស្រេចហើយតែយើងនឹងចេះយកមកកែឆ្នៃឱ្យស្ដាប់បាន និងអនុវត្តបានតែប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

# អ្នកមានទេពកោសល្យ

**ទេពកោសល្យ** គឺការប៉ិនប្រសប់ ការឈ្លាសវៃ ការជំនាញ ដូចជាទេវតា ។ អ្នកដឹកនាំ ក្រៅពីការមានប្រាជ្ញាចាក់ធ្លុះក្នុងបដិសម្ភិទាទាំង ៤ ហើយត្រូវជាមនុស្សប៉ិនប្រសប់ទៀតផង ។ ពាក្យខ្មែរយើងលោកពោលទុកថា « *ចេះដប់មិនស្មើប្រសប់មួយ* » ជាការបង្ហាញឱ្យឃើញថា បើយើងគ្រាន់តែចេះ ហើយធ្វើមិនកើត បានតែថា តែអនុវត្តមិនបាននោះ កិច្ចការទាំងឡាយ ក៏នឹងមិនអាចទៅដល់គោលដៅបានងាយស្រួលឡើយ ។

ព្រះសម្មាសម្ពុទ្ធ បានបែងចែកទេពកោសល្យជា ៣ យ៉ាង តែលោកមិនហៅទេពកោសល្យទេ លោកហៅតែត្រឹមថាកោសល្យប៉ុណ្ណោះ គឺ ៖

*១. អាយកោសល* ៖ គឺឆ្លាតក្នុងការចំរើន ដឹងថាអ្វីជាសេចក្តីចំរើន ការលូតលាស់ វឌ្ឍនភាព សេចក្តីសុខ សេចក្តីទុក្ខរបស់កិច្ចការ ហេតុការណ៍ ឬវត្ថុណាមួយ ថារបស់នោះមានការចំរើនដូចម្តេច និងអ្វីជាប្រភពនៃសេចក្តីចំរើននោះ ។

*២. អបាយកោសល* ៖ គឺការឈ្លៀវឆ្លាតក្នុងសេចក្តីវិនាស ការចុះអន់ថយសេចក្តីទុក្ខ ហាយនភាពរបស់កិច្ចការ ហេតុការណ៍ ឬវត្ថុណាមួយ ថារបស់នោះមានការចុះអន់ថយដូចម្តេច និងអ្វីជាប្រភពដែលនឹងនាំឱ្យរបស់នោះមានហាយនភាព ។

តាមធម្មតា ក្នុងលោកនេះ តែងតែមានរបស់ជាគូៗ «*ទ្វិនិយម* ៖ (Dualism) ដូចជា សុខ-ទុក្ខ, ស-ខ្មៅ, ល្អ-អាក្រក់, វិជ្ជមាន-អវិជ្ជមាន, ចំរើនវិនាស, ប្រយោជន៍-មិនមានប្រយោជន៍ ។ អាយកោសល គឺជាការដឹងឈ្លៀវឆ្លាតក្នុងអ្វីដែលជាផ្នែកល្អដែលមនុស្សចូលចិត្ត ឯអបាយកោសល គឺការដឹងក្នុងអ្វីដែលជាផ្នែកមិនល្អដែលមនុស្សមិនចូលចិត្ត ។ អ្នកដឹកនាំ លុះត្រាតែដឹង និងប៉ិន ប្រសប់ទាំង ២ យ៉ាង ទើបអាចយកការដឹង ឬដំណឹងនោះមកធ្វើការសិក្សា ដើម្បីរកនវិធី ››

www.budinst.gov.kh www.elibraryofcambodia.org

ឧបាយដែលនឹងនាំទៅរកសេចក្ដីចំរើននោះ និងឧបាយវិធីដើម្បីកំចាត់នូវហាយនភាពនោះបាន ។ ពាក្យចាស់ខ្មែរពោលទុកថា « *កាំបិតចិតដងឯង* » ជាពាក្យបញ្ជាក់នូវការដឹង ឬការឆ្លៀវឆ្លាត ដែលមិនគ្រប់ជ្រុងជ្រោយ គឺដឹងតែមួយៗ ។

*៣. ឧបាយកុសល* ៖ គឺការឆ្លៀវឆ្លាត ប៉ិនប្រសប់ក្នុងឧបាយវិធីយុទ្ធវិធី ផ្លូវ មគ្គ ដើម្បីដោះស្រាយបញ្ហាទាំងឡាយ និងដើម្បីធ្វើឱ្យសំរេចនូវកិច្ចការទាំងឡាយ ។ ឧបាយកុសល អាចប្រៀបធៀបនឹងអនុត្តរិយៈទាំង ៦ ដែលបានអធិប្បាយរួចមកហើយ ។



ទេពកោសល្យទាំង ៣ គឺជារបៀប «ព្រួញមួយបាញ់បានសត្វ ២»

www.budinst.gov.kh www.elibraryofcambodia.org

# អ្នកមានយុត្តិធម៌

យុត្តិធម៌ ជាពាក្យសក្តិសិទ្ធិ !

សក្តិសិទ្ធិ ព្រោះថា ដោយហេតុតែពាក្យនេះឯង ដែលធ្វើឱ្យមនុស្សទាំងឡាយហ៊ានស្លាប់ ហ៊ានងើបឡើងតស៊ូ ដើម្បីទាមទារយក ៖

យុត្តិធម៌ក្នុងការកាត់សេចក្តី យុត្តិធម៌ក្នុងការបែងចែក យុត្តិធម៌ក្នុងការប្រើប្រាស់ យុត្តិធម៌ក្នុងការរស់នៅ ... ។

សក្តិសិទ្ធិ ព្រោះថា ដោយហេតុតែពាក្យនេះឯង ដែលធ្វើឱ្យអ្នកដែលគេប្រគល់នាទីសំរាប់ " ផ្តល់យុត្តិធម៌ " ឱ្យគេ ត្រូវធ្លាក់ពីលើកៅអី អស់បុណ្យសក្តិធ្លាក់អំណាច រត់ចោលជួរ ស្លាប់ខ្លួន និងធ្លាក់នរក ។

យុត្តិធម៌នៅត្រង់ណា !

ជាទូទៅ កាលណានិយាយពីរឿងយុត្តិធម៌ គេតែងតែនឹកឃើញពីរឿងជញ្ជីង ជាពិសេស ជញ្ជីងដែលស្ថិតនៅនឹងហោជាងពីមុខសាលាកាត់សេចក្តី ឬសាលាយុត្តិធម៌ ។



គេគូរជញ្ជីងថាសពីរនេះ ជាតំណាងយុត្តិធម៌ ដោយឱ្យថាសទាំងពីរនេះបះស្មើគ្នា បានន័យថា ទ្រនិចកណ្តាលចង្អុលចំលេខសូន្យ ។

www.budinst.gov.kh www.elibraryofcambodia.org

អ្នកដែលគូររូបជញ្ជីង តែងតែខំគូរឱ្យបះស្មើគ្នាជានិច្ច តែទោះជាខំគូរថ្លិតថ្លង់យ៉ាងណាក៏ដោយ ក៏អ្នកដែលឈរមើលនៅតែថាមិនស្មើ គឺបើមិនផ្អៀងខាងឆ្វេង ក៏ផ្អៀងខាងស្តាំ ។ ខ្ញុំមិនដឹងថា ព្រោះអ្នកគូរ គូរមិនស្មើ ឬក៏ព្រោះអាការៈផ្អៀងឬព្រោះផែនដីរាងមូល ឬក៏ព្រោះភ្នែកអ្នកមើលមិនល្អ ។ បើអ្នកអានណាអាចដឹងក៏សូមមេត្តាប្រាប់ខ្ញុំឱ្យបានដឹងផង ។

ក្នុងការថ្លឹង បើទ្រនិចចង្អុលចំលេខសូន្យ បានន័យថា ថាសទាំងសងខាងមានទម្ងន់ស្មើគ្នា តែជញ្ជីងហ្នឹងយុត្តិធម៌ ឬមិនយុត្តិធម៌ មិនទាន់អាចថាបានទេ ព្រោះគេអាចកែឆ្នៃជញ្ជីងឱ្យចង្អុលនៅចំសូន្យដដែល តែទម្ងន់ដែលថ្លឹងបាន មិនមានមាត្រដ្ឋានទេ ដូច្នេះហើយបានជាគេត្រូវសន្មតយកកូនជញ្ជីងណាមួយជាមាត្រដ្ឋានសំរាប់ជាសកល ( កូនជញ្ជីងធម៌ ) និងតួជញ្ជីង ក៏ជាជញ្ជីងធម៌ដែរ ។

ដូចគ្នាដែរ ក្នុងការរកយុត្តិធម៌ ឬផ្តល់យុត្តិធម៌ឱ្យដល់ជនណាមួយ គេត្រូវតែមានមាត្រដ្ឋានយុត្តិធម៌មួយជាគោល ជាទីអាង ។ តែខ្ញុំគិតថា មាត្រដ្ឋានយុត្តិធម៌នេះ នឹងមានយុត្តិធម៌សំរាប់ខ្លួនវាផ្ទាល់ ក៏នៅពេលណាដែល « មនុស្សអ្នកតែង » និង «មនុស្សអ្នកប្រើ» មាត្រដ្ឋានយុត្តិធម៌នោះ ជាមនុស្សដែលមិនមានការលំអៀងនៅក្នុងចិត្តរបស់ខ្លួនជាមុនសិន ។

ឧទាហរណ៍ ៖ បើអ្នកតែងមាត្រដ្ឋានយុត្តិធម៌ ជាមនុស្សលំអៀងឆ្វេង មាត្រដ្ឋានដែលយកទៅប្រើនោះ ថ្វីដ្បិតតែយុត្តិធម៌ តែជាយុត្តិធម៌ខាងឆ្វេង ម្យ៉ាងទៀត បើអ្នកតែងមាត្រដ្ឋាននោះទៀងត្រង់ហើយ តែអ្នកដែលយកមាត្រដ្ឋាននោះទៅប្រើជាមនុស្សលំអៀងស្តាំ យុត្តិធម៌នោះក៏លែងទៅជាយុត្តិធម៌ហើយ គេហៅថាអយុត្តិធម៌ ។

ដូច្នេះ យុត្តិធម៌ ឬអយុត្តិធម៌ សំខាន់នៅលើអ្នកតែងច្បាប់យុត្តិធម៌ និងអ្នកប្រើយុត្តិធម៌ ដែលជា « មនុស្ស » នេះផង ។ ព្រះសម្មាសម្ពុទ្ធ លោកបាន

www.budinst.gov.kh www.elibraryofcambodia.org

បង្ហាញហេតុ ៤ យ៉ាង ដែលនាំឱ្យអ្នកកាន់យុត្តិធម៌លំអៀង ដែលនាំឱ្យអ្នកចង់ប្រើយុត្តិធម៌ ប្រើយុត្តិធម៌មិនបានត្រឹមត្រូវ ។ ព្រះអង្គហៅហេតុដែលនាំឱ្យលំអៀងនោះថា « អគតិ ៤ យ៉ាង » គឺ ៖

១. *ឆន្ទាគតិ* ៖ លំអៀងព្រោះស្រឡាញ់ ។ អ្នកដឹកនាំ នឹងទៅជាមនុស្សអយុត្តិធម៌ កាលណាសេចក្តីស្រឡាញ់ ការចូលចិត្ត ការប្រកាន់ថានេះជាកូនចៅអញ នេះជាបក្សពួកអញ ចូលមកសណ្ឋិតនៅក្នុងចិត្តរបស់ខ្លួន ។ ពាក្យចាស់លោកថា *« យល់ញាតិ ឃ្លាតច្បាប់ »* ។

២. *ទោសាគតិ* ៖ លំអៀងព្រោះក្រោធ ព្រោះស្អប់ អ្នកហ្នឹងមិនមែនជាគ្នាអញ មិនមែនបក្សពួកខ្លួន អ្នកហ្នឹងធ្លាប់ធ្វើបាបក្រុមអញ ។ល។ បើកំហឹងនិងសម្អប់ចូលក្នុងចិត្តហើយ យុត្តិធម៌ប្រាកដជារត់ចេញពីក្នុងខ្លួនអ្នកដឹកនាំហើយ ។ ពាក្យចាស់លោកថា *« ខឹងខូច ខឹងខាត ខឹងខុស »* ។

៣. *ភយាគតិ* ៖ លំអៀងព្រោះភ័យ ព្រោះខ្លាច ។ អ្នកដឹកនាំ ព្រោះមានសេចក្តីភ័យខ្លាចក្នុងចិត្តថា បើអញធ្វើត្រឹមត្រូវទៅ អ្នកនោះនឹងបៀតបៀនដល់ខ្លួនអញ បក្សពួកអញ កូនចៅអញជាមិនខាន ក៏សំរេចចិត្តធ្វើអំពើនោះដោយអយុត្តិធម៌ទាំងដឹងខ្លួនថា រឿងនោះមិនត្រឹមត្រូវទេ ។

៤. *មោហាគតិ* ៖ លំអៀងព្រោះវង្វេង ព្រោះមិនដឹងដល់សាច់រឿង ។ មោហាគតិ ជាការលំអៀងដែលប្រាសចាកការពិត គ្មានដំណឹង ឬពតិមានឱ្យច្បាស់លាស់ពីរឿងដែលត្រូវផ្តល់យុត្តិធម៌ របៀបឱ្យសត្វស្វាអានសំបុត្រ ។

អគតិទាំង ៤ យ៉ាងនេះ ជាដំណើរដែលអ្នកដឹកនាំត្រូវចៀសវាងកុំឱ្យកើតមានដល់ខ្លួន និងត្រូវការពារកុំឱ្យកើតមានដល់បរិមណ្ឌលដែលខ្លួនកាន់ការគ្រប់គ្រង។ បើអគតិកើតមានទីណា ការលោភលន់ ការពុករលួយ ការឃោរឃៅ ក៏នឹងកើតមានដល់ទីនោះជាមិនខាន ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះសម្មាសម្ពុទ្ធបានសម្តែងពីរឿងការវិនិច្ឆ័យក្តីទៀងត្រង់ថា ៖

*ន តេន ហោតិ ធម្មដ្ឋោ យេនត្ថំ សហសា នយេ*

*យោ ច អត្ថំ អនត្ថញ្ច ឧភោ និច្ឆេយ្យ បណ្ឌិតោ ។*

អ្នកកាត់សេចក្តីដោយមិនយកចិត្តទុកដាក់ មិនចាត់ថាជាអ្នកទៀងធមិទេ ចំណែកអ្នកឆ្លាតវិនិច្ឆ័យដោយពិចារណាគ្រប់ជ្រុងជ្រោយ ទាំងខាងត្រូវ ទាំងខាងខុស ទើបចាត់ថាជាអ្នកទៀងធមិ ។

*អសាហសេន ធម្មេន សមេន នយតី បរេ*

*ធម្មស្ស គុត្តោ មេធាវី ធម្មដ្ឋោតិ បវុច្ចតិ ។*

បណ្ឌិតកាត់សេចក្តីអ្នកដទៃដោយការពិចារណាត្រឹមត្រូវ ដោយការទៀងធមិជាប់ជានិច្ច ប្រកាន់យកការត្រឹមត្រូវជាធំ អ្នកនោះបានឈ្មោះថាជាអ្នកទៀងធមិ។

www.budinst.gov.kh www.elibraryofcambodia.org

# អ្នកមានសេចក្ដីព្យាយាម

យើងបាននិយាយរួចមកហើយនូវលក្ខណះរបស់ប្រធាន ដែលជាវេវចន-សព្ទនឹងពាក្យថាអ្នកដឹកនាំ ។ អ្នកដឹកនាំដែលមានសមត្ថភាព ត្រូវមានលក្ខណៈជាប្រធាន គឺមានសេចក្ដីព្យាយាម ឧស្សាហ៍ យកចិត្តទុកដាក់ខ្វាយខ្វល់ចំពោះកិច្ចការទាំងពួង មិនខ្ជិលច្រអូស ឬធ្វើអ្វី១នោះទេ ។

ព្រះសម្មាសម្ពុទ្ធ បានមានពុទ្ធដីកាថា « *វីរិយេន ទុក្ខមច្ចេតិ* » មនុស្សយើងអាចឆ្លង ឬឈ្នះនូវសេចក្ដីទុក្ខ ឬបញ្ហាទាំងឡាយបានដោយសេចក្ដីព្យាយាម ។ សេចក្ដីព្យាយាមនេះគឺជាមគ្គ ឬវិធីមួយក្នុងចំណោមមគ្គទាំង ៨ ដែលព្រះអង្គបានរកឃើញសំរាប់បដិបត្តិឆ្ពោះទៅរកការត្រាស់ដឹងជាព្រះពុទ្ធ និងបានសំរេចនូវនិព្វានដែលជាគោលដៅដ៏ធំខ្ពស់បំផុត ។ បុគ្គលអ្នកព្យាយាម ជាអ្នកដែលមិនចេះអស់សង្ឃឹមក្នុងជីវិត ឱ្យតែមានថ្ងៃស្អែក គេនឹងដើរទៅមុខជានិច្ច ។ អ្នកមានសេចក្ដីព្យាយាម គ្មានគំនិតទុទិដ្ឋិនិយមទេ គេជឿថា គ្មានរឿងអ្វីដែលថាដោះស្រាយមិនរួចនោះទេ គ្រប់បញ្ហាសុទ្ធតែមានផ្លូវដែលអាចដោះស្រាយបាន ។

សេចក្ដីព្យាយាមរបស់អ្នកដឹកនាំ ត្រូវប្រកបដោយអង្គ ៤ ប្រការ គឺព្យា-យាមការពារកុំឱ្យកើតបញ្ហា ព្យាយាមកំចាត់បញ្ហាដែលមានឱ្យអស់ទៅ ព្យាយាមសាងនូវសេចក្ដីសុខស្រួលឱ្យកើតមានច្រើនឡើង និងព្យាយាមរក្សានូវសេចក្ដីសុខស្រួល នោះឱ្យគង់វង្សចំរើនតទៅទៀត ។

ខ្ញុំមិនបាននិយាយបន្ថែមពីរឿងប្រធានទៀតទេ សូមអញ្ជើញបើកត្រឡប់ក្រោយទៅអានត្រង់វគ្គប្រធានចុះ ។ ក្នុងទីនេះ ខ្ញុំសូមជូនជាគន្លឹះសំរាប់ងាយស្រួល

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងការចងចាំអំពីសេចក្តីព្យាយាមនេះ គឺ ៈ

« ព្យាយាមមាន ៤ យ៉ាងគឺ ការពារវិបត្តិ
កំចាត់បញ្ហា បង្កើតសុខា រក្សាការចម្រើន » ។

www.budinst.gov.kh www.elibraryofcambodia.org

## គុណសម្បត្តិទី ៣

# គុណធម៌

**សុខភាព** ជាគុណសម្បត្តិទាក់ទងនឹងខាងរាងកាយ ដែលអ្នកដឹកនាំទាំងឡាយ ត្រូវយកចិត្តទុកដាក់ថែទាំឱ្យបានរឹងប៉ឹង ។

**សមត្ថភាព** ជាគុណសម្បត្តិទាក់ទងនឹងសតិបញ្ញា ដែលអ្នកដឹកនាំទាំងឡាយ ត្រូវបំពេញបន្ថែមឱ្យរឹតតែខ្លាំងក្លាឡើងៗ ជាលំដាប់ ។

រីឯ **គុណធម៌** វិញ ជាគុណសម្បត្តិទាក់ទងនឹងផ្លូវចិត្ត និងការប្រព្រឹត្តិ ដែលអ្នកដឹកនាំត្រូវថែរក្សា និងគោរពស្មើអាយុជីវិតរបស់ខ្លួន ។ បើប្រៀបធៀបនឹងផ្ទះដែលជាលំនៅស្ថានរបស់មនុស្ស គុណសម្បត្តិទាំង ៣ ប្រការនេះ មានមុខងារដូចតទៅ ៖




សុខភាព ទុកដូចជាសសរផ្ទះ មាននាទីសំរាប់ទ្រ

សមត្ថភាព ទុកដូចជាជញ្ជាំងផ្ទះ មាននាទីសំរាប់បិទបាំង

គុណធម៌ ទុកដូចជាដំបូលផ្ទះ មាននាទីសំរាប់ការពារ

www.budinst.gov.kh www.elibraryofcambodia.org

*យថា អគារំ ទុច្ឆន្នំ វុដ្ឋិ សមតិវិជ្ឈតិ*
*ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។*

ភ្លៀងរមែងលេចស្រោចផ្ទះដែលគេប្រក់មិនជិតយ៉ាងណា រាគៈរមែងលេចស្រោចចិត្តដែលគេមិនបានអប់រំ ក៏យ៉ាងនោះដែរ ។

ធម្មតាផ្ទះ តែងតែមានដំបូលជាគ្រឿងសំរាប់ការពារកុំឱ្យទឹកភ្លៀងទទឹកទ្រព្យសម្បត្តិដែលមាននៅក្នុងផ្ទះ ។ ព្រោះបើលេចភ្លៀងហើយ ទ្រព្យសម្បត្តិអស់នោះ ក៏នឹងខូចខាតអសារបង់ជាមិនខាន ។

ដូចគ្នាដែរ អ្នកដឹកនាំដែលមិនបានអប់រំចិត្តឱ្យស្ថិតនៅក្នុងគន្លងគុណធម៌ រមែងតែងតែត្រូវរាគៈ គឺសេចក្តីស្រើបស្រាល និងលោភៈ គឺសេចក្តីប្រាថ្នាចង់បានហួសហេតុចូលមកគ្របដណ្តប់ ។ ឯការខឹងក្រោធ ការបៀតបៀន ក៏ចូលមកតាមជាប់ជាប់ ហើយពេលនោះឯង ដែលមោហៈ គឺសេចក្តីវង្វេងមិនដឹងខុសត្រូវចូលមកគ្របឱ្យងងឹតមើលអ្វីមិនឃើញ មានតែអគតិធម៌ប៉្យាងប៉ុណ្ណោះ ។ តែដល់ប៉ុណ្ណោះហើយ កេរ្តិ៍ឈ្មោះ កិត្តិយស ទ្រព្យសម្បត្តិ ដែលខំរកបានមកដោយកម្លាំងសុខភាព និងសមត្ថភាព ក៏នឹងត្រូវរលាយសាបសូន្យជាមិនខាន ។

ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ថា ៖

*ន អត្តហេតុ ន បរស្ស ហេតុ*
*ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ*
*ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ*
*ស សីលវា បញ្ញវា ធម្មិកោ សិយា ។*

មិនគប្បីធ្វើអាក្រក់ព្រោះតែប្រយោជន៍ខ្លួន ឬប្រយោជន៍អ្នកដទៃ មិន

www.budinst.gov.kh www.elibraryofcambodia.org

គប្បីប្រាថ្នាបុត្រ ប្រាថ្នាទ្រព្យ ប្រាថ្នារដ្ឋ ឬសេចក្តីសំរេចដល់ខ្លួនដោយអធម៌ឡើយ គប្បីមានសីល មានបញ្ញាតាំងខ្ជាប់នៅក្នុងធម៌ជានិច្ច ។

## គុណធម៌ចាំបាច់របស់អ្នកដឹកនាំ

គុណធម៌សំរាប់ដឹកនាំមានច្រើនណាស់ នៅក្នុងគម្ពីរព្រះពុទ្ធសាសនា ។ ក្នុងទីនេះ រចនាករនឹងលើកយកតែ ២ យ៉ាងមកអធិប្បាយតែប៉ុណ្ណោះ ព្រោះពីរយ៉ាងនេះ គ្របដណ្តប់នូវគុណធម៌ដទៃទៀតសព្វគ្រប់ទាំងអស់ ។ គុណធម៌ ២ យ៉ាង នោះគឺ ៖

១. ទសពិធរាជធម៌ មាន ១០ ចំណុច

២. ព្រហ្មវិហារធម៌ មាន ៤ ចំណុច

គុណធម៌ទាំង ២ យ៉ាងនេះ មានសេចក្តីអធិប្បាយ ដូចតទៅ ៖

www.budinst.gov.kh www.elibraryofcambodia.org

# ក- ទសពិធរាជធម៌

**ទសពិធរាជធម៌** ជាធម៌សំរាប់ព្រះរាជា ដែលនឹងអាចធ្វើឱ្យមហាជនស្រែកអបអរសាទរថា " ពេញចិត្ត ពេញចិត្ត ពេញចិត្ត " ទៅតាមអត្ថន័យរបស់ពាក្យ " រាជា " ដែលប្រែថា " ពេញចិត្ត " ដូចដែលបានអធិប្បាយរួចមកហើយ ។ "ពេញចិត្ត២ " ជាឧទានសព្ទដែលសម្ដែងឱ្យឃើញនូវទឹកចិត្តរីករាយ មានសេចក្ដីសុខរបស់អ្នកដើរតាមចំពោះអ្នកដឹកនាំដែលបានបំពេញ " ធម្មៈ " ឬនាទីរបស់ខ្លួនបានដោយត្រឹមត្រូវ និងទៅតាមគោលបំណងរបស់មហាជន ។ " រាជា " ឬអ្នកដឹកនាំណា ដែលបានធ្វើឱ្យមហាជនឧទានយ៉ាងដូច្នេះបាន យើងតែងហៅថា " ធម្មរាជា " ឬ " ធម្មិករាជា " ។ ធម្មរាជា ឬ ធម្មិករាជា ជាអ្នកដឹកនាំនៅក្នុងក្ដីស្រមៃរបស់ខ្មែរដែលថា ថ្ងៃណាមួយលោកនឹងមកជួយដឹកនាំ គ្រប់គ្រងមហាជនខ្មែរដែលកំពុងរងទុក្ខវេទនា ឱ្យបានសេចក្ដីសុខ និងវឌ្ឍនភាពជាអារ្យប្រទេស ។

ក្នុងរាជាណាចក្រខ្មែរ ព្រះរាជាដែលគ្រងរាជ្យក្រោយសម័យអង្គរ សុទ្ធតែជាពុទ្ធសាសនិកជន ដូច្នេះហើយបានជាគោលធម៌ទសពិធរាជធម៌នេះ ជាគោលដែលព្រះរាជាគ្រប់ព្រះអង្គត្រូវគោរពប្រតិបត្ត និងលើកតម្កល់ទុកជាមាត្រដ្ឋាន សំរាប់ការគ្រប់គ្រងប្រទេស ។

ថ្វីដ្បិតតែទសពិធរាជធម៌ ប្រែថា ធម៌សំរាប់ព្រះរាជា តាមកាលសម័យនៃរាជានិយមក្ដី តែដូចយើងបានឃើញហើយថា រាជា សំដៅដល់អ្នកណាដែលជាប្រមុខគេ ដឹកនាំគេ ។ ដូច្នេះ គោលធម៌នេះ មិនត្រឹមតែសំរាប់ព្រះរាជា ១ អង្គដែលគ្រប់គ្រងរាជ្យទេ គឺបានដល់អ្នកណាដែលមាននាទីទទួលខុសត្រូវក្នុងការដឹកនាំគេ ប្រធានគេ ឬប្រមុខគេគ្រប់ជាន់ថ្នាក់ទាំងអស់ ។

ក្នុងប្រទេសឥណ្ឌា ដែលជាប្រភពនៃពុទ្ធសាសនា ពាក្យថាក្សត្រ ឬ វណ្ណៈក្សត្រ ពុំមែនសំដៅតែទៅលើក្សត្រ ដែលសោយរាជ្យនោះទេ ។ ពាក្យថាក្សត្រ មានន័យក្នុងឋានៈជាអ្នកដែលមានមុខនាទីក្នុងការគ្រប់គ្រងប្រទេស គ្រប់គ្រងខេត្ត ជាទ័ពចម្បាំង ជាមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ។ បើនិយាយតាមភាសាបច្ចុប្បន្ន បានដល់រដ្ឋាភិបាល គណៈរដ្ឋមន្ត្រី និងមន្ត្រីរាជការទាំងពួង ។

ទសពិធរាជធម៌ មានទាំងអស់ ១០ ប្រការគឺ :

*១. ទាន* ការឱ្យ

*២. សីល* ការប្រព្រឹត្តល្អ

*៣. បរិច្ចាគ* ការបរិច្ចាគ

*៤. អាជ្ជវៈ* ការស្មោះត្រង់

*៥. មទ្ទវៈ* ការទន់ភ្លន់

*៦. តបៈ* ការដុតកិលេស

*៧. អក្កោធៈ* ការមិនក្រោធ

*៨. អវិហឹង្សា* ការមិនបៀតបៀន

*៩. ខន្តី* ការអត់ធន់

*១០. អវិរោធនៈ* ការមិនធ្វើខុស

រាជធម៌ទាំង ១០ នេះ អាចចងចាំជាភាសាបាលីខ្លី ៗ ថា :

*ទានំ សីលំ បរិច្ចាគំ អាជ្ជវំ មទ្ទវំ តបំ*

*អក្កោធំ អវិហិង្សញ្ច ខន្តិញ្ច អវិរោធនំ ។*

www.budinst.gov.kh www.elibraryofcambodia.org

# ទាន គឺការឱ្យ

ទាន ជារឿងដំបូងដែលត្រូវនិយាយ ។ បានជាប្រការនេះ ក្លាយមកជាប្រការទីមួយ ព្រោះជារឿងដំបូងបំផុតក្នុងចំណោមរឿងនានា ។ កំណើតរបស់មនុស្សយើងសព្វថ្ងៃនេះគឺ ទានរបស់មាតាបិតាយើងដែលលោកបានផ្ដល់ឱ្យ ។ គ្រាន់តែយើងប្រសូតពីផ្ទៃមាតាភ្លាម យើងក៏ចាប់ផ្ដើមទទួលទានភ្លាម . រាប់ចាប់តាំងពីបៅដោះ បរិភោគអាហារ ការបីបមថ្នាក់ថ្នមរបស់អ្នកដែលចិញ្ចឹមយើង អ្នកពយើង ងូតទឹកឱ្យយើង រហូតដល់រៀនសូត្រចេះដឹង ដូច្នេះ យើងត្រូវដឹងគុណរបស់ទានថាព្រោះទាននេះឯង ដែលយើងមានជីវិតរស់នៅរហូតមកដល់សព្វថ្ងៃ ។

" *យើងទទួលទានពីគេ គេទទួលទានពីយើង* " ប្រការនេះឯងដែលយើងធ្វើឱ្យជីវិតនេះ សង្គមនេះ និងពិភពលោកនេះ មានមនុស្សរស់នៅដោយការស្រឡាញ់គ្នា នៅជាមួយគ្នាបាន ។

អាស្រ័យដូចនេះហើយបានជា ខ្មែរយើងប្រើពាក្យ " *ទទួលទាន* " ជំនួសការស៊ី ការផឹក ដែលជាការប្រើដ៏បង្កប់ន័យសំរាប់ជាគតិឱ្យអ្នកដែលចង់រស់ មានជីវិតទាំងឡាយដឹងថា ជីវិតអ្នករស់បានដោយសារ " ការទទួលទាន " ឬ " ការទទួលអំណោយ " ពីអ្នកដទៃ និងជាការបង្ហាត់ឱ្យអ្នកនោះដឹងគុណគេ ហើយព្យាយាម និងតបស្នងសងគុណវិញ ដោយការឱ្យទានទៅអ្នកដទៃទៀតផង ។

ពាក្យថា *ទាន* ប្រើចំពោះបរិបទ ២ យ៉ាងគឺ :

*ក. ទាន* ការឱ្យដើម្បីជម្រះកិលេសដែលមាននៅក្នុងចិត្តរបស់អ្នកឱ្យ,

*ខ. ទាន* ការឱ្យដើម្បីជួយសង្គ្រោះអ្នកទទួលទាន ។

www.budinst.gov.kh www.elibraryofcambodia.org

ទាំងពីរយ៉ាងនេះ មានរបៀបឱ្យខុសប្លែកគ្នាខ្លះ ដូចតារាងខាងក្រោម ៖

| ទាន - ដើម្បីកំចាត់កិលេស | ទាន - ដើម្បីសង្គ្រោះ |
|---|---|
| - អ្នកឱ្យត្រូវមានសីល<br>- រីតតែឱ្យច្រើនរីតតែល្អ<br>- ចេតនាដើម្បីយកបុណ្យ និងលះសេចក្ដីកំណាញ់ក្នុងខ្លួន<br>- ឱ្យដោយការគោរព ។ល។ | - មានសីល ឬគ្មានមិនសំខាន់<br>- ឱ្យដល់អ្នកដែលយើងចង់ឱ្យគេស្រឡាញ់យើងវិញ<br>- ឱ្យរបស់ដែលត្រូវចិត្តអ្នកទទួល<br>- ចង់បានឱ្យគេមានសេចក្ដីស្រឡាញ់ដល់ខ្លួន<br>- ត្រឹមតែសម្ដែងចិត្តស្មោះដល់អ្នកទទួល ។ល។ |

តាមការប្រៀបធៀបនេះ យើងឃើញមានលក្ខណៈខុសគ្នាគឺ ៖

*ក. ការឱ្យដើម្បីជម្រះកិលេស* មានគោលបំណងដើម្បីបដិបត្តខាងផ្នែកផ្លូវចិត្តរបស់ខ្លួន ។

*ខ. ការឱ្យដើម្បីសង្គ្រោះ* មានគោលបំណងដើម្បីប្រណិប័តន៍យកចិត្តអ្នកទទួល ។

អ្នកដឹកនាំគប្បីមានទានទាំង ២ បរិបទនេះ ព្រោះបរិបទមួយៗមានគុណប្រយោជន៍ចំពោះអ្នកដឹកនាំទាំងអស់ ។ ក្នុងបរិបទទីមួយ ទានមានប្រយោជន៍ក្នុងការកំចាត់នូវសេចក្ដីលោភ ដែលជាប្រភពនៃអំពើអាក្រក់គ្រប់បែប គ្រប់យ៉ាង ។ ជាពិសេស អំពើពុករលួយផ្សេងៗ កើតមកពីលោភៈនេះឯង ។ ដូច្នេះទើបការឱ្យទាន

www.budinst.gov.kh www.elibraryofcambodia.org

នេះ ជាការចាំបាច់ដែលត្រូវធ្វើ ដើម្បីការពារកុំឱ្យលោភកើតឡើង និងមានផលក្នុងផ្នែកសាសនា ដូចជាបុគ្គលដែលធ្វើទានរមែងទៅកាន់សុគតិភព និងជាដំណាក់ដំបូងឆ្ពោះទៅរកការមានសីល និងភាវនា ។ ការឱ្យទានបែបនេះ ស្របទៅតាមច្បាប់ធម្មជាតិ គឺនៅពេលយើងកើតមក ឥតមានអ្វីជាប់មកទេ លុះដល់ស្លាប់ទៅវិញ ក៏ឥតមានអ្វីយកទៅជាមួយដែរ អ្វីដែលយើងបានពេលដែលយើងមានជីវិតរស់នៅ សុទ្ធតែរបស់ធម្មជាតិទាំងអស់ ដូច្នេះ ដល់ពេលស្លាប់ ធម្មជាតិក៏ទាររបស់នោះវិញ តែបើយើងបានឱ្យទាន ចិត្តយើងគ្មានសេចក្ដីលោភ បុណ្យកើតដល់យើង អាចទៅជាមួយយើងបាន ពេលដែលយើងស្លាប់ទៅ ។

ម្យ៉ាងទៀត ការឱ្យទានដើម្បីកំចាត់សេចក្ដីលោភនេះ ចំពោះអ្នកដឹកនាំគឺជាការសាងបារមីឱ្យកើតដល់ខ្លួន ឱ្យមហាជនទុកចិត្តលើភាពស្មោះត្រង់ចំពោះនាទីដឹកនាំរបស់អ្នកដឹកនាំបាន ។

ទានប្រភេទនេះ អាចកំចាត់នូវពាក្យស្លោកខ្មែរថា ៖

*« មាន់នៅនឹងស្រូវ លែងអីនឹងស៊ីស្រូវ »*

ចំពោះទានក្នុងបរិបទទី ២ មានប្រយោជន៍ក្នុងការគ្រប់គ្រងមហាជន ។ ទាននោះមានន័យដល់ការជួយសង្គ្រោះ ការទំនុកបំរុងប្រជារាស្ត្រឱ្យបានសេចក្ដីសុខផ្សេងៗផង និងមានន័យបានដល់ការឱ្យដើម្បីទិញទឹកចិត្ត, ចងទឹកចិត្ត, ឱ្យគេនឹក ឱ្យស្រឡាញ់ខ្លួន ដើម្បីឱ្យអ្នកស្រុកអួតថា " លោកហ្នឹងជាមនុស្សចិត្តល្អ " ដើម្បីបានផលប្រយោជន៍ត្រឡប់ពីអ្នកទទួលនោះមកវិញ ។

ផលនៃការឱ្យទានបែបបរិបទទី ២ នេះគឺ ៖

ក. បានទទួលសេចក្ដីស្រឡាញ់ពីអ្នកទទួល ។

ខ. បានទទួលអាមិសតបត្រឡប់មកវិញ ដូចជាទ្រព្យរបស់, កិត្តិយស, កេរ្តិ៍ឈ្មោះ ។

www.budinst.gov.kh www.elibraryofcambodia.org

## ប្រភេទរបស់ទាន

មានមាន ៣ ប្រភេទគឺ ៖

*វត្ថុទាន* គឺការឱ្យវត្ថុ, *ធម្មទាន* គឺការឱ្យធម្មៈ និង *អភ័យទាន* គឺការឱ្យអភ័យ ។

*១. វត្ថុទាន* ៖ គឺការឱ្យវត្ថុបច្ច័យ ឱ្យឧបករណ៍ធ្វើដើមទុន គឺឱ្យអ្វីដែលជាបច្ច័យសំរាប់ជីវិតដល់ប្រជារាស្ត្រ ដល់សាសនា ដល់អ្នករដ្ឋការ ដល់អ្នកដែលមានសេចក្តីត្រូវការ ។ ការឱ្យនេះ លោកប្រើពាក្យថា " ចែងចែកឱ្យ " គឺមិនមែនរហូតដល់ទៅអស់ពីដៃនោះទេ ។

វត្ថុទានដែលឃើញមានក្នុងបាលី ដូចជា បាយ ទឹក សំពត់ ថ្នាំកែរោគ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសំណាក់អាស្រ័យ គ្រឿងបំភ្លឺ ។ល។

*២. ធម្មទាន* ៖ គឺការឱ្យចំណេះវិជ្ជា និងឱ្យសមត្ថភាពដែលអាចឱ្យអ្នកទទួលយកទៅជួយខ្លួនគេបាន ឱ្យធម្មៈ ឱ្យការប្រៀនប្រដៅ ដូចជា ជួយដាស់តឿនណែនាំ ការជួយពន្យល់ឱ្យស្គាល់ពីការប្រព្រឹត្តល្អ ការលើកទឹកចិត្តឱ្យប្រឹងប្រែងតស៊ូជាដើម ។ ព្រះសម្មាសម្ពុទ្ធ លោកសម្តែងថា " *សព្វទានំ ធម្មទានំ ជិនាតិ* " " ការឱ្យធម្មទាន ជាទានប្រសើរជាងគេបង្អស់ " ។ ខ្មែរយើងប្រើធម្មទាននេះក្នុងន័យជាការឱ្យសៀវភៅដែលអាចផ្តល់ចំណេះដឹងដល់អ្នកអានបាន ។ អ្នកដឹកនាំដែលល្អ គឺអ្នកដែលបានគ្រប់គ្រងប្រជារាស្ត្របានល្អ នាំទៅរកសេចក្តីសុខពិតប្រាកដ ហើយបានទាំងប្រាប់នូវរបៀបគ្រប់គ្រងដ៏ល្អនោះ ដល់អ្នកក្រោយទៀតផង ដូចជា ការសរសេរសៀវភៅ ក្បួនខ្នាត ដែលមានប្រយោជន៍ចំពោះការគ្រប់គ្រងនោះ ។

បើយើងប្រែ " ធម្មទាន " ថាការឱ្យនាទីជាទាននោះ រឹតតែត្រូវទៅទៀតចំពោះភារកិច្ចជាអ្នកដឹកនាំ ទានដែលល្អជាទីបំផុតសំរាប់អ្នកដឹកនាំ គឺ " ការឧទ្ទិស

www.budinst.gov.kh www.elibraryofcambodia.org

នាទីអ្នកដឹកនាំ " របស់ខ្លួន ដើម្បីសេចក្ដីសុខរបស់មហាជន មិនឃើញពីប្រយោជន៍ខ្លួន កំចាត់នូវកិលេស លោភៈ ធ្វើឱ្យមហាជនទុកចិត្ត ប្ដូរស្លាប់ ប្ដូររស់ ។

៣. *អភ័យទាន* : គឺការឱ្យអភ័យទោសចំពោះមហាជន មានមេត្តាករុណា មិនមែនជាមនុស្សចងពៀរ ចងអាឃាត ព្យាបាទ ដោយប្រកាន់ថាអញធំ អ្នកណាប៉ះមិនបាន ។ ការអត់ទោសឱ្យ គឺការផ្ដាច់ពៀរ ផ្ដាច់ការសងសឹក ដូចពុទ្ធភាសិត លោកសម្ដែងថា :

*ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ*

*អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។*

តាំងតែពីដើមមក នៅក្នុងលោកនេះ ពៀរមិនដែលរំងាប់ដោយការចងពៀរទេ មានតែរំងាប់ដោយការមិនចងពៀរ ( ឱ្យអភ័យ ) នេះគឺជាច្បាប់អមតៈ ។

ធម្មរាជា ធម្មិក អ្នកដឹកនាំដែលល្អ ដែលមហាជនស្រឡាញ់ គឺ អ្នកដឹកនាំដែលចេះឱ្យ ចេះបែងចែក ។ អ្នកដឹកនាំគប្បីជាអ្នកឱ្យ អ្នកបែងចែក អ្នកធ្វើទានឱ្យដល់មហាជនខ្លួន ទាំងវត្ថុទាន ធម្មទាន និងអភ័យទាន ព្រោះថា *អ្នកឱ្យរមែងជាទីស្រឡាញ់របស់អ្នកទទួល* ។

www.budinst.gov.kh www.elibraryofcambodia.org

# សីល គឺប្រក្រតីភាព

**សីល** គឺជាគោលទី ២ ដែលធ្វើឱ្យព្រះរាជា ឬអ្នកដឹកនាំទាំងឡាយត្រូវមហាជនអបអរសាទរ ថា " ពេញចិត្តហើយ ពេញចិត្តហើយ, ជាខទី ២ ដែលធ្វើឱ្យកើតសេចក្ដីស្រឡាញ់ ភក្ដីភាព ការទុកចិត្ត ការគោរពគ្នា កើតសហប្រតិបត្តិការដល់គ្នានឹងគ្នាគ្រប់ៗផ្នែកទាំងអស់ ។

ឃើញពាក្យសីល អស់លោកអ្នកដឹកនាំអាចភ្ញាក់រលឹកថា " នេះគិតថាឱ្យអ្នកដឹកនាំចូលវត្តចូលវាំឬ ? តាមពិត ការរក្សាសីល ឬធ្វើសីលឱ្យកើតមានដល់ខ្លួនមិនជាការចាំបាច់ត្រូវតែទៅវត្តនោះទេ ដែលសំខាន់គឺការដែលមានសីល នៅពេលដែលកំពុងបំពេញនាទី ឬបដិបត្តិធម្មៈនោះឯង បានដល់គ្រប់ទីកន្លែងទាំងអស់ ដែលមានការនិយាយស្ដី និងការធ្វើការងារ ។ បើយើងមិនស្ញូវចូលចិត្តពាក្យថាសីលទេ យើងអាចប្រើពាក្យ " *វិន័យ* " មកជំនួសវិញក៏បាន ព្រោះវិន័យ គឺសីលហ្នឹងឯង ។

សីល ឬវិន័យនេះ ជាតួសំខាន់ណាស់ក្នុងការធ្វើដំណើរទៅដល់គោលដៅជីវិត គឺព្រះនិព្វាន តាមគតិពុទ្ធសាសនា ។ មុននឹងព្រះសម្មាសម្ពុទ្ធព្រះអង្គបរិនិព្វាន ព្រះអង្គបានផ្ដាំផ្ញើថា " *អត់ពីតថាគតទៅ មានតែធម៌ និងវិន័យទេ ដែលជាសាស្ដារបស់អ្នក* " ។ ឬអាចនិយាយបានថា ពុទ្ធសាសនាក្ដី សេចក្ដីសុខក្ដី ព្រះនិព្វានក្ដី នឹងត្រូវរលាយសាបសូន្យ កាលណាគ្មានវិន័យ ឬ សីលទេ ។

បើនឹងចង់និយាយតាមភាសានីតិសាស្ត្រ សីល ឬវិន័យ បានដល់ច្បាប់ដែលម្នាក់ៗត្រូវគោរព និងអនុវត្តតាមដើម្បីសេចក្ដីសុខរៀបរយក្នុងសង្គម ។ *សង្គមដែលគ្មានច្បាប់ គឺសង្គមដែលមិនមែនជាសង្គម ។*

" *អង្គុយជិតច្បាប់ កុំយកច្បាប់ទ្រាប់អង្គុយ* " ជាពាក្យដែលខ្មែរយើងនិយាយឡើងដើម្បីរំលឹក និងព្រមានចំពោះអ្នកដឹកនាំទាំងឡាយ និងជាការបង្ហាញ

www.budinst.gov.kh www.elibraryofcambodia.org

ថា មហាជនត្រូវការឱ្យអ្នកដឹកនាំគោរពច្បាប់ មានវិន័យ និងរក្សាសីលឱ្យខ្ជាប់ខ្ជួន ។

អ្នកដឹកនាំដែលមិនគោរពច្បាប់ គ្មានវិន័យ គ្មានសីល អ្នកដឹកនាំនោះនឹងក្លាយទៅជាអ្នកដឹកនាំផ្តាច់ការ ឃោរឃៅ រាស្ត្រមានតែសេចក្តីទុក្ខ ដូចដែលបានពោលហើយពីទំព័រដំបូង ក្នុងរឿងសារសំខាន់របស់អ្នកដឹកនាំ ។ ក្នុងកុលចិរដ្ឋិតិធមិ គឺធមិសំរាប់ធ្វើឱ្យវង្សត្រកូល ក្រុមគ្រួសារ អាចស្ថិតស្ថេរតពូជពង្សវង្សដំណែលបានយូរ ព្រះសម្មាសម្ពុទ្ធបានបង្ហាញគោល ៤ យ៉ាងសំរាប់អនុវត្ត គឺ :

*១. នដ្ឋគវេសនា* : របស់បាត់ របស់អស់ ចេះរកមកទុក,

*២.ជិណ្ណបដិសង្ខរណា* : របស់ចាស់ទ្រុឌទ្រោម ចេះជួសជុលប៉ះប៉ុន,

*៣. បរិមិតបាណភោជនា* : ស្គាល់ប្រមាណក្នុងការបរិភោគ ក្នុងការប្រើប្រាស់

*៤. អធិបច្ចសីលវន្តស្ថាបនា* : តែងតាំងអ្នកមានសីលឱ្យធ្វើជាមេផ្ទះ ផ្ទះក៏ដូចជាសង្គម ហើយដូចជាប្រទេសដែរ កាលណាមានអ្នកដឹកនាំមិនល្អហើយ ផ្ទះ សង្គម ប្រទេសនោះ នឹងដល់ការវិនាសអន្តរាយជាពុំខាន ។ លើកជាឧទាហរណ៍ ឱ្យច្បាស់នោះ គឺប្រទេសខ្មែរនេះតែម្តង ។ បើអ្នកដឹកនាំមិនគោរពច្បាប់ គ្មានវិន័យ គ្មានសីល ប្រទេសជាតិនឹងរលាយ ។ តើមហាជនសុខចិត្តឱ្យប្រទេសជាតិរលាយ ឬដកអ្នកដឹកនាំចេញ ? នាបច្ចុប្បន្ននេះ យើងឃើញថា ពិភពលោកមានការមិនពេញចិត្តចំពោះអ្នកដឹកនាំដែលគ្មានសីល ទើបបានជាមានការរំលំរបបផ្តាច់ការនានា កើតឡើងស្ទើរពាសពេញពិភពលោក ។

## ប្រភេទសីល :

សីលដែលជាតួគោលនៃបណ្តាសីលទាំងអស់មាន ៤ យ៉ាង ដែលលោកហៅថាចតុប្បារិសុទ្ធិសីល គឺ :

www.budinst.gov.kh www.elibraryofcambodia.org

១. *ឥន្ទ្រិយសំវរសីល* ៖ ការប្រុងប្រយ័ត្ន សង្រួម រាំងនូវឥន្ទ្រីយ៍ទាំង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ និងចិត្ត ។ បានជាលោកហៅរបស់ទាំង ៦ នេះថា ឥន្ទ្រីយ៍ ដែលប្រែថា " ជាធំ " លើរាងកាយយើង ព្រោះថា ទាំង ៦ នេះ ជាធំ ជាប្រធាននៃសេចក្ដីសុខ សេចក្ដីទុក្ខទាំងឡាយ ។ បើយើងប្រើវាបានត្រឹមត្រូវ យើងក៏នឹងបានសុខ បើប្រើមិនបានត្រឹមត្រូវ យើងក៏នឹងបានទុក្ខ ។

អ្នកដឹកនាំភ្នែកក្រឡិតក្រឡាប់ៗ អ្នកខ្លះត្រចៀកស្រាល អ្នកខ្លះច្រមុះពូកែស្រង់ក្លិនរឿងដែលមិនគួរគប្បី, អ្នកខ្លះនិយាយប៉ប៉ាច់ប៉ប៉ោច និងអាការដៃ អាការជើង ព្រហើន មិនសុភាពរាបទាប, អ្នកខ្លះចិត្តរវើរវាយ មិននឹង ចាប់នេះ ចាប់នោះ មិនខ្ពោះត្រង់ណា ។ លក្ខណៈទាំងអស់នេះ គឺលក្ខណៈដែលមិនសង្រួមឥន្ទ្រីយ៍ទាំង ៦ ។ អ្នកដឹកនាំបែបនេះ មិនអាចឱ្យមហាជនទុកចិត្តបានទេ *ព្រោះបុគ្គលិកលក្ខណៈរបស់លោកដែលកើតពីការមិនសង្រួមនូវឥន្ទ្រីយ៍ទាំង ៦ នេះ វាបង្ហាញនូវអ្វីដ៏ច្រើនដែលមិនជាទីគួរឱ្យទុកចិត្ត* ។

អ្នកដឹកនាំដែលល្អ គឺអ្នកដឹកនាំដែល នឹងធឹង ។ នឹងធឹង ក្នុងទីនេះ គឺការដែលសង្រួមរក្សាឥន្ទ្រីយ៍ទាំង ៦ មិនឱ្យរំភើបទៅតាមការពញ្ញាក់របស់អារម្មណ៍ និងហេតុការណ៍ទាំងឡាយដែលកើតមានចំពោះខ្លួន ។ ជាឧទាហរណ៍ យើងនាំទាហាន ១០០ នាក់ចេញទៅច្បាំង ។ គ្រាន់តែឮសូរកាំភ្លើងភ្លាម ស្រាប់តែយើងញ័រមាត់ប៉ប៉ុប ភ្នែកក្រឡិតក្រឡាប់ៗ រកតែរត់ ។ គ្រាន់តែឃើញប៉ុណ្ណោះ ទាហាននៅក្រោមបង្គាប់គ្មានអស់ទឹកចិត្តប្រយុទ្ធទៅហើយ ។ តែបើយើងនឹងធឹង យើងភ័យដូចគ្នា តែយើងចេះរក្សាភ្នែក មាត់ឱ្យស្ថិតនៅជាប្រក្រតី គឺមានសីល ព្រោះសីល ប្រែឱ្យចំថា " *ប្រក្រតីភាព* " នោះកូនចៅយើង ក៏មិនអាចដឹងថាយើងតក់ស្លុតដែរ ខំស្ដាប់បញ្ជាយើងដោយកោតក្រែង ។

អ្នកដឹកនាំដែលមានឥន្ទ្រីយ៍មិននឹងធឹង មិនប្រក្រតី មិនអាចធ្វើជាគូ

www.budinst.gov.kh www.elibraryofcambodia.org

សន្តនាចំពោះប្រទេសជាតិ ព្រោះនឹងអាចឱ្យគេចាប់ផ្ទាក់បាន ហើយរកចំណុចខ្សោយសង្កត់យើងជាមិនខាន ។

ឧទាហរណ៍មួយទៀត យើងកំពុងបើកឡាន ។ ករណីយកិច្ចរបស់យើងគឺនាំអ្នកជិះឱ្យដល់គោលដៅ យើងត្រូវមានសតិក្នុងការបើកបរ ។ តែកុងដែលកំពុងតែនិយាយប៉ប៉ោច ងាកនេះ ងាកនោះ ស្ដាប់ភ្លេងឱ្យរងំ ទំពារនៅនឹងមាត់មិនដាច់ តែកុងនោះនឹងត្រូវទទួលគ្រោះថ្នាក់ឆាប់ៗជាមិនខាន ។ រឿងនេះ ក៏ព្រោះការមិនរក្សាឥន្ទ្រិយ៍ទាំង ៦ ឱ្យស្ថិតនៅក្នុងការមានសីល ឬប្រក្រតីភាពនេះឯង ។

ខ្មែរយើងមានសុភាសិតមួយ ដែលសម្ដែងអំពីការមិនសង្រួមអណ្ដាត គឺ *« កំភ្លាញស្លាប់ ព្រោះមាត់ »* ។

ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយវិការ និងចិត្ត ដែលឥតរបប ឥតរបៀប គ្មានសីល គ្មានប្រក្រតីភាព រមែងនាំអ្នកជាម្ចាស់ឱ្យដល់នូវសេចក្ដីអន្តរាយ ។ អ្នកដឹកនាំឃើញទោសដូច្នេះហើយ គប្បីរក្សាបុគ្គលិកលក្ខណៈរបស់ខ្លួនឱ្យបានល្អ ដើម្បីជាទីទុកចិត្តរបស់មហាជន ។

*២. បាដិមោក្ខសំវរសីល* ៖ គឺជាការប្រុងប្រយ័ត្នសង្រួម រវាំង គោរព ថែរក្សានូវព្រះបាដិមោក្ខ ។ បាដិមោក្ខ គឺជាច្បាប់ ឬធម្មនុញ្ញ ដែលព្រះភិក្ខុសង្ឃត្រូវសិក្សា និងអនុវត្តតាមជាប់ជានិច្ច ជាទីប្រជុំនូវសិក្ខាបទទាំង ២២៧ សិក្ខាបទ ។ បើប្រៀបធៀបមកនឹងខាងអាណាចក្រ គឺរដ្ឋធម្មនុញ្ញ ដែលជាទីប្រជុំនៃបណ្ដាច្បាប់ទាំងឡាយដែលមាន សំរាប់ការគ្រប់គ្រងប្រទេស ។

ការរក្សាសីល ខទី ២ នេះ គឺការគោរពច្បាប់ ។ ច្បាប់មាន ២ យ៉ាងគឺ ច្បាប់ខាងសាសនាមួយ និងច្បាប់ខាងរដ្ឋមួយ ។

• *រក្សាច្បាប់ខាងសាសនា* គឺការរក្សាសីល ៥ ឬ បញ្ចសីលឱ្យបានជាប់ជានិច្ច ព្រោះការរក្សាសីលនេះ ជាការបណ្ដុះនូវគុណធម៌ ឱ្យកើតមានដល់ខ្លួនឯង

www.budinst.gov.kh www.elibraryofcambodia.org

ដោយផ្ទាល់ ជាទីទំនុកចិត្តជាន់ដំបូងសំរាប់មហាជន ។

សីល ៥ ដែលអ្នកដឹកនាំត្រូវរក្សាឱ្យបានខ្ជាប់ខ្ជួន គឺ :

១. ការមិនបៀតបៀនប្រទូសរ៉ាយជីវិត និងរាងកាយអ្នកដទៃ ក្នុងបាលីលោកសម្តែងថា មិនសម្លាប់ជីវិតសត្វ *(បាណាតិបាតា វេរមណី)* ។

២. ការមិនលួច បោកបន្លំ ឆកោង ស៊ីសំណូកទ្រព្យសម្បត្តិរបស់អ្នកដទៃ ។ ក្នុងបាលីលោកសម្តែងថា មិនលួចទ្រព្យអ្នកដទៃ*(អទិន្នាទានា វេរមណី)*។

៣. ការមិនប៉ះពាល់កូនប្រពន្ធ ស្វាមី ភរិយារបស់ជនដទៃ មិនប្រព្រឹត្តខុសក្នុងកាម ដូចជាការលេងស្រីពេស្យាជាដើម *(កាមេសុមិច្ឆាចារា វេរមណី)* ។

៤. ការមិននិយាយកុហក មុសា បោកបញ្ឆោត ញុះញង់ ចាក់ដោតគេ *(មុសាវាទា វេរមណី)* ។

៥. ការមិនសេពនូវគ្រឿងស្រវឹងទាំងឡាយមាន ស្រា កញ្ឆា អាភៀន ហេរ៉ូអ៊ីនជាដើម ដែលជាគ្រឿងនាំឱ្យសតិមិនល្អ កើតការប្រមាទ *(សុរាមេរយមជ្ជ-បមាទដ្ឋានា វេរមណី)* ។

សីល ៥ នេះ ជាសីលមូលដ្ឋាន ជាសីលដំបូងសំរាប់អ្នកដឹកនាំ ។ សូមលោកអ្នកសាកល្បងស្រមៃលមើល៍ ថាបើយើងយកជនដែលជាមនុស្សឃោរឃៅជាឃាតករ ជាមនុស្សលួចប្រាក់ជាតិ ជាមនុស្សជ្រមុជជ្រមុលតែពីរឿងកាម យកប្រពន្ធកូនគេស្រេចតែចិត្ត ជាមនុស្សនិយាយមិនពិត គ្មានសច្ចៈ បាតដៃខ្នងដៃ និងជាមនុស្សស្រវឹងខ្ជួប ញៀនកញ្ឆា អាភៀន មកធ្វើជាអ្នកដឹកនាំ អនាគតវាសនារបស់យើង តើយើងពេញចិត្តឬទេ ? ព្រមទេ ? ហើយតើអ្វីនឹងកើតឡើង បើខ្មែរយើងមានតែអ្នកដឹកនាំប្រភេទនេះ ។

ជាពិសេស សីល ខ ទី ១ ដែលទាក់ទងទៅនឹងការសម្លាប់គ្រប់ប្រភេទ ។ បើអ្នកណាជាអ្នករំលោភសិទ្ធិជាន់ដំបូងរបស់បុគ្គល គឺជីវិតជាទីស្រឡាញ់ហើយ អ្នក

www.budinst.gov.kh www.elibraryofcambodia.org

នោះ មិនគួរមកធ្វើជាអ្នកដឹកនាំឡើយ ។ ជីវិតនេះ រួមដល់ជីវិតរបស់ព្រៃព្រឹក្សា និងជីវិតរបស់ពួកសត្វព្រៃទាំងឡាយ ដែលកំពុងតែត្រូវវិនាសអន្តរាយផុតពូជ មួយថ្ងៃបន្តិចៗ ជាលំដាប់ ។

ខ្មែរចង់បានអ្នកដឹកនាំ ដែលជាអ្នកគោរពជីវិតជនដទៃ ស្មើនឹងជីវិតរបស់ខ្លួន ។ ខនេះ សូមឱ្យអ្នកដឹកនាំទាំងឡាយពិចារណាឱ្យបានដឹតដល់ផង ។

• *រក្សាច្បាប់ខាងអាណាចក្រ* ៖ គឺការគោរពច្បាប់ ធ្វើតាមច្បាប់ មិនរំលោភច្បាប់ ។ ច្បាប់ចែងយ៉ាងណា ក៏គោរពតាមយ៉ាងនោះ ។

ក្នុងអាណាចក្រ ច្បាប់ដែលធំជាងគេ គឺច្បាប់រដ្ឋធម្មនុញ្ញ ដែលជាសំឡេងរបស់រាស្ត្រ ជាអំណាចរបស់រាស្ត្រ ជាការបញ្ញត្តិរបស់រាស្ត្រ ។ អ្នកដឹកនាំត្រូវបដិបត្តតាមនិតិបញ្ញត្តិនេះឱ្យបានត្រឹមត្រូវ និងត្រឹមត្រង់ ។ អ្នកដឹកនាំដែលរំលោភច្បាប់ មិនអាចស្ថិតនៅលើបល្ល័ង្កជាអង្វែងបានឡើយ ។

*៣. អាជីវបារិសុទ្ធិសីល* ៖ គឺការមានអាជីវកម្មបរិសុទ្ធ ។ អាជីវកម្មបរិសុទ្ធ គឺអាជីវកម្មណាដែលមិនធ្វើឱ្យក្តៅក្រហាយដល់ខ្លួន និងសង្គម ។

អាជីវកម្មមិនបរិសុទ្ធ ដូចជារកស៊ីខុសច្បាប់ មិនបង់ពន្ធ បង់ភាស៊ី ដោយអាងថាខ្លួនជាអ្នកធំ រកស៊ីរត់ពន្ធអាភៀន កញ្ឆា បើកបនស្រីពេស្យា កន្លែងអបាយមុខរាំច្រៀង បើកកាស៊ីណូ ល្បែងស៊ីសង ជំនួញលក់មនុស្ស និងជំនួញខុសច្បាប់ដទៃៗទៀត ។ រឿងនេះ រួមទាំងការបានលុយមកដោយមិនត្រឹមត្រូវ ដូចជាស៊ីសំណូកសូកប៉ាន់ ឬបង្កើតក្រុមទុច្ចរិតផ្សេងៗ ។

ចុះបើអ្នកដឹកនាំរកស៊ីមិនសុចរិតទៅហើយ ប្រជារាស្ត្រឯណានឹងរកស៊ីតាមសម្មាអាជីវោ ? ទូទាំងប្រទេស ពិតជាមានតែមនុស្សរកស៊ីមិនត្រឹមត្រូវទាំងអស់មិនខាន ។

ឧទាហរណ៍ ដែលអាចនឹងឃើញងាយៗ គឺ ដូចជាការដឹកឥវ៉ាន់ទៅលក់

www.budinst.gov.kh www.elibraryofcambodia.org

ក្រៅប្រទេស ។ យើងធ្លាប់តែដឹករបស់ល្អ ត្រូវតាមមាត្រដ្ឋានទៅលក់ ស្រាប់តែពេលមួយ យើងក្លែងបន្លំឥវ៉ាន់ យកឥវ៉ាន់ក្លែងក្លាយ ឬមទៅលក់ ។ យើងចំណេញច្រើនមែន តែយើងនឹងត្រូវខូចហាងឆេង គេលែងទិញពីយើងទៀត ហើយពេលនេះឯងដែលផលប្រយោជន៍យើងត្រូវបាត់បង់ ។

ដូច្នេះហើយបានជាព្រះសម្មាសម្ពុទ្ធ លោកបានដាក់សម្មាអាជីវៈ ជាមគ្គមួយក្នុងចំណោមមគ្គទាំង ៨ សំរាប់ជាផ្លូវឆ្ពោះទៅរកសេចក្ដីសុខ ។

*៤. បច្ចយសន្និស្សិតសីល* ៈ គឺការសង្រួម ប្រយ័ត្នក្នុងការពិចារណាលើការប្រើប្រាស់បច្ច័យ ។ បច្ច័យ គឺគ្រឿងទ្រទ្រង់សំរាប់ឱ្យជីវិតរស់នៅបានដោយសុខស្រួល មាន ៤ យ៉ាងដោយសង្ខេបគឺ បាយទឹកសំរាប់បរិភោគ, សំពត់ខោអាវស្លៀកពាក់, ផ្ទះសម្បែងសំរាប់ស្នាក់អាស្រ័យនៅ និងថ្នាំសង្កូវសំរាប់ព្យាបាលរោគ ។

សីលត្រង់ ខ នេះ លោកមានន័យថា ក្នុងការប្រើប្រាស់បច្ច័យទ្រទ្រង់ជីវិតទាំងឡាយនោះ គប្បីប្រើដោយពិចារណាថា ជីវិតរបស់យើងជាប់ជំពាក់ដោយការចិញ្ចឹមពីអ្នកដទៃ ដោយទាន ឬអំណោយពីរាស្ត្រ ដូច្នេះ ត្រូវប្រើដោយប្រុងប្រយ័ត្ន មិនខ្ជះខ្ជាយ មិនបំផ្លាញ ។ ក្នុងព្រះពុទ្ធសាសនា គោលបំណងនៃការប្រើប្រាស់បច្ច័យ គឺដើម្បីធ្វើកម្មដ្ឋាន ។ កម្មដ្ឋាន ប្រែថាទីតាំងនៃការងារ ដែលជាហេតុនាំឱ្យរួចចាកផុតពីសេចក្ដីទុក្ខ ។ ការបរិភោគប្រើប្រាស់ដោយមិនមានប្រយោជន៍ ដោយមិនធ្វើអ្វីបណ្ដោយឱ្យពេលវេលាកន្លងទៅ ឈ្មោះថាបានកំពុងតែសម្លាប់ខ្លួនឯង ។ ជីវិតនេះត្រូវការធ្វើអភិវឌ្ឍន៍ពីភាវៈថោកទាប " *បុថុជ្ជន* " ឆ្ពោះទៅរកភាពថ្លៃថ្នូរ " *អរិយៈជន* " ហើយដែលអាចសម្រេចបាន ដោយសារការធ្វើការងារដែលត្រឹមត្រូវ ។

ដូច្នេះ សីលត្រង់ចំណុចនេះ *មានគោលបំណងឱ្យអ្នកដឹកនាំចេះពិចារណា និងយល់ពីតម្លៃប្រាក់កាសរបស់រាស្ត្រ ដែលខំបង់ពន្ធមកឱ្យ និងប្រើប្រាស់ដោយសន្សំសំចៃ ប្រុងប្រយ័ត្នមិនខ្ជះខ្ជាយ និងប្រឹងប្រែងបំពេញ*

www.budinst.gov.kh www.elibraryofcambodia.org

*នាទី ( កម្មដ្ឋាន ) របស់ខ្លួនឱ្យសមទៅតាមចេតនារបស់រាស្ត្រ ដែលបានប្រគល់សេចក្តីទុកចិត្តមកឱ្យយើង ។*

ចំណុចមួយទៀត ដែលទាក់ទងនឹងបច្ច័យសន្និស្សិតរបស់អ្នកដឹកនាំដែរនោះ គឺការប្រើប្រាស់នូវទ្រព្យសម្បត្តិធម្មជាតិរបស់ជាតិ ដែលមាននៅក្នុងប្រទេស ។ ទ្រព្យធម្មជាតិទាំងនោះ ជាសម្បត្តិរបស់ជនទូទាំងប្រទេស និងគ្រប់ជំនាន់ទាំងអស់ អ្នកដឹកនាំត្រូវមានវិចារណញ្ញាណ ក្នុងការប្រើប្រាស់ទ្រព្យធម្មជាតិទាំងនោះ ដោយប្រុងប្រយ័ត្ន និងដើម្បីជាប្រយោជន៍ពិតៗរបស់រាស្ត្រ ត្រូវតាមសេចក្តីត្រូវការរបស់រាស្ត្រ ។ ហើយកុំភ្លេចថា ពេលមនុស្សជំនាន់នេះស្លាប់ទៅ កូនចៅយើងជំនាន់ក្រោយ ត្រូវរស់នៅលើទឹកដីនេះជាបន្តទៅទៀត គប្បីអភិរក្សថែរក្សាទ្រព្យនេះឱ្យនៅបានយូរលង់ ជាប្រយោជន៍ដល់ជនជំនាន់ក្រោយតរៀងទៅ ដូចច្បាប់កេរ្តិ៍កាលបានដាស់តឿនថា ៖

*កូនអើយកេរ្តិ៍មេបា ចូររក្សាគន់គិតគ្រង*
*ថែទាំចាំរួសរង ប្រុងប្រយ័ត្នប្រយោជន៍យូរ ។*

## ផលប្រយោជន៍របស់សីល

- *សីលេន សុគតឹ យន្តិ* សីលនាំមកនូវស្ថានសួគ៌នាបច្ចុប្បន្ន ឱ្យកើតឡើង ។ សង្គមមនុស្សនឹងទៅជាសង្គមស្ថានសួគ៌ បើអ្នកដឹកនាំមានសីលជាគំរូឱ្យប្រជារាស្ត្រធ្វើតាម ។

- *សីលេន ភោគសម្បទា* សីលនាំឱ្យភោគសម្បត្តិចំរើនសម្បូរ ប្រើមិនចេះអស់ ។ សង្គមខ្មែរ នឹងទៅជាសង្គមដែលមានការអភិវឌ្ឍន៍ក្លាយទៅជាអារ្យ-ប្រទេស កាលណាអ្នកដឹកនាំមានសីលជាគំរូឱ្យប្រជាពលរដ្ឋនាំគ្នាកាន់តាម ។

- *សីលេន និព្វុតឹ យន្តិ* សីលនាំឱ្យសង្គមបាននូវសេចក្តីសុខ ត្រជាក់

www.budinst.gov.kh www.elibraryofcambodia.org

ត្រជាំ គ្មានភ្លើងសង្គ្រាម ។

*សីលមេវ ឥធ អគ្គំ បញ្ញវា បន ឧត្តមោ*

*មនុស្សេសុ ច ទេវេសុ សីលបញ្ញាណតោជយំ*

ក្នុងលោកនេះ សីលគឺជារបស់ដ៏ប្រសើរបំផុត

ក្នុងលោកនេះ អ្នកមានប្រាជ្ញាជាមនុស្សឧត្តមបំផុត អាស្រ័យ
ដោយសារសីល និងបញ្ញា គេអាចយកជ័យជំនះលើមនុស្ស
និងទេវតាទាំងឡាយបាន ។

www.budinst.gov.kh www.elibraryofcambodia.org

# បរិច្ចាគ គឺការលះបង់

ទាន ក្នុងទសពិធរាជធម៌ ខទី ១ បានដល់ការឱ្យទ្រព្យចំពោះអ្នកណាមួយ ឬក្រុមណានីមួយ ដើម្បីទាក់ទាញចងរឹតទឹកចិត្តរបស់គេឱ្យស្មោះស្ម័គ្រ ឱ្យស្រឡាញ់មកលើខ្លួន ។ ចំណែកបរិច្ចាគដែលជាគោលធម៌ទី ៣ នេះ បានដល់ការលះបង់សេចក្តីសុខរបស់ខ្លួន ឬទ្រព្យសម្បត្តិខ្លួន ដើម្បីប្រយោជន៍រួម មិនចំពោះអ្នកណា ឬក្រុមណាមួយឡើយ ដូចជា ៖

បរិច្ចាគកម្លាំង ដើម្បីកសាងថ្នល់,
បរិច្ចាគដី ដើម្បីកសាងមន្ទីរពេទ្យ,
បរិច្ចាគលោហិត ដើម្បីព្យាបាលអ្នកជំងឺ,
បរិច្ចាគទ្រព្យ ដើម្បីកសាងវត្តអារាម,
បរិច្ចាគសេចក្តីសុខផ្ទាល់ខ្លួន ដើម្បីសេចក្តីសុខមហាជន ។ ល ។

ទាំងនេះគឺជាតួយ៉ាងនៃគោលបដិបត្តិដែលហៅថាបរិច្ចាគ ដែលនឹងអាចធ្វើឱ្យមហាជននាំគ្នាស្រែកថា " ពេញចិត្ត១ " ចំពោះអ្នកដឹកនាំ ។ គប្បីសង្កេតថា ទានដែលធ្វើដោយអ្នកដឹកនាំ អាចនាំទាំងគុណ ទាំងទោស បើសិនជាអ្នកឱ្យមិនមានសិល្បៈក្នុងការឱ្យទេ ។ ដូចជានឹងអាចឱ្យអ្នកតូចមានការច្រណែនគ្នា បែកបាក់គ្នា ព្រោះយល់ថា អ្នកធំរគតិមកលើម្ខាង១ ដែលនឹងក្លាយទៅជារឿងរាលដាល លំបាកតាមក្រោយទៀត ។ ឯធ្វើការបរិច្ចាគវិញ មានតែផលល្អម្យ៉ាងប៉ុណ្ណោះ ព្រោះជាការឱ្យ ដោយមិនប្រាថ្នាផលប្រយោជន៍មកវិញឡើយ ទើបមិនមានអ្វីជាគ្រោះថ្នាក់ ។

www.budinst.gov.kh www.elibraryofcambodia.org

## វិធីបដិបត្តិក្នុងការបរិច្ចាគ

*មត្តា សុខបរិច្ចាគា បស្សេ ចេ វិបុលំ សុខំ*

*ចជេ មត្តាសុខំ ធីរោ សម្បស្សំ វិបុលំ សុខំ*

បណ្ឌិតកាលណាឃើញថា បើលះបង់នូវសេចក្តីសុខល្មមហើយ នឹងបាននូវសេចក្តីសុខដ៏ធំ ក៏គួរលះបង់នូវសេចក្តីសុខល្មមនោះចោល ។

ព្រះពុទ្ធវចនៈបទនេះ ជាមេបទសំរាប់អនុវត្តនូវការលះបង់ ។ សារសំខាន់ក្នុងពុទ្ធភាសិតនេះ គឺថា មុននឹងលះបង់ ឬបរិច្ចាគនូវអ្វី១ណានីមួយ គប្បីពិចារណាឱ្យបានច្បាស់លាស់ ។ បើឃើញច្បាស់ថា ការលះបង់នោះ នឹងបានទទួលប្រយោជន៍ច្រើនជាងខាតប្រយោជន៍ហើយ សឹមលះបង់ ។

ខ្មែរយើងលោកប្រាប់ថា ឱ្យធ្វើខ្លួនដូចដង្កូវបាក់ខ្នង គឺបើចាប់ត្រង់ណាហើយ ត្រូវចាប់ឱ្យបានច្បាស់សិន ទើបលែងកន្ទុយទៅតាមក្រោយ ។ នៅក្នុងការលះបង់នេះ ត្រូវស្ថិតនៅក្នុងគោលការណ៍ " *លះតូចដើម្បីយកធំ* " មិនមែន " *យកលោះទៅដូរលោះ* " នោះទេ ។ ដើម្បីឱ្យងាយយល់ថារបស់ណាតូច មានប្រយោជន៍តិច ហើយរបស់ណាធំ មានប្រយោជន៍ច្រើន ព្រះសម្មាសម្ពុទ្ធបានសំដែងអំពីលំដាប់នៃវត្ថុដែលត្រូវលះបង់ដូច្នេះ ។

*ធនំ ចជេ អង្គវរស្ស ហេតុ*

*អង្គំ ចជេ ជីវិតំ រក្ខមានោ*

*អង្គំ ធនំ ជីវិតញ្ចាបិ សព្វំ*

*ចជេ នរោ ធម្មមនុស្សរន្តោ ។*

គប្បីលះបង់ទ្រព្យសម្បត្តិ ដើម្បីរក្សាអវយវៈ

គប្បីលះបង់អវយវៈ ដើម្បីរក្សាជីវិត

គប្បីលះបង់ សូម្បីតែទ្រព្យ អវយវៈ និងជីវិត ដើម្បីថែរក្សាធម៌ ។

www.budinst.gov.kh www.elibraryofcambodia.org

• *ទ្រព្យសម្បត្តិ :* បានដល់មាសប្រាក់ កេរកង របស់គ្រប់បែបយ៉ាង ក្រៅពីខ្លួនប្រាណ សាច់ឈាមយើង រួមទាំងកម្មសិទ្ធិ និងផលប្រយោជន៍ ដែលនឹងអាចកឱ្យកើតជាទ្រព្យបានទៀតផង ដូចជាតំណែង អំណាច ជាដើម ។

• អវយវៈ : បានដល់រាងកាយ ដូចជាភ្នែក ត្រចៀក ច្រមុះ ដៃ ជើង ។ ល ។

• ជីវិត : បានដល់ជីវិតដែលមានដង្ហើមចេញចូល

• ធម៌ : បានដល់គុណធម៌ ដូចជាសន្តិធម៌ ការត្រឹមត្រូវ យុត្តិធម៌ ។

ទាំង ៤ យ៉ាងនេះ គឺជាលំដាប់នៃតម្លៃ សំរាប់វត្ថុដែលយើងនឹងត្រូវពិចារណាដើម្បីលះបង់ ។ យើងអាចដកស្រង់ចេញជារូប ដូចខាងក្រោម :




តែបើប្រៀបមនុស្សយើងនឹងដើមឈើ ដែលមានក្រមរ សំបក ស្រាយខ្លឹមវិញ យើងអាចគូររូបដូចខាងក្រោមនេះ ។

www.budinst.gov.kh www.elibraryofcambodia.org




## ក. លះបង់ទ្រព្យដើម្បីរក្សាអវយវៈ

ទ្រព្យជារបស់ក្រៅខ្លួន មិនទៀងទាត់ ឧបមាដូចជាក្រមរដើមឈើដែលមានសំរាប់រុំព័ទ្ធដើមឈើ ការពារកំដៅមួយរយៈ ហើយក៏រុះរោយទៅ ។ មាស ប្រាក់ក៏ដូចគ្នា បានហើយក៏អស់ទៅវិញ ព្រោះហេតុផ្សេងៗ មានស៊ី ចាយជាដើម ។ ហេតុដូច្នេះហើយបានជាទ្រព្យ ត្រូវជារបស់ដែលត្រូវលះបង់មុនគេ ព្រោះបើធៀបទៅនឹងអវយវៈ ទ្រព្យថោកជាងអវយវៈយើង ។

សំរាប់អ្នកដឹកនាំ ការលះបង់ទ្រព្យមាន ២ យ៉ាងគឺ :

- រូបទ្រព្យ : បានដល់ដីធ្លី ផ្ទះសម្បែង សត្វពាហនៈ យានជំនិះ មាស ប្រាក់ជាដើម ។
- នាមទ្រព្យ : បានដល់អំណាច កេរ្តិ៍ឈ្មោះ តំណែង ការឃើញតែប្រយោជន៍ខ្លួន សេចក្តីសុខ ស្រួល សេចក្តីស្នេហា ភាពឃោរឃៅ ការចងអាឃាត ព្យាបាទ កិលេស ឧបនិស្ស័យអាក្រក់ប្រចាំខ្លួនជាដើម ។ នាមទ្រព្យទាំងនេះ របស់ណាអាក្រក់ ក៏លះបង់ចេញ របស់ណាដែលមិនជាប្រយោជន៍ច្រើនដល់មហាជន ក៏សុខចិត្តលះបង់ចេញ ។ ជាឧទាហរណ៍ ការលះបង់នូវអំណាចរបស់មេដឹកនាំខ្លះក្នុងលោក នៅពេលដែលប្រជាពលរដ្ឋភាគច្រើន សំដែងនូវការមិនពេញចិត្ត ចុះចេញពីដំណែងនៅពេលដឹងថាខ្លួនឯងធ្វើខុស ជាដើម ។

www.budinst.gov.kh www.elibraryofcambodia.org

## ខ. លះបង់អវយវៈដើម្បីរក្សាជីវិត

អវយវៈ ជារបស់ដែលជាប់នឹងខ្លួន មានស្ថិរភាពជាងទ្រព្យសម្បត្តិ និងជារបស់ដែលសំរាប់បង្កើតនូវទ្រព្យសម្បត្តិ ទើបត្រូវមានតម្លៃជាងទ្រព្យសម្បត្តិ ។ ការលះបង់អវយវៈ បានដល់ការលះបង់ចំណែករបស់រាងកាយ ដែលមិនមានការប៉ះពាល់ដល់ជីវិត ដូចជាលះបង់កម្លាំង លះបង់សេចក្ដីសុខខាងរាងកាយ សុខចិត្តអត់ងងុយ ធន់នឿយហត់ ធន់ឈឺ ធន់ឃ្លាន សុខចិត្តបាត់បង់រូបឆោម. ដើម្បីបំពេញប្រយោជន៍រួម ។ អ្នកដឹកនាំដែលសុខចិត្តដើរសាកសួរសុខទុក្ខប្រជារាស្ត្រខ្លួន ដែលកំពុងរងគ្រោះដោយទឹកជំនន់ ដោយសង្គ្រាម សុខចិត្តទៅពិនិត្យមើលសុខទុក្ខអ្នកស្រុកដល់ជនបទក្រីក្រដាច់ស្រយាល ។ ល ។ ដោយមិនខ្លាចនឿយហត់ លំបាក ឈ្មោះថាលះបង់អវយវៈ ។

## គ. លះបង់ជីវិតដើម្បីរក្សាធម៌

ធម៌ បានដល់សេចក្ដីល្អ កិត្តិយស គុណធម៌ សីលធម៌ ដែលជាសម្បត្តិពិសេសសំរាប់មនុស្សយើង ជាខ្លឹមសាររបស់ជីវិត និងរាងកាយ ជាពិសេសគឺសំរាប់អ្នកដឹកនាំ ។ ជីវិតយើងតូចមួយត្រូវស្លាប់ ត្រូវលះបង់មែន តែជីវិតរាប់រយម៉ឺនសែនត្រូវរស់នោះ យើងក៏ត្រូវលះបង់ ។ ឧទាហរណ៍ នៅក្នុងសមរភូមិ យើងក៏របួស គេក៏របួស តែយើងមើលទៅឃើញថា ម្នាក់ហ្នឹងមានសារសំខាន់ណាស់ សំរាប់កងទ័ពទាំងមូល ប្រទេសជាតិទាំងមូល បើជីវិតអ្នកនោះនៅមាន នឹងកើតប្រយោជន៍ជាច្រើនដល់មហាជន យើងក៏សុខចិត្តលះបង់ថ្នាំព្យាបាលខ្លួនយើងឱ្យទៅអ្នកនោះវិញ ។ ឬដូចជា គេបង្ខំយើងឱ្យលក់ឯកសារសម្ងាត់សំរាប់ប្រទេស បើមិនលក់ទេ គេនឹងសម្លាប់យើងជាមិនខាន ។ យើងសុខចិត្តស្លាប់ ដោយមិនប្រាប់ការអាថ៌កំបាំងនោះទៅបច្ចាមិត្តដឹងជាដាច់ខាត ។ ល ។

អ្នកតាឃ្លាំងមឿង គឺជាបុគ្គលគំរូដ៏ឧត្ដមម្នាក់ក្នុងប្រវត្តិសាស្ត្រខ្មែរ ដែល

www.budinst.gov.kh www.elibraryofcambodia.org

សុខចិត្តលោតចូលក្នុងរណ្ដៅសម្លាប់ខ្លួន ដើម្បីពង្រឹងទឹកចិត្តទាហានខ្មែរ ដែលកំពុងច្បាំងនឹងសៀម រហូតដល់ទាហានខ្មែរមានទឹកចិត្តមោះមុតចូលប្រយុទ្ធ រហូតមានជ័យជំនះលើកងទ័ពសៀម ។ ព្រះអាចារ្យហែម ចៀវ ដែលសុខចិត្តទ្រាំលំបាករហូតដល់អស់ព្រះជន្មជីវិត ដើម្បីទាមទារឯករាជ្យពីបារាំងឱ្យមកប្រជារាស្ត្រខ្មែរ ក៏ជាគំរូនៃការលះបង់ជីវិតដើម្បីធម៌ដែរ ។ ជាពិសេសគឺ ព្រះបរមគ្រូសម្មាសម្ពុទ្ធអង្គយើងនេះឯង ដែលជាគំរូទុកឱ្យបរិស័ទដើរតាម គឺព្រះអង្គបានយកជីវិតជាដើមផាន់ ក្នុងការស្វែងរកសច្ចធម៌ ដើម្បីជួយដោះនូវសេចក្ដីទុក្ខរបស់មនុស្សលោក ។

# ប្រយោជន៍របស់ការលះបង់

សង្គមមនុស្ស ដែលនឹងអាចរស់រានមកដល់ពេលនេះបាន ក៏ពីព្រោះមានមនុស្សជាច្រើនដែលបានលះបង់នូវអ្វីៗគ្រប់បែបយ៉ាង តាំងពីទ្រព្យសម្បត្តិ អវយវៈ និងជីវិតដែលជាទីស្រឡាញ់របស់ខ្លួន ។ ការលះបង់ ពុំមែនជាករណីយកិច្ចដោយបង្ខំទេ តែគឺជាច្បាប់ធម្មជាតិដែលចែងមកសំរាប់ឱ្យយើងធ្វើ ។ ដើមឈើដែលមានស្លឹកលូតលាស់ល្អនៅរដូវវស្សា ព្រោះសម្បូរទឹក ត្រូវតែលះបង់នូវស្លឹករបស់ខ្លួនចេញនៅរដូវប្រាំងដែលខ្វះទឹក ព្រោះបើមិនដូច្នោះទេ ដើមឈើនោះមិនអាចរស់នៅបានឡើយ ព្រោះទឹកមិនគ្រប់គ្រាន់ ។ តែដោយព្រោះការលះបង់ស្លឹកចាស់នេះឯង ទើប ១ ខែ ២ ខែក្រោយមក ដើមឈើនោះបានទទួលនូវស្លឹកថ្មី និងផ្លែផ្កា គួរជាទីមនោរម្យ និងសំរាប់បន្តទៅទៀត ។

មនុស្សប្រសើរជាងរុក្ខជាតិ និងសត្វនានា ដូច្នេះ មនុស្សត្រូវមានបរិច្ចាគ ដើម្បីអនុជនជាន់ក្រោយរបស់ខ្លួនអាចរស់កើតមកទៀតបាន ។ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងថា " *អត្តត្ថបញ្ញា អសុចី មនុស្សា* " ជនមានប្រាជ្ញា តែជាអ្នកឃើញតែប្រយោជន៍ខ្លួន គឺជាមនុស្សអសោច ។ មនុស្សអសោច គឺមនុស្សស្អុយ ឬមនុស្សស្លាប់ ។ ធម្មតាមនុស្សស្លាប់ ពុំអាចនឹងផ្ដល់ផលប្រយោជន៍អ្វីដល់សង្គមបានឡើយ

www.budinst.gov.kh www.elibraryofcambodia.org

ហើយមនុស្សស្លាប់ មិនគប្បីទុកដាក់នៅក្នុងចំណោមមនុស្សរស់ឡើយ ។ ដូចគ្នានេះដែរ សង្គមណាដែលគ្មានមនុស្សបរិច្ចាគ មនុស្សដែលហ៊ានលះបង់ទេ សង្គមនោះគឺសង្គមស្លាប់ សង្គមស្អុយ សង្គមគ្មានការរីកចំរើន មានតែទុក្ខវេទនាតែប៉ុណ្ណោះ ។

ការលះបង់ ត្រូវចាប់ផ្តើមពីអ្នកដែលជាប្រមុខមកមុន ទើបអ្នកដែលនៅពីក្រោយអាចរៀនធ្វើតាមបាន ព្រោះប្រមុខ ជាមុខគេ ។

ការលះបង់ត្រូវចាប់ផ្តើមពីអ្នកដែលជាប្រធានមកមុន ព្រោះប្រធានមានន័យថា ព្យាយាមលះអំពើអាក្រក់ដែលមានឱ្យអស់ចេញពីក្នុងខ្លួន ។ បើប្រធានមានការលះបង់ហើយ អ្នកដែលជាកូនចៅ គង់នឹងធ្វើតាមមិនខាន ។

ស្រុកខ្មែរយើង មានសេចក្តីទុក្ខវេទនាគ្របដណ្តប់ច្រើនណាស់ អំពើអាក្រក់ទាំងឡាយ មានក្នុងសន្តានចិត្តក៏ច្រើន ។ បើអ្នកដឹកនាំព្យាយាមលះបង់អំពើអាក្រក់ លះបង់ទ្រព្យសម្បត្តិ ដើម្បីអវយវៈ លះបង់អវយវៈដើម្បីជីវិត និងលះបង់ជីវិតដើម្បីធម្មៈហើយ សន្តិភាព សន្តិសុខ យុត្តិធម៌ សេរីភាព សុភមង្គល ឧត្តមសុខក៏ប្រាកដជាកើតឡើងក្នុងសង្គមខ្មែរជាមិនខាន ។ ប្រទេសជប៉ុន បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ជាប្រទេសដែលក្រីក្រជាខ្លាំង ។ តែជប៉ុនឥឡូវនេះ បានក្លាយខ្លួនទៅជាប្រទេសមហាអំណាចខាងសេដ្ឋកិច្ចពិភពលោកយ៉ាងឆាប់រហ័ស ព្រោះដោយសារអ្នកដឹកនាំ និងពលរដ្ឋរបស់គេយល់ពីតម្លៃនៃការលះបង់ ដើម្បីធ្វើការងារកសាងប្រទេស ថ្វីដ្បិតតែប្រទេសជប៉ុន ពុំមានទ្រព្យសម្បត្តិអ្វីដែលគួរឱ្យចាប់អារម្មណ៍សោះឡើយ ។

ខ្មែរយើង ទ្រព្យសម្បត្តិជាតិច្រើនណាស់ លះបង់ប្រយោជន៍ផ្ទាល់ខ្លួន តែម្នាក់បន្តិច ប្រទេសយើងនឹងចម្រើនជាមិនខាន ។

## រស់ព្រោះហ៊ានស្លាប់

www.budinst.gov.kh www.elibraryofcambodia.org

# អាជ្ជវៈ គឺការត្រង់

**អាជ្ជវៈ** ប្លែងសព្ទមកពី ឧជុ ប្រែថា *"ការត្រង់"* ជារាជធម៌ ខទី ៤ ដែលប្រមុខណាមានក្នុងសន្តានហើយ នឹងអាចឱ្យមហាជនទាំងឡាយស្រែកអំណរថា "ពេញចិត្ត ពេញចិត្ត" ។

កាលណានិយាយពីពាក្យថា "ត្រង់" គេតែងតែនឹកដល់បន្ទាត់ដែលជាឧបករណ៍មាត្រដ្ឋានសំរាប់គូសបន្ទាត់ ។ បើគេចង់ដឹងថាគំនូសណាមួយ ឬខ្សែណាមួយត្រង់ ឬមិនត្រង់ ឬវៀចខ្លាំងប៉ុណ្ណា គេត្រូវយកគំនូសនោះទៅធៀបនឹងបន្ទាត់ត្រង់ ។ ដូចគ្នាដែរ "ត្រង់" កាលណាយកមកប្រើជាមួយមនុស្ស ដូចជា "មនុស្សត្រង់" ក៏នឹងធ្វើឱ្យមនុស្សនោះ នឹងក្លាយទៅជាមនុស្សមានមាត្រដ្ឋាន មនុស្សគំរូសំរាប់យកទៅវាស់មនុស្សឯទៀត ។ ដូច្នេះ អ្នកដឹកនាំទាំងឡាយដែលជាមនុស្សប្រមុខគេនោះ ត្រូវតែជាមនុស្សត្រង់ ព្រោះថា បើប្រធានទាំងឡាយមិនត្រង់ហើយ អ្នកនៅក្រោមទាំងឡាយ ក៏នឹងមិនត្រង់តាមជាបន្តបន្ទាប់ជាមិនខាន ។ ឯការដែលមិនត្រង់នោះ យើងដឹងគ្រប់គ្នាហើយថា គឺ ពាក្យកោង វៀចវេរ ក្រឡិកក្រឡក់នេះឯង ។

**លក្ខណៈរបស់ត្រង់** ៖ ក្នុងទសពិធរាជធម៌ ដែលជាធម្មៈទាក់ទងនឹងការគ្រប់គ្រងផ្លូវលោក ព្រះសម្មាសម្ពុទ្ធទ្រង់ប្រើពាក្យអាជ្ជវៈ ជាពាក្យសំរាប់អធិប្បាយពីរឿងត្រង់ តែនៅក្នុងទសបារមី ដែលជាធម្មៈសំរាប់បដិបត្តិដើម្បីឆ្ពោះទៅរកពុទ្ធភាវៈ ព្រះអង្គប្រើពាក្យសច្ចៈ សំរាប់អធិប្បាយពីរឿងត្រង់ ។ ដូច្នេះ អ្នកអាន ដែលពុំសូវធ្លាប់ជិតស្និទ្ធនឹងពាក្យអាជ្ជវៈនេះ ក៏សូមសម្គាល់ថា ពាក្យអាជ្ជវៈនេះមាន លក្ខណៈស្រដៀងនឹងពាក្យថាសច្ចៈដែរ ថ្វីដ្បិតតែមិនដូចទាំងស្រុង ក៏ដោយ ។

www.budinst.gov.kh www.elibraryofcambodia.org

បើយើងចង់ដឹងថា របស់ណាមួយត្រង់ ឬមិនត្រង់នោះ លោកឱ្យយើងពិនិត្យមើលលើចំណុច ៣ ចំណុចគឺ ដើម កណ្ដាល និងចុង ។




ព្រោះថា របស់ខ្លះត្រង់ពីដើមដល់ចុង, របស់ខ្លះត្រង់ពីដើមដល់កណ្ដាល ឯពីកណ្ដាលដល់ចុងក៏វៀច, របស់ខ្លះវៀចពីដើមដល់កណ្ដាល ដល់ចាប់ពីកណ្ដាលទៅចុង ត្រង់ក៏មាន ។ ដែលហៅថាត្រង់មែនទែននោះគឺ ត្រូវត្រង់តាំងពីដើម កណ្ដាល និងចុង ។

ចុះចំពោះមនុស្សវិញ តើយើងមើលត្រង់ណា ? ការមើលមនុស្ស លោកថាឱ្យមើលនូវ ទង្វើ ឬ កម្ម របស់អ្នកនោះ ព្រោះបើមើលរូបមនុស្ស យើងមិនអាចរក " ត្រង់ " ឃើញទេ ។ កម្មរបស់មនុស្សយើងមាន ដើម កណ្ដាល ចុង ដូចគ្នានឹងវត្ថុដែរ គឺ ៖

ដើម គឺការគិត

កណ្ដាល គឺសម្ដី

ចុង គឺទង្វើ

ការគិត គឺចេតនារបស់អ្នកធ្វើ ដែលនឹងធ្វើឱ្យអ្នកផងយល់ថាយ៉ាងណាៗ សម្ដី ឬពាក្យនិយាយ គឺបដិញ្ញាកម្មធ្វើឱ្យអ្នកដទៃបានឮ ឬបានឃើញ ឯទង្វើ គឺព្រឹត្តិ-កម្ម ដែលសម្ដែងមក ។

គិតយ៉ាងណា និយាយយ៉ាងនុ៎ះ និយាយយ៉ាងណា ធ្វើយ៉ាងនុ៎ះ ទាំងនេះគឺ

www.budinst.gov.kh www.elibraryofcambodia.org

ជាលក្ខណៈរបស់មនុស្សត្រង់ គឺត្រង់ទាំងដើម កណ្ដាល និងចុង ។ ការដែលពិនិត្យមើលទៅលើតែពាក្យសម្ដី និងព្រឹត្តិកម្ម មិនអាចឱ្យយើងអះអាងថា អ្នកនោះជាអ្នកត្រង់បាន ១០០ ភាគរយទេ តែត្រូវពិនិត្យទៅលើចេតនារបស់អ្នកនោះទៀតផង ទើបគ្រប់គ្រាន់ បើមិនដូច្នោះទេ ប្រាកដជាសន្និដ្ឋានខុសជាមិនខាន ។

## ប្រភេទរបស់ត្រង់

បុរាណាចារ្យលោកបានចែងទុកថា មនុស្សយើងគួរត្រង់ចំពោះអ្វីខ្លះ ដោយលោកបានប្រៀបធៀបទៅនឹងម្រាមដៃទាំង ៥ ដើម្បីឱ្យងាយស្រួលចាំ ដូចរូបខាងក្រោម




*១. ត្រង់ចំពោះនាទី* បានដល់ការទទួលស្គាល់ថា " នាទីជារឿងសំខាន់ " ។ នាទីដែលអ្នកដឹកនាំត្រូវត្រង់ជាមួយ មានពីរប្រភេទ គឺ :

*ក. ត្រង់ចំពោះនាទីខ្លួន* : គឺបដិបត្តិការងារក្នុងនាទីរបស់ខ្លួន ឱ្យបានច្បាស់លាស់ មិនលះបង់នាទី មិនក្លែងបន្លំ បំផ្លាញនាទី យកនាទីរបស់ខ្លួនជាធំ ។

*ខ. ត្រង់ចំពោះនាទីរបស់អ្នកតូច* : មិនបៀតបៀននាទីរបស់អ្នកតូច មិនជ្រៀតជ្រែកនាទីរបស់អ្នកតូច តែ :

www.budinst.gov.kh www.elibraryofcambodia.org

- ត្រួតពិនិត្យឱ្យអ្នកតូចធ្វើការងារក្នុងមុខនាទី,
- មិនលើកទឹកចិត្តចំពោះអ្នកតូចណាដែលយកចិត្ត យកថ្នើមអ្នកធំ តែលះបង់នូវមុខនាទីខ្លួន,
- ផ្តល់កិត្តិយសដល់អ្នកតូចដែលខំបំពេញនាទី ។

នាទីជាករណីយកិច្ចដែលអ្នកដឹកនាំត្រូវធ្វើជាចាំបាច់ ដោយខានមិនបាន ។ អ្នកដឹកនាំដែលមិនធ្វើករណីយកិច្ចរបស់ខ្លួន ជារឿងគួរឱ្យអាម៉ាសជាពន់ពេក ហើយនិងនាំទៅរកសេចក្តីអន្តរាយជាមិនខាន ឧទាហរណ៍ដូចជានាទីខ្លួន គឺត្រូវទទួលពត៌មានតាមវិទ្យុពីសមរភូមិមុខ ចុះបើអ្នកនោះត្រឡប់ជាទៅលេងអុក ឬដើរទៅឯណាឯណីបាត់ ហើយពេលនោះចំជាពេលមានអាសន្នពីសមរភូមិមុខ យើងសួរថាតើនឹងមានហេតុការណ៍ធ្ងន់ធ្ងរប៉ុណ្ណាទៅ ដែលនឹងកើតឡើង ។

*អ្នកដែលអាចលះបង់នាទីខ្លួនបាន អ្នកនោះអាចលះបង់អ្វីៗ បានគ្រប់យ៉ាង លើកលែងតែអំពើអាក្រក់ម្យ៉ាងប៉ុណ្ណោះ ។*

*២. ត្រង់ចំពោះការងារ ៖* បានដល់ការធ្វើការងារគ្រប់យ៉ាងឱ្យបាន " ល្អ " និង " ឱ្យដល់ល្អ ឬដល់កម្រិត " របស់ការនោះ ។ ការងារល្អនោះ គឺការងារដែលមិនខ្ជុក មិនខ្ជោះ មានសុក្រឹតភាព ដូចជា បើនឹងសំពះ ក៏សំពះឱ្យត្រឹមត្រូវល្អ មិនមែនដូចអ្នកដឹកនាំខ្លះដែលយើងធ្លាប់ឃើញ គឺថា បើនឹងសំពះ ក៏លើកដៃទាំងពីរមកពីចំហៀងខាងក មិនបានឱ្យចំពីមុខទេ បើនឹងថ្វាយបង្គំព្រះសង្ឃ ក៏ធ្វើផ្តោមៗដូចជាបន្តោបង់លាមកឥចឹង ។ ឬមេទ័ពខ្លះ ពេលទៅត្រួតកូនទាហាន ក៏ស្លៀកពាក់ជាស៊ីវិល បែបនេះហៅថា មិនត្រង់ការងាររបស់ខ្លួន ។ ជួនកាលការងារខ្លះធ្វើមិនឱ្យចប់ចុង ចប់ដើមទេ ចូលក្នុងតម្រាពាក្យខ្មែរដែលលោកថា *" ចាប់នេះចាប់នោះ មិនឆ្នោះត្រង់ណា "* ។

រួមសេចក្តីទៅ ត្រង់ចំពោះការងារ គឺការធ្វើការងារឱ្យបានល្អជាទីបំផុ

www.budinst.gov.kh www.elibraryofcambodia.org

តាមដែលកម្រិតល្អនៃការងារនោះត្រូវការ មិនឡិមឡុំៗ ធ្វើឱ្យតែបានៗ ខុសៗ ត្រូវៗ នោះទេ ។ម្យ៉ាងទៀត ចំពោះការងាររបស់អ្នកតូច ក៏ត្រូវប្រិតប្រៀនឱ្យបានល្អ ជានិច្ច មិនត្រូវបណ្ដោយស្រេចតែនឹងចិត្តរបស់អ្នកតូចដែលមាក់ងាយ ឬរាយមាយ ចំពោះការងារនោះឡើយ ដូចជា ពេលស្មៀនវាយអង្គុលិលេខយកមកឱ្យអ្នកធំចុះហត្ថលេខា បើឃើញវាយខុសៗ ត្រូវៗ ខ្លះបាត់ជើង ខ្លះបាត់ដៃ បាត់បន្តក់ ខុសអក្ខរា-វិរុទ្ធ ក៏គប្បីកែ មិនគប្បីបណ្ដោយឱ្យនៅតែដូច្នោះឡើយ ។

សូមចាំថា *របៀបធ្វើការងារ មានតែម្យ៉ាងប៉ុណ្ណោះ គឺធ្វើឱ្យល្អ* ។

*៣. ត្រង់ចំពោះវាចា* : គឺការផ្ដល់សារសំខាន់ទៅលើពាក្យនិយាយរបស់ខ្លួន គោរពពាក្យនិយាយរបស់ខ្លួន ថាជារបស់ខ្ពង់ខ្ពស់ស្មើជីវិត គឺនិយាយយ៉ាងណា ក៏ធ្វើតាមការនិយាយនោះ សន្យារឿងអ្វីជាមួយអ្នកណា ក៏ធ្វើតាមពាក្យសន្យា នោះ ទោះបីរឿងនោះជារឿងតូចតាចយ៉ាងណាក៏ដោយ ។ តែបើខ្លួនធ្វើតាមពាក្យនិយាយ មិនបានទេ ក៏គប្បីរកហេតុផលមកបញ្ជាក់ប្រាប់ឱ្យគេដឹង ហើយសុំទោសពៃរ៍ចំពោះការដែលខ្លួនមិនអាចធ្វើតាមពាក្យនិយាយនោះបាន ។ ដូចគ្នានេះដែរ អ្នកដឹកនាំក៏ត្រូវ យកចិត្តទុកដាក់ចំពោះពាក្យអ្នកតូចដែរ គឺបើនិយាយយ៉ាងណា សន្យាយ៉ាងណា ទោះ ជារឿងតូចក្ដី ធំក្ដី ក៏ត្រូវតាមមើលឱ្យដល់កោះដល់ត្រើយ ថាអ្នកតូចនោះបានធ្វើ តាមពាក្យដែលខ្លួននិយាយមែនឬទេ បើធ្វើមិនបាន ក៏ត្រូវឱ្យមានហេតុផលគ្រប់គ្រាន់មកបញ្ជាក់ដោះស្រាយ ។ ធ្វើដូច្នេះ ជាការធ្វើឱ្យអ្នកតូចមិនហ៊ាននិយាយឡេះឡោះតទៅថ្ងៃក្រោយ ។ សូមកុំភ្លេចថា ការកុហក និយាយមិនពិត ការមិនត្រង់ចំពោះវាចាខ្លួនម្ដង ឈ្មោះថាបន្ថយនូវជំនឿដែលគេមានចំពោះយើងមួយកម្រិតផង ដែរ ដូចពាក្យចាស់លោកថា :

*ឈើផ្លែច្រើន ចាញ់ស្លឹក*

*ពាក្យច្រើនភូត ចាញ់អាត្មា*

www.budinst.gov.kh www.elibraryofcambodia.org

*៤. ត្រង់ចំពោះបុគ្គល* : គឺមិនលេងល្បិច ការមិនឆបោកបញ្ឆោតចំពោះអ្នកដទៃ មានអ្វីក៏ធ្វើត្រង់ទៅត្រង់មក មានភក្តីភាពស្មោះត្រង់ ដូចជា :

- មិនបោកអ្នកតូចឱ្យធ្វើខុស ហើយយករួចខ្លួនតែឯង,
- មិននិន្ទាមួលបង្កាច់គេនៅពីក្រោយ ដោយចេតនាអាក្រក់,
- មិនគិតព្យាបាទមិត្ត,
- មិនទុរយសក្បត់ចំពោះអ្នកធំ,
- មិននិរគុណចំពោះអ្នកដែលធ្វើគុណ,
- មិនធ្វើខ្លួនឱ្យទៅជាមនុស្ស *" នៅនឹងមុខហៅលោក កំបាំងដីប្លុកហៅអា "* ។

ខ្មែរយើងមានសុភាសិត ១ ឃ្លា ដែលបញ្ជាក់ពីការគិតយកតែប្រយោជន៍ខ្លួន មិនមានការស្មោះត្រង់ចំពោះបុគ្គល ដូច្នេះគឺ :

*« ចូលព្រៃសត្វសាហាវ រកអំពាវគ្នាមកជុំ*
*ដល់បានស្ករទឹកឃ្មុំ ពួនសម្ងំស៊ីម្នាក់ឯង »* ។

សង្គមខ្មែរយើងសព្វថ្ងៃនេះ សម្បូរអ្នកដឹកនាំប្រភេទនេះណាស់ ដែលជាការគួរឱ្យព្រួយបារម្ភ ព្រោះនឹងធ្វើឱ្យអ្នកដែលរួមការជាមួយគ្នា លែងមានភក្តីភាព រកទុកចិត្តគ្នាមិនបាន ។ ព្រះតេជព្រះគុណព្រះអធិបតីសង្ឃ សាយធូ លោកបាននិណាលរឿងពិតមួយពីជំនាន់បារាំងគ្រប់គ្រងខ្មែរថា : មានកូនទាហានខ្មែរ ១ កង មានការមិនពេញចិត្តចំពោះប្រាក់ខែរបស់ខ្លួនដែលបារាំងឱ្យ ព្រោះចាយមិនគ្រប់ ក៏បានស្រុះស្រួលគ្នាចុះឈ្មោះសរសេរពាក្យដើម្បីឡើងឈ្មោះទៅកុំម៉ង់ដង់ ទាមទារឡើងប្រាក់ខែ ។ ទាហានទាំងនោះបានសុំឱ្យទាហានម្នាក់ដែលបានមាត់បានក ធ្វើជាមេនាំមុខដើរជាផ្លូវទៅជួបបារាំង ដោយសន្យាថានឹងគាំទ្រជានិច្ច ។ ដល់ពេលទៅជួបបារាំង ទាហានអ្នកនាំមុខនោះ ក៏គំនាប់បារាំង ហើយក៏ហុចពាក្យតវ៉ាទាមទារនោះឱ្យបារាំង ។ បារាំង

www.budinst.gov.kh www.elibraryofcambodia.org

អានរួចក៏មុខក្រហមងាំង ហើយក៏ទះតុផ្ទួងសួររកថា អ្នកណាជាអ្នករួមគំនិត ។ ទាហាននោះក៏ប្រាប់ថា " ពួកខ្ញុំទាំងអស់គ្នា. ... ថាបានប៉ុណ្ណោះ ក៏ងាកទៅក្រោយ ដើម្បីឱ្យគ្នាខ្លួនជួយនិយាយ ស្រាប់តែបាត់មនុស្សអស់រលីង មិនដឹងបាត់ពីអង្កាល់ណា ។ ទីបញ្ចប់ ទាហាននោះត្រូវបារាំងចាប់ដាក់គុក ៣ ខែ ជាការដាក់ទោស ។ រឿងនេះចង់បង្ហាញថា ការមិនមានភក្តីភាព ឬការមិនត្រង់នឹងគ្នានេះ ជារឿងមួយគ្រោះថ្នាក់ណាស់ នៅក្នុងការតស៊ូជាយដែននេះ ក៏មានតួយ៉ាងច្រើនណាស់ តាំងពីអ្នកដឹកនាំ និងពីអ្នកក្រោមបង្គាប់ គឺនាំគ្នានិយាយថា ស្មោះត្រង់ៗ ស៊ូស្លាប់ជាមួយៗ តែដល់មែនទែន បែរខ្នងដាក់គ្នា ទៅជាសត្រូវនឹងគ្នាក៏មាន ។

សូមចាំថា ៖

*គប្បីល្អចំពោះមនុស្សគ្រប់គ្នា*
*តែទុកចិត្តចំពោះមនុស្សខ្លះបានហើយ*

*៥. ត្រង់ចំពោះសេចក្តីល្អ* ៖ គឺជាកំពូលនៃសេចក្តីត្រង់ នៃសេចក្តីល្អ ។ ចំពោះការត្រង់នេះ បុរាណលោកប្រើពាក្យធមិ គឺបានន័យថា ត្រង់ចំពោះសេចក្តីល្អ គឺការរក្សាធមិនេះឯង ដូចជា ៖

មានយុត្តិធមិ
ត្រឹមត្រូវតាមធមិ
តាមគន្លងធមិ
ប្រកបដោយធមិ

ឬបើជាពាក្យអវិជ្ជមាននាំមុខវិញ មានដូចជា មិនស៊ីសំណូក មិនភកោង មិនអយុត្តិធមិ មិនលំអៀង ។ ល ។

រួមសេចក្តីថា នៅក្នុងការបំពេញនាទីរបស់ខ្លួនជាអ្នកធំ បើទោះជាមានអ្វី

www.budinst.gov.kh www.elibraryofcambodia.org

មករុញច្រាន ឬបង្ខំឱ្យខ្លួនងាកវេខុសពីធមិយ៉ាងណាក៏ដោយ ក៏ពង្រឹងចិត្ត មិនព្រម លុះទៅតាមអំណាចទាំងនោះ ហ៊ានតស៊ូពុះពារដើម្បីរក្សាធមិឱ្យគង់វង្ស ។ អំណាច ដែលនឹងអាចឱ្យយើងខូចធមិនោះ មានដូចជា សំណូក រង្វាន់ ស្រី បក្សពួក ស្នេហា កំហឹង ការស្រើង ការខ្លាច ការញុះញង់របស់សត្រូវជាដើម ។ គប្បីចាំនូវពុទ្ធវចនៈថា « *ធម្មោ ហវេ រក្ខតិ ធម្មចារឹ* - អ្នករក្សាធមិ ធមិតែងរក្សាអ្នកនោះ » ជាគតិ សំរាប់តស៊ូជាមួយអធមិទាំងឡាយនោះ ។

# ផលប្រយោជន៍របស់ត្រង់

យើងហាក់ដូចជាមិនបាច់អធិប្បាយទេ ពីផលប្រយោជន៍របស់ត្រង់ ព្រោះអ្នកណាក៏ស្រលាញ់ត្រង់ និងចូលចិត្តត្រង់ដែរ ។ ដៃដែលនឹងស្អាតនោះ ព្រោះ មានម្រាមគ្រប់ទាំង ៥ បើបាត់ម្រាមណាមួយ ដៃនោះនឹងទៅជាដៃពិការ បើបាត់ កាន់តែច្រើន ដៃក៏កាន់តែលែងមានប្រយោជន៍ច្រើនឡើងៗដែរ ។

មនុស្សត្រង់ គឺមនុស្សមិនវៀច ធ្វើការអ្វីក៏នឹងបានឆាប់សំរេចមិនខាន ដូចជាផ្លូវត្រង់ និងផ្លូវវៀចអញ្ចឹងដែរ គឺផ្លូវត្រង់ទៅដល់គោលដៅឆាប់ជាងផ្លូវវៀច ។ ផ្លូវត្រង់ គឺផ្លូវកណ្តាល ជាមជ្ឈិមប្បដិបទា មិនងាកឆ្វេង ងាកស្តាំរបស់ព្រះពុទ្ធបរម-គ្រូរបស់យើង ។ ជនដែលដើរតាមផ្លូវត្រង់ ផ្លូវកណ្តាល គឺជាអរិយសាវ័ករបស់ព្រះ សម្មាសម្ពុទ្ធដ៏ពិតៗ ។ អ្នកដឹកនាំដែលត្រង់ គឺពិតជាអ្នកដឹកនាំដែលកំពុងនាំរាស្ត្រប្រជា ដើរលើផ្លូវមជ្ឈិមប្បដិបទា ឆ្ពោះទៅរកការរួចផុតពីសេចក្តីទុក្ខលំបាករបស់រាស្ត្រ ប្រជា និងឆ្ពោះទៅរកព្រះនិព្វានសំរាប់ផ្ទាល់ខ្លួនដ៏ពិតៗ ។

www.budinst.gov.kh www.elibraryofcambodia.org

# មទ្ទវៈ គឺការទន់ភ្លន់

មទ្ទវៈ ប្រែថាការទន់ភ្លន់ ប្រាសចាកការច្រងេងច្រងាង ច្រឡើសបើស ។ គោលបំណងរបស់ធម្មៈ ៦ នេះ គឺថា ក្នុងឋានៈជាអ្នកដឹកនាំ ជាប្រមុខរបស់ជនទាំងឡាយដ៏ច្រើន ក្រៅពីមានទាន គឺការបែងចែកចំណែក, សីល គឺការសង្រួមកាយ វាចា, បរិច្ចាគ គឺការលះបង់, អាជ្ជវៈ គឺការត្រង់ហើយ អ្នកដឹកនាំត្រូវមានកិរិយាសុភាព ទន់ភ្លន់ រៀបរយ ចំពោះអ្នកក្រោមបង្គាប់ខ្លួន គួរឱ្យជាទីគោរពរាប់អាន និងចង់ឱ្យគេចូលចិត្តសន្ទនាប្រាស្រ័យជាមួយ និងជាអ្នកមិនក្រញេងក្រញាង, មិនច្រងេងច្រងាង, មិនរឹងរូសចំពោះមហាជនដែលខ្លួនគ្រប់គ្រង ។

លោកប្រៀបធម្មៈ ៦ នេះថា មានលក្ខណៈដូចដើមត្រែង បើទោះជាមានខ្យល់ព្យុះបោកបក់ខ្លាំងយ៉ាងណា ក៏មិនបាក់ដែរ សុខចិត្តទោរទន់ទៅតាមកម្លាំងខ្យល់លុះដល់ស្ងប់ខ្យល់ ក៏អាចងើបឈរត្រង់បានឡើងវិញ ។

អ្នកអានអាចឆ្ងល់ថា ធម្មតាអ្នកដឹកនាំត្រូវមានភាពរឹងប៉ឹងដាច់ខាត ម៉ាត់ណា ម៉ាត់ហ្នឹង ប្រើអំណាចទើបកូនចៅខ្លាច ។ បើយ៉ាងដូច្នេះ រឿងនេះវាមិនទាស់នឹងធម្មៈ ៦ មទ្ទវៈនេះទៅហើយឬ ?

ឆ្លើយថា មិនទាស់ទេ ព្រោះការទន់ភ្លន់ និងការរឹងប៉ឹង មិនមែនជារបស់បដិបក្សនឹងគ្នាឡើយ តែជាប្រយោជន៍ដល់គ្នានឹងគ្នាទៅវិញទេ លោកប្រៀបថា ការរឹងប៉ឹងដូចជាផ្លែដាវ ឯការទន់ភ្លន់ដូចជាស្រោមដាវ ដែលតែងរក្សាគ្នាទៅវិញទៅមក និងជាលំអដល់គ្នានឹងគ្នា ។ បដិបក្សរបស់ភាពរឹងប៉ឹង គឺទន់ខ្សោយ មិនមែនទន់ភ្លន់ទេ ។

www.budinst.gov.kh www.elibraryofcambodia.org

# មនុស្សពីរជំពូក

មនុស្សយើង ក្នុងឋានៈជាប្រមុខគេ អាចបែងដោយត្រួសៗជាពីរប្រភេទ គឺ រឹងប៉ឹងខាងក្រៅ តែទន់ខាងក្នុង និងមួយប្រភេទទៀត ទន់ខាងក្រៅ តែរឹងប៉ឹងខាងក្នុង ដោយលោកប្រៀបទៅនឹងរុក្ខជាតិពីរជំពូក ៖

| ឈើប្រភេទទន់ក្រៅ រឹងក្នុង | ឈើប្រភេទរឹងក្រៅ ទន់ក្នុង |
|---|---|
| គគី | ត្នោត |
| ធ្នឹក | ដូង |
| នាងនួន | ឫស្សី |
| បេង | អំពៅ |
| ធ្នង់ | ជ្រៃ |
| ម៉ៃសាក់ | ស្លា |
| អំពិល | ទន្សែ |
| ឈើទាល | ល្ហុង |
| ។ ល ។ | ។ ល ។ |

សូមពិចារណាផងចុះ ថាតើរុក្ខជាតិប្រភេទណាមានតម្លៃ និងប្រើការបានមាំមួនជាង មនុស្សយើងក៏ដូចគ្នាដែរ អ្នកខ្លះមានកិរិយាទន់ភ្លន់ សុភាពរៀបរយ មិនក្រញេងក្រញាង ច្រឡើសបើស មិនអួតអាង ទាំងកាយវិការ និងសម្តីសម្តៅ ស្តាប់ និងមើលទៅ ហាក់ដូចជាយកប្រើការមិនបានទេ តែអ្នកនោះ លុះដល់ធ្វើការងារទាំងពួង ត្រឡប់ជារឹងប៉ឹង អត់ធន់ អត់ធ្មត់ ចំពោះសេចក្តីលំបាកទាំងពួងបានយ៉ាងប្រសើរ ចូលក្នុងតម្រាខ្មែរយើងថា *"ត្រុកៗអ្នកស្រុកមើលងាយ រលោងដូចខ្លាយ មានឪឡឹមានភ័ក្ត្រ "* ។

www.budinst.gov.kh www.elibraryofcambodia.org

ឯអ្នកខ្លះទៀត ខាងក្រៅអួតអាង ច្រងេងច្រងាងដូចជាខ្លាំងណាស់ តែលុះដល់ពេលធ្វើការមែនទែន ក៏ស្រាប់តែមិនបានប៉ុន្មានទឹក ក៏ហាបក ឬរហ័សស្រែកញ៉េច ក៏មាន ។ លោកប្រៀបមនុស្សប្រភេទនេះថាជា " *មនុស្សខ្វយ* " ប៉ះបន្តិចតូចងងាម តែពិសមិនជាខ្លាំងទេ បើវរតែគេដឹង ចាប់តែកន្ទុយបាន ក៏អស់ឫទ្ធិមួយរំពេច ។ ខ្មែរយើងមានពាក្យចំអកឡកឡឺយចំពោះមនុស្សប្រភេទនេះថា " *បើមិនខ្លោចកុំឱ្យលង បើមិនមែនថ្លាន់ទេ កុំឱ្យវារកាត់ផ្លូវ* " ។ ច្បាប់បុរាណលោកបានទូន្មានថា ៖

*ទោះនឹងយាត្រា ទៅទីស្ថានណា ដើរដូចភុជង្គ*
*សិរសាទន់ទាប សុភាពផ្គត់ផ្គង់ លំអុតឱនអង្គ*
*ការកេរ្តិ៍អ្នកជា ។*

*វិអ្នកសាមាន្យ ខ្យល់ខ្សោយសន្ទាន អាប់ឥតប្រាជ្ញា*
*ដំណើរអែងអោង ពែងកោងបាត្ថា ដូចខ្វយសោះសា*
*មែនមានពិសពិច ។*

*បំពើងបំពើត ចំកោងស្ទួយស្មើត ពឹងពិសទ្រនិច*
*ខ្លួនតូចត្រឡាំង កម្លាំងសោតតិច ពឹងពិសទ្រនិច*
*មែនមានតិចណា ។*

គុណធម៌ *មទ្ទវៈ* នេះ នឹងអាចបង្កើតផលដល់អ្នកបដិបត្តិបាន ជាដំបូងត្រូវធ្វើឱ្យកើតមាននៅក្នុងចិត្តជាមុនសិន បើចិត្តពុំទាន់មានភាពទន់ភ្លន់ កាយវាចារបស់អ្នកនោះ ក៏មិនអាចមានភាពទន់ភ្លន់បានដែរ ។ វិធីដែលនឹងឱ្យកើតមទ្ទវៈនៅក្នុងចិត្ត ព្រះសម្មាសម្ពុទ្ធលោកប្រាប់ថា ត្រូវធ្វើសមាធិ ជាពិសេស ការចំរើនមេត្តា

www.budinst.gov.kh www.elibraryofcambodia.org

ករុណា មុទិតា និងឧបេក្ខា ។ ក្នុងបាលីលោកសំដែងថា បុគ្គលកាលបើបានសំរេចនូវចតុត្ថជ្ឈាន គឺឈានទី ៤ ហើយ ចិត្តនឹងមានលក្ខណៈទន់ភ្លន់ ( មុទុ ) គួរដល់ការងារ ( កម្មនិយោ ) ។

ចិត្តដែលមានសមាធិ ជាចិត្តដែលទន់ភ្លន់ និងជាចិត្តដែលអាចធ្វើការប្រកបការអ្វីក៏បានទាំងអស់ ។ លោកប្រៀបចិត្តបែបនេះថា ដូចជាក្រមួនឃ្មុំ អាចយកទៅសូន្យធ្វើជារូបអ្វីក៏បាន ។ ដូច្នេះ ធម្មៈ ខ នេះ តម្រូវឱ្យអ្នកដឹកនាំហ្វឹកហាត់សមាធិ អប់រំចិត្តឱ្យមានភាពនឹងន ចិត្តមិនរវើរវាយ មានសតិនៅជាប់ជានិច្ច ។ កាលណាចិត្តមានភាពនឹងហើយ ការងារទាំងឡាយក៏នឹងកើនប្រសិទ្ធិភាពជាមិនខាន ។




## សារសំខាន់របស់សមាធិ និងចិត្ត ដែលទន់ភ្លន់គួរដល់ការងារ

ក្នុង១ថ្ងៃៗ យើងម្នាក់ៗ ត្រូវប្រឈមមុខនឹងនាទីរបស់ខ្លួនគ្រប់ពេលវេលា

www.budinst.gov.kh www.elibraryofcambodia.org

និងគ្រប់ទីកន្លែងទាំងអស់ ៖

- នៅមុខមាតាបិតាយើងជាបុត្រ,
- នៅពីមុខបុត្រយើងជាមាតាបិតា,
- នៅពីមុខគ្រូយើងជាសិស្ស,
- នៅពីមុខសិស្សយើងជាគ្រូ,
- នៅមុខគូស្រករយើងជាស្វាមី ឬភរិយា,
- នៅពីមុខព្រះសង្ឃយើងជាបរិស័ទ,
- នៅពីមុខបរិស័ទយើងជាព្រះសង្ឃ,
- នៅពីមុខប្រមុខយើងជារាស្ត្រប្រជា,
- នៅពីមុខរាស្ត្រប្រជាយើងជាប្រមុខ,
- នៅពីមុខញាតិមិត្តយើងជាញាតិមិត្ត ។

នៅពីមុខស្ថានការណ៍ និងបុគ្គលដ៏ច្រើនឋានៈ និងនាទីដ៏ច្របូកច្របល់បែបនេះ ជាការចាំបាច់ណាស់ដែលអ្នកដឹកនាំត្រូវមានសមាធិក្នុងការងារ ដើម្បីបំពេញមុខនាទីនីមួយៗឱ្យបានល្អ ហើយត្រូវមានចិត្តទន់ភ្លន់ បត់បែនបានស្រួលដើម្បីងាកពីនាទីមួយមកកាន់នាទីមួយទៀត ដែលផ្លាស់ប្តូរចុះឡើងៗមិនដាច់ ដោយមានសុវត្ថិភាព ។ បើមិនដូច្នោះទេ ប្រាកដជាខឹងប្រពន្ធនៅផ្ទះ ដល់មកកន្លែងធ្វើការបត់បែនមិនទាន់ព្រោះចិត្តខឹង ក៏តាំងមកឡូឡា រករឿងគេឯងពេញការិយាល័យ មិនខាន, ឬបើខឹងនឹងមហាជនធ្វើបាតុកម្មបន្តិចបន្តួច ក៏ភ្លេចនាទីខ្លួនជាអ្នកបំរើមហាជន ក៏តាំងប្រើវិធីហិង្សាដាក់មហាជនជាបែបផ្តាច់ការវិញ ។ បើស្ថានការណ៍ក្លាយទៅជាបែបនេះ យើងអាចស្រមៃឃើញមិនខានថា នឹងមានអ្វីកើតឡើងចំពោះអ្នកដឹកនាំរូបនោះ ។

ដូច្នេះ ភាពទន់ភ្លន់ ជារឿងសំខាន់បំផុត ដើម្បីឱ្យការងារទាំងពួងដំណើរ

www.budinst.gov.kh www.elibraryofcambodia.org

ការទៅបានស្រួល ។ អ្នកដឹកនាំទាំងឡាយ គប្បីហ្វឹកហាត់ចិត្ត វាចា កាយរបស់ខ្លួនឱ្យមានភាពទន់ភ្លន់ ដោយការចំរើនមេត្តាភាវនា ករុណាភាវនា មុទិតាភាវនា និងឧបេក្ខា-ភាវនា តាមគោលសមាធិដែលព្រះពុទ្ធជាម្ចាស់បានសម្ដែងហើយ ដោយច្បាស់លាស់ផងចុះ ប្រយោជន៍ទាំងឡាយប្រាកដជាកើត ហើយមហាជនក៏នឹងសាទរ ត្រេកអរថា " ពេញចិត្តហើយៗ " ជាមិនខាន ។

## ការសម្ដែងនូវភាពទន់ភ្លន់តាមកាយវិការ និងសម្ដី

ឧទាហរណ៍ខាងក្រោមនេះ ជាលក្ខណៈនៃភាពទន់ភ្លន់ ដែលអ្នកដឹកនាំគួរមាន ៖

១. មុខញញឹមញញែម មិនធ្វើមុខស្អុយ មុខស្រពោន មុខក្រញូវ,

២. រាក់ទាក់ចំពោះអ្នកតូចមុន,

៣. សម្ដែងសេចក្ដីគោរពចំពោះបូជនីយបុគ្គល និងបូជនីយស្ថាន ថ្វីដ្បិតតែខ្លួនមិនបានគោរពរាប់អាន ក៏ដោយ ។

ត្រង់នេះ ក្នុងសង្គមខ្មែរយើង មានករណីគួរឱ្យសិក្សាជាពន់ពេកចំពោះអ្នកដឹកនាំខ្មែរ គឺថា បើអ្នកធំខ្មែរចូលវត្តណា គឺលោកសម្ដែងការគោរពចំពោះតែចៅអធិការវត្តដែលគាត់គោរពតែប៉ុណ្ណោះ ក្រៅពីនេះ ដូចជាភិក្ខុ-សាមណេរដទៃទៀត គាត់មិនសូវគោរព ឬមិនគោរពសោះក៏មាន ។ ទន់ភ្លន់បែបនេះ គេហៅថាទន់ភ្លន់ចំពោះមុខ ឬរើសមុខ ។ អ្នកដឹកនាំដែលមានមទ្ទវៈ ទោះបីជានៅពីមុខគួរសត្រូវក៏ដោយ ក៏មានភាពទន់ភ្លន់ដែរ ( មិនមែនទន់ខ្សោយទេ ) ។

៤. ទទួលនូវសេចក្ដីគោរពពីគេ ដោយយកចិត្តទុកដាក់ មិនព្រងើយកន្តើយ ( មិនមែនមុខមិនឱ្យ ក្រោយមិនបែរទេ ),

៥. និយាយដាក់ខ្លួន ថ្នមកិរិយាមារយាទ នៅពេលដែលទទួលសេចក្ដី

www.budinst.gov.kh www.elibraryofcambodia.org

សរសើរ,

៦. មិននិយាយអួតអាង ក្អេងក្អាង,

៧. មិនអង្គុយចង្អេរលើកខ្លួនឯង ហើយបន្ទុះបង្អាប់គេ,

៨. ទទួលភ្ញៀវដោយរាក់ទាក់ និងយកចិត្តទុកដាក់ដោយស្មើមុខ ថ្វីត្បិតតែអ្នកនោះជាអ្នកតូច,

៩. សម្តែងការពេញចិត្ត ចំពោះការទទួលរាក់ទាក់របស់អ្នកដទៃ,

១០. សារភាពកំហុសរបស់ខ្លួនដោយមុខមាត់ស្រស់បស់ ដោយការពេញចិត្តនឹងសារភាព,

១១. ។ ល ។

www.budinst.gov.kh www.elibraryofcambodia.org

# តបៈ គឺការកំចាត់អំពើអាក្រក់

**តបៈ** ប្រែតាមសព្ទថា ធ្វើឱ្យក្ដៅ ដុតកម្ដៅ ។ ដូចជាការដាំទឹកក្ដៅជាដើម លោកក៏ប្រើពាក្យ *តបៈ ( ឧទកំ តាបេតិ )* ។ បើយើងទៅធ្វើការអ្វីមួយដែលមិនល្អ ហើយនាំឱ្យក្ដៅក្រហាយក្នុងចិត្តជាខាងក្រោយ លោកក៏ប្រើពាក្យ *តបៈ* ដែរ *( បច្ឆា តបតិ )* ។ គុណធម៌ *តបៈ* នៅក្នុងទសពិធរាជធម៌នេះ ក៏ប្រែថា ដុតធ្វើឱ្យក្ដៅដូចគ្នា តែលោកពន្យល់ថា *« ដុត ឬធ្វើឱ្យក្ដៅនូវសេចក្ដីអាក្រក់ »* *« ដុត ឬធ្វើឱ្យក្ដៅដល់ជនអាក្រក់ »* ។ ដូច្នេះ អ្នកដឹកនាំមាននាទីមួយ គឺត្រូវជាអ្នកព្យាយាមធ្វើតបធម៌ គឺដុតនូវសេចក្ដីអាក្រក់ និងជនអាក្រក់ឱ្យអស់ពីក្នុងអាណាចក្រខ្លួន ។

## ព្រះតេជព្រះគុណ

ព្រះតេជព្រះគុណ ជាពាក្យដែលខ្មែរយើងប្រើសំរាប់ហៅជនឯណាដែលមានឋានៈខ្ពស់ ជាមេគេ ជាអ្នកដឹកនាំ ជាព្រះសង្ឃ ។ ល ។ អ្នកដឹកនាំណាដែលមានទសពិធរាជធម៌ទាំង ១០ ក្នុងខ្លួន អ្នកដឹកនាំនោះ បុរាណលោកហៅថា តេជគុណ ។

គុណធម៌ ទី១. ទាន, ទី២. សីល, ទី៣. បរិច្ចាគ, ទី៤. អាជ្ជវៈ, និងទី៥. មទ្ទវៈ ។ ទាំង ៥ នេះ លោកចាត់ជា ព្រះគុណ មានលក្ខណៈជាអាបោធាតុ គឺត្រជាក់ ។ អ្នកណាមានគុណធម៌ទាំង ៥ នេះ អ្នកនោះនឹងទៅជាអ្នកមានព្រះគុណចំពោះអ្នកដទៃ ធ្វើឱ្យគេឯងចង់ជ្រកកោនជាមួយ ព្រោះមានតែភាពត្រជាក់ ភាពសុខស្រួល គ្មានទុក្ខទោស និងធ្វើឱ្យអ្នកដែលមាន ក្លាយទៅជាមនុស្សមានគុណូបការៈលើគេ ធ្វើឱ្យគេគោរពបូជាតបស្នងមកវិញ ។

ឯគុណធម៌ ចាប់ពីទី៦. តបៈ, ទី៧. អក្កោធំ, ទី៨. អវិហិង្សំ, ទី៩. ខន្តិ,

www.budinst.gov.kh www.elibraryofcambodia.org

ទី១០. អវិរោធនំ ។ ទាំង ៩ ខាងក្រោមនេះ ចាត់ទុកជាផ្នែកដែលបណ្ដាលឱ្យកើតនូវព្រះតេជះ មានលក្ខណៈជាតេជោធាតុ គឺក្ដៅ សំរាប់ដុតកម្ដៅនូវសេចក្ដីអាក្រក់ និងអំពើរអាក្រក់ទាំងឡាយដែលមាន ឱ្យវិនាសបាត់បង់ ។

បុរាណាចារ្យខ្លះលោកបានប្រៀបថា ធ្វើជាអ្នកធំ ត្រូវធ្វើខ្លួនឱ្យដូចជាព្រះអាទិត្យ និងព្រះច័ន្ទ ។ ធម្មតាព្រះអាទិត្យ លោកបញ្ចេញកម្ដៅ តែកម្ដៅលោកមិនបានធ្វើឱ្យអ្នកណាក្ដៅក្រហាយស្លាប់បាត់បង់ជីវិតទេ មានតែផ្ដល់នូវសុខភាព និងផលប្រយោជន៍ ។ ឯព្រះច័ន្ទវិញ លោកមានពន្លឺត្រជាក់ តែមិនមែនត្រជាក់រហូតដល់រឹងពោះទេ គឺត្រជាក់ភ្នែក ត្រជាក់ចិត្ត គួរជាទីមនោរមដល់អ្នកដែលបាននៅក្រោមរស្មីដួងច័ន្ទ ។ អ្នកធំត្រូវមានទាំងត្រជាក់ ទាំងក្ដៅ ទើបធ្វើជាអ្នកធំបាន បើក្ដៅពេកគេនឹងរត់ចេញអស់ជាមិនខាន លុះត្រាតែមានត្រជាក់ មានក្ដៅទើបមានតុល្យភាព ។

## តបៈ ២ ប្រភេទ

តបៈ មាន ២ ប្រភេទគឺ ៖

ក. តបៈព្រះរាជា, និង

ខ. តបៈព្រះឫសី

ទាំង ២ ប្រភេទនេះ ប្រែថាដុតដូចគ្នា ។ តបៈព្រះរាជា ប្រែថា ដុតអំពើអាក្រក់ ឯតបៈព្រះឫសី ប្រែថា ដុតសេចក្ដីអាក្រក់ ។

• *តបៈព្រះរាជា* ៖ គឺតបៈរបស់អ្នកដឹកនាំ ដែលជាប្រធានរបស់អ្នកដទៃដែលហៅថាដុតជនអាក្រក់ ឬអំពើអាក្រក់នោះ ពុំមែនបានន័យថា ចាប់ជនអាក្រក់ទាំងរស់យកមកដុត ដូចដុតមាន់នោះទេ តែបានដល់ការធ្វើឱ្យពួកជនអាក្រក់ក្ដៅ បើមិនដូច្នោះទេ លែងហ៊ានប្រព្រឹត្តអំពើអាក្រក់ ឬក៏លែងហ៊ាននៅជិតគេជិតឯង ជាមនុស្សល្មតែម្ដង ។

www.budinst.gov.kh www.elibraryofcambodia.org

តបៈ ដែលអ្នកដឹកនាំគប្បីដុតកម្តៅជនពាល ជនអាក្រក់ មានដូចជា ៖

- ប្រកាសយ៉ាងបើកចំហ និងដាច់ខាត មិនចូលដៃចូលជើងនឹងមនុស្សអាក្រក់,
- មិនជួយសង្គ្រោះជនអាក្រក់ដោយខុសច្បាប់ ខុសទម្លាប់,
- ដាក់ទោសដល់ជនអាក្រក់ដោយដាច់ខាត,
- មិនផ្តល់កិត្តិយស មិនឱ្យបុណ្យសក្តិ អំណាចដល់ជនអាក្រក់,
- ព្យាយាមបង្ក្រាបជនអាក្រក់ដោយមិនលះបង់,
- មិនត្រេកអរចំពោះលាភសក្ការៈ ដែលជនអាក្រក់នាំមកឱ្យ,
- ដាក់ច្បាប់យកទោសជនអាក្រក់,
- គាំទ្រ លើកតម្លៃ កិត្តិយសមនុស្សល្អឱ្យប្រាកដក្នុងសង្គមឡើង
- ។ ល ។

• *តបៈព្រះឫសី* ៖ បានដល់ការបដិបត្តិធម៌ ដើម្បីដុតកម្តៅនូវសេចក្តីអាក្រក់ដែលមាននៅក្នុងខ្លួនឱ្យអស់ទៅ ។ តាមធម្មតា សេចក្តីអាក្រក់មានបង្កប់នៅជាប់ជានិច្ចជាមួយនឹងតណ្ហា គឺសេចក្តីប្រាថ្នា ចំណង់ ការចូលចិត្តរបស់មនុស្សម្នាក់ៗដូច្នេះហើយបានជា ការធ្វើតបៈ គឺការខំប្រឹងអត់ មិនធ្វើទៅតាមចិត្តខ្លួនចង់ ឬធ្វើផ្ទុយនឹងទម្លាប់របស់ខ្លួន ដូចជា ៖

| | |
|---|---|
| យើងចូលចិត្តដេក | ធ្វើតបៈ គឺមិនដេក |
| ចូលចិត្តតែងខ្លួន | ធ្វើតបៈ គឺមិនតែងខ្លួន |
| ជក់បារី | ធ្វើតបៈ គឺមិនជក់បារី |
| លេងល្បែង | ធ្វើតបៈ គឺមិនលេង |
| មើលងាយគេ | ធ្វើតបៈ គឺមិនមើលងាយគេ |
| ចូលចិត្តស៊ីសំណូក | ធ្វើតបៈ គឺឈប់ស៊ីសំណូក |

www.budinst.gov.kh www.elibraryofcambodia.org

| | |
|---|---|
| ចូលចិត្តស៊ីផឹកខ្ជះខ្ជាយ | ធ្វើតបះ គឺឈប់ស៊ីផឹកខ្ជះខ្ជាយ |
| ចូលចិត្តឃើញតែប្រយោជន៍ខ្លួន | ធ្វើតបះ គឺឈប់ឃើញតែប្រយោជន៍ និងបក្សពួកខ្លួន |

ដូច្នេះ តបៈព្រះឫសី គឺការដែលអ្នកដឹកនាំព្យាយាមហ្វឹកហាត់ខ្លួន ទប់ចិត្ត ទប់ថ្លើម លះបង់នូវអ្វីដែលមិនល្អ ដែលអាក្រក់ ដែលជាទម្លាប់មិនសមគួរ ឱ្យអស់ចេញពីក្នុងខ្លួន ។

ក្នុងព្រះពុទ្ធសាសនា ការដុតបំផ្លាញនូវកិលេស ១៦ យ៉ាងខាងក្រោមនេះ ឱ្យអស់ ឬឱ្យនៅសល់តិចតួចបំផុត ឈ្មោះថាជាការបំពេញតបៈព្រះឫសី យ៉ាងប្រសើរ ។ អ្នកដឹកនាំ ថ្វីដ្បិតតែមិនមែនព្រះឫសី តែក៏គប្បីដុតកម្ទេចនូវកិលេសទាំង ១៦ នេះឱ្យបានធូរស្រាលពីសន្ដានចិត្តខ្លួនដែរ គឺ ៖

| ឈ្មោះកិលេស | តបៈដែលត្រូវលះ |
|---|---|
| ១. អភិជ្ឈាវិសមលោភៈ | ឈប់គិតប្រាថ្នាចង់តែលោភលន់មិនសមគួរ |
| ២. ព្យាបាទ | ឈប់គិតព្យាបាទគេ |
| ៣. ទោសៈ | ឈប់ប្រទូសរ៉ាយគេ |
| ៤. ឧបនាហៈ | ឈប់ចងគំនុំគេ |
| ៥. មក្ខៈ | ឈប់លុបបុណ្យគុណ មួលបង្កាច់អំពើល្អរបស់គេ |
| ៦. បលាសៈ | ឈប់អង្គុយលើចង្កេះលើកខ្លួនឯង |
| ៧. ឥស្សា | ឈប់ច្រណែនឈ្នានីស |
| ៨. មច្ឆរិយៈ | ឈប់កំណាញ់ម៉ៅស្វិតឃើញតែប្រយោជន៍ខ្លួន |
| ៩. មាយា | ឈប់មាយាលាក់ពុតកំហូច |
| ១០. សាឋេយ្យៈ | ឈប់ឡកគេដោយពាក្យអួត |

| | |
|---|---|
| ១១. ថម្ភៈ | ឈប់ក្បាលរឹង រឹងរូស |
| ១២. សារម្ភៈ | ឈប់ប្រកួតប្រជែងក្នុងន័យបំផ្លាញ គិតតែពីចង់ឈ្នះ |
| ១៣. មានះ | ឈប់ប្រកាន់ខ្លួន ឫកខ្ពស់ |
| ១៤. អតិមានះ | ឈប់គិតថាមានតែខ្លួនឯងខ្លាំង មើលងាយប្រមាថគេ |
| ១៥. មទះ | ឈប់ស្រវឹងស្រី ស្រា ល្បែង យស អំណាច បុណ្យសក្តិ សេចក្តីសុខ លាភ សសើរ |
| ១៦. បមាទះ | ឈប់ប្រមាទ ធ្វេសប្រហែស ខ្ជិលខ្ជា |

# របៀបធ្វើតបះ

ក្នុងមហាសន្និបាតលើកទី១ របស់ព្រះពុទ្ធសាសនា ដែលព្រះសម្មាសម្ពុទ្ធបានធ្វើជាមួយព្រះអរហន្ត ១២៥០ អង្គ កាលពី ២៦០០ ឆ្នាំមុន ព្រះអង្គបានសម្តែងពីរបៀបធ្វើតបះដល់ព្រះអរហន្តទាំងអស់ ដើម្បីទុកជាគោលសំរាប់ផ្សាយសាសនាថា " *ខន្តិ បរមំ តបោ តីតិក្ខា* " សេចក្តីអត់ធ្មត់ គឺជាកំពូលនៃការធ្វើតបះ ។ បានសេចក្តីថា ទាំងតបះបែបព្រះរាជាក្តី ទាំងតបះបែបព្រះឫសីក្តី រួមទាំងកិលេស ១៦ ក្តី អាចនឹងបំពេញបានដោយសារ*ការអត់ធ្មត់* ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ពន្យល់សេចក្តីចំពោះអ្នកធ្វើតបះថា « *ទុស្សីលេហិ ពហុជ្ជនោ* » ប្រែថា " *ពួកមនុស្សដែលមិនប្រក្រតីមានចំនួនច្រើន* " មានជនមួយប្រភេទដែលមិនដូចគេដូចឯង គឺចូលចិត្តរារាំង បោកបន្លំ រំខាន បំផ្លាញដល់អ្នកដែលកំពុងបំពេញសេចក្តីល្អទាំងឡាយ ។ ពួកនេះឯងដែលនឹងធ្វើឱ្យតបះរបស់យើងបែកធ្លាយ តែបើយើងចាប់

កំពូលតបះ គឺ *ការអត់ធ្មត់* របស់យើងបាន យើងអាចនឹងដុតកម្តៅពួកនេះឱ្យក្តៅឆេះលែងប្រព្រឹត្តអំពើអាក្រក់ទាំងនោះបានជាមិនខាន ។

ជាសរុប អ្នកដឹកនាំទាំងឡាយត្រូវរៀនចំរើនតបះ គឺត្រូវដុតកម្តៅជនអាក្រក់ និងអំពើអាក្រក់ដែលមាននៅក្នុងសង្គមខ្លួនឱ្យអស់ និងមិនត្រូវភ្លេចផងទេថា យើងជាអ្នកដឹកនាំ ក៏ត្រូវដុតចោលនូវសេចក្តីអាក្រក់ និងអំពើអាក្រក់ដែលយើងមានឱ្យអស់ទៅផង ។ កាលណាតបះរបស់យើងកើតមានច្រើនហើយ ពេលនោះឯងដែលមហាជននឹងស្រែកអបអរឱ្យពរថា " *ពេញចិត្តហើយៗ* " ជាមិនខាន ។

www.budinst.gov.kh www.elibraryofcambodia.org

# អក្កោធៈ គឺការមិនក្រេវក្រោធ

| | |
|---|---|
| ១. *ន ហិ សាធុ កោធោ* | សេចក្ដីក្រោធមិនល្អសោះឡើយ |
| ២. *កោធោ សត្ថមលំ លោកេ* | សេចក្ដីក្រោធ ទុកដូចជាច្រែះរបស់អាវុធក្នុងលោក |
| ៣. *អនត្ថជននោ កោធោ* | សេចក្ដីក្រោធ នាំទៅរកសេចក្ដីវិនាស |
| ៤. *កោធោ ចិត្តបកោបនោ* | សេចក្ដីក្រោធ ធ្វើឱ្យចិត្តមិនបានសម្រាក |
| ៥. *កោធោ ទុម្មេធគោចរោ* | សេចក្ដីក្រោធ ជាលក្ខណៈរបស់មនុស្សពាល |
| ៦. *នត្ថិ ទោសសមោ គហោ* | គ្មានការចាប់ចងឯណាស្មើនឹងទោសៈទេ |
| ៧. *នត្ថិ ទោសសមោ កលិ* | គ្មានកំហុសណាស្មើនឹងទោសៈទេ |
| ៨. *ហន្តិ កុទ្ធោ សមាតរំ* | ជនដែលក្រោធ សូម្បីតែម្ដាយខ្លួនក៏ហ៊ានសម្លាប់ |
| ៩. *កុទ្ធោ អត្ថំ ន ជានាតិ* | ជនដែលក្រោធ រមែងមិនដឹងនូវផលទាំងឡាយ |
| ១០. *កុទ្ធោ ធម្មំ ន បស្សតិ* | អ្នកក្រោធ រមែងមិនឃើញនូវហេតុទាំងឡាយ |
| ១១. *ទុក្ខំ សយតិ កោធនោ* | មនុស្សក្រោធ តែងដេកកើតទុក្ខជានិច្ច |

www.budinst.gov.kh www.elibraryofcambodia.org

*១២. អន្ធោ អត្ថំ គហេត្វាន អនត្ថំ បដិបជ្ជតិ* អ្នកដែលមានសេចក្ដីក្រោធចូលលុកលុយហើយតែងបំផ្លាញនូវផលប្រយោជន៍ដែលខ្លួនមាន ។

ទាំងអស់នេះ គឺជាពុទ្ធភាសិតខ្លះៗ ក្នុងចំណោមពុទ្ធភាសិតដ៏ច្រើនទៀត ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បង្ហាញអំពីទោសនៃសេចក្ដីក្រោធ ។ នៅក្នុងជាតករឿងមហាបទុមជាតក នៃគម្ពីរខុទ្ទកនិកាយ ដែលជាប្រភពនៃទសពិធរាជធម៌នេះ ក៏មានមូលហេតុមកអំពីរឿងក្រោធដែរ ។ រឿងនោះ មានសេចក្ដីសង្ខេបថា ៖ នៅភាគខាងត្បូងនៃភ្នំហិមពាន្តនៃប្រទេសឥណ្ឌា កាលពីយូរលង់មកហើយ មាននគរមួយឈ្មោះ បទុមនគរ សោយរាជ្យដោយព្រះបាទបទុមរាជ និងព្រះនាងបទុមទេវី ជាអគ្គមហេសី ។ ព្រះរាជាមានរាជបុត្រាបុត្រីជាច្រើនអង្គ តែអង្គដែលធំជាងគេ ព្រះនាមថា មហាបទុម ។ ព្រះរាជាសោយរាជ្យដ៏សុខសាន្ត ឯព្រះរាជកុមារមហាបទុម ក៏មានព្រះជន្មាយុ ១៨ វស្សា ជាទីស្រឡាញ់ គោរពរបស់អាណាប្រជារាស្ត្រជាខ្លាំង ព្រោះព្រះអង្គជារាជកុមារដែលមានកិរិយាទន់ភ្លន់ និងឆ្លៀវឆ្លាត ។

ព្រះបាទបទុមរាជ ទ្រង់មានមហេសីថ្មី ១ ព្រះអង្គទៀត ដែលនៅវ័យក្មេងខ្ចី អាយុស្របាលៗនឹងមហាបទុមជារាជបុត្រ ។ ជាធម្មតាទៅហើយ ដែលព្រះបាទបទុមរាជ ទ្រង់មានជន្មាយុជាង ៦០ វស្សាទៅហើយ ហើយបានមហេសីក្មេង ព្រះអង្គពុំអាចបំពេញនូវចំណង់រាគៈតណ្ហាតាមផ្លូវកាមរបស់មហេសីក្មេងនោះបានឡើយ បើទោះជាព្រះអង្គផ្ដល់នូវកិត្តិយស និងព្រះរាជទ្រព្យដ៏បរិបូណ៌យ៉ាងណាក្ដី ។ ដូច្នេះហើយ បន្ទាប់ពីអភិសេកមហេសីទី ២ មិនយូរប៉ុន្មាន ព្រះនាងរតនាវតី ក៏លបលួចស្នេហាទៅលើព្រះរាជកុមារមហាបទុម ព្រោះនៅក្មេង ជាទីពេញចិត្តមនោរមរបស់វ័យស្រីក្មេងដូចគ្នា ។ នាងរតនាវតី តែងតែបញ្ចេញនូវមាយាស្រីទាំងពួងឱ្យមហាបទុមដឹងថានាងស្រឡាញ់ ហើយព្យាយាមនិងបើកដៃឱ្យ[illegible]

www.budinst.gov.kh www.elibraryofcambodia.org

ជាមួយនាងជានិច្ច ។ តែមហាបទុម ជារាជកុមារល្អ តែងតែគេចចេញជានិច្ច មិនឱ្យកាមលោកិយដែលមាតាចុងក្មេងព្យាយាមឱ្យនោះ គ្របដណ្ដប់បានឡើយ ។ សំបុត្រស្នេហាជាច្រើន បានសរសេរផ្ដោះផ្ដងឱ្យព្រះរាជកុមារ តែព្រះអង្គក៏ពុំតប ហើយក៏លាក់ការណ៍នោះរហូត ។

រាត្រីមួយ ដោយទ្រាំទ្រនឹងភ្លើងរាគៈតណ្ហាមិនបាន នាងរតនាវតី មហេសីចុងព្រះបាទបទុមរាជា ក៏ពុតធ្វើជាប្រឈួនខ្លាំង ហើយក៏បានឱ្យភីលៀងទៅតាមរាជកុមារមហាបទុម មកមើលខ្លួនក្នុងបន្ទប់ ។ ពេលបទុមចូលដល់ក្នុងបន្ទប់ ឃើញនាងរតនាវតីសំងំគ្រលុំផាហ៊ុម ក៏ដើរទៅលុតជង្គង់សួរ ។ ពេលនោះឯង នាងរតនាវតីក៏ងើបឡើងមួយរំពេច ហើយក៏ស្ទុះទៅបិទទ្វារយកខ្នងរាំងជាប់ ។ មហាបទុមដឹងថាចាញ់ល្បិចក៏ស្ទុះចេញ តែត្រូវនាងរតនាវតីចាប់ឱបដោយភ្លើងតណ្ហា ហើយក៏ប្រតាយគ្នារហូតដល់របូតស្បៃសំពត់សារីពីខ្លួននាងរតនាវតី ។ មហាបទុមខំរើ នាងរតនាវតីខឹរឹត ។ ជួនជាគ្រោះអកុសល ព្រះបាទបទុមរាជាក៏រុញទ្វារចូលមក ហើយក៏ស្រឡាំងកាំងចំពោះទិដ្ឋភាពប្រតាយគ្នានោះ ។ ពេលនោះ នាងរតនាវតី ស្រីចិត្តចើកក៏ស្រែកយំភ្លាម ហើយធ្វើជាខំរើ ស្រែកសុំឱ្យបទុមរាជាស្វាមីជួយ ដោយចោទថាមហាបទុមកំពុងចាប់រំលោភខ្លួន ។ ព្រះបាទបទុមរាជាក្រោធខ្ញាល់ជាខ្លាំង ក៏បញ្ជាឱ្យអាមាត្យចាប់ចង ហើយឱ្យ យកទៅបោះក្នុងជ្រោះទាំងរស់ឱ្យបានទាន់មុនថ្ងៃរះ បើទោះជាមហាបទុមកុមារខំស្រែកប្រាប់ថាមិនពិតយ៉ាងណាក៏ដោយ ។ តែកំហឹងព្រះរាជា ធ្វើឱ្យព្រះអង្គលែងគិតថា មហាបទុមជាបុត្រព្រះអង្គទៅហើយ ។ ឯព្រះនាងបទុមទេវី ជាព្រះមាតាពុំអាចដឹងរឿងឡើយ ។ មុននឹងដើរទម្លាក់ខ្លួនទៅក្នុងជ្រោះដោយស្ម័គ្រចិត្ត និងបានអនុញ្ញាតពីពេជ្ឈឃាត មហាបទុមកុមារបានផ្ញើសំបុត្រសេរនឹងឈាមតាមពេជ្ឈឃាតទៅឱ្យព្រះមាតាព្រះអង្គដឹង ហើយក៏លោតទម្លាក់ខ្លួនទៅក្នុងជ្រោះទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រឹកព្រហាមឡើង ព្រះនាងបទុមទេវី ក៏បានទទួលសំបុត្រលោហិត ដែលនៅក្នុងនោះមានបញ្ជាក់ពីកន្លែងទុកភស្តុតាងនានា ជាពិសេស សំបុត្ររបស់រតនាវតី ។ ព្រះនាងបទុមទេវីតក់ស្លុតរហូតដល់បាត់ព្រះស្មារតីសន្លប់ ។ លុះដឹងព្រះកាយវិញ ព្រះនាងក៏នាំយកភស្តុតាងនោះទៅថ្វាយព្រះបាទបទុមរាជាឱ្យបានជ្រាប ។ ពេលឃើញភស្តុតាងហើយ ព្រះបាទបទុមរាជា ក៏ក្តៅក្រហាយ ខឹងក្រេវក្រោធជាខ្លាំងចំពោះរតនាវតី ហើយក៏បានឱ្យអាមាត្យចាប់នាងរតនាវតីយកទៅទម្លាក់ក្នុងជ្រោះមុនព្រះអាទិត្យលិចទៀតទៅ ។ ព្រះអង្គមានការសោកស្តាយជាខ្លាំងចំពោះព្រះរាជបុត្រដែលត្រូវអស់ព្រះជន្មជីវិត ដោយសារសេចក្តីក្រោធរបស់ព្រះអង្គ ។

៧ ឆ្នាំក្រោយមក ព្រះបាទបទុមរាជា ក៏បានចេញទៅប្រពាតព្រៃបរបាញ់សត្វជាមួយព្រះរាជបុត្រព្រះអង្គ ១ ព្រះអង្គទៀត ហើយវង្វេងផ្លូវរហូតដល់យប់ នៅតែរកផ្លូវត្រឡប់មករាជវាំងវិញមិនឃើញ ។ ជាភ័ព្វសំណាង ព្រះអង្គក៏បានចូលទៅក្នុងរូងភ្នំមួយ ហើយនៅទីនោះ ព្រះអង្គបានជួបនឹងឫសីយោគី ដែលមានសក់វែងពុកមាត់ ពុកចង្កាវែង ដូចព្រាយម្នាក់កំពុងបដិបត្តិធម៌ ។ ឥសីអង្គនោះ ក៏បានទទួលព្រះរាជា និងរាជបុត្រឱ្យស្នាក់នៅ ១ យប់ ។ បន្ទាប់ពីសន្ទនាគ្នា ១ សន្ទុះធំមក ព្រះរាជាក៏ដឹងថា ឥសីអង្គនោះ គឺជាមហាបទុមរាជបុត្រដែលព្រះអង្គបានឱ្យពេជ្ឈឃាតសម្លាប់ ។ ព្រះរាជាសោកសង្រេងជាខ្លាំង បានថ្វាយបង្គំសូមខមាទោសឥសីមហាបទុម ហើយបានអង្វរសុំឱ្យមហាបទុមវិលត្រឡប់ទៅវិញដើម្បីគ្រងរាជ្យ តែមហាបទុមមិនព្រមឡើយ ព្រោះចិត្តឥសីតម្រង់ឆ្ពោះទៅរកពោធិញ្ញាណ ដើម្បីត្រាស់ដឹងជាព្រះពុទ្ធថ្ងៃក្រោយទៅហើយ ។ ព្រឹកឡើង ដោយចាញ់ចេះនឹងអង្វរ ព្រះបាទបទុមរាជា និងព្រះរាជបុត្រ ក៏លាឥសីមហាបទុមត្រឡប់ទៅវិញ ។ បន្ទាប់ពីបានប្រាប់ផ្លូវដល់ព្រះរាជា និងព្រះអនុជហើយ ឥសីមហាបទុមក៏បានពោលជាគាថាផ្តាំផ្ញើដល់បិតា និងព្រះអនុជថា ៖

www.budinst.gov.kh www.elibraryofcambodia.org

*នាទិដ្ឋា បរតោ ទោសំ អណុំ ថូលានិ សព្វសោ*
*ឥស្សរោបណយេ ទណ្ឌំ សាមំ អប្បដិវេក្ខិយ ។*

« ព្រះរាជាជាឥស្សរជន បើមិនទាន់ឃើញទោសតូចទោសធំដោយសព្វគ្រប់អំពីសំណាក់បុគ្គលដទៃ ទាំងមិនទាន់ពិចារណាឱ្យឃើញច្បាស់ដោយខ្លួនឯងទេ មិនគប្បីដាក់អាជ្ញាឡើយ » ។

• បើក្សត្រណា មិនទាន់ពិចារណា ហើយធ្វើអាជ្ញា ក្សត្រនោះឈ្មោះថា លេបភោជនាហារប្រកបដោយបន្លា ប្រកបដោយរុយ ដូចជាមនុស្សខ្វាក់ ។

• ព្រះរាជាណា ដាក់អាជ្ញាដល់បុគ្គលដែលមិនគួរដាក់អាជ្ញា មិនដាក់អាជ្ញាដល់បុគ្គលដែលគួរដាក់អាជ្ញា ព្រះរាជានោះឈ្មោះថា មិនដឹងការស្មើ និងមិនស្មើ ដូចជាមនុស្សខ្វាក់ដើរតាមផ្លូវមិនរាបស្មើ ។

• ព្រះរាជាណា ឃើញនូវហេតុទាំងឡាយតូច និងធំទុំះដោយសព្វគ្រប់ជាហេតុដែលឃើញត្រឹមត្រូវហើយ សឹមប្រៀនប្រដៅ ព្រះរាជានោះទើបគួរហៅថា ព្រះរាជាបាន ។

• ព្រះរាជាដែលមានព្រះទ័យទន់ពេក មានព្រះទ័យរឹងពេក ក៏មិនអាចតាំងខ្លួនក្នុងភាពជាធំបានទេ ហេតុនេះ ព្រះរាជាគួរប្រព្រឹត្តនូវហេតុទាំងពីរ ។ ព្រោះព្រះរាជាដែលមានព្រះទ័យទន់ ត្រូវពួករាស្ត្រមើលងាយ ឯព្រះរាជាដែលមានព្រះទ័យរឹងពេករមែងមានពៀរ ព្រះរាជាជ្រាបហេតុទាំងពីរនោះហើយ ត្រូវប្រព្រឹត្តជាកណ្តាល ។

រួចហើយ ឫសីមហាបទុម ក៏បានផ្តល់នូវឱវាទទសពិធរាជធម៌ឱ្យដល់ព្រះបិតា និងព្រះអនុជ ដើម្បីគ្រប់គ្រងនគរ ។ ឯតាបសឫសី ក៏សំងំក្នុងព្រៃបដិបត្តិធម៌រហូតអស់អាយុនៅក្នុងព្រៃទៅ ។

ព្រោះអាស្រ័យឃើញទោសរបស់សេចក្តីក្រោធយ៉ាងដូច្នេះឯង ទើបបាន

www.budinst.gov.kh www.elibraryofcambodia.org

ជាព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តគុណធម៌អក្កោធៈ គឺការមិនក្រោធទុកសំរាប់ឱ្យអ្នកដឹកនាំជាប្រមុខទាំងឡាយបដិបត្តិ ដើម្បីនាំនូវសេចក្តីសុខដល់មហាជន ។

## លក្ខណៈរបស់សេចក្តីក្រោធ

មុននឹង " មិនក្រោធ " សូមធ្វើការស្គាល់នូវសេចក្តីក្រោធជាមុនសិនថាតើមានលក្ខណៈយ៉ាងណា ?

ក្រោធ គឺជាអាការៈរបស់ចិត្តដែលក្តៅខ្ញូលឆេះ ក្រវល់ក្រវាយ ពុះកញ្ច្រោល ។ ឯការក្តៅខ្ញូលឆេះមកពី ៖




សេចក្តីក្រោធនេះ បើកើតឡើងចំពោះមនុស្សធម្មតា មិនសូវជាបង្ករឿងប៉ុន្មានទេ តែបើកើតឡើងចំពោះអ្នកដឹកនាំហើយ ប្រាកដជាមានគ្រោះអន្តរាយជាខ្លាំង ។ អាស្រ័យហេតុដូច្នេះ ការរំលត់សេចក្តីក្រោធចាប់តាំងពីអរតិ គឺការមិន

www.budinst.gov.kh www.elibraryofcambodia.org

ពេញចិត្តមក ទើបជាការសំខាន់សំរាប់អ្នកធំ ។

## ការមិនក្រោធ :

អក្កោធៈ គឺការមិនក្រោធ ជាគោលធម៌ទី ៧ ដែលអ្នកដឹកនាំត្រូវមានក្នុងខ្លួន ។ អ្នកដឹកនាំត្រូវដឹងថា សេចក្ដីក្រោធរបស់អ្នកធំឆាប់ឆាបភ្លើងជាងរបស់អ្នកតូចណាស់ ឬបើប្រៀបធៀបនឹងប្រេងឥន្ធនៈ សេចក្ដីក្រោធរបស់អ្នកតូច ដូចជាប្រេងកាត ឯសេចក្ដីក្រោធរបស់អ្នកធំ ដូចជាប្រេងសាំង ឬក៏ហ្គាស ( Gas ) អញ្ចឹង ។ ដូច្នេះ ចូរប្រយ័ត្នកុំឱ្យឧស្សាហ៍ដាក់នៅកៀនភ្លើងពេក ឬក៏ការពារកុំឱ្យភ្លើងចូលមកជិត ឬបើជាចូលមកហើយ ត្រូវរកមធ្យោបាយពន្លត់ភ្លើងឱ្យបានមួយរំពេច កុំឱ្យឆាបរាលដាលមាន ។

ក្នុងការរំលត់ភ្លើងក្រោធឱ្យបានឆាប់ភ្លាមៗនោះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងថា :

*យោ វេ ឧប្បតិតំ កោធំ   រថំ ភន្តំ វធរយេ*

*តមហំ សារថឹ ព្រូមិ   រស្មិគ្គាហោ ឥតរោ ជនោ*

អ្នកណាអាចរម្ងាប់សេចក្ដីក្រោធដែលកើតឡើងបានភ្លាមមួយរំពេច ដូចអ្នកបើកបររថ បញ្ឈប់រថដែលកំពុងរត់ទៅមុខយ៉ាងលឿនបានភ្លាមមួយរំពេចនោះ អ្នកនោះ តថាគតហៅថា ជានាយសារថិ ( អ្នកបើកបរ ) ចំណែកអ្នកក្រៅពីនោះ (អ្នកដែលបញ្ឈប់មិនបានភ្លាម) តថាគតហៅត្រឹមតែអ្នកកាន់ខ្សែ ( ឬចង្កូត ) តែប៉ុណ្ណោះ ។

ព្រះពុទ្ធវចនៈនេះ មានសេចក្ដីថា ព្រះសម្មាសម្ពុទ្ធប្រៀបអ្នកដែលដឹកនាំក្រុម សង្គម ប្រទេស ដូចជាអ្នកដែលបើកបររទេះ ឬរថយន្ត មាននាទីគ្រប់គ្រងដឹកនាំរទេះ ឬរថយន្តនោះពីកន្លែងមួយទៅកន្លែងមួយ ។ ចំណែកឯអ្នកតូចដែលស្ថិត

www.budinst.gov.kh www.elibraryofcambodia.org

នៅក្រោមការគ្រប់គ្រង ឧបមាដូចជាអ្នកដែលជិះដោយសារក្នុងរថយន្ត ។ ក្នុងទីនេះ ទ្រង់ប្រៀបលក្ខណៈរបស់អ្នកបើកបរ ថាអ្នកដែលមានសមត្ថភាព ជាអ្នកបើកបរ ត្រូវអាចចាប់ហ្វ្រាំងរថយន្តឱ្យបានទាន់ចិត្ត គឺថា បើរថយន្តវានឹងលឿនជ្រុលហួស កំហិត ឬគោលដៅ ក៏អាចចាប់ហ្វ្រាំងទាន់មិនឱ្យហួសទៅបាន ឬបើវេរចង្កូត រកកល់នឹងធ្លាក់ស្នាមភ្លោះ ក៏អាចចាប់ហ្វ្រាំងទាន់បាន ឬបើនឹងបំរុងទៅបុកជល់នឹង អ្វីមួយ ក៏ អាចចាប់ហ្វ្រាំងទាន់បាន ។ រួមសេចក្តីមក មានឈ្មោះថាអ្នកបើកហើយ បើចាប់ហ្វ្រាំងទាន់ពេលវេលាបាន ក៏ហៅឈ្មោះថាអ្នកបើកបរបាន បើចាប់ហ្វ្រាំង មិនទាន់ ទៅជល់នេះជល់នោះ ធ្លាក់អូរ ធ្លាក់គន្លុក ហួសស្នាមគំនូស បែបនេះ ព្រះលោកមិនហៅថាអ្នកបើកបរទេ ( សារថី ) លោកហៅត្រឹមតែអ្នកកាន់ខ្សែ ឬជាអ្នកកាន់ចង្កូត ប៉ុណ្ណោះ គឺខុសគ្នាឆ្ងាយណាស់ ។

## របៀបបញ្ឈប់សេចក្តីក្រោធ

ការបញ្ឈប់សេចក្តីក្រោធ មិនមែនជារឿងងាយៗទេ តែក៏មិនមែនដល់ ទៅពិបាក រហូតរំលត់ភ្លើងក្រោធមិនបាននោះដែរ ។ សំខាន់នៅត្រង់ថា យើងត្រូវ តាំងចិត្តថា " យើងឈប់ក្រោធហើយ " តែប៉ុណ្ណោះ ។ ការតាំងចិត្តនេះ ភាសាធម៌ លោកហៅថា "*តាំងអធិដ្ឋានចិត្ត* " ។

វិធីខ្លះៗ ខាងក្រោមនេះ ជាវិធីសំរាប់រំលត់សេចក្តីក្រោធ លោកអ្នកដឹកនាំ អាចសាកល្បងបាន ឬបើមានវិធីផ្សេងហើយ ក៏មិនជាបញ្ហាអ្វីដែរ សំខាន់គឺ "*ឈប់ ខឹងក្រោធ* " ។

១. ត្រូវមានសម្មាទិដ្ឋិ ពិចារណាឱ្យឃើញទោសរបស់សេចក្តីក្រោធ និង ផលអាក្រក់ដែលកើតពីការខឹងក្រោធ ឬពិចារណាតាមពុទ្ធវចនៈ និងតម្រាផ្សេងៗឱ្យ បានច្បាស់ រហូតដល់យល់ថា សេចក្តីក្រោធមានទោសមែន ។

www.budinst.gov.kh www.elibraryofcambodia.org

២. ពិចារណាឱ្យឃើញផលប្រយោជន៍ដ៏មហាសាល ដែលនឹងកើតមក អំពីការដែលមិនខឹង ក្រេវក្រោធ ។

៣. ប្រើវិធីបរិកម្ម គឺទន្ទេញ ឬភាវនាខ្សឹបៗ ប្រាប់ខ្លួនឯងថា *" កុំខឹង កុំខឹង កុំខឹង " " មិនខ្ចីខឹង មិនខ្ចីខឹង " " កុំទៅខឹងៗ " " ខឹងបានការអ្វីៗ "* ឱ្យបានជាប់ជានិច្ចរាល់ឥរិយាបថ៤ រាល់កិច្ចការ និងរាល់ពេលដែលអារម្មណ៍ក្រោធចូលមកប៉ះចិត្ត ។

៤. មានទស្សនៈទៅលើអ្វីៗក្នុងន័យជាល្អ ជាវិជ្ជមាន បើទោះជាមានអ្វីកើតឡើងក៏ប្រាប់ខ្លួនឯងថា *" ល្អហើយ " " គ្រាន់បើជាងមុន " " មិនអីទេ ល្អហើយ "* ជាប់ជានិច្ច ។ មានរឿងក្នុងគម្ពីរព្រះត្រៃបិដក ដំណាលថា មានភិក្ខុ ១ អង្គបានទៅថ្វាយបង្គំលាព្រះសម្មាសម្ពុទ្ធ ដើម្បីទៅបំពេញសមណធម៌នៅស្រុកមួយឈ្មោះ សុនាបរន្តៈ ដែលជាដែនអ្នកលេង មនុស្សល្អ ស្លូតបូត នៅមិនបានទេ ។ ព្រះសម្មាសម្ពុទ្ធសួរថា " ទ្រាំបានទេ " ? លោកថា " ទ្រាំបាន " ។ ព្រះលោកសួរទៀតថា ចុះបើគេជេរតិតធ្វើម៉េច ? លោកថា បើគេជេរ ជេរទៅ ម៉េចក៏គ្រាន់បើជាងគេវាយដែរ ។ ព្រះលោកសួរទៀតថា ចុះបើគេវាយ ? លោកតបថា " វាយ ក៏វាយចុះ " បើគេវាយនឹងដៃជើង ក៏គ្រាន់បើជាងវាយនឹងដំបង ដុំថ្មដែរ ។ ព្រះសួរថែមថា ចុះបើគេវាយនឹងដំបង ? លោកថា ហ្នឹងគ្រាន់បើជាងគេកាប់នឹងដាវ កាំបិត ។ ចុះបើគេកាប់នឹងដាវ កាំបិតស្លាប់ទៅ ? លោកក៏ថា ហ្នឹងក៏ស្រួលហើយក្រាបទូល ព្រោះមនុស្សខ្លះចង់ស្លាប់ មានការលំបាកនឹងរកអ្វីមកសម្លាប់ខ្លួនឯង បើបានគេមកសម្លាប់ ក៏គ្រាន់បើជាងសម្លាប់ខ្លួនឯង ។ ព្រះសម្មាសម្ពុទ្ធ លោកអនុមោទនាថា សាធុ ! សាធុ ! ហើយក៏អនុញ្ញាតឱ្យភិក្ខុអង្គនោះធ្វើដំណើរទៅតាមប្រាថ្នា ។

៥. មានរបៀបរំងាប់សេចក្តីក្រោធតាមបែបបរទេសម្យ៉ាង គឺថា បើខឹងគេ ហើយចង់ឈ្លោះតតបវិញ គេឱ្យរាប់លេខឱ្យបានចំនួន ១០០០ នោះនឹងអាច

www.budinst.gov.kh www.elibraryofcambodia.org

ឈប់ខឹងហើយ ។

៦. វិធីមួយដែលគេឯងប្រើទៅមានប្រសិទ្ធិភាព គឺការធ្វើសមាធិនៅពេលខឹង ។ ឧទាហរណ៍ បើយើងខឹងអ្នកណាមួយខ្លាំង គប្បីបិទភ្នែក ឬមិនបាច់បិទក៏បាន ហើយដកដង្ហើមឱ្យបានវែងៗជាទីបំផុត ចំនួន ១០ ដង ។ នៅពេលកំពុងដកដង្ហើមវែងៗនោះ ភ្នែក ឬ ចិត្ត ត្រូវសម្លឹងមើលចុងច្រមុះ ( ជាកន្លែងដែលខ្យល់រត់ចេញ រត់ចូលប៉ះនឹងរឹមច្រមុះ ) កុំឱ្យចិត្តងាកបែរទៅណាឱ្យសោះ ។ ធ្វើដូច្នេះកម្លាំងរបស់សេចក្ដីក្រោធ នឹងថយចុះជាលំដាប់ រហូតបាត់ជាមិនខាន ។

៧. ចំរើនមេត្តាកម្មដ្ឋាន ។ ពោលគឺ ផ្សាយមេត្តា នឹកស្រមៃក្នុងចិត្តថា សូមឱ្យសត្វ មនុស្សទាំងអស់បានសេចក្ដីសុខ កុំបីមានពៀរវេរា រវាងគ្នានឹងគ្នាឡើយ ។ អ្នកដែលចូលចិត្ត ក៏សូមសាកសួរអាចារ្យសមាធិកម្មដ្ឋាន ឬអានសៀវភៅបន្ថែមទៀតចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

# ខន្តី គឺការអត់ធន់

ខន្តី តាមតួអក្សរនៃភាសាបាលី ប្រែថា ការអត់ធន់ ឬប្រែថា ការសមគួរនឹងទទួលផល ក៏បាន ។

ជាទូទៅ យើងប្រែពាក្យថា ខន្តី តែត្រឹមការអត់ធន់ទេ តែនៅក្នុងព្រះត្រៃបិដក លោកប្រែថា សមគួរនឹងទទួលផលផងដែរ ដូចជានៅក្នុងខណៈដែលអ្នកបដិ-បត្តិធម៌រៀបនឹងបានសំរេចមគ្គផលនិព្វាននោះ ក៏លោកប្រើពាក្យខន្តីដែរ គឺ សមគួរនឹងសំរេច ក្រោយពីបានអត់ធន់ជាយូរមកហើយ ។

ដូច្នេះ ពាក្យខន្តី ១ ម៉ាត់ មានន័យរួមទាំងសកម្មភាពដែលត្រូវអត់ធន់ផងនិងផលនៃការអត់ធន់ផង គឺបន្ទាប់ពីអត់ធន់ដល់កម្រិតមួយហើយ ផលដែលបានមកក៏សមគួរទៅនឹងសេចក្តីព្យាយាមដែលបានអត់ធន់នោះដែរ ។ អត់ធន់តិច សមគួរបានផលតិច អត់ធន់ច្រើន សមគួរបានផលច្រើន អត់ធន់កម្រិតនេះ សមគួរបានផលយ៉ាងនេះ ជាដើម ។

## ហេតុផលដែលចាំបាច់ត្រូវអត់ធន់

នៅក្នុងរាងកាយរបស់យើងនេះ ក្រៅពីមានភ្នែក ត្រចៀក អវយវៈ ដែលយើងអាចមើលឃើញនេះហើយ នៅមានរបស់សំខាន់មួយទៀត ដែលយើងមើលមិនឃើញ គឺ កម្លាំង ។ កម្លាំងនេះដែលយើងត្រូវអាស្រ័យពឹងពាក់ តាំងតែពីយើងនៅតូច ព្រោះបើគ្មានកម្លាំង យើងមិនអាចធ្វើអ្វីបានទេ គឺយ៉ាងហោចណាស់ ក៏ត្រូវមានកម្លាំងសំរាប់ដកដង្ហើម ផឹកទឹក និងទទួលទានអាហារដែរ ។

កម្លាំងដែលយើងនិយាយនេះ គឺជាកម្លាំងខាងរាងកាយ ប្រើសំរាប់ប្រកប

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើកិច្ចការផ្សេងៗ ហើយអាចកើតឡើងបាន អាស្រ័យដោយការបរិភោគម្ហូបអា-ហារដែលមានជីវជាតិ មានថាមពល ។ ល ។

តែនៅមានកម្លាំងមួយទៀត ដែលជារបស់គួរសំរាប់កម្លាំងកាយ គឺកម្លាំងចិត្ត ។ យើងដឹងហើយថា មនុស្សយើងរួមផ្សំដោយវត្ថុពីរយ៉ាង គឺកាយ និងចិត្ត ។ ដូច្នេះ បើរាងកាយត្រូវការកម្លាំង ចិត្តរបស់យើងក៏ត្រូវការកម្លាំងដែរ ហើយកម្លាំងចិត្ត ហាក់ដូចជាសំខាន់ណាស់ ព្រោះយើងតែងនិយាយខ្លួនយើង ឬឮគេនិយាយថា *បើអស់កម្លាំងចិត្តហើយ រកធ្វើអ្វីក៏មិនកើតដែរ* ។ អ្នកដែលធ្វើអត្តឃាតកម្ម គឺសុទ្ធតែជាអ្នកដែលអស់កម្លាំងចិត្តសំរាប់តស៊ូក្នុងជីវិត ថ្វីដ្បិតតែគេជាមនុស្សមានសុខភាព កម្លាំងពលំមាំមួនក៏ដោយ ។

ព្រះសម្មាសម្ពុទ្ធ លោកទ្រង់ញាណឃើញនូវសារសំខាន់របស់កម្លាំងចិត្តដែលមានមុខនាទីសំខាន់ក្នុងជីវិត ជាពិសេស ចំពោះអ្នកដឹកនាំដែលត្រូវទទួលភារៈធ្ងន់ក្នុងការគ្រប់គ្រងគេនោះ ទើបបានជាលោកដាក់កម្លាំងចិត្តជាគោលមួយ ក្នុងចំណោមគោលទាំង ១០ នៃទសពិធរាជធម៌ សំរាប់ឱ្យអ្នកដឹកនាំទាំងឡាយបដិបត្តិ ។ កម្លាំងចិត្តក្នុងទសពិធរាជធម៌ គឺខន្តីនេះឯង ។ ដូច្នេះ អ្នកដែលមានកម្លាំងចិត្តក្នុងការប្រកបកម្ម គឺអ្នកមានខន្តីនេះឯង ។ *អស់ខន្តីពេលណា អស់ការអត់ធ្មត់ពេលណា កម្លាំងចិត្តក៏អស់ពេលនោះ ការសមគួរនឹងទទួលផល ក៏អស់ពេលនោះដែរ* ។

សារសំខាន់របស់ខន្តី មានធំធេងណាស់នៅក្នុងព្រះពុទ្ធសាសនា គឺជាបណ្តូលធម៌ សំរាប់នាំទៅរកការសំរេចគោលដៅខ្ពស់បំផុតរបស់ជីវិត ឬព្រះនិព្វានតែម្តង ។ យើងអាចនិយាយថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គទាំង ៨៤០០០ ព្រះធម្មក្ខន្ធ មករួមនៅត្រង់ថា ខន្តីមួយម៉ាត់នេះឯង ។ អ្នកគ្មានខន្តី មិនអាចសំរេចធម៌សូម្បីតែបន្តិចបន្តួចឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងសេចក្ដីប្រកាសដើម្បីចាត់តាំងអង្គការពុទ្ធសាសនា ជាលើកដំបូង បង្អស់របស់ព្រះអង្គនៅប្រទេសឥណ្ឌា កាលពី ២៦០០ ឆ្នាំមុន ហើយដែល ពុទ្ធបរិស័ទយើងស្គាល់ក្នុងនាមថា "*មហាចតុរង្គសន្និបាត*" ( មាឃបូជា ) នោះ ព្រះអង្គបានលើកខន្តី គឺការអត់ធន់ ថាជាភ្លើងដ៏ធំបំផុត សំរាប់ដុតបំផ្លាញនូវឧបសគ្គ ទាំងឡាយ ដែលរារាំងដល់ការធ្វើដំណើរទៅរកគោលដៅជីវិត គឺព្រះនិព្វាន គឺទ្រង់ សម្ដែងថា "*ខន្តិ បរមំ តបោ តីតិក្ខា* សេចក្ដីអត់ធន់ គឺជាតបៈ (ភ្លើង) ដ៏ឧត្ដម" ។

## វិធីបង្កើនកម្លាំងចិត្ត ឬខន្តី

មកដល់ត្រង់នេះ យើងគង់នឹងដឹងនូវសារសំខាន់របស់ខន្តី ឬកម្លាំងចិត្ត នេះហើយ ។ តែបញ្ហានៅមានតទៅទៀត គឺថា តើយើងធ្វើម្ដេចដើម្បីបង្កើនខន្តីឱ្យ បានរឹតតែច្រើន ។

*វិធីបង្កើនខន្តី គឺត្រូវមានខន្តី* ។ ស្ដាប់ទៅដូចជាប្លែក ឬដូចនិយាយ លេង តែតាមការពិត អ្នកដែលមានខន្តីច្រើន គឺអ្នកដែលមានការអត់ធន់ច្រើននេះ ឯង ។ ព្រោះពាក្យថាអត់ធន់ មានន័យក្នុងនោះស្រេចទៅហើយ គឺត្រូវ ហាត់អត់ និង ហាត់ធន់ ។

**. អត់** គឺទប់ បានដល់ហាមចិត្តរបស់ខ្លួនមិនឱ្យធ្វើអ្វីតាមតែចិត្តចង់ ដូចជាមានអ្នកណាយកសំណូកមកសូករាប់ម៉ឺន រាប់សែន ដោយតាមការពិតទៅ យើងក៏ចង់បានដែរ តែយើងមិនព្រមលុះទៅតាមអំណាចចង់របស់ចិត្ត យើងខំអត់ មិនព្រមទទួល ។ ការភ្លើតភ្លើនក្នុងកាមារម្មណ៍ ដែលមានមនុស្សមកចាំបំរើលិច បំរើ កើត យកចិត្តយកថ្លើមជាពិសេសជាដើម តាមពិត យើងចង់ដូចគ្នា តែយើងខំអត់

www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

មិនព្រមធ្វើក្នុងរបស់ដែលមិនសមគួរទាំងនោះ ។ ដូច្នេះ យើងតែងប្រើពាក្យ **អត់ធ្មត់** ។

• **ធន់** គឺទ្រាំចំពោះអារម្មណ៍ ដែលខ្លួនមិនចូលចិត្ត ដែលខ្លួនស្អប់ កាលណារបស់នោះចូលមកប៉ះទង្គិចផ្លូវចិត្ត យើងក៏ធន់ ដើម្បីប្រកាន់ខ្ជាប់នៅក្នុងសេចក្តីល្អរបស់យើង ។ តាមពិត ពេលអារម្មណ៍មិនល្អទាំងនោះចូលមករុករានយើង យើងចង់តែធ្វើអ្វីមួយត្រឡប់ទៅវិញណាស់ តែយើងទ្រាំ ដូចជាធន់នឹងការឃ្លាន ធន់នឹងការនឿយហត់ ធន់នឹងពាក្យជេរប្រទេចជាដើម ។ បែបនេះ យើងច្រើនហៅថា **អត់ទ្រាំ** ។

ការអត់ធ្មត់ និងការអត់ទ្រាំ ទាំងពីរនេះរួមគ្នាទៅជាអត់ធន់ ឬខន្តី ។ អ្នកណាត្រូវការខន្តី ក៏ត្រូវហ្វឹកហាត់ឱ្យបានច្រើន គឺ ហាត់អត់ និង ហាត់ធន់ ជាពិសេសអ្នកដឹកនាំដែលមានចិត្តដូចប្រេងសាំង រហ័សឆាបនោះ ត្រូវរៀនធន់ឱ្យបានច្រើនជាទីបំផុត ទើបមានកម្លាំងចិត្តធ្វើការតទៅទៀត ទើបសមគួរនឹងបានផលដែលខ្លួនប្រាថ្នាបាន ។

## អ្នកដឹកនាំត្រូវអត់ធន់ចំពោះអ្វីខ្លះ ?

*១. អត់ធន់ចំពោះកិលេសរបស់ខ្លួន* ដែលតែងតែគៀបសង្កត់ ជំរុញឱ្យប្រព្រឹត្តនូវអ្វីដែលមិនត្រឹមត្រូវ ដែលជំរុញឱ្យធ្វើអ្វីស្រេចតែចិត្ត ។

*២. អត់ធន់ចំពោះភាពល្ងង់ខ្លៅរបស់ខ្លួន* ដែលជាការនាំឱ្យកើតផលអាក្រក់ បណ្តាលមកពីខ្លួនមានការសិក្សាតិច ។ម្យ៉ាងទៀត ម្នាក់ៗមិនអាចចេះអ្វីទាំងអស់ទេ រឿងខ្លះយើងមិនចេះ យើងត្រូវអត់ធន់ មិនបង្ខំធ្វើទេ ទុកឱ្យគេធ្វើ ថ្វីដ្បិតតែយើងចង់ធ្វើក៏ដោយ ។

*៣. អត់ធន់ចំពោះអ្នកតូច* អ្នកនៅក្រោមបង្គាប់ ។ អ្នកខ្លះមានព្រឹត្តិកម្ម ប្លែកៗ ដែលជារឿងត្រូវឱ្យយើងអត់ធន់ ព្រោះបើមិនអត់ធន់ មានតែបែកបាក់ ប្រេះឆា កើតរឿងកើតរ៉ាវមិនខាន ។

*៤. អត់ធន់ចំពោះការងាររបស់ខ្លួន* គឺការងារដែលខ្លួនកំពុងធ្វើ នាទីដែលកំពុងមាន ត្រូវអត់ធន់ មិនលះបង់ចោល មានសេចក្ដីព្យាយាមជានិច្ច ទោះជាមានឧបសគ្គយ៉ាងណាៗ ក៏ដោយ ក៏ព្យាយាមអត់ធ្មត់ អត់ទ្រាំ ដោះស្រាយបញ្ហានោះទៅតាមហេតុផល សតិបញ្ញាជាលំដាប់ រហូតសមគួរនឹងបានផលដែលខ្លួនប្រាថ្នា ។ អត់ធន់ចំពោះនាទី ការងារខ្លួននេះ ជាការអត់ធន់ចម្បងនៃការអត់ធន់ដទៃទៀត ។

*៥. អត់ធន់ចំពោះពាក្យណែនាំ ពាក្យប្រឹក្សា* ដែលទីប្រឹក្សា គ្រូអាចារ្យ ពលរដ្ឋបានណែនាំ បានប្រឹក្សា ។ ត្រូវអត់ធន់ក្នុងការស្ដាប់ បើទោះជាពាក្យប្រឹក្សានោះមិនល្អក៏ដោយ ។ ធម្មជាតិបង្កើតយើងឱ្យមានត្រចៀក ២ គឺឱ្យស្ដាប់ឱ្យបានច្រើនជាងនិយាយ ។ ក្នុងលទ្ធិប្រជាធិបតេយ្យ ដែលម្នាក់ៗមានសិទ្ធិបញ្ចេញយោបល់ អ្នកដឹកនាំគប្បីអត់ធន់ស្ដាប់ បើទោះជាពាក្យណែនាំនោះ យកជាការមិនបានក៏ដោយ មិនត្រូវយកតែគំនិតរបស់ខ្លួនថាត្រូវស្រេច ត្រូវទាំងអស់នោះឡើយ ។

*៦. អត់ធន់ចំពោះសេចក្ដីប្រមាទធ្វេសប្រហែស* ដែលក្រុមសមាជិករបស់ខ្លួនបានធ្វើរួមគ្នា ត្រូវអត់ធន់ ទើបអាចធ្វើការតទៅទៀតបាន ។

*៧. អត់ធន់ចំពោះមនុស្សល្ងង់* ដែលមាននៅក្នុងសង្គម ។ មនុស្សល្ងង់តែងធ្វើអ្វីមិនជាទីប្រាថ្នា ក៏ត្រូវអត់ធន់ មិនមែនសម្លាប់មនុស្សល្ងង់ឱ្យអស់នោះទេ ។

*៨. អត់ធន់ចំពោះកូនក្មេង* ធម្មតាកូនក្មេង យុវជន តែងមានឈាមរាវពីស រលោម ធ្វើអីមិនគិតមុខគិតក្រោយ ក្នុងឋានៈជាអាណាព្យាបាល ត្រូវអត់ធន់ចំពោះសកម្មភាពទាំងនោះ ។

*៩. អត់ធន់ចំពោះអ្នកប្រឆាំង* ជាពិសេសក្នុងឋានៈជារដ្ឋាភិបាលនៃលទ្ធិ

www.budinst.gov.kh www.elibraryofcambodia.org

ប្រជាធិបតេយ្យ ឬស្ទួម្បីតែនៅក្នុងអង្គប្រជុំ ក៏តែងតែមានអ្នកប្រឆាំងជានិច្ច អ្នកដឹកនាំទាំងឡាយ ត្រូវអត់ធន់ ព្រោះជាសេរីភាព ជាសិទ្ធិក្នុងរបបនយោបាយពហុបក្ស ដូចជាការទិនាស់ក្នុងរដ្ឋសភា ការដើរបាតុកម្មជាដើម ជារឿងដែលរដ្ឋាភិបាលនីមួយៗតែងតែជួប ។ បើមិនអត់ធន់ទេ ប្រជាធិបតេយ្យមិនអាចអភិវឌ្ឍបានឡើយ ។

*១០. អត់ធន់ចំពោះពាក្យត្មះតិះដៀល* ពាក្យរិះគន់ទាំងឡាយដែលតែងតែមាន ដែលស្ទួម្បីតែព្រះសម្មាសម្ពុទ្ធបរិសុទ្ធដោយសីល សមាធិ បញ្ញា ចរិយា-វត្តទៅហើយ ក៏នៅតែមានគេមិនពេញចិត្ត ហើយនិន្ទា ជេរ ដៀលដែរ ដូចព្រះអង្គបានសម្តែងថា "*នត្ថិ លោកេ អនិន្ទិតោ នាម*" អ្នកដែលថាគ្មានគេនិន្ទានៅក្នុងលោកនេះ មិនមានទេ ។

*១១. អត់ធន់ចំពោះភាពស្មោកគ្រោក* ដូចជាការដើរទៅមើលសុខទុក្ខអ្នកស្រុកជាដើម អ្នកដឹកនាំខ្លះមិនហ៊ានលុកទៅជ្រៅទេ ព្រោះខ្លាចស្អុយឆ្អាប ឬប្រឡាក់ជើងជាដើម ។ តែបើសិនជាហ៊ានលុកលុយវិញ អ្នកដឹកនាំនោះនឹងបានទទួលការសរសើរពេញចិត្តពីមហាជន ព្រមទាំងឃើញការពិតពីជីវិតរស់នៅរបស់រាស្ត្រពិតៗ មិនខាន មិនមែនបានឃើញតែត្រឹមក្រដាសពតិមានទេ ។

*១២. អត់ធន់ចំពោះសង្គម* ដែលមានវិបត្តិកើនឡើងៗ ព្រោះក្នុងលោកបច្ចុប្បន្ននេះ ប្រែប្រួលទៅតាមវត្ថុនិយមនៃកិលេសតណ្ហា មានការឃើញតែប្រយោជន៍ខ្លួនកាន់តែច្រើនឡើង ប្រកាប់ប្រចាក់គ្នា ឈ្លោះគ្នា ដណ្តើមគ្នា យើងត្រូវអត់ធន់ បើមិនដូច្នោះទេ ប្រាកដជាឆ្កួតមិនខាន ។

*១៣. អត់ធន់ចំពោះពេលវេលា* គឺរឿងនីមួយៗ សុទ្ធតែកំណត់ឡើងដោយពេលវេលាមួយ ដូចជារឿងនេះ ត្រូវការស៊ីពេលប៉ុន្មានខែ ប៉ុន្មានឆ្នាំ ជាដើម បើយើងមិនអត់ធន់រងចាំដល់ពេលហ្នឹងទេ ចង់តែបានលឿន មិនទៅតាមលំដាប់នៃពេលវេលា ឬទំុមុនស្រគាល ក៏នឹងនាំឱ្យខូចការមិនខាន ។

www.budinst.gov.kh www.elibraryofcambodia.org

*១៤. អត់ធន់ចំពោះការប្រែប្រួលនៃធម្មជាតិ* ដូចជាក្តៅពេក ត្រជាក់ពេក ទឹកជន់ រាំងស្ងួតជាដើម ដែលជាលក្ខណៈរបស់ធម្មជាតិ មិនមានអ្នកណាអាចទៅត្រួតត្រាបាន ។

*១៥. អត់ធន់ចំពោះការបដិបត្តិធម៌* គឺការបដិបត្តិតាមទសពិធរាជធម៌ទាំង ១០ នេះ ត្រូវការខន្តី ត្រូវការអត់ធន់ គឺអត់ធន់ក្នុងការធ្វើទាន អត់ធន់ក្នុងការរក្សាសីល អត់ធន់ក្នុងការបរិច្ចាគ អត់ធន់ក្នុងការធ្វើខ្លួនឱ្យត្រង់ អត់ធន់ក្នុងការធ្វើខ្លួនឱ្យទន់ភ្លន់ អត់ធន់ក្នុងការកំចាត់អំពើអាក្រក់ អត់ធន់ក្នុងការមិនក្រោធខឹង អត់ធន់ក្នុងការមិនបៀតបៀនគេ អត់ធន់ក្នុងការពង្រឹងកម្លាំងចិត្ត និងអត់ធន់ក្នុងការមិនធ្វើខុស ។

*១៦. ។ល។*

## សង្ខេបវត្ថុដែលត្រូវអត់ធន់

ការអត់ធន់ បើនឹងរៀបរាប់មានច្រើនតទៅទៀតណាស់ ដែលដាក់មកខាងលើជាឧទាហរណ៍ចំនួន ១៥ នេះ គ្រាន់តែជាគំរូប៉ុណ្ណោះ ដើម្បីជាការងាយស្រួលចាំ បុរាណាចារ្យបានចែកវត្ថុដែលត្រូវអត់ធន់ជាមួយ ចំនួន ៤ យ៉ាង ដូចមានរូបខាងក្រោម ៖




រូបនេះចង់បង្ហាញថា មនុស្សយើងមានកម្រិតនៃការអត់ធន់ចំពោះ

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីលំបាកបានច្រើន ចំពោះទុក្ខវេទនាជាលំដាប់ ចំពោះការឈឺចាប់ជាបន្ទាប់ និង ចំពោះអំណាចកិលេសបានតិចជាទីបំផុត ។ បានសេចក្ដីថា កាលណាអំណាចកិលេស ចូលមកដល់ អ្នកដែលអត់ធន់ចំពោះអំណាចកិលេស មានតិចណាស់ ។

*១. អត់ធន់ចំពោះសេចក្ដីលំបាក* គឺអត់ធន់ចំពោះការលំបាករបស់ ការងារ មិនរញ៉េរញ៉ៃចំពោះឧបសគ្គ ការហត់នឿយ ស្រេកឃ្លាន ក្ដៅត្រជាក់ជាដើម ។

*២. អត់ធន់ចំពោះទុក្ខវេទនា* ដូចជាការឈឺចាប់ ជំងឺតម្កាត់ ចំពោះ ការសោកសៅ ការព្រាត់ប្រាស រប្ចួស មុតនេះនោះជាដើម ។

*៣. អត់ធន់ចំពោះការឈឺចិត្ត* ដូចជាបានទទួលការអយុត្តិធម៌ ត្រូវគេ ដើរនិន្ទា មួលបង្កាច់ ត្រូវគេចំអកឡកឡឺយ មើលងាយមើលថោក ត្រូវគេរារាំងមិន ឱ្យសំរេចកិច្ចការជាដើម ។

*៤. អត់ធន់ចំពោះអំណាចកិលេស* ដូចជាអត់ធន់ចំពោះវត្ថុដែលមក ជន្លួនវកាមារម្មណ៍របស់យើងឱ្យស្រើបស្រាល អត់ធន់ចំពោះការបញ្ឆោរ អួតលើក ជើង អត់ធន់ចំពោះការចង់បានអំណាចមិនត្រឹមត្រូវតាមធម៌ រួមគឺការអត់ធន់ចំពោះ ចិត្តដែលចង់ធ្វើអ្វីស្រេចតែចិត្ត ។

## វិធីទប់ទល់ចំពោះវត្ថុដែលជាឧបសគ្គរបស់ខន្តី

*ពុទ្ធានុស្សតិ មេត្តា ច អសុភំ មរណស្សតិ*

*ឥច្ចិមា ចតុរោ រក្ខា កាតព្វា ច វិបស្សនា*

អារក្ខកម្មដ្ឋានទាំង ៤ គឺ ពុទ្ធានុស្សតិ មេត្តា អសុភៈ និងមរណស្សតិ ជាកម្មដ្ឋានគប្បីធ្វើទុក និងចំរើនវិបស្សនា ។

ពុទ្ធភាសិតនេះ បង្ហាញពីកម្មដ្ឋាន ៤ យ៉ាង ដែលពុទ្ធបរិស័ទគប្បីចំរើន ឬ ប្រើប្រាស់ សំរាប់ទប់ទល់នឹងអំណាចកិលេស ។

www.budinst.gov.kh www.elibraryofcambodia.org

**កម្មដ្ឋាន** កម្មដ្ឋានប្រែថា ដ្ឋាននៃការងារ ទីតាំង ឬគ្រឹះនៃការងារ ។ បានសេចក្តីថា ដ្ឋានទាំង ៤ នេះ ជាគ្រឹះនៃការសំរេចជោគជ័យលើឧបសគ្គទាំងពួង បើនរណាមានក្នុងខ្លួនហើយ ការងារដែលចេញពីអ្នកនោះ នឹងបានជោគជ័យជាមិនខាន ។

| | | | |
|---|---|---|---|
| កំចាត់សេចក្តីលំបាក | ពុទ្ធានុស្សតិ | មេត្តា | កំចាត់ការឈឺចិត្ត |
| កំចាត់អំណាចកិលេស | អសុភៈ | មរណៈ | កំចាត់ទុក្ខវេទនា |

*១. ពុទ្ធានុស្សតិ* ៖ បើសេចក្តីលំបាក ចូលមកបៀតបៀនចំពោះខន្តីរបស់យើង ហើយយើងគិតថាមិនអាចទ្រាំបានទៀតទេ សូមឱ្យយើងរំលឹកដល់ព្រះសម្មាសម្ពុទ្ធ ដោយយកបដិបទា គឺការប្រព្រឹត្តរបស់ព្រះអង្គយកមកធ្វើជាគំរូ យកធម្មៈរបស់ព្រះអង្គមកសិក្សា ។ ដូចជាបញ្ហានេះ តើព្រះសម្មាសម្ពុទ្ធលោកដោះស្រាយយ៉ាងដូចម្តេច បញ្ហានោះលោកយកធម្មៈអ្វីទៅដោះ ទើបបានសំរេចជាដើម ។ ជាឧទាហរណ៍ ក្នុងការផ្តាញ់អាឡវកយក្សឱ្យលុះក្នុងឱវាទព្រះអង្គបានជាដើម ។ ការយកគំរូនៃការដោះស្រាយបញ្ហាតាមបែបព្រះសម្មាសម្ពុទ្ធនេះ លោកហៅថា ពុទ្ធានុ-ស្សតិ គឺរំលឹកទៅដល់ព្រះពុទ្ធ ។

*២. មេត្តានុស្សតិ* ៖ បើមានការបៀតបៀន ការចងគំនុំ ឈឺចិត្ត ឈឺថ្លើម មានកំហឹងកើតឡើង ក្រោយពីប្រើពុទ្ធានុស្សតិ ជាគោលសំរាប់ដោះស្រាយហើយ គប្បីផ្សាយមេត្តាដល់ជននោះ ដោយគិតថា គ្នាល្ងង់ គ្នាមិនដឹងអីទេ កុំខឹងគ្នា ឱ្យគ្នាបានសេចក្តីសុខចុះ ដើម្បីជាការបង្អន់ការចងពៀរនឹងគ្នាទៅវិញទៅមក ។

www.budinst.gov.kh www.elibraryofcambodia.org

ម្យ៉ាងទៀត ការមានមេត្តាចិត្តនឹងនាំឱ្យមានមេត្តាវាចា នឹងនាំឱ្យមានមេត្តាកាយ ដែលជាការទប់មិនឱ្យយើងធ្វើអ្វីដល់ជននោះដោយអំពើឃោរឃៅ ដែលជាហេតុនាំឱ្យរឿង រឹតតែរីកដុះដាលឡើងទៀតផង គឺ *ឈ្នះឧបសគ្គដោយវិធីអហិង្សា* ។

*៣. អសុភានុស្សតិ* ៖ បើមានការកំណត់ក្នុងកាមចំពោះភេទកើតឡើង ឬសេចក្ដីស្នេហាដែលអាចកើតឡើង ក៏ពិចារណាឱ្យឃើញថា បុរស-ស្រីទាំងឡាយសុទ្ធសឹងជាអសុភ ជារបស់ស្មោកគ្រោក-ស្អុយគគ្រុក មិនមានអ្វីគួរជាទីរីករាយ មានលក្ខណៈដូចខ្មោចស្លាប់ហើម គឺប្រៀបមនុស្សដូចនឹងខ្មោចស្លាប់ ។

*៤. មរណានុស្សតិ* ៖ គឺយកសេចក្ដីស្លាប់មកពិចារណាថាមនុស្សយើងយ៉ាងខ្លាំងណាស់អស់ត្រឹមស្លាប់ អ្នកណាក៏ស្លាប់ យើងក៏ស្លាប់ មិនមានអ្នកណាអាចរស់បានរហូតទេ ។ ធ្វើយ៉ាងនេះ ក៏នឹងនាំឱ្យកម្លាំងចិត្តរឹងប៉ឹងលែងខ្លាច ព្រោះមនុស្សយើងខ្លាចជាងគេ គឺខ្លាចស្លាប់ បើស្លាប់លែងខ្លាចហើយ ខន្តី ឬកម្លាំងចិត្តក៏នឹងកើនដែរ ។

រួមសេចក្ដីមក បើមានឧបសគ្គណានីមួយកើតឡើងដែលនឹងនាំឱ្យខន្តីបែកធ្លាយ ក៏គប្បីយកកម្មដ្ឋានណានីមួយ ឬ ទាំងអស់ចូលមកចាត់ការឧបសគ្គនោះទៅ ក៏នឹងបានផលជាមិនខាន ។

## ផលប្រយោជន៍របស់ខន្តី

*ខន្តិ បរមំ តបោ តីតិក្ខា* ៖ ខន្តីជាភ្លើង ជាតបៈ សំរាប់កំចាត់នូវឧបសគ្គក្នុងជីវិត ក្នុងកិច្ចការទាំងពួង,

*ខន្តិ បធានការណំ* ៖ ខន្តីជាប្រធាននៃកិច្ចការទាំងពួង,

*កេវលានំបិ បាបានំ ខន្តិមូលំ និកន្តតិ* ៖ សេចក្ដីអត់ធន់ អាចកំចាត់នូវ

www.budinst.gov.kh www.elibraryofcambodia.org

ឬសនៃអំពើអាក្រក់បាបទាំងពួង,

*គរហកលហាទីនំ មូលំ ខណាតិ ខន្តិកោ* ៖ សេចក្តីអត់ធន់ អាចកំចាត់បង់នូវពាក្យតិះដៀល និងពាក្យឈ្លោះប្រកែកបាន,

*ខន្តិ ធីរស្សាលង្ការោ* ៖ សេចក្តីអត់ធន់ ជាគ្រឿងអលង្ការបស់អ្នកប្រាជ្ញ

*ខន្តិ ពលំ វ យតីនំ* ៖ សេចក្តីអត់ធន់ ជាកម្លាំងរបស់អ្នកបំពេញតបធម៌ ឬអ្នកដែលព្យាយាមកំចាត់នូវសេចក្តីអាក្រក់,

*ខន្តិកោ មេត្តវា លាភី យសស្សី សុខសីលវា*
*បិយោ ទេវមនុស្សានំ មនាបោ ហោតិ ខន្តិកោ*

អ្នកដែលអត់ធន់នឹងបានមិត្តសម្លាញ់, អ្នកដែលអត់ធន់នឹងបានលាភ, អ្នកដែលលអត់ធន់នឹងបានយស, អ្នកដែលអត់ធន់នឹងបានសេចក្តីសុខ, មនុស្ស និងទេវតា ( អ្នកធំ ) តែងស្រឡាញ់អ្នកមានខន្តី ។

*អត្តនោបិ បរេសញ្ច អត្ថាវហោ វ ខន្តិកោ*
*សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោ ហោតិ ខន្តិកោ*

អ្នកដែលអត់ធន់ ឈ្មោះថាជាអ្នកបានធ្វើប្រយោជន៍ឱ្យដល់ខ្លួនឯងផង ឱ្យដល់សង្គមផង អ្នកអត់ធន់ឈ្មោះថាបានឡើងលើផ្លូវដែលធ្វើដំណើរទៅកាន់ស្ថានសួគ៌ និងព្រះនិព្វាន ។

*សត្ថុនោ វចនោវាទំករោតិយេវ ខន្តិកោ*
*បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ ។*

អ្នកណាអត់ធន់ អ្នកនោះឈ្មោះថាបានធ្វើតាមឱវាទព្រះសម្មាសម្ពុទ្ធ ។ បណ្តាការបូជាទាំងឡាយ ការបូជាដោយការអត់ធន់ ឈ្មោះថាជាការបូជាដ៏ឧត្តមបំផុត ។

សង្គ្រាមស្រុកខ្មែរនេះឡើងជាង ២០ ឆ្នាំហើយ ។ លទ្ធផលរបស់សង្គ្រាម

www.budinst.gov.kh www.elibraryofcambodia.org

គឺសេចក្តីទុក្ខលំបាកដ៏ធំហួសប្រមាណ ហើយផលនេះនឹងមានឥទ្ធិពលជាច្រើនឆ្នាំទៀត ។ សូមឱ្យអ្នកដឹកនាំប្រទេសខ្មែរទាំងឡាយ មានខន្តីក្នុងការធ្វើសន្តិភាព ធ្វើសន្តិសុខ កសាងប្រទេសជាតិ វប្បធម៌ សាសនា ដោយសេចក្តីអត់ធ្មត់ អត់ទ្រាំឱ្យបានខ្លាំងជាទីបំផុត ។ ជាពិសេសសូមឱ្យអត់ធន់ក្នុងផ្លូវមេត្តា និងព្យាយាមយកគំរូតាមព្រះពុទ្ធជាបរមគ្រូរបស់យើង ព្រោះថា សង្គ្រាមដោយអាវុធនឹងចប់មែន តែសង្គ្រាមជីវិត សង្គ្រាមក្រពះ សង្គ្រាមប្រជាធិបតេយ្យ នឹងមានកើតឡើងជាពិតប្រាកដ និងជាធម្មតាមិនខាន សូមគិតថា បើកាលណាខន្តីរបស់អ្នកដឹកនាំបែកធ្លាយជីវិតខ្មែរនឹងត្រូវប្រឈមជាចំពោះសង្គ្រាមអាវុធទៀតជាមិនខាន ។

ខ្មែរយើងចង់ស្រែកណាស់ នូវពាក្យ " ពេញចិត្តហើយៗ រាជាៗ " ចំពោះអ្នកដឹកនាំខ្មែរដែលមានខន្តីក្នុងការដឹកនាំប្រទេសជាតិ ព្រោះកាលណាខ្មែរមានខន្តីខ្មែរនឹងសមគួរទទួលនូវសុគតិ គឺសេចក្តីសុខ និងនិព្វាន គឺគ្មានសេចក្តីទុក្ខជាពិតប្រាកដ ។

www.budinst.gov.kh www.elibraryofcambodia.org

# អវិហឹង្សា គឺការមិនបៀតបៀន

**អវិហឹង្សា** ៖ ប្រែថា ការមិនបៀតបៀន គឺមិនធ្វើឱ្យគេក្តៅក្រហាយ រងទុក្ខ ។ គោលបំណងរបស់រាជធម៌ ៩ នេះ គឺឱ្យអ្នកដឹកនាំវៀរចាកប្រើអំណាច នាទីរបស់ខ្លួន ក្នុងផ្លូវដែលមិនត្រឹមត្រូវ ដូចជាជិះជាន់ កំហែងគម្រាមអ្នកដែលនៅក្រោមអំណាចនាទីរបស់ខ្លួន ពលរដ្ឋខ្លួន ឱ្យទុក្ខវេទនា ក្តៅក្រហាយ ព្រោះតែដើម្បីផលប្រយោជន៍ខ្លួន សេចក្តីសុខរបស់ខ្លួន ឬបក្សពួកខ្លួន ។

មានពាក្យ ១ ម៉ាត់ទៀត ស្មើនឹងពាក្យអវិហឹង្សាដែរ គឺពាក្យ អព្យាបជ្ឈា ដែលប្រែថា មិនបៀតបៀន មិនព្យាបាទដូចគ្នា ។

ផលប្រយោជន៍របស់ការមិនបៀតបៀន មានយ៉ាងណានោះ សូមមើលពុទ្ធវចនៈដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងទុកថា " *អព្យាបជ្ឈំ សុខំ លោកេ* " ប្រែថា " ការមិនបៀតបៀនគ្នា គឺជាសេចក្តីសុខក្នុងពិភពលោក " ដូច្នេះ បើយើងត្រឡប់សុភាសិតនេះវិញ យើងនឹងឃើញថា "*ការបៀតបៀនគ្នា គឺជាសេចក្តីទុក្ខក្នុងពិភពលោក* " ។ យើងឃើញថា *ការមិនបៀតបៀន និងការបៀតបៀន* គឺជាកត្តាកំណត់នូវជោគវាសនារបស់ពិភពលោក ឬពិភពលោកនឹងស្ងប់សុខ មានសន្តិភាព ឬ ក៏កើតសង្គ្រាមវិនាសហិនហោច ក៏ព្រោះ *អាស្រ័យតួបៀតបៀន និងមិនបៀតបៀនគ្នានេះឯង* ។ យើងមិនបាច់និយាយធ្វើឱ្យវែងឆ្ងាយទេ ប្រទេសខ្មែរយើងនេះឯងជាឧទាហរណ៍យ៉ាងច្បាស់ ដែលបង្ហាញពីទោស ពីទុក្ខលំបាកដែលកើតចេញពីការបៀតបៀនគ្នាមិនចេះចប់ មិនចេះហើយ រហូតដល់បរទេសខ្លះដេរប្រៀនប្រដៅកូនថា "*ក្មេងកុំធ្វើដូចអាពួកខ្មែរទុំះ* " ។

www.budinst.gov.kh www.elibraryofcambodia.org

# ប្រទេសខ្មែរយើងនឹងបានសេចក្ដីសុខភ្លាម ! បើខ្មែរទាំងអស់ឈប់បៀតបៀនគ្នា

*អបិ ចេ បត្តមាទាយ អនាគារំ បរិព្វជេ*

*អញ្ញំ អហិង្សយំ លោកេ អបិ រជ្ជេន តំ វរំ ។*

« ថ្វីដ្បិតតែដៃកាន់អម្បែងដើរសុំទានគេ ថ្វីដ្បិតតែគ្មានផ្ទះសម្បែង ដើរត្រាច់គ្រប់ទីកន្លែងយ៉ាងណាក្ដី តែមិនបៀតបៀនអ្នកណានៅក្នុងលោកហើយ ប្រការនេះ ប្រសើរជាងការគ្រប់គ្រងប្រទេស រាជសម្បត្តិទៅទៀត ។ »

ព្រះសម្មាសម្ពុទ្ធ លោកលើកតម្លៃការមិនបៀតបៀននេះថា មានតម្លៃប្រសើរជាងការគ្រងរាជសម្បត្តិ ការគ្រប់គ្រងប្រទេសទៅទៀត ឬអាចនិយាយបានថា ក្នុងលោកនេះ ក្នុងប្រទេសនេះ មិនបាច់មានការគ្រប់គ្រងក៏បានដែរ បើសិនជាមិនមានការបៀតបៀនគ្នា តែបើសិនជាការគ្រប់គ្រងនោះ មិនមានការបៀតបៀន ពីអ្នកដឹកនាំចំពោះរាស្ត្រ ពីរាស្ត្រទៅអ្នកដឹកនាំ និងពីរាស្ត្រទៅរាស្ត្រទៀតនោះ ការគ្រប់គ្រងនោះ គឺជាការគ្រប់គ្រងដ៏ប្រសើរបំផុត ។ តែបើការគ្រប់គ្រងណាដែលមានការបៀតបៀន អ្នកដឹកនាំណាដែលមានការបៀតបៀនក្នុងការគ្រប់គ្រង អ្នកដឹកនាំនោះ *មានតម្លៃមិនស្មើនឹងអ្នកសុំទាន* ( ដែលគ្មានផ្ទះសម្បែង តែមិនបានបៀតបៀននរណាឱ្យក្ដៅក្រហាយ ) ឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

# អ្នកដឹកនាំមិនត្រូវបៀតបៀនអ្វីខ្លះ ?




រូបបង្ហាញពីវត្ថុដែលជនអាក្រក់តែងបៀតបៀន

បើនឹងរៀបរាប់ថា មានអ្វីខ្លះដែលជនអាក្រក់តែងបៀតបៀន ឃើញថាមិនអាចរាប់អស់ទេ ព្រោះជនអាក្រក់តែងតែនឹករកឃើញមធ្យោបាយ និងរបស់ដែលគួរបំផ្លាញឃើញជានិច្ច ។ ក្នុងទីនេះ យើងសូមយកពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធដែលលោកបានបង្ហាញអំពីវត្ថុ ១០ យ៉ាង ដែលពួកជនអាក្រក់តែងធ្វើ ។ ទាំង ១០ យ៉ាងនេះជាការបៀតបៀនធំៗ ឯការបៀតបៀនដទៃៗទៀត ដែលមិនបានលើកយកមកបង្ហាញ សូមសម្គាល់ថា សុទ្ធតែបែកចេញពីមេ១០យ៉ាងនេះទាំងអស់ ។ វត្ថុ ១០ យ៉ាងនេះ ព្រះសម្មាសម្ពុទ្ធលោកត្រាស់ហៅថា អកុសលកម្មបថ ១០ ។

១. *បាណាតិបាត* ៖ បៀតបៀនជីវិត បានដល់ការសម្លាប់ ការធ្វើបាបរាងកាយ ការធ្វើទារុណកម្មព្រៃផ្សៃខុសនឹងមនុស្សធម៌ ការធ្វើឱ្យឈឺ ខូចសុខភាព ខូចដល់ស្ថិរភាពជីវិត ។ ល ។

www.budinst.gov.kh www.elibraryofcambodia.org

*២. អទិន្នាទាន* ៖ បៀតបៀនទ្រព្យ បានដល់ការលួច កេងប្រវ័ញ្ច ឆក់ កោង ស៊ីសំណូក ពុករលួយ ការប្រើឥទ្ធិពលសំឡុតយកទ្រព្យ កៀបសង្កត់ឱ្យគេខូចបង់ទ្រព្យសម្បត្តិ ការបំផ្លាញទ្រព្យសម្បត្តិសាធារណៈជាដើម ។

*៣. កាមេសុមិច្ឆាចារ* ៖ បៀតបៀនក្រុមគ្រួសារ បានដល់ការទៅសាហាយស្មន់ជាមួយប្រពន្ធ-ប្តីគេ ការតំរាមកំហែងឱ្យគេស្រឡាញ់ខ្លួន ការចាប់រំលោភ ការពង្រាត់បង្រាសប្តីប្រពន្ធគេ ធ្វើឱ្យគេឈ្លោះប្រកែកគ្នា លែងមានសេចក្តីសុខក្នុងគ្រួសារ ។

*៤. មុសាវាទ* ៖ បៀតបៀនខាងផ្លូវចិត្ត បានដល់ការកុហក បញ្ឆោតបោកឱ្យជឿ ធ្វើឱ្យគេក្តៅក្រហាយក្នុងចិត្ត ឱ្យគេរងទុក្ខលំបាក ព្រោះពាក្យសម្តីមិនពិតរបស់យើង ។

*៥. ផរុសវាទ* ៖ បៀតបៀនសេចក្តីស្ងប់សុខ បានដល់ការជេរប្រទេចនូវពាក្យអាក្រក់ ពាក្យរាសអាភាស ថោកទាប ពាក្យបញ្ឈឺ ពាក្យផ្តែផ្តា ធ្វើឱ្យគេខូចសេចក្តីស្ងប់ក្នុងចិត្ត ខ្មាសគេខ្មាសឯង ខូចកិត្តិយស ដើម្បីបំពេញតែផលប្រយោជន៍ខ្លួនឯង ។

*៦. បិសុណាវាទ* ៖ បៀតបៀនការសាមគ្គី ភាពសុខដុមរមនារបស់គេដោយការទៅនិយាយញុះញង់ ចាក់ចុច ភ្លឹះភ្លៀល ធ្វើឱ្យគេខូចមិត្តភាព ខូចសាមគ្គីខូចការស្រឡាញ់គ្នា បាក់បែក ឈ្លោះប្រកែកគ្នា មើលមុខមិនត្រង់ ។

*៧. សម្ផប្បលាប* ៖ បៀតបៀនសេចក្តីចំរើន ដោយការធ្វើឱ្យគេខូចកិត្តិយស កេរ្តិ៍ឈ្មោះបោះសំឡេង ខូចយីហោ ខូចបាងឆេង ដោយការដើរនិយាយនិន្ទា និយាយមួលបង្កាច់ ប្រឌិតរឿងផ្តេសផ្តាស យកការពិតមិនបាន ធ្វើឱ្យគេខាតប្រយោជន៍ និយាយក្អេកមួយជាក្អេកដប់ មាត់ចាបមាត់ព្រាប ។

*៨. អភិជ្ឈា* ៖ បៀតបៀនផលប្រយោជន៍ គឺសម្តែងចិត្តឱ្យគេឃើញជា

www.budinst.gov.kh www.elibraryofcambodia.org

មនុស្សលោភ មនុស្សប្រេត គិតតែពីចង់ប្រមូលយកផលប្រយោជន៍ឱ្យខ្លួនឯង ជានិច្ច គិតតែប្រយោជន៍ខ្លួន ។

*៩. ព្យាបាទ* ៖ បៀតបៀនសន្តិសុខដោយការសម្ដែងចិត្តឱ្យគេឃើញនូវទឹកចិត្តឃោរឃៅ ចងអាឃាត ព្យាបាទ ចង់ឱ្យតែគេវិនាស ។

*១០. មិច្ឆាទិដ្ឋិ* ៖ បៀតបៀនសទ្ធា ជំនឿរបស់គេ ដោយសទ្ធាជំនឿរបស់ខ្លួន ដោយគ្មានខ្លាចក្រែងចិត្ត ។

ទាំង ១០ នេះ គឺជាទង្វើបៀតបៀនដែលជនពាលតែងធ្វើ ។ ឯអវិហឹង្សា ឬការមិនបៀតបៀនដែលអ្នកដឹកនាំត្រូវអនុវត្តនោះ មានន័យផ្ទុយពីការបៀតបៀនទាំង ១០ ប្រការនេះ ។

## វិមាត្រ ៣ យ៉ាង នៃការមិនបៀតបៀន

ការមិនបៀតបៀនទាំង ១០ យ៉ាង ដែលបានពោលរួចមកហើយ ត្រូវសំគាល់កំណត់ទុកក្នុងចិត្តថា ៖

១. មិនត្រូវបៀតបៀនចំពោះបុគ្គលម្នាក់ៗជាឯកជន,

២. មិនត្រូវបៀតបៀនចំពោះសង្គម ក្រុមសហគមន៍ អង្គការ, ...

៣. មិនត្រូវបៀតបៀនចំពោះធម្មជាតិ ។

ចំពោះប្រការ ១ និងប្រការ ២ គ្រាន់តែយកប្រការមិនបៀតបៀនទាំង ១០ យ៉ាង មកអនុវត្តចំពោះបុគ្គលម្នាក់ៗ និងសង្គមណានីមួយតែប៉ុណ្ណោះ ក៏នឹងអាចយល់ជាមិនខាន ។ តែដែលសំខាន់ និងប្លែកនោះ គឺការមិនបៀតបៀនចំពោះធម្មជាតិ ដែលត្រូវអធិប្បាយឱ្យច្បាស់បន្តិច ។ ក្នុងប្រព័ន្ធនៃការរស់នៅរបស់សត្វលោកលើផែនដីនេះ តាមទស្សនៈព្រះពុទ្ធសាសនា មានរបស់ ៣ យ៉ាង ដែលត្រូវពាក់ព័ន្ធ ពឹងពាក់គ្នាទៅវិញទៅមក គឺទំនាក់ទំនងគ្នារវាងបុគ្គល សង្គម ធម្មជាតិ ។ ជាពិសេស ធម្មជាតិដែលរួមដោយទឹក ដី ភ្លើង ខ្យល់ អាកាស ទាំងអស់នេះជាបច្ច័យ

www.budinst.gov.kh www.elibraryofcambodia.org

ជាទីពឹងរបស់មនុស្ស និងសព្វសត្វដែលមានជីវិត ។ ជីវិតយើងបច្ចុប្បន្ននេះ អាចរស់នៅបាន ក៏អាស្រ័យធម្មជាតិ ធម្មជាតិផ្តល់នូវអ្វីឱ្យយើងសព្វបែបយ៉ាង តាំងពីម្ហូបអាហារ សម្លៀកបំពាក់ ផ្ទះសម្បែង ថ្នាំសង្កូវ គ្រឿងប្រើប្រាស់ផ្សេងៗ គ្រឿងបំភ្លឺ ។ល។ បើធម្មជាតិដែលនៅជុំវិញយើងនេះ ត្រូវបៀតបៀនដោយគ្មានការពិចារណា ធម្មជាតិនេះនឹងត្រូវរបួស ស្លាប់ សាបសូន្យនៅក្នុងថ្ងៃណាមួយមិនខាន ឯផលវិបាកក៏នឹងត្រូវធ្លាក់មកលើមនុស្សខ្លួនឯងវិញ ដោយពិតប្រាកដ ។ លើកជាឧទាហរណ៍ ការបៀតបៀនធម្មជាតិនាបច្ចុប្បន្ន ដូចជាការកាប់ព្រៃឈើហួសប្រមាណ ដោយក្នុង ១ ឆ្នាំៗ អស់ដល់ទៅរាប់លានហិកតាក្នុងពិភពលោកនេះ បានធ្វើឱ្យកើតទៅជាជំងឺធម្ម-ជាតិម្យ៉ាង ដែលភាសាអង់គ្លេសហៅថា (Green House Effect) គឺពិភពលោកនេះកាន់តែក្តៅឡើងៗជាលំដាប់ ភ្លៀងធ្លាក់មិនត្រូវតាមរដូវកាល ទឹកជំនន់ញឹកញាប់ ខ្យល់ព្យុះកាចៗជាដើម ដែលនឹងមានផលប៉ះទង្គិចដល់ផលិតផលធញ្ញជាតិ ដែលជាអាហាររបស់មនុស្ស ។ ឧទាហរណ៍មួយទៀត គឺការនាំមកនូវត្បូងថ្ម និងប្រេងកាតមកប្រើដ៏សន្ធឹកសន្ធាប់ ។ ផ្សែងដែលចេញពីចំហេះនេះបានធ្វើឱ្យកើតជាអាកាសពិសពុល ពិបាកដកដង្ហើម ភ្លៀងទឹកក្រូដ ។ល។

រឿងដែលគួរឱ្យព្រួយបារម្ភនោះ គឺផ្សែងជាតិកាបោននេះ បានទៅបំផ្លាញជាតិឧស្ម័ន អូសូន (Ozone Layer) ដែលជាស្រទាប់បរិយាកាស មាននាទីការពារពន្លឺព្រះអាទិត្យកុំឱ្យជះមកផែនដីខ្លាំងពេក ។ កាលណាអូសូនបាត់បង់ហើយ ផែនដីនេះនឹងរឹតតែក្តៅ ហើយមនុស្សយើងក៏នឹងកើតរោគមហារីកស្បែក កាន់តែច្រើនដែរ ។

ដូច្នេះយើងឃើញថា ការបៀតបៀនធម្មជាតិ មានតែសេចក្តីទុក្ខត្រឡប់មករកយើងវិញតែប៉ុណ្ណោះ ។

សួរថា បើមិនបៀតបៀនធម្មជាតិ តើយើងបានអ្វីប្រើ ? ឆ្លើយថា បើ

www.budinst.gov.kh www.elibraryofcambodia.org

យើងត្រឹមតែប្រើប្រាស់តាមសេចក្ដីត្រូវការចាំបាច់នោះ យើងប្រាកដជាមិនមានឈ្មោះបៀតបៀនទេ ។ រឿងដែលអាក្រក់ គឺការប្រើប្រាស់ដោយគ្មានវិចារណ-ញ្ញាណ គ្មានសេចក្ដីសន្ដោស ប្រើដោយលោភលន់ ប្រើដោយឥតគោរព ប្រើតាមចំណង់ ដែលនាំឱ្យវិនាសហិនហោច ។

ចំណុចត្រង់នេះ ធ្វើឱ្យយើងនឹកឃើញដល់ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដែលលោកតែងតែដាស់តឿនឱ្យពុទ្ធបរិស័ទគោរពធម៌ រក្សាធម៌ បដិ-បត្តិធម៌ យកធម៌ជាធំ ព្រោះថាសូម្បីតែព្រះអង្គក៏គោរពធម៌ដែរ ដូចពុទ្ធភាសិតព្រះអង្គសម្ដែងថា *" ធម្មោ ហវេ រក្ខតិ ធម្មចារី "* ប្រែថា អ្នកណារក្សាធម៌ ធម៌រក្សាអ្នកនោះវិញ ធម៌គឺធម្មជាតិដែលមានគុណលើជីវិតយើងនេះឯង ។

## កាល ៣ យ៉ាង នៃការមិនបៀតបៀន

អ្នកដឹកនាំត្រូវគិតពីបច្ច័យពេលវេលា ដែលមានចំពោះការមិនបៀតបៀន ពោលគឺ អតីត បច្ចុប្បន្ន អនាគត ។ វត្ថុដែលនៅសល់ពីអតីត ដូចជាវត្ថុបុរាណវប្បធម៌ ប្រពៃណី អារ្យធម៌ទាំងឡាយ ជារបស់ដែលមិនអាចរកបានទៀតទេ អ្នកដឹកនាំទាំងឡាយមិនគួរនឹងបៀតបៀនឡើយ ។ សព្វថ្ងៃនេះ យើងកំពុងជួបប្រទះនឹងការបំផ្លាញវត្ថុបុរាណទាំងឡាយ ដែលជាកេរ្ដិ៍មរតកជាតិយើងយ៉ាងសម្បើមដោយជនពាលមួយចំនួន ដែលមានការចូលរួមពីអ្នកដឹកនាំ និងពីមេកើយមួយចំនួន ។ សូមឱ្យអ្នកដឹកនាំដែលល្អមេត្តាជួយគិតគូរ និងធ្វើការបង្ក្រាបជនពាលផង បើនៅតែបណ្ដោយ ក៏នឹងមានឈ្មោះថា *បៀតបៀនដោយផ្លូវអមជាមិនខាន* ។

ការមិនបៀតបៀននាបច្ចុប្បន្ន ជាបច្ច័យនាំមិនឱ្យមានការបៀតបៀន នានាអនាគត ។ ក្នុងការធ្វើកិច្ចការអ្វីមួយ ក្រៅពីពិនិត្យមើលឱ្យច្បាស់លាស់ មិនប៉ះពាល់ មិនបៀតបៀន សំរាប់ពេលបច្ចុប្បន្ននេះហើយ គប្បីគិតក្នុងរយៈពេលវែង

www.budinst.gov.kh www.elibraryofcambodia.org

យូរអង្វែងផង ដោយការសិក្សាពិនិត្យឱ្យបានត្រឹមត្រូវ និងមានការធានាថា គ្រោងការ ឬកិច្ចការនេះ នឹងមិនមានទោស ឬមិនបៀតបៀនសំរាប់ពេលអនាគតទេ ។ ធ្វើយ៉ាងដូច្នេះ ក៏ព្រោះគោលបំណងដើម្បីសន្សំទ្រព្យាករធម្មជាតិរបស់មនុស្ស ឱ្យបានគង់វង្សច្រើន និងយូរអង្វែងជាទីបំផុត សំរាប់អនុជនជាន់ក្រោយ ដែលជាកូនចៅរបស់យើង ។

## អ្វីដែលយើងមាននាបច្ចុប្បន្ន
## គឺជារបស់ដែលយើងខ្ចីកូនចៅយើងទេ !

មហាជននឹងស្រែកថា " ពេញចិត្តហើយ ៗ " ចំពោះអ្នកដឹកនាំណាដែលមានអហិង្សា គឺការមិនបៀតបៀននៅក្នុងការគ្រប់គ្រងរបស់ខ្លួន ។

សូមឱ្យអ្នកដឹកនាំខ្មែរឈប់បៀតបៀនគ្នា និងរក្សាអហិង្សាឱ្យបានជាប់ជានិច្ច ។

www.budinst.gov.kh www.elibraryofcambodia.org

# អវិរោធនៈ គឺធ្វើអ្វីមិនឱ្យខុស

យើងមកដល់ចុងបញ្ចប់នៃទសពិធរាជធម៌ហើយ គឺមកដល់ត្រង់គុណធម៌ចុងក្រោយរបស់ព្រះរាជា ឬអ្នកដឹកនាំ គឺអវិរោធនៈ ដែលប្រែថា ការមិនមានកំហុស ការធ្វើអ្វីកុំឱ្យខុស ការធ្វើអ្វីដែលមិនមានពិរុទ្ធ ។

ឈ្មោះថា អ្នកធំ អ្នកដឹកនាំ ប្រមុខ ព្រះរាជា ប្រធាន នាយក ត្រូវមិនធ្វើខុស ព្រោះបើខុស មហាជនដែលនៅពីក្រោយ នៅពីក្រោម ដែលផ្ញើវាសនាលើខ្លួនជាអ្នកកាច់ចង្កូត ប្រាកដជាធ្វើខុសតាម និងប្រាកដជាទទួលផលអាក្រក់ ព្រោះការធ្វើខុសរបស់អ្នកដឹកនាំ ជាមិនខាន ។

**អវិរោធនៈ** ជាធម្មសមោធាន គឺរួមនូវទសពិធរាជធម៌ទាំងអស់ រួមនូវគុណសម្បត្តិ គុណភាព សុខភាព និងគុណធម៌របស់អ្នកដឹកនាំដែលគួរមាន ។ ធម្មិកភាវៈ ឬភាពជាអ្នកធម្មិក ជាព្រះបាទធម្មិក ដែលត្រូវមកប្រោសប្រទេសខ្មែរ ត្រូវមានអវិរោធនៈនេះជាដាច់ខាត ខ្វះធម៌នេះពេលណា វិនាសកម្មនឹងកើតដល់ខ្មែរទៀត ជាមិនខាន ។

## ធ្វើអ្វីមិនឱ្យខុសខ្លះ ?

ពាក្យថា *អវិរោធនៈ* ស្មើនឹងពាក្យថា *សម្មា* ដែលជាក្បាលធម៌របស់អរិយមគ្គទាំង ៨ និងជាផ្លូវតែមួយគត់ ឆ្ពោះទៅរកការរំលត់ទុក្ខ ការអស់បញ្ហាទាំងពួង ។ បដិបត្តិគោលធម៌អវិរោធនៈនេះបាន ឈ្មោះថាបដិបត្តិតាមពុទ្ធវចនៈទាំងអស់ ។

១. យល់មិនឱ្យខុស

២. គិតមិនឱ្យខុស

www.budinst.gov.kh www.elibraryofcambodia.org

៣. និយាយមិនឱ្យខុស

៤. ធ្វើការមិនឱ្យខុស

៥. ចិញ្ចឹមជីវិតមិនឱ្យខុស

៦. ព្យាយាមមិនឱ្យខុស

៧. រលឹកឃើញមិនឱ្យខុស

៨. តម្កល់ចិត្តមិនឱ្យខុស

កាលណាធ្វើមិនឱ្យខុសទាំង ៨ យ៉ាងនេះហើយ ឈ្មោះថា មានសម្មាមគ្គ គឺបានដើរលើផ្លូវដែលត្រូវ ដែលនឹងនាំទៅរក សម្មត្តៈ = ភាវៈដែលត្រូវ ២ ប្រការ ជាផល ដែលកើតពីការមិនធ្វើខុស គឺ ៖

- សម្មាញាណ ដឹងត្រូវ

- សម្មាវិមុត្តិ ការរួចផុតពីទុក្ខ ពីបញ្ហាទាំងពួងដោយត្រូវសម្មាវិមុត្តិ គឺការរួចផុតពីសេចក្តីទុក្ខ ការផុតបញ្ហា ភាវៈគ្មានបញ្ហា គ្មានអ្វីរុកគួន មានឥស្សរភាព មានសេចក្តីសុខដ៏បរិបូណ៌ ទាំងអស់នេះកើតឡើងពីការធ្វើមិនឱ្យខុសក្នុងមគ្គទាំង ៨ ។ បើជាប្រទេសវិញ គឺមានសន្តិភាព មានសន្តិសុខ មានវឌ្ឍនភាព មានការអភិវឌ្ឍន៍ សម្បូរសប្បាយ គ្មានបញ្ហា គ្មានសេចក្តីទុក្ខ គ្មានវិបត្តិ ដែលជាសេចក្តីប្រាថ្នារបស់ពួក ជនទាំងពួង និងជារបស់ដែលព្រះបាទធម្មិកទាំងឡាយអាចធ្វើបាន ។

ជាផ្លូវប្រតិបត្តិដែលយើងជួបជារាល់ថ្ងៃ ការមិនធ្វើខុសរបស់អ្នកដឹកនាំ និងរដ្ឋាភិបាល ត្រូវមានលក្ខណៈជាវិទ្យាសាស្ត្រ ដូច្នេះគឺ ៖

I. ធ្វើគម្រោងផែនការមិនខុស

១. ស្រាវជ្រាវ ពិនិត្យឱ្យឃើញស្គាល់បញ្ហា និងសេចក្តីត្រូវការរបស់រាស្ត្រ ឱ្យបានត្រឹមត្រូវជាទីបំផុត មិនខុសពីការពិត ( ទុក្ខំ អរិយសច្ចំ បរិញ្ញាតព្វន្តិ ) ។

២. វិគ្រោះ វិភាគ និងវិនិច្ឆ័យរកមូលហេតុនៃបញ្ហាដែលនឹងត្រូវកែខៃ

www.budinst.gov.kh www.elibraryofcambodia.org

កំចាត់ឱ្យអស់ ឱ្យបានត្រឹមត្រូវ មិនឱ្យខុសពីហេតុពិត ( ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ ) ។

៣. ដាក់តាំងភារៈប្រាសចាកបញ្ហា ដែលជាគោលដៅត្រូវការឱ្យបានត្រឹមត្រូវ ដោយឱ្យឃើញថាការដោះស្រាយបញ្ហានោះ ជារឿងដែលអាចធ្វើបាន ជារបស់ដែលត្រូវដើរទៅឱ្យដល់ និងត្រូវធ្វើឱ្យបានសំរេច ( ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកា-តព្វន្តិ ) ។

៤. រៀបចំ កំណត់នូវវិធីការ យុទ្ធវិធី ដំណាក់ការនៃយុទ្ធការ ព្រមទាំងសេចក្តីពិស្តារផ្សេងៗ ដែលទាក់ទងនឹងការប្រតិបត្តិ ដើម្បីដោះស្រាយ កែខៃបញ្ហាឱ្យបានជោគជ័យ ( ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ភាវេតព្វន្តិ ) ។

ដើម្បីធានាដល់ប្រសិទ្ធផល និងប្រសិទ្ធភាពរបស់កិច្ចការខាងលើនេះ អ្នកដឹកនាំគប្បីត្រួតពិនិត្យដោយមាត្រាត្រួត ៣ យ៉ាង ខាងក្រោមនេះគឺ :

១. សិក្សាឱ្យយល់ស្គាល់នូវធាតុពិត និងធម្មជាតិ របស់លំដាប់នីមួយៗ ឱ្យបានត្រឹមត្រូវ ឱ្យច្បាស់ កុំឱ្យច្រឡំ កុំឱ្យខុស គឺស្គាល់ថានេះគឺជាបញ្ហា នេះគឺជាហេតុរបស់បញ្ហា នេះគឺជាគោលដៅនៃការដោះស្រាយបញ្ហា និងនេះជាយុទ្ធវិធីសំរាប់ដោះស្រាយបញ្ហា ( សច្ចញ្ញាណ ) ។

២. ដឹងនូវកិច្ច មុខងារ ដែលលំដាប់នីមួយៗត្រូវធ្វើ ។ បញ្ហាជារបស់ដែលត្រូវសិក្សាស្រាវជ្រាវឱ្យច្បាស់ ហេតុរបស់បញ្ហា ជារបស់ដែលត្រូវតែកំចាត់ចោល គោលដៅដែលត្រូវការ ជារបស់ដែលត្រូវធ្វើឱ្យបានសំរេច ទៅឱ្យដល់ និងយុទ្ធវិធីទាំងឡាយនោះជារបស់ដែលត្រូវប្រតិបត្តិការ ត្រូវអនុវត្តតាមគឺចុះធ្វើ (កិច្ចញ្ញាណ)។

៣. បញ្ជាក់ត្រួតពិនិត្យឱ្យច្បាស់ក្នុងចិត្តថា បញ្ហាទាំងឡាយបានសិក្សាដឹងត្រឹមត្រូវហើយ ហេតុរបស់បញ្ហាបានដោះស្រាយកំចាត់ចោលហើយ គោលដៅដែលតាំងបានសំរេចដល់គោលដៅហើយ និងយុទ្ធវិធីដែលកំណត់ហើយនោះ បានអនុវត្ត

www.budinst.gov.kh www.elibraryofcambodia.org

បដិបត្តិតាមហើយ ។

របៀបធ្វើមិនឱ្យខុសដែលបានអធិប្បាយខាងលើនេះ គឺជាអរិយសច្ចៈ ៤ ប្រការ របស់ព្រះសម្មាសម្ពុទ្ធយើងនេះឯង ។ ដើម្បីឱ្យងាយយល់ សូមមើលតារាងសង្ខេប ៖

វិធីធ្វើមិនខុសតាមបែបអរិយសច្ចៈ ៤

ដែលប្រកបដោយបរិវដ្ដ ៣ និងអាការៈ ១២

| លំដាប់នីមួយៗ ត្រូវមានគ្រប់អង្គទាំង ៣ | | | |
|---|---|---|---|
| | សិក្សាវិច័យ | កំណត់មុខងារ និងកិច្ច | ត្រួតពិនិត្យ |
| ទុក្ខ | ទុក្ខមានពិត " ១ " | ទុក្ខគួរកំណត់ឱ្យដឹង " ៥ " | ទុក្ខ (យើង) បានដឹងហើយ " ៩ " |
| សមុទ័យ | ហេតុឱ្យកើតទុក្ខមានពិត " ២ " | ហេតុគួរតែលះចេញ "៦" | ហេតុនោះ (យើង) បានលះបង់ហើយ " ១០ " |
| និរោធ | ការមិនមានទុក្ខមានពិត " ៣ " | និរោធ គួរធ្វើឱ្យកើតឡើង " ៧ " | និរោធ (យើង) បានធ្វើឱ្យសំរេចហើយ " ១១ " |
| មគ្គ | វិធីដោះស្រាយបញ្ហាមានពិត " ៤ " | វិធីធ្វើឱ្យគ្រប់ " ៨ " | វិធីនោះ (យើង) បានធ្វើឱ្យគ្រប់អស់ហើយ " ១២ " |

www.budinst.gov.kh www.elibraryofcambodia.org

សរសេរមកដល់ត្រង់នេះ ខ្ញុំអត់មិនបានដើម្បីអួតផ្សព្វផ្សាយពីបញ្ញាគុណដ៏លើសលប់របស់ព្រះសម្មាសម្ពុទ្ធ ដែលលោករកឃើញវិធីនេះ ទុកឱ្យដល់យើងសព្វថ្ងៃ ។ អ្វីដែលនាំឱ្យខ្ញុំមានមោទនភាពពីអរិយសច្ចៈ ៤ នេះ រឹតតែខ្លាំងទៀតនោះ គឺកាលពីខែកក្កដា ឆ្នាំ ១៩៨៩ ខ្ញុំបានទទួលអាហាររូបករណ៍ពីមូលនិធិ-ខុនរ៉ាដ-អាដិនណៅអើរ (Konrad-Adenauer-Foundation) នៃប្រទេសអាឡឺម៉ង់ ដើម្បីទៅទទួលការអប់រំពីរឿងធ្វើគម្រោងការអភិវឌ្ឍន៍ នៅឯប្រទេសអាឡឺម៉ង់ ។ ខ្ញុំហួសចិត្ត អស្ចារ្យក្នុងចិត្ត និងខ្ញុំអរជាខ្លាំង នៅពេលចាប់ផ្ដើមរៀនបានបន្តិច ។

ហួសចិត្តព្រោះថា ខ្ញុំត្រូវមករៀនអរិយសច្ចៈ ដើម្បីដោះស្រាយបញ្ហាអ្នកស្រុក ក្នុងកិច្ចការអភិវឌ្ឍន៍ ។ អស្ចារ្យក្នុងចិត្ត ត្រង់ថា សច្ចធម៌របស់ព្រះសម្មាសម្ពុទ្ធមិនកំណត់ដោយកាល ( អកាលិកោ ) ដែលអាចធានានូវឋានៈរបស់ព្រះអង្គបានថាពិតជាគ្រូរបស់មនុស្ស និងទេវតាទាំងឡាយគ្រប់ជំនាន់មែន ព្រោះសូម្បីតែពួកអឺរ៉ុប ក៏ប្រើវិធីនោះដែរ ទោះជាដោយចម្លង ឬដោយចៃដន្យក៏តាម ។ ខ្ញុំអរ ព្រោះខ្ញុំរៀនទៅងាយ មិនពិបាកយល់ ដោយមានមូលដ្ឋានពីអរិយសច្ចៈរបស់ពុទ្ធសាសនារួចទៅ ហើយ រហូតដល់ខ្ញុំអាចយកនិទ្ទេសល្អណាស់ ( very good ) នៅពេលបញ្ចប់ការសិក្សា ។

ដែលខុសគ្នាបន្តិចនោះ គឺវិធីដែលគេប្រើនៅអាឡឺម៉ង់ គេមិនហៅថាអរិយសច្ចៈទេ គេហៅថា វិធី ZOPP មកពីពាក្យអាឡឺម៉ង់ថា Zielorientierte Projektplanung ស្មើនឹងពាក្យអង់គ្លេសថា Objectives-Oriented Project Planning ឬបើនឹងប្រែជាខ្មែរក៏ប្រហែល ។ នឹងន័យថា ៖ វិធីធ្វើគម្រោងផែនការដោយតម្រង់ទៅរកគោលដៅដែលតាំង ។ ហើយក្រៅពីនេះ ក៏មានសេចក្ដីពិស្ដារខុសគ្នាខ្លះទៀត តែដែលជាគោលការណ៍ធំៗ គឺដូចគ្នា ។

www.budinst.gov.kh www.elibraryofcambodia.org

II. មិនធ្វើឱ្យខុសក្នុងទសពិធរាជធម៌ ទាំង ១០ ( បើមិនទាន់ច្បាស់ សូមត្រឡប់ទៅមើលថាប់ពីមានម្ដងទៀត ) ។

III. ការមិនធ្វើខុសដោយចិត្ត ដោយសម្ដី ដោយកាយវិការ ដោយការងារ ៖

- ចំពោះ ខ្លួនឯង
- ចំពោះ អ្នកតូច
- ចំពោះ សហការី
- ចំពោះ ការងារ
- ចំពោះ មហាជន
- ចំពោះ ច្បាប់
- ចំពោះ នាទី
- ចំពោះ ទំនៀមទម្លាប់ វប្បធម៌ ប្រពៃណី

IV. មិនគាំទ្រអ្នកធ្វើខុស

- មិនគាំទ្រការធ្វើខុស
- ពេលខ្លួនធ្វើខុស ប៉ានទទួលកំហុសដោយរីករាយ
- មិនលំអៀងព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះខឹង ព្រោះដឹងមិនដល់ ព្រោះការលំអៀងនេះ អាចធ្វើឱ្យអ្នកធំធ្វើអ្វីតែងតែខុសជានិច្ច ។

អ្នកដែលដឹកនាំទាំងអស់អាចនឹងជជែកថា " ពួកយើងទាំងអស់គ្នា សុទ្ធតែជាបុថុជ្ជនមានកិលេស ការមិនឱ្យខុសសោះនោះ មិនអាចប្រព្រឹត្តទៅបានទេ " ។ ពិតហើយយើងជាបុថុជ្ជន ដែលមិនខុសនោះ មិនមានទេ តែក៏មិនមានអ្នកណាមួយបដិសេធថា " ការធ្វើមិនឱ្យខុស" នោះមិនមានប្រយោជន៍នោះឡើយ គឺនៅតែទទួលស្គាល់ និងចង់បាន " ការធ្វើមិនឱ្យខុស " គ្រប់គ្នាទាំងអស់ ។

www.budinst.gov.kh www.elibraryofcambodia.org

រឿងដែលសំខាន់បំផុតចំពោះគោលធម៌អរិរោធនះនេះ គឺចង់ឱ្យអ្នកដឹកនាំទាំងឡាយ មានការយល់ត្រូវថា អរិរោធនះនេះចាំបាច់សំរាប់ការគ្រប់គ្រងហើយត្រូវមានសតិ សម្បជញ្ញៈ ឱ្យជាប់ជានិច្ច ដើម្បីនឹងធ្វើអរិរោធនះឱ្យបានច្រើនជាទីបំផុត តាមដែលអាចធ្វើទៅបាន ។

## ផលប្រយោជន៍របស់អរិរោធនះ

ខ្មែរយើង មិនអាចខុសទៀតទេ ព្រោះខុសជាយូរណាស់មកហើយ ទាំងអ្នកដឹកនាំ ទាំងអ្នកដើរតាម ។ ល្មមដល់ពេលហើយដែលយើងទាំងអស់គ្នា ជាពិសេស អ្នកដឹកនាំត្រូវកំចាត់វិរោធនះ ឬ មិច្ឆាមគ្គ គឺកំហុស និងផ្លូវអាក្រក់ ផ្លូវខុសទាំងឡាយចេញឱ្យអស់ពីដំណើរនយោបាយការគ្រប់គ្រងប្រទេស ។ មិនទាន់ហួសពេលទេ បើយើងចាប់ផ្តើមធ្វើល្អ ធ្វើត្រូវពីឥឡូវនេះទាំងអស់គ្នា ដូចពុទ្ធភាសិតដែលព្រះបរមគ្រូយើងបានណែនាំថា ៖

*យស្ស បាបំ កតំ កម្មំ        កុសលេន បហីយតិ*

*សោមំ លោកំ បភាសេតិ   អព្ភា មុត្តោ វ ចន្ទិមា ។*

អ្នកណាធ្វើបាប ( ធ្វើខុស ធ្វើមិនត្រូវ ) ពីពេលមុន ហើយឥឡូវនេះបានលះបង់ចេញដោយការធ្វើល្អ ( ធ្វើត្រូវ ធ្វើមិនខុស ) អ្នកនោះរមែងបំភ្លឺលោក ( សង្គម ) នេះ ឱ្យភ្លឺឡើងដូចជាដួងព្រះច័ន្ទ្រា ដែលអណ្តែតផុតពីផ្ទៃពពកដូច្នេះដែរ ។

www.budinst.gov.kh www.elibraryofcambodia.org

# សរុបសេចក្តីទសពិធរាជធម៌

យើងបានដឹងនូវសេចក្តីពិស្តារ របស់ទសពិធរាជធម៌គួរសមហើយ ឥឡូវនេះ យើងនឹងសរុបសេចក្តីធម៌សំរាប់អ្នកដឹកនាំនេះ ។

*១. ទាន :* បានដល់ការឱ្យមាន ៣ ប្រការធំៗ គឺ :

. *អាមិសទាន* : ការឱ្យវត្ថុ

. *ធម្មទាន* : ការឱ្យធម្មៈ ចំណេះដឹង

. *អភ័យទាន* : ការឱ្យការអត់ទោស

ក្នុងរដ្ឋប្រសាសនោបាយ ទានមានប្រយោជន៍ក្នុងការបណ្តុះនូវស្វាមីភក្តិភក្តីភាព កតញ្ញូកតវេទី ធ្វើឱ្យអ្នកដែលបានទទួលទាន អាចរហូតដល់ទៅលះបង់ជីវិតដើម្បីអ្នកដែលឱ្យខ្លួន ធ្វើឱ្យចងមិត្តបាន លែងជាសត្រូវគ្នានឹងគ្នា ។

*២. សីល :* គឺការធ្វើឱ្យខ្លួនស្ថិតនៅក្នុងប្រក្រតីភាព មិនបង្កនូវសេចក្តីក្តៅក្រហាយដល់ខ្លួននិងអ្នកដទៃ សុភាពរាបសារ គោរពច្បាប់វិន័យ ចិញ្ចឹមជីវិតក្នុងអំពើសុចរិត រួមទាំងការប្រើប្រាស់ទ្រព្យសម្បត្តិដោយមានការពិចារណាផង ។ ក្នុងរដ្ឋប្រសាសនោបាយ សីលនឹងស្ថាបនានូវភាពគោរព ការទុកចិត្តគ្នា ការធ្វើជីវិតដោយមិនមានភិតភ័យ ពីសំណាក់អ្នកតូច ។ រដ្ឋាភិបាលដែលមានសីល ជារដ្ឋាភិបាលដែលស្ថិតនៅលើអំណាចបានតាមអាណត្តិ ដោយមិនបាច់ភិតភ័យថាប្រជារាស្ត្រ នឹងធ្វើបដិវត្ត ព្រោះខ្លួនមិនស្អាតស្អំ ។

*៣. បរិច្ចាគ :* គឺការលះបង់ដោយពុំគិតទាមទារ ឬចង់បាននូវអ្វីមកវិញ ជាបច្ច័យដែលនាំឱ្យកើតនូវការគោរព ការកោតសរសើរ ការយកជាគំរូ ។ លះបង់ទ្រព្យ ដើម្បីអវយវៈ លះបង់អវយវៈដើម្បីជីវិត សូម្បីតែជីវិតក៏ហ៊ានលះបង់ ដើម្បីភាពត្រឹមត្រូវ ដើម្បីធម៌ ។ សង្គមណាក៏ដោយ នឹងអាចស្ថិតនៅបាន ព្រោះអាស្រ័យ

www.budinst.gov.kh www.elibraryofcambodia.org

គ្រប់គ្នាចេះបរិច្ចាគ ។

*៤. អាជ្ជវៈ* ៖ គឺការត្រង់ ការមិនវៀចក្រឡិកក្រឡុច មានមុខ មានក្រោយ ។ ត្រង់ក្នុងមុខនាទី ត្រង់ក្នុងការងារ ត្រង់ចំពោះវាចា ត្រង់ចំពោះបុគ្គល ចំពោះរាស្ត្រប្រជា និងត្រង់ចំពោះសេចក្តីល្អ ។ អាជ្ជវៈ ធ្វើឱ្យរយៈពេលដែលត្រូវធ្វើដំណើរទៅរកគោលដៅខ្លីឆាប់ ព្រោះជាផ្លូវត្រង់ ព្រមទាំងអាចធ្វើឱ្យប្រជារាស្ត្រកើតការទុកចិត្ត កើតការគោរព យកជាគំរូតាម មិនហ៊ានប្រព្រឹត្តផ្តេសផ្តាស ។

*៥. មទ្ទវៈ* ៖ គឺការទន់ភ្លន់ មិនរឹងរូស មិនចចេស គោរពទៅតាមមតិរបស់រាស្ត្រ បត់បែនទៅតាមស្ថានការណ៍បាន ធ្វើឱ្យសង្គម ឬក្រុមសហការីកើតទស្សនៈ " គ្នាឯង " ចូលគ្នារហ័សចុះ ធ្វើឱ្យកើតសាមគ្គី ។ ដើមព្រែងដែលត្រូវខ្យល់ខ្លាំង ក៏ទោរទៅ តាមខ្យល់ តែនៅពេលស្ងប់ខ្យល់ ក៏ត្រឡប់មករកសភាពរឹងប៉ុងវិញ ។

*៦. តបៈ* ៖ គឺការដុតកម្តៅអំពើអាក្រក់ ដុតកម្តៅជនអាក្រក់កុំឱ្យមានក្នុងខ្លួន និងក្នុងសង្គម ធ្វើឱ្យជនអាក្រក់មិនហ៊ានធ្វើបាបតទៅទៀត ធ្វើឱ្យជនល្អមានចិត្តចង់ធ្វើល្អដើម្បីជាប្រយោជន៍រួម ធ្វើឱ្យប្រទេសជាតិមានការរួបរួមកម្លាំងគ្នាជាបាច់ មានអ្នកដឹកនាំសុទ្ធតែជាមនុស្សល្អ ។

*៧. អក្កោធៈ* ៖ ការមិនក្រោធ មិនខឹង មិនទ្រង់ព្រះពិរោធ ។ ខ្មែរយើងប្រើពាក្យពិរោធសំរាប់ព្រះរាជាពេលដែលព្រះអង្គខឹងខ្លាំង ត្រូវណាស់ និងជាពាក្យជាស់ជឿនស្រេចតែម្តង ។ ពិរោធ ឬវិរោធ ប្រែថា *ខុស* បានសេចក្តីថា ពេលព្រះរាជាលោកខ្ញាល់ ឬពិរោធ ពេលនោះជាពេលដែលលោកកំពុងខុស ដែលផ្ទុយនឹងអវិរោធនៈ មិនខុស ដែលព្រះរាជាត្រូវបំពេញឱ្យបានជាចាំបាច់ ។ ដូច្នេះ សេចក្តីក្រោធនេះជាសត្រូវរបស់អវិរោធនៈ បើមិនចង់ខុស មិនត្រូវក្រោធឡើយ ។ ខឹងខុស ខឹងខូច ខឹងខាត ។ អ្នកដឹកនាំប្រទេស មិនត្រូវខឹង ព្រោះសេដ្ឋកិច្ចក្តី នយោបាយក្តី

www.budinst.gov.kh www.elibraryofcambodia.org

សង្គមកិច្ចក្តី ទាហានក្តី មិនអាចប្រើខឹងបានទេ ព្រោះខឹង ប្រែថា ខុសរួចស្រេចទៅហើយ ។ សាមគ្គី មិត្តភាព ការធ្វើឱ្យគេហ៊ានចូលជិត ការមិនស្តាយក្រោយ ជាប្រយោជន៍របស់អក្កោធៈ ។

*៨. អវិហឹង្សា* ៖ គឺការមិនបៀតបៀន ការគោរពសិទ្ធិមនុស្ស សិទ្ធិកុមារ សិទ្ធិស្ត្រី សិទ្ធិសត្វតិរច្ឆាន ។ អវិហឹង្សា ជាប្រភពនៃប្រជាធិបតេយ្យ ប្រភពនៃសិទ្ធិសេរីភាព និងយុត្តិធម៌សង្គម ។

*៩. ខន្តី* ៖ គឺអត់ធន់ អត់ធ្មត់ អត់ទ្រាំ អត់ អត់ អត់ ! ធន់ ធន់ ធន់ ! ទាល់តែអត់ ទាល់តែធន់ ទើបសមគួរធ្វើជាអ្នកដឹកនាំ សមគួរនឹងបាននូវប្រយោជន៍ដែលខ្លួនប៉ងប្រាថ្នា សមគួរនឹងបានសន្តិភាព ... ។ សេចក្តីគោរព សេចក្តីកោតក្រែង មានជំនឿ និងគ្រប់បែបយ៉ាង កើតពីខន្តី ១ ម៉ាត់នេះឯង ។

*១០. អវិរោធនៈ* ៖ ភារនាឱ្យចាំជាប់ជានិច្ចគ្រប់ដង្ហើមចេញចូលថា *អញនឹងមិនធ្វើខុស អញនឹងធ្វើមិនឱ្យខុស* ព្រោះមានតែមិនខុស ទើបត្រូវ ទើបសុខ ទើបមានសន្តិភាព ទើបចំរើនល្អតលាស់ ទើបទៅជាព្រះបាទធម្មិក ទើបខ្មែរបានសុខ ទើបទៅស្ថានសួគ៌ ទើបសំរេចនិព្វាន ។

www.budinst.gov.kh www.elibraryofcambodia.org

# បារមីអ្នកដឹកនាំ

ចាស់ ៗ របស់យើងតែងនិយាយថា «បារមីព្រះអង្គធំណាស់ ទើបធ្វើការហ្នឹងបានសំរេច » « បារមីព្រះអង្គខ្លាំងណាស់ កុំមើលងាយលោក » ជាដើម ដើម្បីអួតសរសើរចំពោះព្រះមហាក្សត្រ ព្រះសង្ឃ ឬអស់លោកដែលជាអ្នកដឹកនាំធំៗ ។ តែបារមីជាអ្វីទៅ ? បារមី គឺជាឈ្មោះគុណធម៌ ឬដែលយើងតែងនិយាយថាបំពេញបារមីនោះ គឺ :

*១. ទានបារមី* ការបំពេញទាន

*២. សីលបារមី* ការរក្សាសីល

*៣. នេក្ខម្មបារមី* ការបព្វជា

*៤. បញ្ញាបារមី* ការចំរើនបញ្ញា

*៥. វិរិយបារមី* ការព្យាយាម

*៦. ខន្តីបារមី* ការអត់ធន់

*៧. សច្ចបារមី* ការមានសច្ចះ

*៨. អធិដ្ឋានបារមី* ការអធិដ្ឋាន

*៩. មេត្តាបារមី* ការចំរើនមេត្តា

*១០. ឧបេក្ខាបារមី* ការមានឧបេក្ខា

ក្នុងគម្ពីរដីកាជិនាលង្ការ បានពន្យល់ពាក្យបារមីថា : *បារមិយោតិ បារំ និព្វានំ ឥយន្តិ គច្ឆន្តិ បវត្តេន្តិ សាធេន្តីតិ បារមីយោ ។ និព្វានសធកា ហិ ទានចេតនាទយោ សព្វា បារមិតា បារមីតិបិ វុច្ចន្តេ* ប្រែថា : « គុណជាតិទាំងឡាយណាតែងនាំទៅដល់ត្រើយគឺព្រះនិព្វាន គុណជាតិទាំងឡាយនោះ មានឈ្មោះថាបារមី » ( ប្រែយកន័យកាត់ ) ។

www.budinst.gov.kh www.elibraryofcambodia.org

តាមន័យនេះ គុណជាតិ ឬបារមី គឺជាឧបករណ៍ ឬជាយានជំនិះសំរាប់ធ្វើដំណើរ ( នាំទៅ ) ទៅកាន់គោលដៅ ( ត្រើយ ) ដែលខ្លួនប្រាថ្នា ។

ព្រះសិទ្ធត្ថកុមារដែលនឹងអាចបានសម្រេចឋានៈជាព្រះពុទ្ធនោះ ពីព្រោះព្រះអង្គបានបំពេញបារមីទាំង ១០ ដោយបរិបូណ៌រួចមកហើយ ទើបនៅក្នុងជាតិជាព្រះសិទ្ធត្ថកុមារ ព្រះអង្គអាចសម្រេចគោលបំណងរបស់ព្រះអង្គ ដែលបានអធិដ្ឋានតាំងពីព្រះពុទ្ធនាមទីបង្ករម្ល៉េះ ដោយប្រើរយៈវេលាដល់ទៅ ៤ អសង្ខេយ្យ និង ១ សែនកប្ប ។

ចំពោះអ្នកដឹកនាំខាងផ្នែកអាណាចក្រ យើងដឹងហើយថា គោលបំណងនៃការដឹកនាំប្រទេស គឺផ្តល់សេចក្តីសុខឱ្យមហាជន *«បជាសុខំ មហុត្តមំ* = សេចក្តីសុខរបស់រាស្ត្រប្រជា ជារបស់ដ៏មហាឧត្តម» ។ តែត្រឹមតែមានឈ្មោះថា អ្នកដឹកនាំមិនអាចផ្តល់សេចក្តីសុខឱ្យមហាជនបានទេ លុះត្រាតែមានបារមីផង ទើបអាចសម្រេចគោលដៅនៃការដឹកនាំនេះបាន ។ រឿងនេះ មិនខុសពីរឿងការស្វែងរកពុទ្ធភាវៈរបស់ព្រះបរមគ្រូយើង ដើម្បីជួយសត្វលោកឱ្យផុតពីទុក្ខនោះទេ ដូច្នេះបើព្រះអង្គត្រូវការបារមីជាជំនួយឧបត្ថម្ភយ៉ាងណា អ្នកដឹកនាំ ឬរាជា ក៏ត្រូវការបារមី ដូចព្រះអង្គដែរ ។ បារមីរបស់ព្រះសម្មាសម្ពុទ្ធលោកហៅថា ទសបារមី ឯបារមីរបស់អ្នកដឹកនាំលោកហៅថា ទសពិធរាជធម៌ ។

## តារាងប្រៀបធៀប

| បារមីព្រះសម្មាសម្ពុទ្ធ | បារមីអ្នកដឹកនាំ |
|---|---|
| ១. ទាន | ១. ទាន |
| ២. សីល | ២. សីល |
| ៣. នេក្ខម្មៈ | ៣. បរិច្ចាគ |
| ៤. បញ្ញា | ៤. អាជ្ជវៈ |

www.budinst.gov.kh www.elibraryofcambodia.org

៥. វិរិយៈ ៥. មទ្ទវៈ

៦. ខន្តី ៦. តបៈ

៧. សច្ចៈ ៧. អក្កោធៈ

៨. អធិដ្ឋាន ៨. អវិហឹង្សា

៩. មេត្តា ៩. ខន្តី

១០. ឧបេក្ខា ១០. អវិរោធនៈ

បើរៀងលំដាប់គោលធម៌ដែលប្រហែលៗគ្នា មានដូចតទៅ ៖

## តារាងប្រៀបធៀប

| | |
|---|---|
| បារមីព្រះពោធិសត្វ | បារមីអ្នកដឹកនាំ |
| ១. ទាន | ១. ទាន |
| ២. សីល | ២. សីល |
| ៣. នេក្ខម្មៈ | ៣. បរិច្ចាគ |
| ៤. បញ្ញា | ៤. អវិរោធនៈ |
| ៥. វិរិយៈ | ៥. តបៈ |
| ៦. ខន្តី | ៦. ខន្តី |
| ៧. សច្ចៈ | ៧. អាជ្ជវៈ |
| ៨. អធិដ្ឋាន | ៨. មទ្ទវៈ |
| ៩. មេត្តា | ៩. អក្កោធៈ, អវិហឹង្សា |
| ១០. ឧបេក្ខា | ១០. អវិរោធនៈ |

ទាំង ២ យ៉ាងនេះ មានន័យស្រដៀងគ្នា គ្រាន់តែធ្ងន់ស្រាលជាងគ្នាតែប៉ុណ្ណោះ ។ បារមីព្រះពោធិសត្វ នាំឱ្យព្រះអង្គក្លាយទៅជាព្រះពុទ្ធ ដូច្នេះ បារមីរបស់អ្នកដឹកនាំ នឹងនាំឱ្យគេក្លាយទៅជាអ្នកដឹកនាំល្អ ដែលមហាជនទាំងឡាយនឹងជ្រើស

www.budinst.gov.kh www.elibraryofcambodia.org

រើសឱ្យធ្វើជាអ្នកដឹកនាំគេ ដោយសន្មតថាជាសម្មតិទេព គឺទេពតាដោយសម្មត បាន ដល់ព្រះមហាក្សត្រ និងអ្នកដឹកនាំទាំងឡាយនោះឯង ។ ជាពិសេស មហាជនទាំង ឡាយនឹងនាំគ្នាសាទរស្រែកកងរំពងថា « ពេញចិត្តហើយ ពេញចិត្តហើយ » ដែលជា លក្ខណៈមូលដ្ឋានរបស់ព្រះរាជា និងអ្នកដឹកនាំទាំងឡាយ ។

សូមឱ្យអ្នកដឹកនាំខ្មែរគ្រប់ស្រទាប់ទាំងអស់ នាំគ្នាបំពេញបារមីទាំង ១០ នេះ ដើម្បីសេចក្ដីសុខរបស់មហាជនខ្មែរអស់កាលដ៏យូរអង្វែងតទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

# ខ- ព្រហ្មវិហារធម៌

ព្រហ្មវិហារធម៌ ជាឈ្មោះធម៌ដែលយើងតែងឮគ្រប់ៗ គ្នា ។ យ៉ាងហោចណាស់ក៏យើងឮគេនិយាយថា "មាតាបិតា មានព្រហ្មវិហារធម៌លើបុត្រធីតា" ដែរ ។

ព្រហ្មវិហារធម៌ ប្រែថា គោលនៃការប្រព្រឹត្តដែលប្រសើរបរិសុទ្ធ ឬប្រែថា " ធម៌ជាទីអាស្រ័យរបស់ព្រះព្រហ្ម " ពោលគឺ ព្រះព្រហ្មលោកមានធម៌ទាំង ៤ នេះប្រចាំចិត្តរបស់លោក ។

ក្នុងប្រទេសឥណ្ឌា កាលពីប្រហែល ១០០០ ឆ្នាំមុនគ.ស គឺជាសម័យដែលប្រជាជនឥណ្ឌាកំពុងតែគោរពរាប់អានសាសនាព្រាហ្មណ៍ មានជំនឿថាព្រះព្រហ្មជាអ្នកបង្កើតចក្រវាឡនេះទាំងមូល និងជាអ្នកបង្កើតសព្វសត្វមនុស្សទាំងឡាយ ។ តាមជំនឿសាសនាព្រាហ្មណ៍នេះ កាលណាគេបានបូជា និងគោរពព្រះព្រហ្មដោយល្អហើយ ដល់ពេលគេស្លាប់ទៅ នឹងចូលរួមជាភាគតែមួយរបស់ព្រហ្ម ដែលជាបរមត្ថានវិញ ។

នៅពេលព្រះពុទ្ធសាសនាកើតឡើង គឺប្រហែល ៥៨៨ ឆ្នាំមុន គ.ស នោះព្រះសម្មាសម្ពុទ្ធបានបដិសេធនូវជំនឿដែលថា ព្រះព្រហ្មជាអ្នកបង្កើតចក្រវាឡ និងមនុស្ស សត្វ ហើយទ្រង់បានសម្តែងនូវគោលធម៌ឥទប្បច្ចយតា និងបដិច្ចសមុប្បាទដែលនិយាយអំពីការកើតឡើងអាស្រ័យដោយការផ្សំគ្នាតាមធម្មជាតិ និងបានដោះបញ្ហាពីរឿងមនុស្សកើតពីព្រហ្ម ដោយមានព្រះពុទ្ធដីកាថា មនុស្សកើតចេញពីផ្ទៃមាតា ឬកើតពីមនុស្សនេះឯង ។

ព្រះអង្គបានទាំងបដិសេធចោលនូវការបួងសួងព្រះព្រហ្ម និងការបូជាយញ្ញ ដើម្បីទៅកើតរួមជាមួយព្រហ្ម ថាជាអំពើដែលមិនមានប្រយោជន៍ និងមិនបានផល តែព្រះអង្គជំរុញមនុស្សឱ្យខំធ្វើខ្លួនជាព្រះព្រហ្មខ្លួនឯង ដោយការបដិបត្តិធម៌

www.budinst.gov.kh www.elibraryofcambodia.org

ដែលព្រះអង្គហៅថា " *ព្រហ្មវិហារធម៌* " ជំនួសវិញ ។

អាស្រ័យដោយហេតុថា មនុស្សជំនាន់នោះមានជំនឿលើព្រហ្ម ដោយសំគាល់ថា ខ្លួនកើតចេញពីព្រហ្មនោះ ព្រះអង្គបានសម្តែងថា បើអ្នកជឿថា ខ្លួនអ្នកកើតពីព្រហ្មនោះ គឺមាតាបិតាអ្នកនេះឯងជាព្រហ្ម ព្រោះលោកជាអ្នកបង្កើតរូបអ្នកនាបច្ចុប្បន្ននេះដោយពិតៗ ហើយលោកបរិបូណ៌ទៅដោយព្រហ្មវិហារធម៌ ៤ ប្រចាំចិត្តលោក គឺមាន មេត្តាធម៌ ករុណាធម៌ មុទិតាធម៌ និង ឧបេក្ខាធម៌ ។

ព្រហ្មក្នុងពុទ្ធសាសនា មិនដូចព្រហ្មរបស់ព្រាហ្មណ៍ទេ ។ ព្រហ្មរបស់ព្រាហ្មណ៍ជាអាទិទេពមិនចេះស្លាប់ ដែលចេះខឹង ចេះស្រឡាញ់ មានមហេសី និងរាប់អានតែនរណាដែលគោរពព្រះអង្គតែប៉ុណ្ណោះ ។ ឯព្រហ្មរបស់ពុទ្ធសាសនា គឺពួកទេវតា ឬសត្វលោកម្យ៉ាងដែលមានគុណធម៌ប្រចាំចិត្តទាំង ៤ ប្រការ ហើយមានកំណើតពីស្ថានមនុស្ស ។ អ្នកណាដែលមានធម៌ទាំង ៤ ប្រការនេះ ពេលដែលស្លាប់ទៅនឹងទៅកើតជាព្រហ្ម តែជាពិសេស ព្រះសម្មាសម្ពុទ្ធលោកហៅមនុស្សណាដែលមានព្រហ្មវិហារធម៌ ៤ នេះឯង ថាជា *ព្រហ្មរស់* នាមនុស្សលោក ។ ដោយហេតុព្រហ្មរបស់ព្រាហ្មណ៍ មាននាទីមើលខុសត្រូវមនុស្សលោកនោះ ទើបព្រហ្មវិហារធម៌នេះ ក្លាយទៅជាធម៌សំរាប់អ្នកណាដែលជាប្រមុខរបស់មហាជន មាននាទីដឹកនាំគ្រប់គ្រងឱ្យគេបានសុខ ហើយដែលក្លាយទៅជាគុណធម៌ប្រចាំរបស់អ្នកដឹកនាំដែលកាន់ព្រះពុទ្ធសាសនា នៅម្តុំភូមិភាគអាស៊ីអាគ្នេយ៍នេះ ដែលមានរួមប្រទេសខ្មែរ លាវ ថៃ ភូមា និងលង្កា គ្រប់ជំនាន់តមក ។

ព្រហ្មវិហារធម៌ ឬធម៌សំរាប់អ្នកធំ មាន ៤ យ៉ាងគឺ ៖ *១. មេត្តា* ការមានមេត្តាអាណិតស្រឡាញ់ចង់ឱ្យគេបានសុខ, *២. ករុណា* ការមានករុណាជួយសង្គ្រោះគេឱ្យរួចពីទុក្ខ, *៣. មុទិតា* ការត្រេកអរពេលដែលគេបានសុខ, *៤. ឧបេក្ខា* ការដាក់ចិត្តជាកណ្តាល ។

www.budinst.gov.kh www.elibraryofcambodia.org

# មេត្តា

**មេត្តា** គឺការស្រឡាញ់ ការមេត្តា ការមានសេចក្តីប្រាថ្នាល្អចង់ឱ្យគេបានសុខ ជាគុណធម៌ដំបូងបង្អស់ដែលអ្នកដឹកនាំត្រូវមាន ព្រោះមេត្តាជាពាក្យផ្ទុយនឹងវិហិង្សា គឺការបៀតបៀន ឬហិង្សា ការឃោរឃៅ ។ បើអ្នកដឹកនាំមានសន្តានចិត្តជាមនុស្សឃោរឃៅ គិតតែចង់ព្យាបាទ បៀតបៀនរាស្ត្រប្រជារបស់ខ្លួនឯងទៅហើយ តើសេចក្តីសុខ សន្តិភាព និងការចំរើនលូតលាស់នឹងមានមកពីណា ? ឧបមាដូចមាតាបិតាដែលមិនស្រឡាញ់កូន ស្អប់កូន ធ្វើបាបកូន គ្មានការថ្នាក់ថ្នមអ្វីទាល់តែសោះ តើកូននោះនឹងចំរើនលូតលាស់ មានសតិបញ្ញា មានអនាគតរុងរឿងម្តេចនឹងកើត ? យើងដឹងហើយថា គោលបំណងរបស់ការគ្រប់គ្រងប្រទេសគឺ « *បជា-សុខំ មហុត្តមំ* = សេចក្តីសុខរបស់រាស្ត្រ គឺជារបស់ដ៏មហាឧត្តម » ចុះបើអ្នកដឹកនាំគ្មានមេត្តា គឺសេចក្តីប្រាថ្នាឱ្យគេបានសុខសោះ តើនយោបាយ ការគ្រប់គ្រងនោះអាចនឹងទៅដល់គោលដៅឬទេ ? នេះជាចម្លើយដែលអស់លោកអ្នកដឹកនាំ និងប្រជារាស្ត្រទាំងពួង ដែលមាននាទីត្រូវរើសប្រមុខដើម្បីដឹកនាំខ្លួន គប្បីឆ្លើយបានដោយខ្លួនឯង ។

បើមិនអាចឆ្លើយបានទេ ក៏គប្បីរំលឹកដល់អតីតកាលពីសម័យឆ្នាំ ១៩៧៥-១៩៧៨ ចុះ គង់នឹងយល់ពីសារសំខាន់របស់មេត្តាជាពុំខាន ថាតើមានសោកនាដកម្មអ្វីកើតឡើងខ្លះ នៅពេលដែលអ្នកដឹកនាំខ្មែរនាំគ្នាគ្រវាត់មេត្តាធម៌ចោល ។

## មេត្តា ៣ យ៉ាង :

*១. មេត្តាមនោកម្ម* : គឺមេត្តាតាមផ្លូវចិត្ត តាមការគិត គឺ :

- គិតតែរឿងដែលនាំឱ្យរាស្ត្របានសុខ

www.budinst.gov.kh www.elibraryofcambodia.org

- គិតតែរឿងណាមិនឱ្យរាស្ត្រមានការចងគំនុំ ព្យាបាទគ្នានឹងគ្នា
- គិតតែរឿងណា ដែលឱ្យរាស្ត្រស្រឡាញ់គ្នា ចេះជួយគ្នា,
- គិតតែពីរឿងណា ដែលឱ្យរាស្ត្រសម្បូរសប្បាយ មានទ្រព្យសម្បត្តិ មិនមានជំងឺ មានការចេះដឹង បានចំរុងចំរើនក្នុងការងារ,
- គិតតែពីរឿងណា ដែលអាចការពារមិនឱ្យឧបសគ្គ សត្រូវទាំងឡាយចូលមកបំផ្លាញសេចក្ដីសុខ សិទ្ធិ សេរីភាព សីលធម៌ ប្រជាធិបតេយ្យរបស់រាស្ត្រប្រជាខ្លួនបាន,
- ។ ល ។ និង ។ ល ។

- ភាវនា ទន្ទេញ ផ្សាយមេត្តាចិត្តដល់រាស្ត្រប្រជាខ្លួនជាប់ជានិច្ចថា សូមឱ្យរាស្ត្រប្រជាទាំងឡាយដែលនៅទិសខាងកើត ខាងលិច ខាងជើង ខាងត្បូង កុំបីមានពៀរវេរានឹងគ្នាឡើយ សូមឱ្យបាននូវសេចក្ដីសុខ សូមកុំឱ្យមានសេចក្ដីទុក្ខ សូមកុំមានការព្យាបាទគ្នា សូមឱ្យបានអាយុវែង សូមកុំឱ្យមានរោគ សូមឱ្យបរិបូណ៌ដោយទ្រព្យសម្បត្តិ សូមឱ្យបានសុខគ្រប់ៗគ្នាទាំងអស់ បើទុក្ខមាន ក៏សូមឱ្យអស់ទៅ ភ័យឯណាដែលមាន ក៏សូមឱ្យអស់ទៅ សេចក្ដីសោកសៅដែលកំពុងមាន ក៏សូមឱ្យអស់ទៅហោង ។

២. *មេត្តាវចីកម្ម* ៖ គឺមេត្តាតាមផ្លូវសំដី តាមវាចា គឺបានដល់ ៖

- និយាយតែពាក្យពិរោះ មិនទ្រគោះបោះបោក,
- និយាយតែពាក្យពិត ពាក្យមិនបោកបញ្ឆោត ភូតភរ,
- និយាយតែពាក្យដែលនាំឱ្យគេស្រឡាញ់គ្នា មានសាមគ្គី,
- និយាយតែពាក្យដែលមានប្រយោជន៍ ពាក្យដែលនាំឱ្យចំរើនដល់ជីវិតរស់នៅរបស់រាស្ត្រប្រជា,
- និយាយតែពាក្យដែលត្រូវគ្នានឹងមេត្តាមនោកម្មបានគិតពីខាង

www.budinst.gov.kh www.elibraryofcambodia.org

លើ,

៣. *មេត្តាកាយកម្ម* ៖ គឺមេត្តាតាមទង្វើដែលប្រព្រឹត្តដោយកាយ ៖

- ធ្វើតែកម្មណា ដែលមិនប៉ះពាល់ដល់ជីវិត រាងកាយរបស់រាស្ត្រប្រជា ដូចជាមិនប្រើអំពើឃោរឃៅ អំពើអមនុស្សធម៌ ផ្តាច់ការដោយអាវុធជាដើម ។
- ធ្វើតែកម្មណា ដែលមិនប៉ះពាល់ដល់សេចក្តីសុខ ទ្រព្យសម្បត្តិរបស់រាស្ត្រប្រជា ដូចជាស៊ីសំណូក លួចទ្រព្យជាតិ រឹបអូសទ្រព្យរាស្ត្រ ដោយអាងអំណាចទាំងខុសច្បាប់ យកពន្ធ ភាស៊ី អាករធ្ងន់ពេកជាដើម ។
- ធ្វើតែអំពើណា ដែលធ្វើឱ្យសុភមង្គលក្នុងគ្រួសាររបស់រាស្ត្រប្រជា រឹងប៉ឹង សុខដុមរមនា ។
- ធ្វើតែអំពើណា ដែលមេត្តាមនោកម្មបានគិត មេត្តាវចីកម្មបាននិយាយ ដោយការមានមេត្តាស្រឡាញ់រាស្ត្រស្មើនឹងស្រឡាញ់ខ្លួនឯង ។
- ។ល។

## មិត្ត និងសត្រូវរបស់មេត្តា

សត្រូវលេខមួយរបស់មេត្តា ឬសេចក្តីប្រាថ្នាចង់ឱ្យគេបានសេចក្តីសុខនេះ គឺ *សេចក្តីក្រោធ* និង *ទោសៈ* ។ ឯមិត្តរបស់មេត្តា គឺ *អវិហឹង្សា* ។ លោកអ្នកអានដែលចង់នឹងសេចក្តីអធិប្បាយច្បាស់លាស់ថែមទៀត សូមអញ្ជើញបើកត្រឡប់មើលក្នុងទសពិធរាជធម៌ចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

## មេត្តាជាបន្សាំរសំរាប់ផ្សារភ្ជាប់ពិភពលោក ៖

« មេត្តាជាបន្សាំរសំរាប់ផ្សារភ្ជាប់លោក » ជាវចនៈដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែង ដោយមានសេចក្តីថា លោក គឺគ្រួសារសង្គម ប្រទេសជាតិ និងលោកទាំងមូល អាចផ្សារភ្ជាប់គ្នាបានជាសាច់ឈាមតែមួយ អស់មានការប្រកាន់ពូជសាសន៍ ប្រកាន់វណ្ណៈ អស់មានសង្គ្រាម មានតែសន្តិភាព សន្តិសុខ និងការស្រឡាញ់គ្នា ដោយសារតែមេត្តា ១ ម៉ាត់នេះឯង ។

## មេត្តាជាសេចក្តីស្រឡាញ់សាកល

តាមពិត មេត្តានេះ អ្នកប្រាជ្ញអឺរ៉ុបខាងភាសាបាលីបានប្រែថា " សេចក្តីស្រឡាញ់ជាសាកល (Universal Love) " ។ មេត្តានេះ ព្រះសម្មាសម្ពុទ្ធលោកហៅថាជាអប្បមញ្ញា គឺមិនមានព្រំដែនកំណត់ទេ អ្នកដែលមានមេត្តា គឺជាអ្នកស្រឡាញ់អាណិតពិភពលោកទាំងមូល រួមដោយសត្វទាំងឡាយ " មនុស្ស ទេវតា ប្រេត តិរច្ឆាន អសុរកាយ នរក " និងធម្មជាតិដែលនៅជុំវិញ ។

តែដែលរចនាករអធិប្បាយចំពោះតែអ្នកដឹកនាំ និងរាស្ត្រប្រជានោះ ព្រោះក្នុងទីនេះកំពុងអធិប្បាយពីគុណធម៌របស់អ្នកដឹកនាំ ដែលត្រូវមានចំពោះរាស្ត្រ ទើបមិនបានអធិប្បាយវែងឆ្ងាយ ។ សូមលោកអ្នកអានសំគាល់ទុកក្នុងចិត្តផងចុះថា ក្រៅពីសេចក្តីស្រឡាញ់ចង់ឱ្យរាស្ត្រប្រជាខ្លួនបានសុខដោយចំពោះហើយ អ្នកដឹកនាំត្រូវផ្សាយមេត្តាដល់អ្នកជិតខាង និងប្រទេសជិតខាង ព្រមទាំងពិភពលោក ក្នុងឋានៈជាមនុស្សជាតិ និងជាបងប្អូនគ្នាជាចាំបាច់ ។

www.budinst.gov.kh www.elibraryofcambodia.org

# ករុណា

ករុណា គឺការអាណិត ជួយគេឱ្យផុតពីសេចក្តីទុក្ខ ជាព្រហ្មវិហារធម៌ទី ២ ដែលអ្នកដឹកនាំត្រូវបំពេញ ។ ករុណា គឺជាការបង្ហាញនូវមេត្តាចិត្តដែលខ្លួនមាន ឱ្យប្រាកដច្បាស់ដោយការចូលទៅជួយយកជាធុរៈក្នុងការកំចាត់នូវបញ្ហា វិបត្តិ សេចក្តីទុក្ខទាំងឡាយ ដែលរាស្ត្រប្រជាកំពុងមាន និងដែលបំរុងកើតមាន ។ ឧទាហរណ៍ មានមនុស្សម្នាក់កំពុងលង់ទឹក ហើយយើងដើរទៅជួប ។ អាស្រ័យដោយចិត្តរបស់យើងជាអ្នកមានមេត្តា ពេលដែលឃើញជននោះលង់ទឹក យើងក៏ទៅជួយដោយការចុះទឹកទៅអូសឡើងគោកក្តី ឬ ដោយការហុចឈើឱ្យអ្នកនោះតោងក្តី ។ ការដែលយើងជួយជននោះឱ្យរួចពីស្លាប់នេះ ហៅថា ករុណាធម៌ ។

ដូច្នេះ បើយល់ពីមេត្តាធម៌ច្បាស់លាស់ហើយ ករុណាធម៌ ក៏ងាយនឹងយល់ណាស់ ដោយគ្រាន់តែប្តូរ និងធ្វើមេត្តាចិត្តនោះឱ្យក្លាយទៅជាសកម្មភាពតែប៉ុណ្ណោះ ក៏ឈ្មោះថាមានករុណាទៅហើយ ។

ព្រោះថា សេចក្តីសុខនេះ ស្ថិតនៅក្នុងសេចក្តីទុក្ខ ឧបមាដូចជា អនាម័យស្ថិតនៅក្នុងភាពកខ្វក់អញ្ចឹងដែរ ។ ឧទាហរណ៍ គេឱ្យកូនកន្សែងកខ្វក់ ប្រឡាក់ដោយគ្រឿងស្មោកគ្រោកមកឱ្យយើងមួយ ហើយប្រាប់ថាឱ្យយើងរកកូនកន្សែងស្អាតទៅឱ្យគេវិញ ដោយឱ្យយកកូនកន្សែងដដែលហ្នឹង ។ វិធីដែលយើងរកកូនកន្សែងស្អាត គឺធ្វើយ៉ាងណា បោកគក់ ឬដកគ្រឿងកខ្វក់ និងស្មោកគ្រោកដែលនៅជាប់នឹងកូនកន្សែងនោះចេញឱ្យអស់ទៅ យើងនឹងបានកន្សែងមួយដែលស្អាតមានអនាម័យមិនខាន ។ គឺយើងមិនបាច់ទៅចាត់ការនឹងភាពស្អាតទេ គឺត្រូវចាត់ការនឹងភាពកខ្វក់ ។ ការចាត់ការនឹងភាពកខ្វក់របស់កន្សែង ឬសេចក្តីទុក្ខរបស់រាស្ត្រប្រជានេះ គឺជាបណ្តូលរបស់ព្រះពុទ្ធសាសនា ដូចព្រះអង្គមានពុទ្ធដីកាថា បើមានអ្នក

www.budinst.gov.kh www.elibraryofcambodia.org

ណាសួរពុទ្ធបរិស័ទថា ព្រះសមណគោតមប្រៀនប្រដៅពីរឿងអ្វី ក៏គប្បីឆ្លើយថា ព្រះសមណគោតមបង្រៀនឱ្យស្គាល់ពីអ្វីដែលហៅថាសេចក្តីទុក្ខ ( បញ្ហា ) និងផ្លូវសំរាប់រំលត់សេចក្តីទុក្ខនោះ ។

## សេចក្តីទុក្ខរបស់រាស្ត្រប្រជា

១. *ជិឃច្ឆា បរមា រោគា* គម្លានជារោគដ៏កាចខ្លាំងបំផុត ។

២. *ទលិទ្ទិយំ ទុក្ខំ លោកេ* ការក្រក្រី គឺជាសេចក្តីទុក្ខរបស់លោក ( សង្គម, មនុស្ស ) ។

៣. *ឥណាទានំ ទុក្ខំ លោកេ* ការជំពាក់បំណុលគេ គឺជាសេចក្តីទុក្ខរបស់លោក ។

៤. *នត្ថិ ខន្ធសមា ទុក្ខា* មិនមានទុក្ខណាស្មើនឹងបញ្ចក្ខន្ធ (ជីវិត) ទេ ។

ទាំង ៤ ប្រការខាងលើ ជាសេចក្តីទុក្ខដ៏ខ្លាំង ដែលកាច ដែលធំជាងគេបង្អស់ក្នុងលោក ។ អ្នកដឹកនាំដែលមានករុណាធម៌ គឺអ្នកដឹកនាំដែលព្យាយាមកំចាត់នូវបញ្ហាទាំង ៤ នេះ ឱ្យអស់ពីក្នុងសង្គមរបស់ពលរដ្ឋខ្លួន ។

www.budinst.gov.kh www.elibraryofcambodia.org

# មុទិតា

**មុទិតា** គឺការត្រេកអរ សប្បាយរីករាយ ពេលដែលគេមាន ឬបានសេចក្ដីសុខ ជាព្រហ្មវិហារធម៌ទី ៣ ដែលអ្នកដឹកនាំគប្បីបណ្ដុះនៅក្នុងសន្ដានចិត្តខ្លួន ។

មេត្តា គឺការប្រាថ្នាឱ្យគេបានសុខ ករុណា ពេលគេលង់ទឹកក៏ស្ទុះទៅជួយ ឯមុទិតាវិញ ពេលដែលជួយគេរួចហើយ ក៏សប្បាយចិត្តមិនមានចិត្តគិតថានឹងទាមទារអ្វីពីជនរងគ្រោះទេ ឬលុះដល់ថ្ងៃក្រោយ ខ្លួនរងគ្រោះថ្នាក់វិញ ឥតមាននរណាជួយ ( សូម្បីតែជនដែលខ្លួនធ្លាប់ជួយក៏ដោយ ) ក៏មិនតូចចិត្ត ។

មុទិតា បើនិយាយឱ្យចំ គឺមិនចេះច្រណែន មិនចេះនិន្ទាឈ្នានីស មិនព្យាបាទ និងមិនចេះផ្ដន្ទា ចំពោះសេចក្ដីសុខរបស់ជនណាទេ គឺមានតែត្រេកអរ និងជួយអនុមោទនា សាធុ ! សាធុ ! សាធុ ! នៅពេលឃើញ ឬ ដឹងថាអ្នកណាមួយមានសេចក្ដីសុខ ។

ពួកយើងដែលជាមនុស្សបុថុជ្ជននេះ តែងមានរោគផ្លូវចិត្ត ១៦ យ៉ាង ដែលតែងចូលមកយាយីសុខភាពផ្លូវកាយ បន្ថយនូវសមត្ថភាពក្នុងកិច្ចការ និងបំផ្លាញនូវគុណធម៌ជាមនុស្សឱ្យទន់ទាប ។ រោគផ្លូវចិត្តនោះ ភាសាធម្មៈលោកហៅថា កិលេស ឬឧបកិលេស ដែលបានរៀបរាប់ម្ដងរួចហើយក្នុងទសពិធរាជធម៌ ត្រង់ចំណុចតបៈ ។

មានរោគមួយដែលកាចសាហាវជាងគេសំរាប់អ្នកធំ រហូតដល់ព្រះសម្មាសម្ពុទ្ធប្រទានថ្នាំឈ្មោះ មុទិតា ឱ្យទុកសំរាប់ព្យាបាលអ្នកកើតរោគនោះ ។ រោគសំរាប់អ្នកធំនេះឈ្មោះឥស្សា ឬការច្រណែនឈ្នានីសដែលជារោគទី៧ ក្នុងចំណោមរោគទាំង ១៦ ។

www.budinst.gov.kh www.elibraryofcambodia.org

## មនុស្ស ឬ មនីស្ស ?

មានពាក្យពីរម៉ាត់ដែលខ្មែរយើងតែងបញ្ចេញសំឡេងផ្សេងគ្នា និងឱ្យនិយមន័យផ្សេងគ្នា ។ អ្នកណាដែលបញ្ចេញសំឡេងថា " មនុស្ស " គេតែងថាអ្នកនោះជាអ្នកបានទទួលការសិក្សា ។ បើអ្នកណាបញ្ចេញសំឡេងថា " មនីស្ស " គេថាអ្នកនោះសម្រែ ឬគ្មានការសិក្សា ។ ចុះតើពាក្យណាត្រូវជាង ?

**មនុស្ស** ៖ ក្នុងភាសាបាលី មកពីពាក្យពីរម៉ាត់ គឺ *មនៈ* = ចិត្ត និង *ឧស្ស* = ខ្ពស់ រួមគ្នាទៅជាមនុស្ស ដែលប្រែតាមព្យញ្ជនៈថា អ្នកមានចិត្តខ្ពស់ ។ បានជាលោកប្រើពាក្យ មនុស្ស ហៅពួកយើងជាបុគ្គលម្នាក់ៗនេះ ព្រោះលោកចង់ឱ្យយើងយកពាក្យនេះជាមាត្រដ្ឋាន សំរាប់ដើរទៅឱ្យដល់ ឬសំរាប់អភិវឌ្ឍខ្លួនឱ្យផុតពីភាពជា **បុគ្គល** ដែលលោកប្រែថា " *អ្នកស្លាយនូវផង់ស្អុយ* " បានដល់ស្លាយក្រពះ គឺគិតតែពីរឿងស៊ីផុះតែម្យ៉ាង ។ មនុស្ស ជាអ្នកមានចិត្តខ្ពស់ គឺខ្ពស់ជាងពីរឿងស៊ីផុះ ខ្ពស់ជាងរោគ ១៦ យ៉ាងខាងផ្លូវចិត្ត ដែលតែងតែមកបៀតបៀន ។ គឺបើអ្នកណាទៅជាមនុស្សហើយ អ្នកនោះមិនមានរោគឧបកិលេសទាំង ១៦ យ៉ាងនេះទេ ។

**មនីស្ស** ៖ ខ្ញុំមិនដឹងថាពាក្យនេះមានក្នុងភាសាបាលី ឬពុទ្ធវចនៈទេ តែពាក្យនេះ អាចញែកចេញប្រែ ហើយមានន័យបានត្រូវល្អណាស់ ។ មនីស្ស មកពីពាក្យ *មនៈ* ប្រែថាចិត្ត និង *ឥស្ស* ប្រែថាច្រណែនឬស្សា ឈ្នានីស ភ្ជាប់គ្នាទៅបានជាពាក្យថា មនីស្ស ដែលអាចប្រែជាអត្ថន័យថា អ្នកមានចិត្តឫស្សា ច្រណែន ។

រោគច្រណែននេះ ជារោគកាចណាស់ ។ ច្រណែនព្រោះបានមិនស្មើគ្នា

www.budinst.gov.kh www.elibraryofcambodia.org

គេធំជាងខ្លួន វាប្រសើរជាងអញ វាចង់មកវាយឫកស្មើអញ ។ ល ។ គឺសុទ្ធតែជារោគកាចទាំងអស់ ជាពិសេស ពេលដែលវាមកកើត មកទំលើអ្នកធំជាអ្នកដឹកនាំហើយ វានឹងបង្កឱ្យកើតគ្រោះថ្នាក់ មហន្តរាយដល់អ្នកដែលវាមកទំណាស់ ។ មុនដំបូង វាធ្វើឱ្យអ្នកជំងឺនោះដេកមិនលក់ បក់មិនឆ្ងើយ រសាប់រសល់នៅមិនសុខ ឈឺចិត្ត ក្តៅចិត្ត តូចចិត្ត រហូតដល់ស្រក់ទឹកភ្នែកក៏មាន ។ ដល់ពេលជំងឺនេះវាចាប់សន្ធំ វានឹងធ្វើឱ្យអ្នកជំងឺ ប្រកាច់ប្រកិន វង្វេងវែងដឹងខុសត្រូវ អស់សតិ វាយគេវាយឯង រហូតហ៊ានទៅសម្លាប់ជីវិតអ្នកដទៃ ហ៊ានទៅដណ្តើមទ្រព្យសម្បត្តិគេ ហ៊ានទៅបំផ្លាញសេចក្តីសុខរបស់ស្វាមី-ភរិយាគេ ទៅជាចេះនិយាយកុហក ចេះនិយាយអាក្រក់ សម្តីវែងពិរោះពិសារ ចេះនិយាយញុះញង់ ចេះនិយាយសម្តុយកេរ្តិ៍ឈ្មោះ និយាយប៉ប៉ាច់ប៉ប៉ោចពីគេ ចិត្តគិតពីចង់បាន ចិត្តគិតតែរកឱកាសដើម្បីប្រទូសរ៉ាយឱ្យគេវិនាស ហើយទីបំផុត ក៏ទៅជាវិកលចរិត វែងដឹងខុសត្រូវ បាបបុណ្យ គុណទោសអស់រលីង ព្រោះមេរោគច្រណែនវាឡើងដល់កម្រិតសញ្ញាក្បាលខ្មោចទៅហើយ ។ និយាយរួម អ្នកមានចិត្តឥស្សា ឬ មច្ឆរិយ នេះ អាចប្រព្រឹត្តនូវអកុសលកម្មបថទាំង ១០ ដូចដែលមានអធិប្បាយរួចមកហើយ ក្នុងទសពិធរាជធម៌ ទី៨ គឺអវិហឹង្សាបានទាំងអស់ ។

ថ្នាំការពារ និងថ្នាំព្យាបាលរោគឥស្សា គឺ មុទិតានេះឯង ។ អាស្រ័យហេតុដូច្នេះឯង ទើបបានព្រះសម្មាសម្ពុទ្ធ លោកដាក់មុទិតាធម៌ជាគោលទី៣ សំរាប់ឱ្យអ្នកដឹកនាំចំរើន ភាវនា ទន្ទេញ និងប្រព្រឹត្តឱ្យបានជាប់ទាំងយប់ទាំងថ្ងៃ ដើម្បីការពារកុំឱ្យរោគនេះចូលមកយាយីបាន ។ បើសិនជាវាចូលមកយាយីហើយ ប្រាកដជាលំបាកក្នុងការព្យាបាលណាស់ ព្រោះរាស្ត្រប្រជាគេមិនដែលទុកឱ្យមនុស្សមានជំងឺផ្លូវចិត្ត ឬមនុស្សឆ្កួត ឡប់សតិ ឱ្យធ្វើជាប្រមុខនាំគេទៅរកសេចក្តីសុខឡើយ បើ

www.budinst.gov.kh www.elibraryofcambodia.org

មិនឆាប់ក៏យូរ គង់តែនឹងត្រូវគេទម្លាក់ជាមិនខាន ទោះដោយសន្តិវិធី ឬដោយគ្រឿងអាវុធក្តី ព្រោះមនុស្សយើង ៖

- ទី១ ចង់រស់
- ទី២ ចង់មានសេរីភាព ដើម្បីជ្រើសរើសដំណើរជីវិតខ្លួន
- ទី៣ ចង់មានឥស្សរភាព គឺភាពជាធំលើចិត្តគំនិតរបស់ខ្លួន និងជីវិតរបស់ខ្លួន មិនចង់ឱ្យអ្នក ណា ត្រួតត្រាជិះជាន់ , និង
- ទី៤ ចង់រស់ជាមនុស្ស និងមានលក្ខណៈជាមនុស្សជាមួយគ្នា ។

ជាធម្មជាតិ *មនុស្ស* មិនចង់ឱ្យ *មនីស្ស* កើតមានទេ ក៏ដូចជាមនុស្សមិនចង់ឱ្យមានរោគចូលមកបៀតបៀនរាងកាយគេដែរ ដោយហេតុថា ៖

**អរោគ្យា បរមា លាភា**

ការមិនមានរោគ គឺជាលាភដ៏ឧត្តមបំផុត

www.budinst.gov.kh www.elibraryofcambodia.org

# ឧបេក្ខា

ឧបេក្ខា តាមព្យញ្ជនៈ ប្រែថា ចូលទៅឱ្យជិតដើម្បីត្រិះរិះ មកពីពាក្យថា ឧបៈ = ចូលទៅជិត និង ឥក្ខា = ត្រិះរិះពិចារណា រួមទៅបានន័យថា ចូលទៅឱ្យជិតដើម្បីពិចារណា ។

ប្រែតាមអត្ថន័យ ឧបេក្ខា គឺការតាំងចិត្តជាកណ្ដាល មានចិត្តទៀងត្រង់ដូចជញ្ជីង មិនងាកវេទៅតាមអគតិទាំង ៤ មានយុត្តិធម៌ មានចិត្តស្ងប់ ពិចារណាទៅតាមការពិត ។

ឧបេក្ខា គឺជាក្រុមបញ្ញា មាននាទីឃុំគ្រង ត្រួតពិនិត្យនូវគោលធម៌ និងសកម្មភាពផ្សេងៗ ដែលកើតចេញពីមេត្តា ករុណា និង មុទិតា ។

*ឧទាហរណ៍ ពីរឿងអ្នកលង់ទឹកដដែល :*

យើងដើរទៅជួបមនុស្សម្នាក់កំពុងលង់ទឹក ។ យើងមានចិត្តមេត្តាចំពោះជនរងគ្រោះនោះណាស់ ក៏ករុណាទៅជួយដើម្បីឱ្យគាត់ផុតពីសេចក្ដីស្លាប់ ។

ពេលនេះឯង ជាពេលដែលយើងត្រូវប្រើឧបេក្ខា ។ បើយើងមានតែមេត្តា និងករុណាដ៏លើសលប់ ហើយក៏លោតប្រុងចុះទៅក្នុងទឹក ដោយពុំមានគិតថាខ្លួនឯងមិនចេះហែលទឹកទេ តើផលដែលកើតឡើងនឹងទៅជាយ៉ាងណា ? អ្នកនោះក៏ស្លាប់ យើងក៏ស្លាប់ដោយឥតប្រយោជន៍ ។ បើមានឧបេក្ខា យើងនឹងពិចារណាហេតុផលបន្តិចសិន បើថាយើងមិនចេះទេ យើងក៏ស្រែកហៅគេជួយ ។ បើគ្មានគេជួយទេ យើងរកឈើហុចឱ្យគេតោង ឬបោះកំណាត់ឈើឱ្យគេតោងកុំឱ្យលិច ឬក៏គ្មានអ្វីដែលនឹងអាចជួយបានទេ មនុស្សក៏គ្មាន ឈើក៏គ្មាន យើងក៏មិនចេះហែលទឹក ឧបេក្ខា គឺតម្រូវឱ្យយើងពិចារណាទៅតាមច្បាប់កម្មរបស់សត្វថា « ធ្វើម្ដេចនេះជាវិបាកកម្មរបស់សត្វ ប្រហែលជាបាបកម្មពីមុនមកហើយ » ។

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះ ឧបេក្ខា គឺបញ្ហានេះជាការចាំបាច់ណាស់ ដែលត្រូវយកមកប្រើជាមួយករុណា បើមិនដូច្នោះទេ ករុណានឹងអាចផ្តល់នូវសេចក្តីទុក្ខមកដល់អ្នកមានករុណាជាមិនខាន ។

## ឧបេក្ខារបស់អ្នកដឹកនាំ

យើងមកមើលពីសេចក្តីទុក្ខរបស់រាស្ត្រប្រជាម្តងទៀត ដែលមាន ៤ គឺ :

១. គម្លាន ជារោគដ៏កាចសាហាវ,

២. សេចក្តីក្រ ជាទុក្ខនៅក្នុងសង្គម,

៣. ការជំពាក់បំណុល ជាទុក្ខរបស់សង្គម,

៤. ការរស់នៅ ជាទុក្ខធំជាងគេ,

ទាំង ៤ នេះ គឺបញ្ហារបស់រាស្ត្រប្រជា ដែលអ្នកដឹកនាំត្រូវដោះស្រាយ ។ បើយើងប្រើឧបេក្ខា ដែលប្រែថា ចូលឱ្យជិតទៅត្រិះរិះពិចារណា ជាមួយនឹងករុណារបស់យើងនោះ ករុណានោះគប្បីមានលក្ខណៈ ដូច្នេះ :

- ជាការជួយដែលអាចឱ្យគេជួយខ្លួនឯងបាន គឺមិនមែនជួយជាបែបចិញ្ចឹមរហូតអស់មួយជីវិតនោះទេ តែជួយមួយរយៈពេលខ្លី ដើម្បីដោះភាពអាសន្ន ហើយប្រាប់មធ្យោបាយអាចឱ្យគេរស់ខ្លួនគេបាន ដោយមិនបាច់ពឹងលើយើងតទៅទៀត ។ ឧទាហរណ៍ អ្នកស្រែកឃ្លានម្នាក់មកសុំឱ្យយើងជួយ ។ ជាដំបូង យើងឱ្យអាហារបំបាត់ការស្រេកឃ្លានមួយរយៈសិន លុះមានកម្លាំងហើយ ក៏រកការងារឱ្យធ្វើ ដែលអាចឱ្យអ្នកនោះធ្វើការរកលុយមកទិញបាយទឹកបំបាត់ការស្រេកឃ្លានដោយខ្លួនគេបាន ដោយមិនបាច់ពឹងពាក់លើយើងរហូតឡើយ ។

« កុំឱ្យត្រីទៅអ្នកនោះរាល់ថ្ងៃ តែឱ្យឧបករណ៍ត្រីទៅអ្នកនោះ និងវិធីរកត្រី ដើម្បីឱ្យគេរកត្រីបានដោយខ្លួនគេ » ។

- ជាការជួយ ដែលហុចផលក្នុងរយៈពេលវែង គឺមិនមែនជួយហើយ

www.budinst.gov.kh www.elibraryofcambodia.org

បណ្ដោយឱ្យគ្នារស់បានរយៈពេលតែមួយភ្លែតហ្នឹង ហើយក្រោយមកស្លាប់នោះទេ ។

• ជាការជួយប្រភេទ « កំចាត់ហេតុរបស់បញ្ហា » គឺរកហេតុឱ្យឃើញ ដោយប្រើរបៀបអរិយសច្ចៈ ៤ ប្រការ ដែលអធិប្បាយមកហើយ ។ ព្រោះបើជួយដោះស្រាយតែចុងបញ្ហានោះ បញ្ហាមួយរលត់ទៅ បញ្ហាមួយគង់នឹងកើតទៀតមិនខាន ។

• បញ្ហាដោះមិនបានទាល់តែសោះ ក៏គប្បីតាំងចិត្តជាកណ្ដាល ដោយគិតថា « យើងបានធ្វើការនោះអស់ពីសមត្ថភាពហើយ » ដើម្បីការពារកុំឱ្យមានវិបត្តិផ្លូវចិត្តកើតឡើង ។

• ។ ល ។

## តុល្យភាពរវាង ករុណា និង បញ្ញា

ទាំងករុណា និងបញ្ញា ត្រូវមានទម្ងន់ស្មើគ្នា ។ តែបើមានតែករុណា ឥតបញ្ញា មនុស្សនឹងទៅជាខ្ជិល ចាំឱ្យតែគេមកជួយខ្លួន ។ តែបើមានតែបញ្ញា ឥតករុណា អ្នកនោះនឹងប្រើបញ្ញាទៅក្នុងផ្លូវខុសដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ហើយពិភពលោកនេះនឹងមានតែសង្គ្រាមប៉ុណ្ណោះ ។

## សារសំខាន់របស់ព្រហ្មវិហារធម៌ ៤

**ព្រហ្មវិហារធម៌** ជាធម៌សំរាប់ធ្វើមនុស្សឱ្យទៅព្រហ្ម សំរាប់ធ្វើមនុស្សឱ្យក្លាយទៅជាមនុស្សពេញបរិបូណ៌ ។

លោកនេះនឹងមានតែសេចក្ដីសុខ ព្រោះព្រហ្មវិហារធម៌ ។ ធម៌នេះ ពិតមែនតែនៅទីនេះសង្កត់តែពីរឿងអ្នកដឹកនាំ តែតាមការពិត ធម្មជាតិរបស់ព្រហ្មវិហារធម៌ គឺសំរាប់មនុស្សទូទៅដែលត្រូវរស់នៅក្នុងសង្គមជាមួយគ្នា ។

ពាក្យថា *សង្គម* ស័ព្ទដើមមកពីពាក្យថា *សង្គាម* ឬ *សង្គ្រាម* ដែលប្រែថា

www.budinst.gov.kh www.elibraryofcambodia.org

ការវឹកវរ ការច្របូកច្របល់ ការធ្វើសង្គ្រាម ការច្បាំងគ្នា ។

*អ្នកដឹកនាំសង្គម គឺជាអ្នកដែលកំពុងប្រយុទ្ធជាមួយសង្គ្រាម ៖*

សង្គ្រាមព្រោះឃ្លាន សង្គ្រាមព្រោះក្រ សង្គ្រាមព្រោះបំណុល និង សង្គ្រាមព្រោះរឿងជីវិត ។ គេមិនអាចយកសាំងទៅពន្លត់ភ្លើងសាំងបានទេ ក៏ដូចជា គេមិនអាចយកសង្គ្រាមទៅពន្លត់សង្គ្រាមបានជាដាច់ខាតដែរ ។ ស្អប់ មិនអាចដោះ ស្រាយបានដោយសារស្អប់បានទេ តែស្អប់នឹងដោះស្រាយបានដោយការស្រឡាញ់ ក៏ដូចជាសង្គ្រាមខ្មែរមិនអាចបញ្ចប់ដោយការប្រយុទ្ធឡើយ តែនឹងបញ្ចប់បានដោយ អ្នកដឹកនាំមានមេត្តាចិត្តដាក់គ្នា ចង់ជួយរាស្ត្រប្រជាឱ្យផុតពីទុក្ខ ត្រេកអរ រីករាយ ពេលម្នាក់ទៀតបានថ្កុំថ្កើង និងប្រើបញ្ញាដែលប្រកបដោយមេត្តា ករុណា ដើម្បីដោះ ស្រាយនូវបញ្ហាដែលមាន ។ សង្គម ឬសង្គ្រាមជាភ្លើង មានតែព្រហ្មវិហារធម៌ទាំង ៤ ដែលជាទឹកទេ ទើបអាចពន្លត់ភ្លើងសង្គ្រាមបាន ។

*ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ*

*អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ ។*

« តាំងតែពីកាលណាមក ក្នុងលោកនេះមិនដែលមានការចងពៀរណា រំងាប់ដោយការចងពៀរតបតទេ មានតែរំងាប់ដោយការមិនចងពៀរ ព្រោះនេះជា ច្បាប់អមតៈសកល » ។

ជាទីបញ្ចប់ សូមអ្នកដឹកនាំទាំងឡាយចាំនូវពុទ្ធភាសិតរបស់ព្រះសម្មា-សម្ពុទ្ធ ពីរឃ្លាខាងក្រោមទុកជាគតិ ក្នុងការគ្រប់គ្រង ដឹកនាំពលរដ្ឋខ្មែរ តទៅ ៖

- *លោកោបត្ថម្ភកា មេត្តា* ៖ មេត្តាជាអ្នកឧបត្ថម្ភលោក,
- *មហាបុរិសភាវស្ស លក្ខណំ ករុណាសហោ* ៖ ការមានករុណា គឺ ជាលក្ខណៈរបស់មហាបុរស,

www.budinst.gov.kh www.elibraryofcambodia.org

# ៥- ដើម្បីសេចក្តីសុខរបស់មហាជន

សុខភាព !

សមត្ថភាព !

គុណធម៌ !

អង្គប្រកប ៣ យ៉ាង សំរាប់អ្នកដែលចង់ធ្វើជាអ្នកដឹកនាំ ជាប្រមុខ ជាប្រធាន ជារាជា ជាមេគេ នៅក្នុងសហគមន៍ ឬប្រទេសណានីមួយ ដើម្បីត្រៀមខ្លួនសំរាប់នាទី និងកិច្ចការទាំងឡាយដ៏លំបាក និងស្មុគស្មាញ ។

អង្គប្រកប ៣ យ៉ាងសំរាប់រាស្ត្រប្រជា និងអ្នកតូចដែលត្រូវសម្លឹងមើលឱ្យជិត ពិចារណាឱ្យបានត្រឹមត្រូវ មុននឹងសំរេចចិត្តលើកដៃ ឬបោះឆ្នោតជ្រើសរើសនរណាម្នាក់ឱ្យមកធ្វើជាអ្នកដឹកនាំខ្លួន ។

ជាពិសេស គុណធម៌ អង្គប្រកបដែលមិនអាចរករៀនបាននៅតាមសាលាទូទៅដែលមិនត្រូវការទន្ទេញ ឬរៀនឱ្យចាំ ដើម្បីប្រឡងយកសញ្ញាប័ត្រ តែកើតឡើងដោយសតិសម្បជញ្ញៈជាមនុស្ស និងដោយសារការអប់រំរបស់សាសនា ។

ខ្មែរយើងបាត់បង់គុណធម៌ និងខ្វះខាតគុណធម៌ច្រើនណាស់ ទើបជាការចាំបាច់ត្រូវនាំគ្នាបណ្តុះ និងពង្រីកអង្គប្រកបនេះឱ្យបានរីកស្គុះស្គាយគ្រប់ទីកន្លែង ។

*សុខភាពមិនល្អ* យើងទៅពេទ្យ !

*សមត្ថភាពមិនគ្រប់គ្រាន់* អាចមានគ្រូបរទេសមកបំពេញឱ្យ ! តែបើ

*គុណធម៌ដាច់រលែក* គឺយើងជាអ្នកប៉ះខ្លួនយើង !

ព្រោះអ្វី ? - ព្រោះដើម្បីសេចក្តីសុខរបស់មហាជន !

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីសុខរបស់មហាជន !

សេចក្តីសុខរបស់មនុស្ស តាមទស្សនៈវដ្តសាស្ត្ររបស់ព្រះពុទ្ធសាសនា មាន ៥ ប្រការគឺ អត្ថិសុខ ភោគសុខ អនណសុខ អនវជ្ជសុខ និងសន្តិភាព ។




**ក. អត្ថិសុខ** ៖ សេចក្តីសុខព្រោះមានទ្រព្យសម្បត្តិ មានមាសប្រាក់ មានវត្ថុជាជំនួយសំរាប់សេចក្តីត្រូវការក្នុងការរស់នៅគ្រប់គ្រាន់ ។ ជាមូលដ្ឋាន គឺមានបច្ច័យជីវិត ៤ យ៉ាងគឺ ៖

១. មានសម្លៀកបំពាក់សំពត់ខោអាវ គ្រឿងអលង្ការ សំរាប់បិទបាំង និងតុបតែងខ្លួនឱ្យបានសមរម្យ និងសមគួរ ។

២. មានម្ហូបអាហារ បាយទឹក ស្រូវអង្ករ មើមឈើ ផ្លែឈើ បង្អែមចំអាប សំរាប់ទទួលទានបំបាត់ការស្រេកឃ្លានរបស់ក្រពះ និងឱ្យរាងកាយចំរើន លូតលាស់ ធំធាត់ ទៅតាមវ័យ និងទៅតាមក្បួនភោជនវិទ្យា ។

៣. មានគេហដ្ឋាន ផ្ទះសម្បែង ទីជម្រក ជារបស់ខ្លួន និងឧបករណ៍

www.budinst.gov.kh www.elibraryofcambodia.org

ផ្សេងៗ សំរាប់សំរួលដល់សេចក្តីត្រូវការ ដូចជាគ្រែដេក កៅអីអង្គុយ ភ្លើងបំភ្លឺ តុទូ ពាង ជង្រុក និងយានជំនិះផ្សេងៗ ។

៤. មានថ្នាំព្យាបាលរោគ មានពេទ្យសំរាប់ព្យាបាលជំងឺ និងគ្រឿងភេសជ្ជៈផ្សេងៗ សំរាប់ផឹកនៅពេលអស់កម្លាំង ពេលមានជំងឺ ។

ពាក្យដែលថា *មាន* នេះ មានន័យថា មានល្មមនឹងសេចក្តីត្រូវការជាចាំបាច់ ពុំមែនចំបាច់ថាមានរហូតដល់ហូរហៀរជាបែបមហាសេដ្ឋីនោះទេ ព្រោះសេចក្តីចង់បានរបស់មនុស្សគ្មានព្រំដែនទេ ដូចពាក្យគេថា « ចំណង់មនុស្សដូចថង់ធ្លុះបាត » ដាក់ប៉ុណ្ណាក៏មិនពេញដែរ ។

**ខ. ភោគសុខ** : សេចក្តីសុខព្រោះបានប្រើនូវទ្រព្យដែលខ្លួនបានមកនោះ ដូចជាមានផ្សារសំរាប់លក់ផលិតផលដែលខ្លួនត្រូវការ មានផ្សារសំរាប់ទទួលទិញនូវស្រូវអង្ករដែលខ្លួនផលិតបាន មានកម្មសិទ្ធិឯកជនពេញទីលើទ្រព្យសម្បត្តិរបស់ខ្លួន (ព្រោះបើជាប្រទេសកុម្មុយនិស្ត ទ្រព្យសម្បត្តិជារបស់រដ្ឋ ឯកជនមិនអាចប្រើបានទេ) មានផ្លូវសំរាប់បើកបរ រួមទាំងមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈប្រើសម្បត្តិរបស់រដ្ឋបាន ដូចជាមន្ទីរពេទ្យ សាលារៀន ប្រៃសណីយ៍ ។ ល ។ តាមសិទ្ធិដែលខ្លួនគួរមាន និងដែលច្បាប់រដ្ឋអនុញ្ញាត និងរួមទាំងទ្រព្យធម្មជាតិដែលមាននៅក្នុងប្រទេសរបស់ខ្លួនឯងដែរ ។

**គ. អនណសុខ** : សេចក្តីសុខព្រោះការមិនមានបំណុល មិនជំពាក់គេមិនមែនជាខ្ញុំបំរើដាច់ថ្លៃអ្នកណា មិនមែនជាទាសករ ជាសេចក្តីសុខដែលកើតពីការដែលខ្លួនឯងមានទ្រព្យសម្បត្តិល្មមគ្រប់គ្រាន់ និងមិនបានប្រើប្រាស់ទ្រព្យនោះដោយខ្ជះខ្ជាយ រហូតដល់ទៅអស់ ហើយខ្ចីគេមកចាយ ។ រឿងនេះ រួមដល់ទៅប្រព័ន្ធនៃការខ្ចីបំណុលផងដែរ គឺខ្ចីបំណុលហើយអាចសងបំណុលនោះបានវិញ ហើយប្រាក់បំណុលនោះ មិនយកការប្រាក់ថ្លៃរហូតដល់ទៅហួសហេតុពេក ដូចជាធនាគារ

www.budinst.gov.kh www.elibraryofcambodia.org

ខ្ចីយកការប្រាក់ក្នុង ១ ឆ្នាំ ១៤ ភាគរយ ឯនាយទុនយកដល់ទៅ ២០ ភាគរយក្នុង ១ ខែ ជាដើម ។

**ឃ. អនវជ្ជសុខ** : សុខកើតមកពីការដែលមិនមានទោស :

ឃ. ១. ការដែលមានការងារសុចរិតធ្វើជាបង្គោលជាប់លាប់សំរាប់ផានាដល់ការរកទ្រព្យសម្បត្តិ ការចាយវាយ និងការមិនជំពាក់បំណុលគេ ឬបើមានជំពាក់បំណុលគេ ក៏អាចនឹងសងរួច ព្រោះមានការងារសំរាប់ផានារកប្រាក់ទៅសងគេវិញបាន ។ ការងារនេះ បើចំពោះកសិករ គឺបានដល់ការដែលមានស្រែ ចំការ គោ ក្របី សំរាប់ផលិតធញ្ញផលដើម្បីលក់ដូរ បើចំពោះអ្នកដែលមិនមែនជាកសិករ គឺមានការងារសំរាប់ទទួលឱ្យខ្លួនធ្វើ ។ ការងារទាំងនេះត្រូវជាការងារសុចរិត ការងារមិនខុសច្បាប់ មិនហុចទោសឱ្យដល់អ្នកប្រកប ។

*ឃ. ២.* មិនមានការបៀតបៀនយកទោសពៃរ៍ ដោយអំណាចព្រៃផ្សៃ ដោយការរំលោភច្បាប់ ដោយអយុត្តិធម៌ ឬ ដោយការមូលបង្កាច់ រហូតដល់ទៅមានទោស បង់ផាក ជាប់ពន្ធនាគារ ។

*ឃ. ៣.* មានសេចក្ដីសុខរីករាយ ព្រោះបានប្រព្រឹត្តទៅតាមគន្លងសីលធម៌ មិនរំលោភបំពារបំពានលើច្បាប់ ទំនៀមទម្លាប់ ប្រពៃណី នៅកន្លែងដែលខ្លួនរស់នៅ ។

**ង. សន្តិ** : «នត្ថិ សន្តិបរំ សុខំ» មិនមានសេចក្ដីសុខណាដូចសន្តិសុខ។ នេះគឺព្រះពុទ្ធវចនៈដែលទ្រង់សម្ដែងអំពីកំពូលនៃសេចក្ដីសុខ ឬបរមសុខ ។ *សន្តិ* ប្រែថា ស្ងប់ ជាសភាវៈដែលមិនមានភាពវឹកវរ មិនមានការច្របូកច្របល់ មិនមានការក្ដៅក្រហាយ មិនមានសង្គ្រាម មិនមានការលំបាក មិនមានសេចក្ដីទុក្ខ ។ បណ្ដាសុខតូច សុខធំទាំងប៉ុន្មាន មករួមនៅក្នុងសុខស្ងប់នេះទាំងអស់ ។ ជីវិតស្ងប់ គ្រួសារ

www.budinst.gov.kh www.elibraryofcambodia.org

សង្គមស្ងប់ ពិភពលោកស្ងប់ គឺអ្វីៗស្ងប់ទាំងអស់ ។

ពាក្យផ្ទុយនឹងសន្តិ គឺសង្គ្រាម ឬសង្គម ។ សង្គមតែងមានភាពវឹកវរ ព្រោះគ្មានការស្ងប់ បើមានការស្ងប់ សង្គមក៏នឹងលែងមានសង្គ្រាម ។

## សន្តិ ឬសេចក្តីស្ងប់ មានពីរប្រការគឺ ៖

*១. សេចក្តីស្ងប់ផ្លូវកាយ* ៖ គឺការរស់នៅជាមួយគ្នាដោយស្ងប់សុខ មិនបៀតបៀនគ្នា ប្រព្រឹត្តទៅក្នុងគន្លងសីលធម៌ មានតែមេត្តា ករុណាដល់គ្នានឹងគ្នា ។

*២. សេចក្តីស្ងប់ផ្លូវចិត្ត* ៖ ម្នាក់ៗមានសេចក្តីស្ងប់ចិត្ត មិនមានការលោភលន់ មិនមានការខឹងសម្បារ ដឹងខុសត្រូវ ចិត្តមិនវឹកវរ មិនមានវិបត្តិផ្លូវចិត្ត ។

តាមធម្មតា យើងតែងប្រើពាក្យសន្តិ នៅក្នុងបរិបទ ២ យ៉ាងគឺ ៖

• សន្តិសុខ ៖ បានដល់សេចក្តីសុខដែលកើតនៅក្នុងចិត្តម្នាក់ៗ ដែលត្រូវនឹងពាក្យថា សេចក្តីសុខខាងផ្លូវចិត្ត ។

• សន្តិភាព ៖ សេចក្តីសុខដែលកើតពីការរួមរស់ជាមួយគ្នាយ៉ាងសុខ-ដុមរមនា មិនមានការចលាចលក្នុងសង្គម មិនមានសង្គ្រាម មិនមានអ្វីមកគាបសង្កត់ខាងជីវិត ដែលនឹងនាំឱ្យមានអសន្តិសុខកើតឡើងនៅក្នុងចិត្ត ។

សេចក្តីសុខទាំង ៥ ប្រការនេះ គឺជាសេចក្តីប្រាថ្នា ជាគោលបំណងក្នុងជីវិតរបស់រាស្ត្រប្រជា និងជាគោលបំណងនៃនយោបាយ ការដឹកនាំប្រទេស តាមគោលការណ៍ " *បជាសុខំ មហុត្តមំ* = សេចក្តីសុខរបស់រាស្ត្រប្រជា " គឺជារបស់ដ៏មហាឧត្តម ជាពិសេស សន្តិភាព សន្តិសុខ ដែលជាកំពូលនៃសេចក្តីសុខ និងជាមូលដ្ឋាននៃសេចក្តីសុខទូទៅរបស់មនុស្សជាតិ ។

www.budinst.gov.kh www.elibraryofcambodia.org

## រកសេចក្តីសុខដោយការកំចាត់ទុក្ខ

សេចក្តីសុខរបស់រាស្ត្រ បើប្រៀបធៀបទៅនឹងអរិយសច្ចៈ ៤ បានដល់ អរិយសច្ចៈ ទី៣ គឺនិរោធ ប្រែថា ការរំលត់ទុក្ខ ។ និរោធ ឬនិព្វាននេះនឹងកើតឡើង កាលណាទុក្ខរលត់អស់ទៅ ។ ដូចគ្នាដែរ សេចក្តីសុខទាំង ៥ ប្រការ របស់រាស្ត្រ នឹងកើតមានឡើង កាលណាបញ្ហារបស់រាស្ត្រត្រូវបានរដ្ឋាភិបាលកំចាត់ចោលអស់ ដូចគ្នានឹងការបោកជម្រះក្អែលចេញឱ្យអស់ ដើម្បីឱ្យបានកូនកន្សែងដែលស្អាតដែរ ។

> ជាភាសានយោបាយ គោលបំណងរបស់រដ្ឋាភិបាល គឺឱ្យប្រជារាស្ត្រមានសេចក្តីសុខដ៏លើសលប់ តែជាផ្លូវប្រតិបត្តិវិញ នាទីរបស់រដ្ឋាភិបាល គឺកំចាត់បញ្ហារបស់ប្រជារាស្ត្រវិញទេ ។

សេចក្តីទុក្ខ ឬបញ្ហារបស់រាស្ត្រដែលយើងដឹងមកហើយមាន ៤ គឺ

មានជំងឺ ( ឃ្លាន )

ការរស់នៅលំបាក

ក្រីក្រ

ជំពាក់បំណុល

www.budinst.gov.kh www.elibraryofcambodia.org

**១. ជំងឺ** ៖ ពលរដ្ឋដែលមានជំងឺ គឺពលរដ្ឋដែលគ្មានសុខភាព ទន់ខ្សោយខ្វះសក្តានុភាព ដើម្បីនឹងប្រកបកិច្ចការ ឬ ការពារប្រទេស ។ ជំងឺដែលកាចជាងគេ គឺជំងឺឃ្លាន ។ បើឃ្លានហើយអត់អ្វីបរិភោគ ឬបរិភោគមិនគ្រប់គ្រាន់តាមក្បួនភោជនវិទ្យា មនុស្សនោះនឹងមានជំងឺ ។ តែបើគិតតែពីឃ្លាន បរិភោគហួសប្រមាណ បរិភោគមិនដឹងពេលវេលា បរិភោគមិនតាមក្បួន ក៏នឹងបណ្តាលឱ្យកើតជំងឺដែរ ។ ម្យ៉ាងទៀត ផលនៃការឃ្លាននេះ នឹងបណ្តាលឱ្យមនុស្សនោះប្រព្រឹត្តអំពើទុច្ចរិតខុសពីសីលធម៌ ដើម្បីរកប្រាក់មកទិញអាហារសំរាប់តបស្នងដល់គម្លានរបស់ខ្លួន ។ ដូច្នេះហើយ ទើបបានព្រះពុទ្ធអង្គទ្រង់ហៅឃ្លានថា ជាជំងឺដ៏កាចសាហាវជាងគេ ព្រោះវាបណ្តាលទោសឱ្យដល់ទាំងអ្នកឃ្លានផង និងដល់ទៅសង្គមដែលអ្នកឃ្លាននោះ រស់នៅផង ។

**២. ក្រីក្រ** ៖ ចំណុចត្រង់នេះ យើងមិនបាច់អធិប្បាយទេ ព្រោះអ្នកណាក៏ ដឹងដែរថា ក្រ លំបាកយ៉ាងណា ។ ដោយសង្ខេប ក្រ នឹងនាំឱ្យមនុស្សបាត់នូវសេចក្តីសុខដែលកើតពីការមានទ្រព្យ ដែលកើតពីការចាយវាយ ក្រនាំឱ្យមនុស្សជំពាក់បំណុលគេ ហើយក្រនាំឱ្យហ៊ានប្រព្រឹត្តការងារទាំងឡាយដែលមានទោសដែលខុសច្បាប់គ្រប់យ៉ាង ។ ព្រោះក្រនាំឱ្យឃ្លាន ហើយឃ្លានជាជំងឺមួយដ៏កាចសាហាវ ។

**៣. ជំពាក់បំណុល** ៖ ការជំពាក់បំណុល គឺការ « ក្រជាន់កទាល់ » ឬក្រ ពីរដង ។ តែជំពាក់បំណុលហើយ ស្ថានការណ៍ រឹតតែធ្ងន់ជាប្រាកដ ។ « ដែលជំពាក់បំណុលនេះ ពុំសំដៅលើការខ្ចីលុយគេទិញឡានជិះទេ តែបានដល់ខ្ចីលុយគេដើម្បី យកមកទិញបាយទឹក ទិញថ្នាំសង្កូវ » ។

**៤. ការរស់នៅ** ៖ *នត្ថិ ខន្ធសមា ទុក្ខា* មិនមានទុក្ខណាស្មើនឹងខន្ធ-

www.budinst.gov.kh www.elibraryofcambodia.org

ទុក្ខទេ ។ នេះគឺជាទុក្ខធំធេងជាងគេទាំងអស់ គឺទុក្ខកើតពីការប្រឹងធ្វើឱ្យខន្ធ " បញ្ច-ក្ខន្ធ = ជីវិត " របស់ខ្លួនអាចស្ថិតស្ថេរនៅបាន មិនបែកធ្លាយ និងបំពេញនូវចំណង់របស់ជីវិតនេះបាន ។

មនុស្សជាសត្វមានបញ្ញា ដឹងខុសត្រូវ ដឹងចំរើន វិនាស និងចេះរស់ជាសង្គម ។ មនុស្សមានតណ្ហា គឺសេចក្តីប្រាថ្នា ជាគ្រឿងបើកបរជីវិត ។ ការដែលមានតណ្ហាជាអ្នកបើកបរនេះ បានធ្វើឱ្យមនុស្សទទួលនូវសេចក្តីទុក្ខជាបន្តបន្ទាប់ អស់ពីមួយដល់មួយ និងអស់ពីតូចទៅរកទុក្ខដែលធំៗជាលំដាប់ ។

សេចក្តីទុក្ខក្នុងការរស់នៅនេះ ចែកចេញជា ៣ ប្រភេទ គឺ ៖

- សេចក្តីទុក្ខ ដែលកើតពីសេចក្តីប្រាថ្នា មិនចេះអស់មិនចេះហើយ នូវវត្ថុដែលជាគ្រឿងបំរើកាមារម្មណ៍ទាំងឡាយ ដែលជាវត្ថុតបស្នងដល់សេចក្តីត្រូវការរបស់ភ្នែក ត្រចៀក ច្រមុះ អណ្តាត រាងកាយ និងចិត្តរបស់គេ ។ សេចក្តីប្រាថ្នានេះបានធ្វើឱ្យគេក្លាយទៅជាអ្នកវត្ថុនិយម ( Materialist ) គិតតែពីខាងឱ្យបាន ដែលបណ្តាលឱ្យទៅជាបញ្ហាសង្គមផ្សេងៗរាប់មិនអស់ ។ សេចក្តីត្រូវការអារម្មណ៍ដ៏ហួសហេតុនេះ បានបំផ្លាញនូវទ្រព្យសម្បត្តិ បំផ្លាញនូវសេដ្ឋកិច្ចជាតិ និងជាពិសេស បំផ្លាញនូវទ្រព្យសម្បត្តិធម្មជាតិដ៏គួរឱ្យស្តាយ និងមិនអាចរកអ្វីមកជំនួសវិញបាន ។

- សេចក្តីទុក្ខ ដែលកើតពីសេចក្តីប្រាថ្នា ក្នុងការចង់បានកិត្តិយស ចង់បានឧត្តមភាព ចង់បានអំណាច ចង់ទៅជាអារ្យជន ចង់ឱ្យគេសរសើរ ចង់ទៅជាអ្នកដឹកនាំ ចង់ធ្វើជាចោរ ចង់ធ្វើឱ្យគេកោតខ្លាច ។ល។ ការប្រកួតប្រជែង ការទាមទារការប្រយុទ្ធ ឧក្រិដ្ឋកម្មផ្សេងៗត្រូវកើតឡើង ព្រោះសេចក្តីប្រាថ្នារបស់មនុស្ស ក្នុងការចង់ទៅជានេះជានោះ ។

- សេចក្តីទុក្ខដែលកើតពីការចង់ មិនចង់ ទៅជានេះជានោះ ជាសេចក្តីត្រូវការប្រឆាំងតតបទប់ទល់ ។ ដូចជាមនុស្សម្នាក់ ត្រូវគេគាបសង្កត់ឱ្យមានឋានៈ

www.budinst.gov.kh www.elibraryofcambodia.org

ជាទាសករ អ្នកនោះទ្រាំមិនបានទេ ចំពោះសភាពបែបនោះ ក៏ខំរកមធ្យោបាយដើម្បីរំដោះខ្លួនឱ្យចេញផុតពីការដែលខ្លួនមិនចូលចិត្តនោះចេញ ។ សេចក្តីទុក្ខនេះ កាលបើគេមិនអាចដោះស្រាយចេញទេ ក៏ក្លាយទៅជាការធ្វើអត្តឃាតខ្លួនឯង ឬសម្លាប់ខ្លួនឯង ដើម្បីឱ្យសមបំណងខ្លួន ។

សេចក្តីទុក្ខក្នុងរឿងជីវិតនេះ គ្របដណ្តប់នូវសេចក្តីទុក្ខផ្សេងៗទាំងអស់ បញ្ហាផ្សេងៗរាប់មិនអស់ កើតឡើងពីចំណង់របស់មនុស្សក្នុងជីវិតរបស់ខ្លួននេះទាំងអស់ ។ រាស្ត្រប្រជានឹងងើបឡើងប្រឆាំងតបត ទប់ទល់ បាតុកម្ម បដិវត្ត បើសិនជាគេមិនមានសិទ្ធិក្នុងការចង់ មិនមានសេរីភាពក្នុងការស្វែងរក ដើម្បីតបស្នងដល់ចំណង់នោះទេ ។ ដូច្នេះហើយបានជាយើងឃើញបាតុភាពវឹកវរក្នុងសង្គមមិនចេះអស់ មិនចេះហើយ កើតឡើងក្នុងពិភពលោកនេះ ៕

www.budinst.gov.kh www.elibraryofcambodia.org

# ៦- ព្រោះត្រូវធ្វើជាប្រធាន

## ដើម្បីសេចក្តីសុខរបស់មហាជន !

ពាក្យដែលអ្នកដឹកនាំត្រូវចាំជានិច្ច ។ ពាក្យដែលកាលមួយនោះធ្លាប់បានឧទានចេញមកពីព្រះឱស្ឋរបស់ព្រះពោធិសត្វ ដើម្បីយកជំនះលើគ្រប់ឧបសគ្គទាំងឡាយ ដែលចូលមករារាំងមិនឱ្យព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធ ។

អ្នកដែលធ្វើការដើម្បីសេចក្តីសុខរបស់មហាជន អ្នកនោះកំពុងតែដើរតាមផ្លូវព្រះពោធិសត្វ កំពុងតែធ្វើត្រាប់តាមព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ផលដែលកើតចេញពីការងារនេះ គឺជាកុសល ជាបារមីសំរាប់ខ្លួនអ្នកតទៅថ្ងៃក្រោយ និងអនាគតជាតិ ។

> អ្នកដឹកនាំដែលកំពុងធ្វើការ ដើម្បីសេចក្តីសុខរបស់មហាជនដ៏ពិតៗ គឺជាមនុស្សដែលកំពុងកសាងមហាបុណ្យ ដ៏មានគុណជាអនេកអនន្ត ។

ពុទ្ធានុស្សតិ ! ពុទ្ធានុស្សតិ ! ពុទ្ធានុស្សតិ !

យកតម្រាប់តាមព្រះពុទ្ធ ! យកព្រះពុទ្ធជាគម្រូ ! រលឹកដល់ព្រះពុទ្ធ !

ព្រះអង្គឈ្នះហើយគ្រប់សេចក្តីទុក្ខទាំងពួង ! ទ្រង់ឈ្នះដោយសារ «វីរិយេន ទុក្ខមច្ចេតិ មនុស្សឆ្លងផុតពីសេចក្តីទុក្ខបាន ដោយសារសេចក្តីព្យាយាម !»

ពួកយើងជាអ្នកដឹកនាំ ត្រូវតែព្យាយាមដើម្បីដោះស្រាយនូវសេចក្តីទុក្ខរបស់រាស្ត្រប្រជាយើង ព្រោះយើងជា *ប្រធាន* របស់ជនទាំងនោះ ។ ប្រធានដែលប្រែដោយច្បាស់ថា *អ្នកមានព្យាយាម* ។

www.budinst.gov.kh www.elibraryofcambodia.org

• ព្យាយាមដើម្បីការពារកុំឱ្យបញ្ហា សេចក្ដីទុក្ខ និងអំពើបាប អំពើអាក្រក់ផ្សេងៗ កើតឡើងដល់រាស្ត្រប្រជា ។

• ព្យាយាមដើម្បីដោះស្រាយ កំចាត់នូវបញ្ហានានា ដែលកើតឡើងដល់រាស្ត្រប្រជាឱ្យអស់ទៅ ។

• ព្យាយាមដើម្បីកសាងនូវសេចក្ដីសុខ សេចក្ដីចំរើន វិបុលភាព វឌ្ឍន-ភាព សន្តិភាព បុណ្យឱ្យកើតឡើង ឱ្យបានច្រើនបំផុតដល់រាស្ត្រប្រជា , និង

• ព្យាយាមដើម្បីថែរក្សា ការពារ គ្រប់គ្រងនូវសេចក្ដីសុខទាំងឡាយនោះឱ្យស្ថិតស្ថេរចិរកាល គង់វង្សរហូតទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

# ៧- គោលធម៌បន្ថែមសំរាប់អ្នកដឹកនាំ

ខ្ញុំត្រូវបង្ខំចិត្តដើម្បីលាអ្នកអានទាំងអស់ត្រឹមនេះ ដោយហេតុថា ទំព័រសៀវភៅនេះកាន់តែក្រាស់ណាស់ទៅហើយ ថ្វីដ្បិតតែមានគោលធម៌ជាច្រើនសន្ធឹកទៀត ដែលមានប្រយោជន៍សំរាប់ការគ្រប់គ្រងប្រទេសជាតិ និងការដឹកនាំមហាជន ។ គោលធម៌ទាំងនោះ ទាក់ទងទៅនឹងស្ថាប័នការគ្រប់គ្រង ស្ថាប័នសេដ្ឋកិច្ច ស្ថាប័នការសិក្សា ស្ថាប័នសាសនា និងស្ថាប័នក្រុមគ្រួសារ ។ អ្នកអានដែលមានចិត្តប្រាថ្នាចង់ជ្រាប ក៏សូមអញ្ជើញរកអាន ឬសាកសួរពីសំណាក់លោកអ្នកចេះដឹង ខាងពុទ្ធសាសនាទៀតផងចុះ ។

ក្នុងទីនេះ ខ្ញុំនឹងជូនជាបន្ថែមនូវគោលធម៌ខ្លះទៀត ដោយពុំមានសេចក្ដីអធិប្បាយពិស្ដារទេ ទុកសំរាប់អ្នកអានត្រិះរិះពិចារណាយកជាគតិសំរាប់នាទីដឹកនាំគ្រប់គ្រងតាមការគួរចុះ ។

## អធិបតេយ្យ ៣

គោលសំរាប់ធ្វើការសំរេចចិត្ត និងជាបែបនៃរបបគ្រប់គ្រង

១. *អត្តាធិបតេយ្យ* : ការយកខ្លួនជាធំ

២. *លោកាធិបតេយ្យ* : ការយកមតិសាធារណៈជាធំ

៣. *ធម្មាធិបតេយ្យ* : ការយកធម៌ យកច្បាប់ជាធំ

ក្នុងការប្រើអត្តាធិបតេយ្យ លោកឱ្យប្រើសតិឱ្យច្រើនដើម្បីកុំឱ្យភ្លេចខ្លួន ។ ក្នុងការប្រើលោកាធិបតេយ្យ លោកឱ្យប្រើបញ្ញា និងការត្រិះរិះឱ្យច្រើន ។ ក្នុងការប្រើធម្មាធិបតេយ្យ លោកឱ្យប្រព្រឹត្តឱ្យត្រឹមត្រូវតាមធម៌ ។ ចំពោះអ្នកដឹកនាំលោកណែនាំឱ្យប្រើបែបធម្មាធិបតេយ្យ ។

www.budinst.gov.kh www.elibraryofcambodia.org

# អបរិហានិយធម៌ ៧

គោលធម៌សំរាប់ពង្រឹងការគ្រប់គ្រងមិនឱ្យអន់ថយសាបសូន្យ ៖

១. ឧស្សាហ៍ប្រជុំគ្នាឱ្យបានញឹកញាប់

២. ព្រមព្រៀងគ្នាងើបឡើងដើម្បីការពារប្រទេស ព្រមព្រៀងគ្នា ដើម្បីបំពេញនូវកិច្ចការប្រទេសជាតិទាំងឡាយ ។

៣. មិនបញ្ញត្តនូវអ្វីដែលមិនទាន់បានបញ្ញត្តទុក ( ដែលខុសទៅនឹងគោលនយោបាយដើម ) មិនលុបបំបាត់នូវអ្វីដែលបានបញ្ញត្តទុករួចហើយ ( តាមគោលនយោបាយដើម ) តែតាំងមាំ នាំគ្នាបដិបត្តិតាមគោលនយោបាយ ដែលបានដាក់តាំងពីដើមរួចហើយ ។

៤. លោកណាដែលជាធំនៅក្នុងសហគមន៍ ឬប្រទេស គោរពរាប់អានអ្នកនោះ យកសំដីរបស់លោកថាជារបស់ដែលគួរត្រូវស្តាប់ ។

៥. ការពារថែទាំកុលស្ត្រី កុលធីតា កុលកុមារី ឱ្យរស់នៅជាសុខ មិនឱ្យទទួលការ គំរាមកំហែង ឬ រំលោភបំពារបំពាន ( ការពារសិទ្ធិស្ត្រី ) ។

៦. គោរពសក្ការបូជាបូជនីយដ្ឋាន បូជនីយវត្ថុ ព្រមទាំងវត្ថុកេរ្តិ៍មរតកជាតិទាំងឡាយដែលស្ថិតនៅក្នុងទីក្រុង និងជនបទ មិនបណ្តោយឱ្យប្រពៃណីនៃការគោរពបូជាចេតិយ៍ទាំងអស់នោះបាត់បង់សាបសូន្យទៅ ។

៧. ចាត់ឱ្យមានការថែទាំ ឃុំគ្រង ការពារដោយត្រឹមត្រូវតាមធម៌ដល់ព្រះអរហន្តទាំងឡាយ ក្នុងទីនេះបានន័យទូលំទូលាយដល់ព្រះសង្ឃ អ្នកបួស បព្វជិតដែលស្ថិតនៅក្នុងធម៌ វិន័យដែលជាបង្គោលចិត្តរបស់រាស្ត្រប្រជា ដោយតាំងចិត្តថាសូមឱ្យព្រះអរហន្តទាំងឡាយដែលមិនទាន់មកដល់ ក៏សូមនិមន្តមកដល់ ដែលនិមន្តមកដល់ហើយ ក៏សូមគង់នៅដោយរីករាយចុះ ។

អបរិហានិយធម៌ ៧ ប្រការនេះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងដល់ស្តេចវជ្ជី

www.budinst.gov.kh www.elibraryofcambodia.org

ទាំងឡាយដែលជាអ្នកដឹកនាំ នៅនគរវេសាលី ប្រទេសឥណ្ឌាពីដើម ដែលគ្រប់គ្រងដោយរបបសាមគ្គីធម៌ (Republic) ពួកសត្រូវរបស់នគរវេសាលីបានកោតស្ញប់ស្ញែង និងទទួលស្គាល់ថា ដរាបណាស្តេចវជ្ជីទាំងឡាយនៅតែប្រកាន់ខ្ជាប់តាមគោលធម៌នេះ គេនឹងមិនអាចយកឈ្នះបានដោយសង្គ្រាមឡើយ ក្រៅពីការធ្វើម្តេចទៅញុះញង់ ចាក់ដោតឱ្យបែកបាក់សាមគ្គីគ្នាសិន ។

## ចក្រវត្តិធម៌ ១២

ទំនៀមការបំពេញព្រះរាជករណីយកិច្ចរបស់ស្តេចចក្រពត្តិ ឬនាទីរបស់មហាបុរសអ្នកគ្រប់គ្រងដែលល្បីល្បាញ ។

*១. ធម្មាធិបតេយ្យ* ៖ គោរពរាប់អានធម៌ បូជាកោតក្រែងធម៌ យកធម៌ជាគោល យកធម៌ជាទង់ជ័យ , និង

*ធម្មិការក្ខាវរណគុបតិ* ៖ ចាត់ការរក្សាការពារ និងគ្រប់គ្រងដោយត្រឹមត្រូវតាមធម៌ និងជាធម៌ ដល់ ៖

*ក. អន្តោជន* ៖ ដល់ជនខាងក្នុង តាំងតែមហេសី ឱរស ធីតា រហូតអ្នកបដិបត្តកិច្ចការរាជការផ្ទាល់ព្រះអង្គទាំងអស់ គឺជនដែលស្ថិតនៅក្រោមអាណាព្យាបាលដោយផ្ទាល់ តាំងតែភរិយា បុត្រធីតា ដោយការចិញ្ចឹម អប់រំ ប្រៀនប្រដៅឱ្យស្ថិតនៅដោយស្ងប់សុខ មានរបៀបរៀបរយ និងគោរពរាប់អានគ្នា ។ ( ២ )

*ខ. ពលកាយ* ៖ ដល់កងទ័ព គឺរាជការខាងទាហាន ។ ( ៣ )

*គ. ខត្តិយ* ៖ ដល់ក្សត្រទាំងឡាយដែលស្ថិតនៅក្នុងព្រះបរមតេជានុភាពលោកម្ចាស់ស្រុកឡើងស្វ័យសារអាករ ឬបច្ចុប្បន្ននេះបានដល់មន្ត្រីរាជការ អ្នកគ្រប់គ្រងខាងផ្នែករដ្ឋបាល ។ ( ៤ )

*ឃ. អនុយន្ត* ៖ ដល់អ្នកដែលតាមព្រះអង្គ គឺរាជបរិវារទាំងឡាយបច្ចុប្បន្នបានដល់មន្ត្រីរាជការខាងផ្នែកស៊ីវិលទាំងអស់ ។ ( ៥ )

www.budinst.gov.kh www.elibraryofcambodia.org

៥. *ព្រាហ្មណគហបតី* ៖ ដល់ព្រាហ្មណ៍ អ្នកជំនួញ ម្ចាស់ដី អ្នកប្រកបអាជីវកម្មដោយចំណេះវិជ្ជា គ្រូបង្រៀន ពេទ្យ ឧស្សាហករ ដោយជួយផ្តល់ទុន ឬរកទុន និងឧបករណ៍ឱ្យជាដើម ។ ( ៦ )

៦. *នេគមជានបទ* ៖ ដល់អ្នកនិគមជនបទ គឺរាស្ត្រប្រជាទាំងពួងគ្រប់ទីកន្លែងរហូតទៅដល់ជាយដែន មិនបោះបង់ចោល ។ ( ៧ )

៧. *សមណព្រាហ្មណ៍* ៖ ដល់ព្រះសង្ឃ និងបព្វជិត ដែលទ្រទ្រង់គុណធម៌ ។ ( ៨ )

៨. *មិគបក្សី* ៖ បានដល់សត្វព្រៃដែលគួរថែរក្សា មិនឱ្យផុតពូជទាំងឡាយ និងរួមទាំងការថែរក្សាព្រៃឈើផង ។ ( ៩ )

២. *មាអធម្មការ* ៖ បង្ក្រាបមិនឱ្យមានឧក្រិដ្ឋកម្ម ចោរកម្ម អំពើអាក្រក់ឃោរឃៅទាំងឡាយកើតឡើងក្នុងព្រះរាជាណាចក្រ ។ ( ១០ )

៣. *ធនានុប្បទាន* ៖ បែងចែកទ្រព្យសម្បត្តិឱ្យដល់អ្នកគ្មានទ្រព្យ មិនឱ្យមានមនុស្សក្រីក្រតោកយ៉ាកនៅក្នុងប្រទេស ។ ( ១១ )

៤. *សមណព្រាហ្មណបរិបុច្ឆា* ៖ ប្រឹក្សាសាកសួរបញ្ហាដល់សមណព្រាហ្មណ៍ អ្នកប្រព្រឹត្តល្អ ប្រព្រឹត្តត្រូវជានិច្ចតាមការសមគួរ ដើម្បីឱ្យដឹងថា ការណាអាក្រក់ ការណាល្អ គួរធ្វើ ឬមិនគួរធ្វើ មានប្រយោជន៍ ឬគ្មាន ហើយអនុវត្តប្រព្រឹត្តតាមដោយត្រឹមត្រូវ ។ ចំណុចនេះ បច្ចុប្បន្នបានដល់អ្នកជំនាញការ អ្នកប្រាជ្ញ អ្នកវិទ្យាការ ដែលទ្រង់នូវគុណធម៌ល្អផងដែរ ។ ( ១២ )

## ភាវនា ៤

ចំណុចដែលត្រូវធ្វើការអភិវឌ្ឍន៍ប្រទេស ៖

១. *កាយភាវនា* ៖ អភិវឌ្ឍន៍ខាងកាយ បានដល់ការអភិវឌ្ឍន៍ខាងផ្នែកសេដ្ឋកិច្ចឱ្យរាស្ត្រប្រជា មានគ្រឿងឧបភោគបរិភោគ ដែលជាជំនួយដល់រាងកាយ

www.budinst.gov.kh www.elibraryofcambodia.org

ឱ្យបានល្អិតលោស់ល្អ និងរឹងប៉ឹងមាំមួនខាងសុខភាព និងគុណភាព ។

*២. សីលភាវនា* : អភិវឌ្ឍន៍ខាងការប្រព្រឹត្ត ទំនាក់ទំនងក្នុងសង្គម ការមានសីលធម៌ ច្បាប់វិន័យ មានអាជីវកម្មសុចរិត និងចេះសន្សំសំចៃ ( សូមមើលទសពិធរាជធម៌ ខទី ២ គឺសីលផងចុះ ) ។

*៣. ចិត្តភាវនា* : អភិវឌ្ឍន៍ខាងផ្នែកផ្លូវចិត្ត ឱ្យចិត្តមានសុខភាព មានគុណភាព និងគុណធម៌ល្អប្រចាំសន្តាន ។

*៤. បញ្ញាភាវនា* : ការអភិវឌ្ឍន៍ខាងសតិបញ្ញា ប្រាជ្ញាស្មារតី ចំណេះវិជ្ជា ដែលនឹងធ្វើឱ្យបញ្ញាមានការឆ្លៀវឆ្លាតពូកែ ។

## រាជសង្គហវត្ថុ ៤

គោលនយោបាយជួយសង្គ្រោះរាស្ត្រប្រជាឱ្យបានសុខ :

*១. សស្សមេធៈ* : មានការឆ្លាតពូកែក្នុងការធ្វើឱ្យសេដ្ឋកិច្ចដើរ ផលិត-ផលកសិកម្មបានល្អច្រើន ភោគទ្រព្យសម្បូរ ។

*២. បុរិសមេធៈ* : មានការឆ្លាត ពូកែក្នុងរឿងរដ្ឋបាលសាធារណៈ មានការរើសមនុស្សល្អឱ្យចូលមកធ្វើការ ពូកែក្នុងការដាក់ការងារឱ្យត្រូវនឹងសមត្ថភាពមនុស្ស លើកស្ទួយមនុស្សល្អឱ្យប្រាកដជាគំរូក្នុងសង្គម ។

*៣. សម្មាបាសៈ* : មានការឆ្លាតក្នុងការកែបញ្ហាសង្គម ដោយការឧបត្ថម្ភឱ្យមានការងារធ្វើ មានអាជីវកម្មរកទទួលទាន ផ្តល់ទុនឱ្យខ្ចីទៅប្រកបរបរទាំងខាងកសិកម្ម ពាណិជ្ជកម្ម និងឧស្សាហកម្ម ។

*៤. វាជបេយ្យ* : ការមានវាចាពីរោះ វាចាដឹកនាំឱ្យមានសាមគ្គី វាចាមានហេតុផលត្រឹមត្រូវតាមហេតុការណ៍ វាចាដែលដឹកនាំឱ្យមនុស្សខំធ្វើការ ខំធ្វើល្អមានវាទសិល្ប៍ ។

គោលនយោបាយទាំង៤ នេះ បើកាលណាធ្វើបានត្រឹមត្រូវ និងគ្រប់គ្រាន់

www.budinst.gov.kh www.elibraryofcambodia.org

ហើយនិងហុចជាផលដ៏ធំមហិមា គឺ *និរគ្គឡៈ* ប្រែថា មិនមានគន្លឹះ គឺផ្ទះមិនបាច់ដាក់គន្លឹះ ព្រោះស្រុកទេសស្ងប់សុខ ប្រាសចាកចោរ មិនបាច់ភ័យបារម្ភ ដោយហេតុថា ម្នាក់ៗមានស៊ី មានចាយគ្រប់គ្រាន់ ។

## កុលចិរដ្ឋិតិធម៌ ៤

### គោលការណ៍សំរាប់ធ្វើឱ្យវង្សត្រកូលមានស្ថិរភាព

*១. នដ្ឋគវេសនា* ៖ របស់បាត់ របស់អស់ ចេះរកមកទុកវិញ,

*២. ជិណ្ណបដិសង្ខរណា* ៖ របស់ចាស់ទ្រុឌទ្រោម ចេះជួសជុលប្រើ មិនចោល,

*៣. បរិមិតាបាណភោជនា* ៖ ស្គាល់ប្រមាណនៅក្នុងការប្រើប្រាស់,

*៤. អធិបច្ចសីលវន្តស្ថាបនា* ៖ តែងតាំងអ្នកមានសីលធម៌ជាប្រមុខ ។

## បាបណិកធម៌ ៣

### អង្គប្រកបរបស់អ្នកជំនួញ

*១. ចក្ខុមា* ៖ មានភ្នែកល្អ គឺស្គាល់ឥវ៉ាន់ ចេះមើលចេះប៉ាន់តម្លៃ ចេះស្មានចំណេញបានត្រឹមត្រូវ ។

*២. វិធុរោ* ៖ ពូកែក្នុងរឿងជំនួញ គឺស្គាល់កន្លែងទិញ កន្លែងលក់ ដឹងហាងឆេងឡើងចុះ ចេះយកចិត្តអតិថិជន ... ។

*៣. និស្សយសម្បន្នោ* ៖ មានប្រភពដើមទុនច្រើន អាចរកលុយមកបណ្តាក់ទុនបាន ។

## ៨- ឧបសម្ព័ន្ធ

# ពុទ្ធទស្សនគតិក្នុងការកសាងសង្គម

១. *ក្នុងអគ្គញ្ញសូត្រ* នៃគម្ពីរទីឃនិកាយ បាដិកវគ្គ ព្រះសម្មាសម្ពុទ្ធទ្រង់បានសម្តែងពីការវិវត្តន៍របស់ផែនដី និងវឌ្ឍនាការនៃមនុស្សជាតិ ។ ព្រះសូត្រនោះបានបង្ហាញឱ្យឃើញនូវកំណើតសង្គមមនុស្សឡើង ដោយការរួមប្រវេណី រវាងភេទប្រុស និងភេទស្រី ការសន្សំអាហារ និងបែងចែកដីធ្លី បង្កើតសេដ្ឋកិច្ចគ្រួសារ ការគ្រប់គ្រង ដើម្បីដោះស្រាយរឿងការលួចអាហារគ្នា ការកុហក ដោយការសន្មតបុគ្គលដែលមានសមត្ថភាពឱ្យធ្វើជាអ្នកវិនិច្ឆ័យរកខុសត្រូវ ការស្វែងរកការស្ងប់ក្នុងផ្លូវចិត្ត និងការបន្តនូវចំណេះវិជ្ជាដល់គ្នានឹងគ្នា ។ យើងអាចស្រង់អង្គប្រកបនៃការបង្កលក្ខណៈសង្គម តាមបែបពុទ្ធសាសនា ជា ៥ យ៉ាង គឺ ៖

១. មានការរួមគ្នាជាក្រុមគ្រួសារ និងការបន្តពូជ,

២. មានសេដ្ឋកិច្ចសំរាប់ដោះស្រាយជីវិត,

៣. មានការគ្រប់គ្រងដើម្បីសេចក្តីសុខរួម,

៤. មានសាសនាសំរាប់បង្ហាត់អ្វីខុសអ្វីត្រូវ,

៥. មានការសិក្សាសំរាប់បន្តវប្បធម៌ ដែលក្រុមជនបានបណ្តុះឡើង ។

ទាំង ៥ នេះជាមូលដ្ឋានទ្រទ្រង់សង្គមឱ្យមានស្ថិរភាព និងបន្តជាតំណពទៅមុខទៀតបាន ។ បច្ចុប្បន្ន អង្គប្រកបទាំង ៥ នេះ ខាងសង្គមវិទ្យា គេហៅថាស្ថាប័ន (Institution) ។

ទង្វើអ្វីមួយដែលនឹងត្រូវធ្វើឡើងជាមួយសង្គម ត្រូវគិតពិចារណាចំពោះស្ថាប័នទាំង ៥ នេះ ជាប់ជានិច្ច ព្រោះវាជាធាតុដើមរបស់សង្គម ។

២. *ក្នុងករណីប្រទេសខ្មែរ* ដែលសង្គ្រាមកាប់សម្លាប់គ្នាបានកើតឡើង

www.budinst.gov.kh www.elibraryofcambodia.org

ជាង ២០ ឆ្នាំ រួចមកហើយនោះ ព្រះសូត្រឈ្មោះ ចក្កវត្តិសូត្រ នៃគម្ពីរទីឃនិកាយ បាដិកវគ្គដូចគ្នា មានលក្ខណៈសមរម្យ នឹងយកមកធ្វើជាឧទាហរណ៍ណាស់ ។

ព្រះសូត្របាននិយាយពីយុគមួយឈ្មោះ មិគសញ្ញី ជាយុគដែលមនុស្ស លែងស្គាល់បងប្អូន គ្រូសិស្ស អ្នកធំអ្នកតូច មិត្តភក្តិ ម៉ែឪ អស់រលីង គិតតែសំគាល់ថា អ្នកដែលមាននៅចំពីមុខខ្លួន គឺជាសត្វម្រឹគ ដែលត្រូវតែសម្លាប់ដើម្បីយកធ្វើអាហារ ។ ព្រឹត្តិការណ៍សម្លាប់រង្គាលនេះបានកើតឡើងមួយរយៈ ហើយក៏ស្ងប់ទៅ ។ ជនដែលនៅរស់រួចពីស្លាប់ បាននាំគ្នាពិចារណាពីទោសនៃសង្គ្រាម ពីទោសនៃការសម្លាប់ជីវិតសត្វ ហើយក៏ទ្រហោយំ ព្រមទាំងសន្យាគ្នាថា ឈប់សម្លាប់ជីវិតទៀតហើយ ។ ដោយការប្រឹងប្រែង និងតាំងមាំក្នុងពាក្យសច្ចៈ ជនទាំងនោះក៏បានសេចក្តីសុខ មានអាយុវែងឡើង១ជាលំដាប់ ហើយក្រោយមកទៀត ក៏នាំគ្នារក្សាសីលទី២ គឺមិនលួច រក្សាសីលទី៣ គឺមិនប៉ះពាល់កូនប្រពន្ធគេ និងមិនប្រព្រឹត្តខុសក្នុងកាម រក្សាសីលទី៤ គឺមិននិយាយកុហក និងរក្សាសីលទី៥ គឺមិនសេពគ្រឿងស្រវឹង ។ ទីបំផុតនៃការតស៊ូដើម្បីធ្វើសេចក្តីល្អ ជនទាំងនេះក៏បានឈានដល់យុគព្រះសិរិអារ្យមេត្រី ដែលជាយុគពោរពេញទៅដោយមេត្តា ករុណា និងសម្បូរសប្បាយ អាយុយឺនយូរ ។

> អ្វីដែលយើងអាចទាញយកពីព្រះសូត្រនេះមកធ្វើជាគម្រូសំរាប់ការកសាងប្រទេសយើងដែលរងគ្រោះដោយសារសង្គ្រាម កាប់សម្លាប់គ្នានោះ គឺការបញ្ឈប់សង្គ្រាម ការឈប់បៀតបៀនសម្លាប់គ្នា និងសមាទានសីលទាំង៥ ឱ្យបានបរិបូណ៌ ។ ទើបអាយុយើងកើន និងមានវិបុល-ភាពក្នុងជីវិតបាន ។

www.budinst.gov.kh www.elibraryofcambodia.org

សន្តិភាព និងការឈប់សម្លាប់គ្នា ត្រូវមកមុខគេបង្អស់ ដោយការសមាទានសីលខទី១ ។ ឈប់កេងប្រវ័ញ្ច ឈប់លួច ឈប់ប្រព្រឹត្តអំពើទុច្ចរិត ប៉ះពាល់សម្បត្តិគេ ត្រូវមកជាលំដាប់ ដោយការសមាទានសីលខទី២ ។ សីលខទី៣ គឺគោរពសិទ្ធិក្រុមគ្រួសារគេ មិនលុះទៅដោយអំណាចកាមគុណ ។ សីលខទី៤ គឺការមានសច្ចៈរវាងគ្នានិងគ្នា មិនបោកបញ្ឆោត មិនកុហកគ្នា ។ និងសីលខទី៥ គឺការមិនវង្វេងស្មារតី មិនមានសេចក្តីប្រមាទ ព្រោះការសេពនូវគ្រឿងញៀន ។

យើងទាំងអស់គ្នាជឿថា មិនមានអ្នកដឹកនាំ ឬរាស្ត្រប្រជាណា សូម្បីតែម្នាក់ដែលមិនឃើញតម្លៃសន្តិភាព និងសីល ៥ នេះឡើយ ។ បញ្ហានៅត្រង់ថា តើយើងអនុវត្ត ឬមិនអនុវត្តតែប៉ុណ្ណោះ ។ បើអនុវត្ត រាស្ត្រខ្មែរនឹងបានសុខ ការកសាងទាំងឡាយ នឹងអាចប្រព្រឹត្តទៅបាន បើមិនអនុវត្តទេនោះ ក៏ជាសេចក្តីសំរេចចិត្តរបស់យើងក្នុងការទ្រាំរស់នៅជាមួយសេចក្តីទុក្ខ ដោយយល់ថាសេចក្តីទុក្ខ ជារបស់គួររីករាយ ដូចសត្វដង្កូវដែលតែងត្រេកអរជាមួយនឹងលាមកក្នុងបង្គន់ដូច្នោះដែរ ។

៣. *គំនិតបញ្ចក្ខន្ធ* ៖ ការទាញយកនូវគំនិតបញ្ចក្ខន្ធ ឬខ័ន្ធ ៥ ដែលជាធម្មៈនិយាយពីរាងកាយមនុស្សដែលផ្សំឡើងដោយរូប (កាយ) វេទនា (ការទទួលអារម្មណ៍) សញ្ញា (ការចងចាំ) សង្ខារ (ការគិត ) និងវិញ្ញាណ (ការដឹងច្បាស់) មកធ្វើជាចំណុចចងចាំនេះ យើងអាចទាញត្រង់ថា អង្គទាំង ៥ នេះត្រូវមានលក្ខណៈរៀបចំខ្លួនជាស្រេចសំរាប់ធ្វើការ មានសុខភាពល្អ រឹងប៉ឹង និងធ្វើការដោយព្រមព្រៀងគ្នា ។ បើអង្គណាមួយពិការ រាងកាយនេះ ក៏នឹងមិនអាចដំណើរការបានស្រួលដែរ ។ ដូច្នេះ គំនិតបញ្ចក្ខន្ធនៅត្រង់ថា អង្គធាតុនិមួយៗនៃធាតុទាំង ៥ របស់សង្គម ( ស្ថាប័ន ) ត្រូវមានសុខភាពរឹងប៉ឹង ត្រៀមខ្លួនសំរាប់ធ្វើការធ្វើដោយព្រមព្រៀងគ្នា និងបើកសាង ត្រូវកសាងឱ្យបានគ្រប់អង្គទាំង ៥ ។

www.budinst.gov.kh www.elibraryofcambodia.org




គំ និ ត ប ញ្ច ក្ខ័ ន្ធ
ភាពព្រមព្រៀងគ្នា និងស៊ីចង្វាក់នៃការកសាង

*៤. គំនិតត្រៃរតនៈ* ត្រៃរតនៈគឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជារឿងដែលពុំអាចញែកចេញពីគ្នា មានតែមួយ ឬស្ថិតនៅតែឯងពុំបានជាដាច់ខាត ។ ព្រះពុទ្ធដែលតំណាងឱ្យមនុស្ស ព្រះធម៌ដែលតំណាងឱ្យធម្មជាតិ និងព្រះសង្ឃតំណាងឱ្យសង្គម គឺជារឿងដែលមិនអាចញែកចេញពីគ្នា ឬស្ថិតនៅឯកោបានឡើយ ។ ការកសាង ឬអភិវឌ្ឍន៍សង្គមត្រូវធ្វើទៅដើម្បីជាប្រយោជន៍ ដើម្បីការតម្រង់ជីវិតទៅបាន និងមានសម្ពន្ធភាពទៅវិញទៅមករវាងមនុស្ស ធម្មជាតិ និងសង្គម ។ អង្គណានិមួយដែលមិនបានទទួលប្រយោជន៍ ឬបាត់បង់ប្រយោជន៍ នឹងនាំការកសាងឆ្ពោះ

www.budinst.gov.kh www.elibraryofcambodia.org

ទៅរកសេចក្តីអន្តរាយ ទាំងក្នុងរយៈខ្លី និងរយៈវែង ជាពិត ប្រាកដ ។




*៥. គំនិតនាមរូប :* គំនិតនាមរូប គឺជាគំនិតបកស្រាយដោយសង្ខេបនូវជីវិតមនុស្ស ដែលផ្សំឡើងដោយចិត្ត ( នាម ) និងកាយ ( រូប ) ។ ទាំងកាយ និងចិត្តមានទំនាក់ទំនងនឹងគ្នា ដោយមិនអាចញែកឱ្យដាច់ ឬខ្វះមួយណាមិនបានឡើយ គឺត្រូវមានទាំងគូ ទើបជីវិតមានតុល្យភាព ។ យើងអាចទាញមកជាគំនិតដែលត្រូវចងចាំថា ការកសាង អភិវឌ្ឍន៍សង្គមបែបពុទ្ធសាសនា ត្រូវមានតុល្យភាពរវាងចិត្ត-និយម និងវត្ថុនិយម មិនអាចធ្ងន់ជាងតែម្ខាង១បានទេ ។




www.budinst.gov.kh www.elibraryofcambodia.org

៦. *គំនិតមជ្ឈិមប្បដិបទា* ៖ មជ្ឈិមប្បដិបទា ប្រែថា ផ្លូវកណ្ដាល ជាផ្លូវដែលព្រះសម្មាសម្ពុទ្ធទ្រង់រកឃើញ បន្ទាប់ពីបានធ្វើការពិសោធន៍អស់រយៈពេល ៦ ឆ្នាំ ។ ផ្លូវកណ្ដាលជាផ្លូវអព្យាក្រឹត *មិនលំអៀងឆ្វេង* ( ធ្វើបាបខ្លួនឯង មិនមែនជាកុម្មុយនិស្ត ជិះជាន់ដោយអំណាច « អត្តកិលមថានុយោគ » ) និង *មិនលំអៀងស្ដាំ* ( គិតតែពីសប្បាយ សេរីនិយម រហូតគ្មានព្រំដែន ឬបាត់បង់សីលធម៌អស់ « កាម-សុខល្លិកានុយោគ » ។ លក្ខណៈត្រង់ និងជា *កណ្ដាលៗ មិនជ្រុលទៅរកមួយចំហៀងៗ* ( អព្យាក្រឹត ) ជាផ្លូវដែលពុទ្ធសាសនាគាំទ្រក្នុងការកសាងសង្គម ។




៧. *គំនិតអដ្ឋង្គិកមគ្គ* ៖ អដ្ឋង្គិកមគ្គ ជាផ្លូវ ឬវិធីទាំង ៨ យ៉ាង សំរាប់ដោះស្រាយបញ្ហា និងពន្លត់នូវសេចក្ដីទុក្ខ ។ គឺការយល់ឃើញត្រូវ ការគិតត្រូវ ការនិយាយត្រូវ ការធ្វើត្រូវ ការចិញ្ចឹមជីវិតត្រូវ ការព្យាយាមត្រូវ ការតាំងសតិត្រូវ និងការតម្កល់ចិត្តត្រូវ ។ ការកសាងនិមួយៗតាមបែបពុទ្ធ ត្រូវមានលក្ខណៈជាសម្មា ឬត្រឹមត្រូវទៅតាមមគ្គ ទាំង ៨ ។

www.budinst.gov.kh www.elibraryofcambodia.org

*៤. គំនិតសន្តោស* ៖ ព្រះសម្មាសម្ពុទ្ធ ទ្រង់បានសម្តែងថា « *សន្តុដ្ឋី បរមំ សុខំ* » ប្រែថា ការសន្តោស គឺជាសេចក្តីសុខដ៏ឧត្តម ។ សន្តោស ៣ យ៉ាងគឺ ៖

*១. សកេន សន្តោស* ៖ ត្រេកអរតាមផ្លូវខ្លួនមាន ឧទាហរណ៍ ប្រទេសយើងផលិតរបស់ណាមួយ យើងក៏ទិញរបស់នោះប្រើប្រាស់ ដោយមិនទិញនូវរបស់ដែលនាំមកពីស្រុកក្រៅ ។ បែបនេះហៅថា សន្តោសចំពោះរបស់ដែលខ្លួនមាន ។

*២. សន្តេន សន្តោស* ៖ ត្រេកអរចំពោះរបស់ដែលខ្លួនបាន ឧទាហរណ៍ យើងធ្វើការមានប្រាក់ខែល្មមតែទិញកង់ ១ ជិះ តែយើងចង់តែបានម៉ូតូ រហូតរសាប់រសល់ ខូចចិត្ត ថ្វីដ្បិតតែដឹងខ្លួនថាមិនបានទេក៏ដោយ ។ បែបនេះហៅថា មិនមានសន្តោសចំពោះរបស់ដែលខ្លួនបាន ។

*៣. សមេន សន្តោស* ៖ ត្រេកអរចំពោះការគួរ ។ ឯការគួរនោះ មាន ៣ យ៉ាង ៖

*ក. យថាឋានៈ* ៖ គួរដល់ឋានៈ ឧទាហរណ៍ ឋានៈយើងជាជនភៀសខ្លួន យើងត្រូវនៅផ្ទះស្លឹក បើទោះជាយើងមានប្រាក់កាស ក៏យើងមិនអាចធ្វើភូមិគ្រឹះបានដែរ ។ ការដែលយើងអាចរស់នៅក្នុងផ្ទះស្លឹកនោះ ហៅថាយើងមានសន្តោសសមគួរដល់ឋានៈយើង ។

*ខ. យថាពលៈ* ៖ សមគួរដល់កម្លាំង ឬសមគួរដល់សមត្ថភាព ឧទាហរណ៍ ជនដែលមានសមត្ថភាពលើកដែកបានតែ ៥០ គីឡូក្រាម តែតូចចិត្តដែលខ្លួនលើកមិនបាន ៨០ គីឡូក្រាមដូចគេ ឈ្មោះថាខ្វះសន្តោសសមគួរដល់សមត្ថភាព ។

*គ. យថាសរុប* ៖ គួរដល់កិត្តិយស ឧទាហរណ៍ យើងជាមនុស្សស្អាតល្អដែលគេឯងស្គាល់ ផ្តល់កិត្តិយសអោយគ្រប់គ្នា ។ ពេលមួយ គេយកលុយមកសូកប៉ាន់ បើយើងយកលុយនោះដោយធ្វើឱ្យកិត្តិយសយើងខូច ឈ្មោះថាយើងគ្មានសេចក្តីសន្តោសដែលសមគួរដល់កិត្តិយស ។

www.budinst.gov.kh www.elibraryofcambodia.org

*៩. គំនិតអហឹង្សា* ៖ ព្រះពុទ្ធសាសនា ជាសាសនាសន្តិភាព មិននិយមប្រើហឹង្សា ។ គេមិនដែលឃើញសង្គ្រាមកើតឡើង ព្រោះក្នុងនាមពុទ្ធសាសនាឡើយ ។ ព្រះអង្គសម្តែងពីរឿងការចរចា ដែលជាហេតុនាំមកនូវសេចក្តីសុខ ដូចដែលព្រះអង្គទៅប្រោសញាតិដែលគិតធ្វើសង្គ្រាម ព្រោះរឿងចែកទឹកមិនត្រូវគ្នា រហូតដល់ជនទាំងពីរខាងស្តាប់គ្នាបាន ហើយក៏ឈប់ធ្វើសង្គ្រាម ។ រឿងមួយទៀត ព្រះអង្គបានទូន្មានភិក្ខុទាំងឡាយថា បើមានគេត្មះតិះដៀលព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ភិក្ខុមិនគប្បីក្រោធ គប្បីពន្យល់ដោះស្រាយរឿងដែលមិនពិត ឱ្យឃើញថាមិនពិត រឿងនោះមិនមែន រឿងនោះមិនមាននៅក្នុងពួកយើងទេ ។ ព្រះអង្គបានសម្តែងពីការឈ្នះចាញ់ដោយការឱ្យឈ្នះ ក្រោធដោយការមិនក្រោធតប ឬពៀររមែងរំងាប់ដោយការមិនចងពៀរ ជាដើម ។ សូមចងចាំថា អហឹង្សាជាគំនិតចម្បងនៅក្នុងព្រះពុទ្ធ-សាសនា និងនៅសង្គមពុទ្ធដែលត្រូវកសាង ។

*១០. គំនិតវិជ្ជាចរណសម្បន្នោ* ៖ វិជ្ជាចរណសម្បន្នោ ជាព្រះនាមទី ៣ របស់ព្រះសម្មាសម្ពុទ្ធ ក្នុងចំណោមព្រះនាមទាំង ៩ ដែលប្រែថា បរិបូណ៌ដោយវិជ្ជា និងការប្រព្រឹត្ត ។ ត្រង់នេះយើងអាចទាញជាគំនិតថា គំរោងការណាមួយដែលនឹងត្រូវដាក់ដើម្បីអនុវត្ត ត្រូវមានលក្ខណៈជាបែប **វិជ្ជាការ** មិនមែនចេះតែដាក់ៗទៅទេ គប្បីមាន **សីលធម៌** និងអាចអនុវត្តបានផង ។

*១១. គំនិតភគវា* ៖ ភគវាជាព្រះនាមទី ១០ ប្រែថា អ្នកមានជោគ គឺទ្រង់ធ្វើការអ្វីក៏បានជោគជ័យ មាននិរភ័យគ្រប់គ្រាន់ ។ ការកសាងអ្វីមួយ ត្រូវគិតពីនិរភ័យរបស់រឿងកសាងនោះ និងនិរភ័យដល់អ្វីដែលនៅជុំវិញផង មិនគប្បីបានមួយតែទៅឱ្យកើតទុក្ខដល់របស់មួយទៀតឡើយ ។

*១២. គំនិតកល្យាណទេសនា* ៖ នៅពេលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រោសធម្មទេសនាបានសាវ័កចំនួន ៦០ អង្គហើយ ទ្រង់ក៏បានបញ្ជូនព្រះសាវ័កទាំង

www.budinst.gov.kh www.elibraryofcambodia.org

នោះឱ្យទៅសម្តែងធម៌នៅតាមធានី ជនបទ និគម ដោយត្រូវសម្តែងធម៌ឱ្យល្អ ទាំងខាងដើម ល្អទាំងកណ្តាល និងល្អទាំងខាងចុង ។ គំនិតនេះ យើងអាចទាញប្រយោជន៍នៅក្នុងការកសាងសង្គមថ្មី តាមបែបពុទ្ធសាសនា នៅត្រង់ចំណុចថា ការដែលត្រូវធ្វើកិច្ចការណាមួយ ត្រូវធ្វើឱ្យល្អតាំងពីដើម កណ្តាល រហូតដល់ចប់ និងធ្វើ ឬអភិវឌ្ឍន៍ទាំងក្នុងរាជធានី ទីរួមខេត្ត និងជនបទទូទៅឱ្យបានស្មើៗ និងល្អដូចគ្នា ។

*១៣. គំនិតវិមុត្តិ* : វិមុត្តិ គឺជាការរួចចាកផុតពីទាសភាពជីវិត ពីភារៈទាស់ទែង ពីភារៈដែលកើតទុក្ខ មានសេរីភាព មានឥស្សរភាពលើកិច្ចការ បញ្ហាទាំងពួង ។

វិមុត្តិ ឬឥស្សរភាព មាន ៤ យ៉ាង :

១- ឥស្សរភាពខាងកាយ ( កាយវិមុត្តិ ) បានដល់កាយដែលឆ្លងផុតពីភារៈដែលស្រេកឃ្លាន ដោះស្រាយបញ្ហាបច្ច័យ ៤ ដែលជាមូលដ្ឋានជីវិតបាន និងមិនធ្លាក់ទៅជាទាសករនៃបញ្ហាកាមគុណទាំងឡាយ ។

២- ឥស្សរភាពខាងសង្គម ( សីលវិមុត្តិ ) បានដល់សង្គមដែលពឹងលើខ្លួនឯងបាន មានសីលធម៌ ចរិយាធម៌ មានសន្តិភាព ជនក្នុងសង្គមគោរពច្បាប់ទម្លាប់ មិនជាទាសភាពរបស់សង្គមដទៃ និងឥទ្ធិពលរបស់វប្បធម៌ដទៃ ។

៣- ឥស្សរភាពខាងចិត្ត ( ចិត្តវិមុត្តិ ) គឺចិត្តដែលមានសុខភាព មិនសៅហ្មងដោយការខឹងក្រោធ លោភៈ វង្វេង ។ ឥស្សរភាពខាងចិត្ត ជាចិត្តដែលគ្មានសេចក្តីសោកសៅមកគ្របសង្កត់ មិនលុះទៅដោយអំណាចញាះញង់របស់លោកធម៌ទាំង ៨ និងអគតិទាំង ៤ មានតែព្រហ្មវិហារធម៌ ៤ ។

៤- ឥស្សរភាពខាងបញ្ញា ( បញ្ញាវិមុត្តិ ) គឺការរួចផុតពីទុក្ខដោយមិនមានសល់អ្វី យល់នូវលក្ខណៈធម្មជាតិយ៉ាងច្បាស់ គឺមិនទៀង តាំងនៅយូរមិនបាន និងមិនមានសារៈ ដែលនឹងត្រូវប្រកាន់យកថាជាខ្លួន ឬជារបស់ខ្លួន ជាបញ្ញាបរិសុទ្ធឆ្ពោះ

www.budinst.gov.kh www.elibraryofcambodia.org

ទៅរកសេចក្ដីសុខតែម្យ៉ាង ។

*១៤. គំនិតអប្បមាទ* ៖ សេចក្ដីមិនប្រមាទ គឺការរស់នៅដោយមានសតិ ឬសេចក្ដីព្យាយាម ដែលមានសតិជាគ្រឿងជំរុញ និងឃុំគ្រង បានដល់ការដំណើរជីវិត ដោយមានសតិជាគ្រឿងត្រួតត្រាការប្រព្រឹត្តប្រតិបត្តិ និងទង្វើគ្រប់យ៉ាងប្រយ័ត្នប្រយែងខ្លួន មិនព្រមធ្លាក់ទៅក្នុងផ្លូវវិនាស តែមិនព្រមខ្ជះឱកាសសំរាប់សេចក្ដីល្អប្រសើរ និងការចំរើនល្អតលោស់ ។ មានមនសិការក្នុងរបស់ដែលគួរធ្វើ និងគួរលះ យកចិត្ត នឹករលឹកជានិច្ចចំពោះនាទីដែលខ្លួនត្រូវទទួលខុសត្រូវ មិនបណ្ដោយ ឬលះបង់ ធ្វើការដោយយកចិត្តទុកដាក់ ប្រុងប្រៀប និងចំរើនជារឿយៗ ។ គ្រប់កិច្ចការត្រូវមានសេចក្ដីមិនប្រមាទ ព្រោះសេចក្ដីមិនប្រមាទជាផ្លូវមិនស្លាប់ ឬដូចពុទ្ធភាសិតមួយកន្លែងទៀតថា ៖ ធម៌ឯកដែលនឹងនាំឱ្យទទួលប្រយោជន៍ទាំងពីរយ៉ាង ប្រយោជន៍បច្ចុប្បន្ន និងប្រយោជន៍អនាគត គឺសេចក្ដីមិនប្រមាទ ... ។

*១៥. គំនិត អត្តា ហិ អត្តនោ នាថោ* " ខ្លួនទីពឹងខ្លួន " ៖ គឺការកសាងនិងអភិវឌ្ឍន៍ ដែលមិនពឹងតែលើគេតែម្យ៉ាង តែពឹងលើខ្លួនឯងបាន មិនដេកចាំតែទទួលពីគេ ។ អ្នកដែលពឹងលើខ្លួនឯងបាន រមែងមានមោទនភាពលើខ្លួនឯង ក្នុងឋានៈជាមនុស្ស ។

*១៦. គំនិតត្រៃលក្ខណ៍* ៖ ទុក្ខៈ គឺភាវៈដែលទ្រាំបានដោយលំបាក ភាវៈប្រជែង មិនចុះសម្រុង ជាទុក្ខ ។ អនិច្ចា គឺការប្រែប្រួល ផ្លាស់ប្ដូរ មិនទៀងទាត់ មិននៅនឹងមួយកន្លែង និងអនត្តា គឺភាវៈដែលមិនមែនជារបស់ខ្លួន កើតឡើងព្រោះការរួមប្រជុំពីវត្ថុដទៃ ។ ទាំង ៣ នេះ ជាលក្ខណៈដែលត្រូវចងចាំក្នុងការកសាងអភិវឌ្ឍន៍ ។ ការសង្ឃឹមហួសពេក ឬការស្មានថាមិនជាអ្វីទេ អាចនឹងនាំឱ្យកើតបញ្ហាដែលនឹងមិនអាចកែខៃបាននៅពេលកើតឡើង ។

www.budinst.gov.kh www.elibraryofcambodia.org

*១៧. គំនិតអរិយសច្ចៈ* ក្នុងការកែបញ្ហាអ្វីមួយ ត្រូវមានគំនិតអរិយសច្ចៈរបស់ព្រះសម្មាសម្ពុទ្ធ ។ អរិយសច្ចៈ ជាគំនិតពិសេសមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងជាបែបដែលវិទ្យាសាស្ត្រកំពុងអនុវត្ត ។

- ពិនិត្យមើល សិក្សា វិភាគ សាកល្បង ឱ្យបានច្បាស់លាស់ ថាតើជំងឺនេះមានលក្ខណៈ អាការៈដូចម្តេចហើយ តើជាជំងឺអ្វី ( ទុក្ខអរិយសច្ចៈ ) ។

- ស្រាវជ្រាវរកមើលនូវមូល ឬសគល់ មើមចមដែលនាំឱ្យបញ្ហានេះកើតមានឡើង ដូចជាគ្រូពេទ្យដែលត្រូវរកមូលហេតុនៃជំងឺឱ្យបានច្បាស់លាស់ មុននឹងរើសថ្នាំដែលត្រូវនឹងជំងឺយកទៅព្យាបាល ( ទុក្ខសមុទយអរិយសច្ចៈ ) ។

- តាំងគោលដៅ គោលបំណង ឬសភាវៈ ដែលមិនមានបញ្ហាឱ្យបានច្បាស់លាស់ ដូចជាគ្រូពេទ្យដែលដឹងថាជំងឺនេះអាចព្យាបាលជាបាន ( ទុក្ខនិរោធ-អរិយច្ចៈ ) ។

- ជ្រើសរើសផ្លូវដែលត្រូវ ដែលស័ក្តិសមទៅនឹងបញ្ហា ត្រៀមយុទ្ធវិធី និងវិធីការការពារ ដើម្បីដោះស្រាយបញ្ហា ឧបមាដូចជាគ្រូពេទ្យជ្រើសរើសថ្នាំដែលត្រូវនឹងជំងឺមកព្យាបាល ( ទុក្ខនិរោធគាមិនីបដិបទា ) ។

*១៨. គំនិតបដិច្ចសមុប្បាទ* ៖ ព្រះពុទ្ធសាសនា បដិសេធនូវគំនិតបឋម-ហេតុ គឺបដិសេធនូវគំនិតដែលយល់ថា របស់នេះជាបឋមហេតុ ។ ព្រះពុទ្ធសាសនានិយមពីការកើតឡើងព្រោះអាស្រ័យបច្ច័យតគ្នា មានលក្ខណៈជាកំណាត់ច្រវាក់ដែលត១គ្នា គឺហេតុនាំឱ្យកើតផល ផលជាតួហេតុដែលឱ្យកើតផល តទៅខាងមុខទៀត ។ ដូច្នេះ ការដោះស្រាយបញ្ហាដោយចោទទៅលើតែហេតុ ដែលនៅជាប់នឹងតួបញ្ហា មិនមែនជាការដោះស្រាយបែបសម្បូរឡើយ តែការស្រាវឱ្យដល់គល់ និងដោះតាមលំដាប់ឱ្យបានព្រមនោះ ទើបជាការដោះពិតប្រាកដ ។

លើសពីនឹងទៅទៀត បញ្ហាដែលកើតមានឡើង មិនមែនអាស្រ័យព្រោះ

www.budinst.gov.kh www.elibraryofcambodia.org

តែហេតុទេ តែមានបច្ច័យដែលជាតួឱ្យកើតដែរ ឧទាហរណ៍ងាយៗ គឺដើមស្វាយកើតពីគ្រាប់ស្វាយ ។ តែបើមើលឱ្យជ្រៅ គ្រាប់ស្វាយជាតួហេតុហើយ តែត្រូវអាស្រ័យលើបច្ច័យផ្សេងទៀត ដូចជាទឹក ដី អាកាសធាតុ ការថែរក្សាជាដើម ។

*១៩. គំនិតឥទប្បច្ចយតា* ៖ ព្រោះរបស់នេះកើតឡើង ទើបរបស់នុ៎ះកើតឡើង (និង) ព្រោះរបស់នេះរលត់ទៅ ទើបរបស់នុ៎ះរលត់ទៅដែរ គឺជាគំនិតមួយដែលយកមកគិតទុកក្នុងការការពារកុំឱ្យបញ្ហាកើតឡើង និងចំពោះការកែបញ្ហាគឺកែនៅត្រង់តួហេតុ ។ ការកែបញ្ហានៅត្រង់តួបញ្ហា មិនអាចឱ្យចប់បញ្ហាបានឡើយ តែគឺការកែហេតុ និងធ្វើយ៉ាងណាប្រយ័ត្នកុំឱ្យបញ្ហានោះកើតឡើង ទើបជាការកែដោយចប់សព្វគ្រប់ ។

*២០. គំនិតសង្ឃាធិបតេយ្យ* ៖ សង្ឃ ប្រែថា ក្រុម ។ ក្នុងទីនេះ បានដល់ការសម្រេចចិត្តណានីមួយ គប្បីស្តាប់មតិ និងការយល់ព្រមពីក្រុម ។ ជាន័យអនុវត្តក្នុងសង្គម បានដល់គំនិតប្រជាធិបតេយ្យ គឺយករាស្ត្រជាធំ យករាស្ត្រជាចៅហ្វាយ ស្តាប់បង្គាប់រាស្ត្រ ។ អ្នកដឹកនាំជាខ្ញុំបំរើរបស់រាស្ត្រ មិនមែនជាចៅហ្វាយរាស្ត្រ ដូចដែលយើងធ្លាប់ហៅ និងនិយមចូលចិត្តនោះទេ ។ សង្ឃាធិបតេយ្យ ឬប្រជាធិបតេយ្យ ជារបបគំរូក្នុងសង្គមពុទ្ធសាសនា ដែលព្រះសម្មាសម្ពុទ្ធបានតាំងឡើង ។

> ប្រជាពលរដ្ឋខ្មែរ ជាចៅហ្វាយរបស់ខ្ញុំ
>
> ស៊ីន សាន

www.budinst.gov.kh www.elibraryofcambodia.org

# យោបល់

ការកសាងសង្គមខ្មែរជាថ្មី តាមទស្សនគតិពុទ្ធសាសនា ដែលអធិប្បាយមកនេះ គឺគ្រាន់តែជាគោលគំនិត ដែលព្យាយាមដកយកចេញពីព្រះពុទ្ធវចនៈខ្លះៗ តែប៉ុណ្ណោះ ហើយដែលត្រូវស្រាវជ្រាវឱ្យបានច្បាស់លាស់ថែមទៀត មុននឹងដាក់អនុវត្តជាទូទៅ ។ ជាពិសេស គំនិតដែលទាក់ទងទៅនឹងប្រព័ន្ធស្ថាប័នទាំង ៥ ដែលពោលរួចមកហើយ ។ ការរៀនសូត្រនូវកំហុសដែលមានពីអតីត ក្នុងប្រទេសខ្មែរ ការសិក្សាពីស្ថានភាពសង្គម និងការអភិវឌ្ឍន៍សង្គមក្នុងប្រទេសដែលកាន់ព្រះពុទ្ធ-សាសនា អាចឱ្យយើងមើលឃើញនូវកំហុស និងចំណុចល្អៗ សំរាប់យកមករៀបចំធ្វើគំរោងកសាងមួយ ដែលមានការខុសផ្គាតតិចតួច ។ តែទោះជាយ៉ាងណាក្តី **សច្ចៈ គឺការពិត ទៀងត្រង់ ច្បាស់លាស់ ពិតប្រាកដ ជារឿងដែលត្រូវមកមុនគេបង្អស់ក្នុងការធ្វើកិច្ចការនេះ ៕**

## ចប់

www.budinst.gov.kh www.elibraryofcambodia.org

# ៩. ឯកសារពិគ្រោះ

- ព្រះត្រៃបិដកខ្មែរ នៅបណ្ណាល័យមជ្ឈមណ្ឌលស្រាវជ្រាវព្រះពុទ្ធសាសនាខ្មែរ ជីវ សាយធ្វ
- ធម្មសង្គហៈ
- សាសនសុភាសិត ភាគ ១ - ២ - ៣
- សុភាសិតធម្មបទ
- ឯកសារបង្រៀនអភិវឌ្ឍន៍សហគមន៍, ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ នៃជីវសាយធ្វ
- វចនានុក្រមខ្មែរ ភាគ ១ - ២
- ធម្មរាជា ( ច្បាប់ភាសាថៃ ) ពិនមុទុកន្ត
- ទសពិធរាជធម៌ ( ច្បាប់ភាសាថៃ ) ពុទ្ធទាសភិក្ខុ
- ពាក្យអធិប្បាយពុទ្ធសាស្ត្រ ( ច្បាប់ភាសាថៃ ) ភាគ ១ - ២ - ៣ ពិមុទុកន្ត
- Dictionary of Buddhism, Phra Depavedi, Mahachula Longkon Buddhist University of Thailand
- រួមឯកសារមួយចំនួនទៀត

www.budinst.gov.kh www.elibraryofcambodia.org



**ទេហិនាន្ទេហរោគោ យ (នស្វរោ)**

**គោ រុជ្ឈរាមិ រាស្ត្រ ទុះខំ ហិ**

**ក្រក្រុណាំ ទុះខំ ទុះខន្តុ នាត្មនះ**

<<ទ្រង់មានព្រះទយ័ព្រួយបារម្ភចំពោះរោគរបស់ ប្រជារាស្ត្រ ព្រះអង្គ ជាងព្រះអាពាធព្រះអង្គទៅទៀត ព្រោះថាសេចក្តីទុក្ខរបស់រាស្ត្រ គឺជាសេចក្តីទុក្ខរបស់អ្នកគ្រប់គ្រងទាំងឡាយ មិនមែនសេចក្តីទុក្ខផ្ទាល់ព្រះអង្គទេ ដែលនាំឱ្យព្រះអង្គព្រួយ >>

**ជ័យវរ្ម័នទី៧**

www.budinst.gov.kh www.elibraryofcambodia.org